# អភិធម្មត្ថសង្គហ

ប្រែចាកបាលិភាសាមកជាខេមរភាសាដោយ

## ព្រះឧត្តមមុនីអ៊ុម ស៊ូរ ធម្មវិនយរក្ខិតោ

អធិបតីរងក្រុមជំនុំព្រះត្រៃបិដក នៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ
និងជាអាចារ្យប្រចាំរាជបណ្ណាល័យភ្នំពេញ

ចម្លងផ្សាយតាមច្បាប់បោះពុម្ពលើកទី ៤ របស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស.២៤៦៧ គ.ស.១៩២៧

ចម្លងសំរាប់ផ្សាយតាមវើបសាយ http://www.dhammaroom.org

## ពាក្យប្រារពរបស់ក្រុមអ្នកសរសេរវើបសាយ http://www.dhammaroom.org

គម្ពីរអភិធម្មត្ថសង្គហវិភាគនេះជាបករណ៍មួយដ៏សំខាន់របស់ព្រះពុទ្ធសាសនាដែលជាស្នាព្រះហស្ថរបស់ព្រះអនុរុទ្ធាចារ្យជាតិឥណ្ឌាភាគខាងត្បូង លោកបានរចនាគម្ពីរនេះក្នុងប្រទេសលង្កាទ្វីប នាវត្តតុមូលសោមវិហារដែលមានឧបាសក ឈ្មោះ នម្ពៈ ជាអ្នកអារាធនាលោកឱ្យរចនាបករណ៍នេះឡើង ។ ក្នុងកាលជាខាងក្រោយមកបរកណ៍បានផ្សាយល្បីល្បាញដល់សិក្ខាកាមកុលបុត្រក្នុងព្រះពុទ្ធសាសនា ហើយត្រូវបានលោកអ្នកប្រាជ្ញជាច្រើនរូបក្នុងប្រទេសអ្នកកាន់ព្រះពុទ្ធសាសនាបានព្យាយាមប្រែបករណ៍នេះមកជាភាសារបស់ខ្លួនមានច្រើនប្រទេសនិងជាច្រើនភាសាដែលខ្ញុំធ្លាប់បានអានមក មានជា ភាសាអង់គ្លេស ឡាវ ភូមា ថៃ និងភាសាឯទៀតជាច្រើន ។ ក្នុងចំណោមនោះប្រទេសកម្ពុជាយើងជាប្រទេសអ្នកកាន់ព្រះពុទ្ធសាសនាមួយដែរដែលមានតាំងអំពីបុរាណកាលមកគម្ពីរនេះមានទាំងបាលិភាសាជាតួអក្សរខ្មែរយើង មិនតែប៉ុណ្ណោះគម្ពីរត្រូវបាន**ព្រះឧត្តមមុនី អ៊ុម ស៊ូរ ធម្មវិនយរក្ខិតោ** អធិបតីរងក្រុមជំនុំព្រះត្រៃបិដក នៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញនិងជាអាចារ្យប្រចាំនៅរាជ-បណ្ណាល័យកម្ពុជា បានជ្រើសរើសយកមកប្រែជាខេមរភាសាដរាបដល់ចប់ ។ ក្នុងគម្ពីរនេះមាន ៩ បរិច្ឆេទជាអត្ថធម៌សំខាន់ដែលព្រះអនុរុទ្ធាចារ្យលោកបានបំព្រួញសេចក្តីចាកអភិធម្មទាំង ៧គម្ពីរឱ្យបានជាការងាយស្រួលដល់កុលបុត្រ ក្នុងការប្រែរបស់ព្រះឧត្តមមុនីអ៊ុម ស៊ូរសោតក៏មានសេចក្តីពិរោះរណ្តំធ្វើអ្នកអានអ្នកសិក្សាចូលចិត្តបានដោយងាយ ។ ក្នុងឱកាសនេះវើបសាយយើងខ្ញុំមានបីតិសោមនស្សរីករាយណាស់ដែលបានយកឯកសារប្រកបដោយខ្លឹមសារមកផ្សព្វផ្សាយដល់ពុទ្ធបរិស័ទទាំងឡាយ ក្នុងការផ្សាយនេះយើងខ្ញុំមិនបាន Scan ដើម្បីរក្សាទុកតាមទំរង់ដើមទេព្រោះអាចធ្វើឱ្យមិនច្បាស់នូវតួអក្សរអាចកើតមានឡើង ។ ដូច្នេះទើបត្រូវចំណាយពេលដើម្បីវាយតាមម៉ាស៊ីនកុំព្យូទ័រដើម្បិធ្វើឱ្យច្បាស់ ដើម្បីងាយស្រួលដល់លោកអ្នកអានអ្នកសិក្សាដែលបានអានហើយ ក៏មានប្រាថ្នាចង់ព្រីនយកជាធ្វើជាសៀវភៅសំរាប់អានផ្ទាល់ខ្លួនតែម្តងបានច្បាស់ ។

វើបសាយយើងខ្ញុំសូមអភ័យទោសនូវកំហុសគ្រប់យ៉ាងដែលអាចកើតមានដោយអចេតនាក្នុងការធ្វើនូវអត្ថបទនេះ អំពីសំណាក់លោកអ្នកអានអ្នកសិក្សាទាំងឡាយ ដោយយើងខ្ញុំបានរក្សាពាក្យពេចន៍ដើមទាំងស្រុងមិនមានការកែប្រែឡើយ ។ យើងនឹងខិតខំស្រាវជ្រាវរកឯកសារសំខាន់បែបនេះទៀតដើម្បីយកផ្សាយតាមបែបប្រព័ន្ធអ៊ិនទ័រណែតនេះ ។

ក្នុងកាលជាទីបញ្ចប់នេះ យើងខ្ញុំសូមឧទ្ទិសកុសលនេះប្រគេនដល់ព្រះតេជគុណឧត្តមមុនីអ៊ុម ស៊ូរជាអ្នកប្រែគម្ពីរនេះផ្ទាល់ ដែលលោកបានអនិច្ចធម្មទៅជាយូរហើយផង សូមផ្សាយកុសលនេះដល់ពុទ្ធបរិស័ទទាំង-ឡាយផង សូមបានទទួលនូវចំណែកបុណ្យនេះកុំបីខានឡើយ ។ សូមអនុមោទនា !

តំណាងឱ្យក្រុមសរសេរវើបសាយ ព្រះមហាទូច សុវណ្ណមុនី ចិរវិនយោ

## សេចក្តីប្រារព្ធចំពោះការបោះពុម្ពឡើងវិញ
## របស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ក្នុងឆ្នាំកន្លងទៅនេះ ពុទ្ធសាសនបណ្ឌិត្យនៃក្រសួងធម្មការ និងសាសនា បានស្រាវជ្រាវរើសរកក្បួនខ្នាត ទាក់ទងនឹងអក្សរសាស្ត្រសាសនា មកបោះពុម្ពឡើងវិញដើម្បីរក្សាស្នាដៃរបស់បុព្វបុរសខ្មែរយើង ។ ក្នុងបណ្តាសៀវភៅដែលបោះពុម្ពយូរមកហើយសៀវភៅ"**អភិធម្មត្ថសង្គហ**"គឺជាស្នាដៃមួយដែលមានធម៌អាថ៌សំរាប់ពុទ្ធ-បរិស័ទសិក្សាប្រតិបត្តិ ។

ក្នុងការបោះពុម្ពឡើងវិញលើកនេះ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យបានយកច្បាប់ដើមដែលបោះពុម្ពលើកទី៤ ព.ស.២៤៨៣ មកចម្លងរៀបរៀងឃ្លា និងទំព័រជាថ្មីតាមកម្មវិធីកុំព្យូទ័រអក្សរខ្មែរ ដោយរក្សាខ្លឹមសារតាមច្បាប់ដើម គ្រាន់តែមានការកែអក្ខរាវិរុទ្ធត្រង់អន្លើខ្លះទាំងបាលីនិងសម្រាយ ដែលច្បាប់បោះពុម្ពលើទី ៤ពុំបានកែអស់កំហុស ។

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ សូមអភ័យទោសជាមុន ចំពោះកង្វះខាតផ្សេងៗដែលអាចនឹងកើតមានដោយអចេតនាក្នុងការបោះពុម្ពជាថ្មីឡើងវិញនេះ ។

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ នឹងខិតខំចាត់ការបោះពុម្ពឯកសារល្អៗបែបនេះផ្សេងទៀត ដើម្បីតម្រូវការទៅតាមការចំបាច់ប្រើប្រាស់របស់សាធារណជនផង ដើម្បីរក្សាមរតកវប្បធម៌អក្សរសាស្ត្រឱ្យបានគង់វង្សនិង រីកចំរើនផង ។

សូមព្រះពុទ្ធសាសនាបានចំរើនរុងរឿងស្ថិតស្ថេរជាស្ថាពរ! សូមជនានុជនក្នុងកម្ពុជារដ្ឋ បានចំរើនលូត-លាស់ដុះដាលដោយវិជ្ជា និងវិបុលសុខគ្រប់ប្រការ ហើយរួបរួមគ្នាកសាងប្រទេសជាតិ និងលើស្ទួយព្រះពុទ្ធ-សាសនា ឱ្យបានរីកចំរើនជាភិយ្យោភាព តរៀងទៅ !

ភ្នំពេញ,ខែវិច្ឆិកា ឆ្នាំ ២០០១

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

# បញ្ជីរឿង

ឈ្មោះអត្ថបទធម៌ លេខទំព័រ


ក.ពាក្យប្រារព្ធរបស់ក្រុមអ្នកសរសេររៀបសាយ................. ក

ខ.សេចក្តីប្រារព្ធរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ................ ខ

គ.បញ្ជីរឿង.................................................................គ

ឃ. ពាក្យប្រារព្ធរបស់អ្នករបស់អ្នកធ្វើ...................................ឃ

១.បរិច្ឆេទទី ១ ចិត្តសង្គហវិភាគ.........................................១

២.បរិច្ឆេទទី ២ ចេតសិកសង្គហវិភាគ..................................១៤

៣.បរិច្ឆេទទី ៣ បកិណ្ណកសង្គហវិភាគ..................................២៩

៤.បរិច្ឆេទទី ៤ វិថីសង្គហវិភាគ...........................................៤៤

៥.បរិច្ឆេទទី ៥ វិថីមុត្តកសង្គហវិភាគ....................................៦០

៦.បរិច្ឆេទទី ៦ រូបសង្គហវិភាគ...........................................៧៦

៧.បរិច្ឆេទទី ៧ សមុច្ចយសង្គហវិភាគ....................................៩០

៨.បរិច្ឆេទទី ៨ បច្ចយសង្គហវិភាគ.......................................១០១

៩.បរិច្ឆេទទី ៩ កម្មដ្ឋានសង្គហវិភាគ....................................១២៣

## ពាក្យប្រារព្ធរបស់អ្នកធ្វើ

(ព្រះឧត្តមមុនី អ៊ុម ស៊ូ ធម្មវិនយរក្ខិតោ)

អភិធម្មត្ថសង្គហៈប្រែនេះ ខ្ញុំបានរៀបរៀងរួចស្រេចក្នុងពុទ្ធសករាជ ២៤៦២ ត្រូវនឹងគ្រិស្តសករាជ ១៩២០ តែពុំទាន់មានឱកាសនឹងបោះពុម្ពបាននៅឡើយ លុះដល់មកពុទ្ធរាជ ២៤៦៩ ត្រូវនឹងឆ្នាំ ១៩២៦ នោះព្រះរាជបណ្ណាល័យត្រូវការយកមកបោះពុម្ពជាមួយនឹងសៀវភៅទស្សនាវដ្ដីកម្ពុជសុរិយា ផ្សាយចេញជាសាធារណៈទូទៅ តាមអ្នកដែលត្រូវការចូលជាវយក ។

ឯគុណសម្បត្តិដែលដឹកនាំខ្ញុំឱ្យមានព្យាយាមអត់ទ្រាំពុំបាន ខំធ្វើសៀវភៅនេះឡើងនោះ — ដោយហេតុ ៣ យ៉ាង :

១– ដោយខ្ញុំបានសេចក្ដីសរសើរតែរឿយៗ អំពីសំណាក់លោកអ្នកចេះដឹងទាំងឡាយថា ធម៌ព្រះអភិធម្មនេះ ជាធម៌ពិត ធម៌មែន ប្រាកដជាពុទ្ធភាសិតសុទ្ធ ឥតមានលាយឡំដោយភាសិតដទៃឡើយ តែធម៌នោះមានសេចក្ដីជ្រាលជ្រៅ ឆ្ងារល្អិតពន្លឹកញឹកពេកណាស់ ជាអត្ថបទដ៏សុខុមគម្ភីរភាព ចង្អៀតផ្លូវសតិបញ្ញា និងជ្រៀតជ្រែករកកិច្ចកល់នឹងពិចារណាក្នុងធម៌នោះបានដោយកម្រពេកណាស់ តែថាបើអ្នកឯណាបានរៀន បានស្ដាប់នូវធម៌នោះហើយ ទោះបីយល់ក្ដី ពុំយល់ក្ដី ក៏គង់បានផលានិសង្សនោះច្រើនជាងបានរៀន បានស្ដាប់នូវធម៌ឯទៀត ព្រោះធម៌ឯទៀតដែលនឹងកើតឡើងបាន ក៏តែងអាស្រ័យនូវធម៌ព្រះអភិធម្មនេះ ប្រៀបដូចពូជទាំងពួងដែលជាហេតុតែងបណ្ដាលឱ្យផ្ដួចឱ្យដុះខ្នែងចេញនោះឯង ។

២– ដោយសេចក្ដីចង់ដឹងនូវមូលហេតុនៃនាមធម៌ និងរូបធម៌ឱ្យច្បាស់លាស់ក្នុងចិត្តល្មមកត់ចំណាំទុកបានផង ដោយសេចក្ដីប្រាថ្នាឱ្យជាប្រយោជន៍ដល់ពុទ្ធបរិស័ទ លោកអ្នករៀនសូត្រវិជ្ជាចំណេះជាន់ខ្ពស់ក្នុងពុទ្ធសាសនា ឱ្យមានជាបែបយ៉ាងគ្រាន់សិកាល់ផង ។

៣– ដោយសេចក្ដីប្រារព្ធដល់គុណូបការៈនៃមាតាបិតា ដែលលោកជាអ្នកចែកចាយផ្សាយនូវធម៌ព្រហ្មវិហារ គឺ មេត្តា ករុណា មុទិតា ឧបេក្ខា ចំពោះខ្លួនខ្ញុំដោយសេចក្ដីព្យាយាមយ៉ាងខ្ពស់ យ៉ាងល្អិតអស់ពីចិត្តរបស់លោកនោះផង ។

គុណសម្បត្តិទាំង ៣ យ៉ាងនេះមូលមកជួបជុំគ្នាវេលាណា ក៏បណ្ដាលចិត្តខ្ញុំឱ្យមានព្យាយាមរៀបចំធ្វើសៀវភៅនេះឡើងដរាបដល់ចប់ ភ្លេចអស់សេចក្ដីហត់នឿយព្រួយលំបាកក្នុងការនេះ ។

កាលដែលខ្ញុំនឹងរៀបរៀងធ្វើសៀវភៅឡើងនោះ ក៏បានលោក**ព្រះគ្រូសង្ឃវិជ្ជា តាត** លោកមានកុសលចេតនាស្មើគ្នា បានជួយរៀបរៀងផង លោក**ព្រះគ្រូសង្ឃសត្ថា ឈាត** លោកក៏បានជួយផ្ទៀងផ្ទាត់។

ឯវិធីដែលនឹងរៀបចំធ្វើសៀវភៅនេះឡើងនោះ ខ្ញុំបានយកគម្ពីរព្រះអភិធម្មត្ថសង្គហបាលីព្រមទាំងដីកា និងយោជនា នៃគម្ពីរនោះមកទុកជាគោលដើម ហើយបានយកទាំងសស្ត្រាស្លឹករឹតឈ្មោះអភិធម្ម ៩ បរិច្ឆេទ ប្រែរយ និងសៀវភៅអភិធម្មត្ថសង្គហៈប្រែរយរបស់សៀម ជាស្យាមភាសាផង មកទុកជាគ្រឿង–ជួយកំលាំងក្នុងការរៀបចំធ្វើសៀវភៅនេះ ហើយបានចាប់ប្រែ និងរៀបរៀងដរាបដល់ចប់ ។

ឯគម្ពីរអភិធម្មត្ថសង្គហៈនេះ និងគម្ពីរសត្តបករណាភិធម្មនោះ មានរបៀបប្លែកគ្នាខ្លះដោយកន្លែងដូចក្នុងគម្ពីរធម្មសង្គណី ពុទ្ធភាសិតទ្រង់សម្តែងរៀងមាតិកាធម៌ គឺលោករៀងមាតិកាដាក់កុសលចិត្តទី ១ អកុសលចិត្តទី ២ អព្យាកតចិត្តទី ៣ ឯគម្ពីរអភិធម្មត្ថសង្គហៈនេះ ព្រះអនុរុទ្ធាចារ្យជាម្ចាស់ លោកសម្តែងអកុសលចិត្តទី ១ អព្យាកតចិត្តទី ២ កុសលចិត្តទី ៣ តាមសេចក្តីពេញចិត្តរបស់លោកប្រហែលគ្នានឹងគម្ពីរ–វិសុទ្ធិមគ្គ ដែលព្រះពុទ្ធឃោសាចារ្យជាម្ចាស់ លោករៀបរៀងនោះដែរ គឺលោកសម្តែងរូបក្ខន្ធជាមុន–ហើយ ទើបអធិប្បាយវិញ្ញាណក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធជាលំដាប់គ្នា តែឯក្នុងគម្ពីរវិភង្គនោះពុទ្ធភាសិតទ្រង់សម្តែងរូបក្ខន្ធជាមុនបង្អស់ ។

កាលដែលខ្ញុំបានរៀបរៀងស្រេចហើយ បានយកទៅប្រគេន**ព្រះមហាវិមលធម្ម (នាមថោង)** ចាងហ្វាងសាលាបាលីជាន់ខ្ពស់ សូមឱ្យលោកជួយពិនិត្យផ្ទៀងផ្ទាត់ឱ្យ លោកក៏បានទទួលត្រួតត្រាមើលដោយសព្វគ្រប់រួចហើយ យល់ឃើញថាត្រឹមត្រូវតាមបាលី ដីកា យោជនា ឥតមានទាស់ខុសអ្វីឡើយ ។

ក្នុងទីបំផុតនេះ សូមកុសលរាសីជួយឧបត្ថម្ភគាំទ្រូវយើងខ្ញុំទាំងឡាយគ្រប់គ្នា ដែលជាអ្នករៀបរៀង–ធម៌ក្នុងសៀវភៅនេះផង ដល់អ្នកសិក្សារៀនសូត្រទាំងឡាយផងឱ្យសេចក្តីសុខ សេចក្តីចំរើន គ្រប់ប្រការតទៅ ។

**ព្រះឧត្តមមុនី អ៊ុម ស៊ូ ធម្មវិនយរក្ខិតោ**

**អធិបតីរងក្រុមជំនុំព្រះត្រៃបិដក និងជាអាចារ្យត្រួតតម្រាព្រះរាជបណ្ណាល័យកម្ពុជា**

**ក្រុងភ្នំពេញ**

# ចិត្តសង្គហវិភាគ

*សម្មាសម្ពុទ្ធមតុលំ សសទ្ធម្មគណុត្តមំ*
*អភិវាទិយ ភាសិស្សំ អភិធម្មត្ថសង្គហំ ។*
*តត្ថ វុត្តាភិធម្មត្ថា ចតុធា បរមត្ថតោ*
*ចិត្តំ ចេតសិកំ រូបំ និព្វានមីតិ សព្វថា ។*

ខ្ញុំឈ្មោះអនុរុទ្ធាចារ្យ សូមនមស្សការថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់រកបុគ្គលដទៃប្រាកដស្មើមិនបាន មួយអន្លើដោយព្រះសទ្ធម្ម និងប្រជុំនៃព្រះអរិយសង្ឃទាំង ៨ ពួក ដ៏ប្រសើរខ្ពង់ខ្ពស់ដោយគោរព ហើយនឹងពោលនូវគម្ពីរព្រះអភិធម្មត្ថសង្គហៈ គឺកិរិយាបំព្រួញនូវសេចក្ដីនៃព្រះអភិធម្ម ។

វីអត្ថនៃព្រះអភិធម្ម ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ទុកក្នុងអភិធម្មទាំង ៧គម្ពីរ នោះ ដោយសេចក្ដីសុខុមល្អិតក្រៃពេក ដោយចំណែកធម៌ ៤ ប្រការ គឺ ចិត្ត ១ ចេតសិក ១ រូប ១ និង និព្វាន ១ ត្រូវជា ៤ ។

លំដាប់នេះ នឹងពោលនូវចិត្តជាមុន ។ ចិត្តនោះមាន ៤ ប្រការគឺ កាមាវចរចិត្ត ១ រូបាវចរចិត្ត ១ អរូបាវចរចិត្ត ១ លោកុត្តរចិត្ត ១ ។ បណ្ដាចិត្តទាំង ៤ នោះ លើកទុកចិត្ត ៣ សិន នឹងពោលនូវកាមាវចរចិត្តជាមុន, កាមាវចរចិត្តនោះមានដូចម្ដេច ?

កាមាវចរចិត្តនោះមាន ៥៤ គឺ អកុសលចិត្ត ១២ កុសលចិត្ត ៨ អព្យាកតចិត្ត ៣៤ ។ អកុសលចិត្ត ១២ ចាត់ជាមូល ៣ គឺ លោភមូល ៨ ទោសមូល ២ មោហមូល ២ ។

*** លោភមូល ២ គឺ :**

១. *សោមនស្សសហគត ទិដ្ឋិគតសម្បយុត្ត អសង្ខារិក* លោភចិត្តប្រកបដោយសោមនស្ស–វេទនា និងព្រមដោយទិដ្ឋិ ២ ប្រការគឺ **ឧច្ឆេទទិដ្ឋិ** សេចក្ដីឃើញថា សត្វមានខ្លួននៅក្នុងខ្លួន គឺស្លាប់ហើយសូន្យទៅ មិនកើតទៀត ១, **សស្សតទិដ្ឋិ** សេចក្ដីឃើញថា សត្វលោកទៀង គឺស្លាប់ហើយកើតទៀត ធ្លាប់កើតយ៉ាងណា ក៏កើតមកយ៉ាងនោះទៀត ១ មិនប្រកបដោយសង្ខារ គឺមិនមានបុគ្គល–ណាមកដឹកនាំ (ក្លៀវក្លាដោយធម្មតាខ្លួនឯង) ។

២. *សោមនស្សសហគត ទិដ្ឋិគតសម្បយុត្ត សសង្ខារិក* លោភចិត្តប្រកបដោយសោមនស្ស –

វេទនា និងព្រមដោយទិដ្ឋិទាំង ២ ប្រការដូចគ្នា ប្រកបដោយសង្ខារ គឺមានបុគ្គលមកដឹកនាំ ( មិនក្លៀវក្លាដោយធម្មតាខ្លួនឯង ) ។

៣. *សោមនស្សសហគត ទិដ្ឋិគតវិប្បយុត្ត អសង្ខារិក* លោភចិត្ត ប្រកបដោយសោមនស្ស-វេទនា តែប្រាសចាកទិដ្ឋិទាំង ២ ប្រការ មិនប្រកបដោយសង្ខារ គឺមិនមានបុគ្គលមកដឹកនាំ (ក្លៀវក្លាដោយទំនើងខ្លួនឯង ) ។

៤. *សោមនស្សសហគត ទិដ្ឋិគតវិប្បយុត្ត សសង្ខារិក* លោភចិត្ត ប្រកបដោយសោមនស្ស-វេទនា តែប្រាសចាកទិដ្ឋិទាំង ២ ប្រការដូចគ្នា ប្រកបដោយសង្ខារ គឺមានបុគ្គលមកដឹកនាំ (មិនក្លៀវក្លាដោយទំនើងខ្លួនឯង ) ។

៥. *ឧបេក្ខាសហគត ទិដ្ឋិគតសម្បយុត្ត អសង្ខារិក* លោភចិត្តប្រកបដោយ ឧបេក្ខាវេទនា និងព្រមដោយទិដ្ឋិទាំង ២ ប្រការ មិនប្រកបដោយសង្ខារគឺមិនមានបុគ្គលមកដឹកនាំ (ក្លៀវក្លាដោយ-ទំនើងខ្លួនឯង ) ។

៦. *ឧបេក្ខាសហគត ទិដ្ឋិគតសម្បយុត្ត សសង្ខារិក* លោភចិត្តប្រកបដោយ ឧបេក្ខាវេទនា និងព្រមដោយទិដ្ឋិទាំង ២ប្រការ ប្រកបដោយសង្ខារ គឺ មានបុគ្គលមកដឹកនាំ (មិនក្លៀវក្លាដោយ-ខ្លួនឯង) ។

៧. *ឧបេក្ខាសហគត ទិដ្ឋិគតវិប្បយុត្ត អសង្ខារិក* លោភចិត្តប្រកបដោយ ឧបេក្ខាវេទនា តែ-ប្រាសចាកទិដ្ឋិទាំង ២ ប្រការ មិនប្រកបដោយសង្ខារ ។

៨. *ឧបេក្ខាសហគត ទិដ្ឋិគតវិប្បយុត្ត សសង្ខារិក* លោភចិត្តប្រកបដោយ ឧបេក្ខាវេទនា តែ-ប្រាសចាកទិដ្ឋិទាំង ២ ប្រការ ប្រកបដោយសង្ខារ ។

*** ទោសមូល ២ គឺ :**

១. *ទោមនស្សសហគត បដិឃសម្បយុត្ត អសង្ខារិក* ទោសចិត្តប្រកបដោយទោមនស្សវេទនា និងព្រមដោយបដិឃៈ គឺសេចក្តីថ្នាំងថ្នាក់ចិត្ត មិនប្រកបដោយសង្ខារ ។

២. *ទោមនស្សសហគត បដិឃសម្បយុត្ត សសង្ខារិក* ទោសចត្តិប្រកបដោយទោមនស្ស-វេទនា និងព្រមដោយបដិឃៈ គឺសេចក្តីថ្នាំងថ្នាក់ចិត្ត ប្រកបដោយសង្ខារ ។

*** មោហមូល ២ គឺ :**

១. *ឧបេក្ខាសហគត វិចិកិច្ឆាសម្បយុត្ត* មោហចិត្តប្រកបដោយឧបេក្ខាវេទនា និងព្រមដោយវិចិកិច្ឆា គឺសេចក្តីសង្ស័យ ។

២. *ឧបេក្ខាសគត ឧទ្ធច្ចសម្បយុត្ត* មោហចិត្តប្រកបដោយឧបេក្ខាវេទនា និងព្រមដោយ–ឧទ្ធច្ចៈ គឺសេចក្តីរាយមាយ ។

( អកុសល ១២ ចប់ )

*អដ្ឋធា លោភមូលានិ ទោសមូលានិ ច ទ្វិធា*
*មោហមូលានិ ច ទ្វេតិ ទ្វាទសាកុសលា សិយុំ ។*

អកុសលចិត្តមាន ១២ គឺលោភមូល ៨ ទោសមូល ២
មោហមូល ២ រួមគ្នា ត្រូវជាអកុសលចិត្តមាន ១២ ។

*** អកុសលវិបាក ៧ គឺ :**

១. *ឧបេក្ខាសហគត ចក្ខុវិញ្ញាណ* ចិត្តដឹងច្បាស់នូវអនិដ្ឋារម្មណ៍ គឺអារម្មណ៍មិនជាទីប្រាថ្នាក្នុងចក្ខុទ្វារ ប្រកបដោយឧបេក្ខាវេទនា ។

២. *ឧបេក្ខាសគត សោតវិញ្ញាណ* ចិត្តដឹងច្បាស់នូវអនិដ្ឋារម្មណ៍ក្នុងសោតទ្វារ ប្រកបដោយឧបេក្ខាវេទនា ។

៣. *ឧបេក្ខាសគត ឃានវិញ្ញាណ* ចិត្តដឹងច្បាស់នូវអនិដ្ឋារម្មណ៍ក្នុងឃានទ្វារ ប្រកបដោយឧបេក្ខាវេទនា ។

៤. *ឧបេក្ខាសគត ជីវ្ហាវិញ្ញាណ* ចិត្តដឹងច្បាស់នូវអនិដ្ឋារម្មណ៍ក្នុងជីវ្ហាទ្វារ ប្រកបដោយឧបេក្ខាវេទនា ។

៥. *ទុក្ខសគត កាយវិញ្ញាណ* ចិត្តដឹងច្បាស់នូវអនិដ្ឋារម្មណ៍ក្នុងកាយទ្វារ ប្រកបដោយទុក្ខវេទនា ។

៦. *ឧបេក្ខាសគត សម្បដិច្ឆន* ចិត្តសម្រាប់ទទួលនូវអនិដ្ឋារម្មណ៍ក្នុងទ្វារទាំង ៥ ប្រកប ដោយឧបេក្ខាវេទនា ។

៧. *ឧបេក្ខាសគត សន្តីរណ* ចិត្តសម្រាប់ពិចារណានូវអនិដ្ឋារម្មណ៍ក្នុងទ្វារទាំង ៥ ប្រកបដោយឧបេក្ខាវេទនា ។

ត្រង់អកុសលវិបាកទី ៦ ចំណែកខាងអកុសលកើតអំពីហទយវត្ថុសម្រាប់ទទួលនូវអនិដ្ឋារម្ម- ណ៍ក្នុងទ្វារទាំង ៥ ។

ត្រង់អកុសលវិបាកទី ៧ ចំណែកខាងអកុសលកើតអំពីហទយវត្ថុសម្រាប់ពិចារណនូវអនិដ្ឋារម្មណ៍ក្នុងទ្វារទាំង ៥ ។

(អកុសលវិបាក ៧ ចប់ )

*** កុសលវិបាកអហេតុកៈ ៨ គឺ :**

១. *ឧបេក្ខាសហគត ចក្ខុវិញ្ញាណ* ចិត្តដឹងច្បាស់នូឥដ្ឋារម្មណ៍ គឺអារម្មណ៍ជាទីប្រាថ្នាក្នុងចក្ខុទ្វារ ប្រកបដោយឧបេក្ខាវេទនា ។

២. *ឧបេក្ខាសហគត សោតវិញ្ញាណ* ចិត្តដឹងច្បាស់នូវឥដ្ឋារម្មណ៍ គឺ អារម្មណ៍ក្នុងសោតទ្វារ ប្រកបដោយឧបេក្ខាវេទនា ។

៣. *ឧបេក្ខាសហគត ឃានវិញ្ញាណ* ចិត្តដឹងច្បាស់នូវឥដ្ឋារម្មណ៍ក្នុងឃានទ្វារ ប្រកបដោយឧបេក្ខាវេទនា ។

៤. *ឧបេក្ខាសហគត ជិវ្ហាវិញ្ញាណ* ចិត្តដឹងច្បាស់នូវឥដ្ឋារម្មណ៍ក្នុងជិវ្ហាទ្វារ ប្រកបឧបេក្ខាវេទនា ។

៥. *សុខសហគត កាយវិញ្ញាណ* ចិត្តដឹងច្បាស់នូវឥដ្ឋារម្មណ៍ក្នុងកាយទ្វារ ប្រកបដោយសុខវេទន ។

៦. *ឧបេក្ខាសហគត សម្បដិច្ឆន្ន* ចិត្តសម្រាប់ទទួលនូវឥដ្ឋារម្មណ៍ក្នុងទ្វារទាំង ៥ ប្រកបដោយឧបេក្ខាវេទនា ។

៧. *សោមនស្សសហគត សន្តីរណ* ចិត្តសម្រាប់ពិចារណានូវឥដ្ឋារម្មណ៍ក្នុងទ្វារទាំង ៥ ប្រកដោយសោមនស្សវេទនា ។

៨. *ឧបេក្ខាសហគត សន្តីរណ* ចិត្តសម្រាប់ពិចារណានូវឥដ្ឋារម្មណ៍ក្នុងទ្វារទាំង ៥ ប្រកបដោយឧបេក្ខាវេទនា ។

ត្រង់កុសលវិបាកទី ៦ ចំណែកខាងកុសលកើតអំពីហទយវត្ថុសម្រាប់ទទួលនូវឥដ្ឋា-រម្មណ៍ក្នុងទ្វារទាំង ៥ ។

ត្រង់កុសលវិបាកទី ៧ ចំណែកខាងកុសលកើតអំពីហទយវត្ថុសម្រាប់ពិចារណានូវឥដ្ឋារម្មណ៍ និងអតិឥដ្ឋារម្មណ៍ គឺអារម្មណ៍ជាទីប្រាថ្នាក្រៃពេកក្នុងទ្វារទាំង ៥ ។

ត្រង់កុសលវិបាកទី ៨ ចំណែកខាងកុសលកើតអំពីហទយវត្ថុសម្រាប់ពិចារណានូវឥដ្ឋារម្មណ៍ក្នុងទ្វារទាំង ៥ តែមិនទទួលពិចារណានូវ អតិឥដ្ឋារម្មណ៍បានឡើយ ។

(កុសលវិបាកអហេតុក ៨ ចប់)

*** អហេតុកកិរិយាចិត្ត ៣ គឺ :**

១. *ឧបេក្ខាសហគត បញ្ចទ្វារាវជ្ជន* ចិត្តសម្រាប់នឹករកអារម្មណ៍ក្នុងទ្វារទាំង ៥ ប្រការ ប្រកបដោយឧបេក្ខាវេទនា ។

២. *ឧបេក្ខាសហគត មនោទ្វារាវជ្ជន* ចិត្តសម្រាប់នឹករកនូវអារម្មណ៍ក្នុងមនោទ្វារ ប្រកដោយឧបេក្ខាវេទនា ។

៣. *សោមនស្សសហគត ហសិតុប្បាទ* ចិត្តដែលរីករាយប្រកបដោយសោមនស្ស-វេទនា ។

ឯហសិតុប្បាទចិត្តនេះ កើតមានតែក្នុងសន្តានព្រះអរិយបុគ្គល មិនដែលកើតមានក្នុងសន្តានបុថុជ្ជនឡើយ ។

(អហេតុកកិរិយាចិត្ត ៣ ចប់ )

*សត្តាកុសលបាកានិ* *បុញ្ញបាកានិ អដ្ឋធា*
*ក្រិយាចិត្តានិ តីណិតិ* *អដ្ឋារស អហេតុកា ។*
*បាបាហេតុកមុត្តានិ* *សោភណានីតិ វុច្ចរេ*
*ឯកូនវសដ្ឋី ចិត្តានិ* *អថេកនវុតីបិ វា ។*

អកុសលវិបាក ៧ កុសលវិបាក ៨ អហេតុកកិរិយា ៣ រួមគ្នាត្រូវជា អហេតុកចិត្ត ១៨ ចិត្តដែលផុតចាក អកុសល ១២ អហេតុកចិត្ត ១៨ ឈ្មោះថា សោភណចិត្ត ។ សោភណចិត្ត

មាន ៥៩ គឺកាមាវចរសោភណ ២៤ រូបាវចរសោភណ ១៥ អរូបាវចរសោភណ ១២ លោកុត្តរសោភណ ៨ រួមគ្នាត្រូវជាសោភណចិត្តមាន ៥៩ ដោយសង្ខេប ។ បើចែកចិត្តដោយពិស្តារវិញ ត្រង់លោកុត្តរចិត្តនោះញែកចេញដោយឈានជាបញ្ចកន័យ ជាចិត្ត ៤0 យកមករួមគ្នា ត្រូវជាសោភណចិត្ត ៩១ ។

កាមាវចរសោភណចិត្ត ២៤ គឺសហេតុកកាមាវចរកុសល ៨ សហេតុកកាមាវចរ–វិបាក ៨ សហេតុកកាមាវចរកិរិយា ៨ ឬនឹងហៅថា មហាកុសល មហាវិបាក មហាកិរិយា ដូច្នេះវិញក៏បាន ។

*** មហាកុសល ៨ គឺ :**

១. *សោមនស្សសហគត ញាណសម្បយុត្ត អសង្ខារិក* កុសលចិត្តប្រកបដោយ – សោមនស្សវេទនា និងព្រមដោយប្រាជ្ញាមិនប្រកបដោយសង្ខារ គឺមិនមានបុគ្គលមកដឹកនាំ (ភ្លៀវក្លាដោយទំនើងខ្លួនឯង ) ។

២. *សោមនស្សសហគត ញាណសម្បយុត្ត សសង្ខារិក* កុសលចិត្តប្រកបដោយ — សោមនស្សវេទនា និងព្រមដោយប្រាជ្ញា ប្រកបដោយសង្ខារ គឺមានបុគ្គលមកដឹកនាំ (មិនភ្លៀវក្លាដោយទំនើង ខ្លួនឯង ) ។

៣. *សោមនស្សសហគត ញាណវិប្បយុត្ត អសង្ខារិក* កុសលចិត្តប្រកបដោយ – សោមនស្សវេទនា តែប្រាសចាកប្រាជ្ញា មិនប្រកបដោយសង្ខារ ។

៤. *សោមនស្សសហគត ញាណវិប្បយុត្ត សសង្ខារិក* កុសលចិត្តប្រកបដោយ — សោមនស្សវេទនា តែប្រសចាកប្រាជ្ញា ប្រកបដោយសង្ខារ ។

៥. *ឧបេក្ខាសហគត ញាណសម្បយុត្ត អសង្ខារិក* កុសលចិត្តប្រកបដោយ ឧបេក្ខា — វេទនា និងព្រមដោយប្រាជ្ញា មិនប្រកបដោយសង្ខារ ។

៦. *ឧបេក្ខាសហគត ញាណសម្បយុត្ត សសង្ខារិក* កុសលចិត្តប្រកបដោយ ឧបេក្ខា — វេទនា និងព្រមដោយប្រាជ្ញាប្រកបដោយសង្ខារ ។

៧. *ឧបេក្ខាសហគត ញាណវិប្បយុត្ត អសង្ខារិក* កុសលចិត្តប្រកបដោយ ឧបេក្ខា — វេទនា តែប្រាសចាកប្រាជ្ញា មិនប្រកបដោយសង្ខារ ។

៨. *ឧបេក្ខាសហគត ញាណវិប្បយុត្ត សសង្ខារិក* កុសលចិត្តប្រកបដោយ ឧបេក្ខា- វេទនា តែប្រាសចាកប្រាជ្ញា ប្រកបដោយសង្ខារ ។

( មហាកុសល ៨ ចប់ )

មហាវិបាក ៨ មហាកិរិយា ៨ ក៏មានអធិប្បាយចែកចេញទៅដូចគ្នានឹងមហាកុសល ដែរ តែបើនឹងពោលដោយភូមិជាកាមាវចរភូមិដូចគ្នាទាំង ៣ បើនឹងពោលដោយជាតិវិញ មហាកុសល ជាកុសលជាតិ មហាកវិបាកនិងមហាកិរិយា ជាអព្យាកតជាតិ ។

មហាកុសលឱ្យសម្រេចកិច្ច ៤ យ៉ាងគឺ បដិសន្ធិ ១ *ភវង្គ* ១ ចុតិ ១ តទាលម្ពណ ១ មហាកុសលនេះជាអ្នកតាក់តែងជាតិ ភព សម្បត្តិ ជាអ្នកដឹកនាំឱ្យកើតមហាវិបាក ជាតួ — បដិសន្ធិ ជាអ្នកសោយនូវសម្បត្តិ ។

មហាកុសល និងមហាកិរិយាដូចគ្នា ឧបមាដូចតួត្រា និងស្នាមត្រាដែលបោះចុះ ឬ ដូចស្រមោលក្នុងកញ្ចក់ និងអ្នកដែលឆ្លុះកញ្ចក់នោះឯង ផ្សេងគ្នាតែទីកើត គឺមហាកុសល កើតសន្តាននៃបុថុជ្ជន និងសេក្ខបុគ្គល ឯមហាកិរិយាកើតចំពោះតែក្នុងសន្តាននៃ — ព្រះខីណាស្រព ។

| | |
|---|---|
| *វេទនាញាណសង្ខារ-* | *ភេទេន ចតុវីសតិ* |
| *សហេតុកាមាវចរ-* | *បុញ្ញបាកក្រិយា មតា ។* |
| *កាមេ តេវីស បាកានិ* | *បុញ្ញាបុញ្ញានិ វីសតិ* |
| *ឯកាទសក្រិយា ចេតិ* | *ចតុប្បញ្ញាស សព្វថា ។* |

សោភណចិត្ត ២៤ គឺកុសលចិត្ត ៨ វិបាកចិត្ត ៨ កិរិយាចិត្ត ៨ ដែលព្រះសម្មាសម្ពុទ្ធ សំដែងហើយ ផ្សេងគ្នាដោយវេទនា ២ គឺ សោមនស្ស១ ឧបេក្ខា១ និងផ្សេងគ្នាដោយ ញាណ ២ គឺញាណសម្បយុត្ត ១ ញាណវិប្បយុត្ត ១ និងផ្សេងគ្នាដោយសង្ខារ ២ គឺអសង្ខារ ១ សសង្ខារ ១ ។

កាមាវចរចិត្តនេះចាត់ជាវិបាក ២៣ គឺ អកុសលវិបាក ៧ កុសលវិបា ៨ មហាវិបាក ៨ រួមគ្នាជា ២៣ កុសលចិត្ត និងអកុសលចិត្ត ២០ គឺមហាកុសល ៨ អកុសល ១២ រួមគ្នាជា ២០ កិរិយាចិត្ត ១១ គឺមហាកិរិយា ៨ អហេតុកកិរិយា ៣ រួមគ្នាជា ១១ រួបរួមកាមាវចរ-ចិត្តទាំងអស់ត្រូវជា ៥៤ ដូច្នេះ ។

( កាមាវចរចិត្ត ៥៤ ចប់ )

**រូបាវចរចិត្ត ១៥ គឺរូបាវចរកុសល ៥ រូបាវចរវិបាក ៨ រូបាវចរកិរិយា ៥ រួមជា ១៥ ដូច្នេះ ។**

*** រូបាវចរកុសល ៥ គឺ :**

១. *បឋមជ្ឈាន* មានអង្គ ៥ គឺវិត្តកៈ សភាពញ៉ាំងចិត្តឱ្យឡើងកាន់អារម្មណ៍ ១ វិចារៈ សភាពញ៉ាំងចិត្តឱ្យត្រាច់ទៅក្នុងអារម្មណ៍ ១ បីតិ ធម្មជាតិញ៉ាំងកាយ និងចិត្តឱ្យពេញឱ្យឆ្អែត ឱ្យរីករាយ ១ សុខៈ ធម្មជាតិញ៉ាំងកាយ និងចិត្តឱ្យតាំងនៅដោយស្រួលល្អ ១ ឯកគ្គតា ភាវៈនៃចិត្តតាំងនៅក្នុងអារម្មណ៍ ១ ។

២. *ទុតិយជ្ឈាន* មានអង្គ ៤ គឺ វិចារៈ ១ បីតិ ១ សុខៈ ១ ឯកគ្គតា ១ ។

៣. *តតិយជ្ឈាន* មានអង្គ ៣ គឺ បីតិ ១ សុខៈ ១ ឯកគ្គតា ១ ។

៤. *ចតុត្ថជ្ឈាន* មានអង្គ ២ គឺ សុខៈ ១ ឯកគ្គតា ១ ។

៥. *បញ្ចមជ្ឈាន* មានអង្គ ២ គឺ ឯកគ្គតា ១ ឧបេក្ខា ១ ។

រូបាវចរវិបាក រូបាវចរកិរិយា ក៏ចាត់ជាឈានបញ្ចកន័យជាប្រាំ ៧ ដូចគ្នា ។

រូបាវចរកុសលជាអ្នកតាក់តែង ជាតិ ភព សម្បត្តិ ជាអ្នកដឹកនាំឱ្យបដិសន្ធិ រូបាវចរ-វិបាកជាតួបដិសន្ធិ ជាអ្នកសោយសម្បត្តិ រូបាវចរកុសលជាកុសលជាតិ រូបាវចរវិបាក និង រូបាវចរកិរិយា ជាអព្យាកតជាតិ ។

រូបាវចរកុសល និងរូបាវចរកិរិយាក៏ដូចគ្នា ផ្សេងតែទីកើត គឺ រូបាវចរកុសលកើតក្នុងសន្តានបុថុជ្ជន និងសេក្ខបុគ្គល ឯរូបាវចរកិរិយាកើតក្នុងសន្តានព្រះខីណាស្រព ។

*បញ្ចធា ឈានភេទេន* *រូបាវចរមានសំ*
*បុញ្ញបាកក្រិយាភេទា* *តំ បញ្ចទសធា ភវេ ។*

រូបាវចរចិត្ត ១៥ ញែកចេញដោយឈាន ៥ គឺ កុសល ៥ វិបាក ៥ កិរិយា ៥ រួមគ្នាជា ១៥ ។

( រូបាវចរចិត្ត ១៥ ចប់)

អរូបាវចរចិត្ត ១២ គឺ អរូបាវចរកុសល ៤ អរូបាវចរវិបាក ៤ អរូបាវចរកិរិយា ៤ រួមគ្នាត្រូវជា ១២ ។

* **អរូបាវចរកុសល ៤ គឺ :**

១. *អាកាសនញ្ចាយតន* ព្រះយោគាវចរដែលជាអ្នកចំរើឈាន យកអាកាសដែលបើកកសិណហើយមកជាអារម្មណ៍ គឺបដិភាគនិមិត្តដែលកើតអំពីកសិណ ៩ លើកអាកាសកសិណចេញ ព្រះយោគាវចរកាន់យកអាកាសដែលជារបស់ទទេមកជាអារម្មណ៍, បរិកម្មថា "អាកាសមិនមានទីបំផុត ៗ " បរិកម្មទៅដរាបដល់អប្បនាចិត្តកើតឡើង អប្បនាចិត្តនោះលោកហៅថា បឋមារូបចិត្ត ។

២. *វិញ្ញាណញ្ចាយតន* ព្រះយោគាវចរសំដៅយក ឬស្រាវយកនូវបឋមារូបចិត្តមក-ជាអារម្មណ៍ បរិកម្មថា " វិញ្ញាណមិនមានទីបំផុត ៗ " បរិកម្មទៅដល់អប្បនាចិត្តកើតឡើង អប្បនាចិត្តនោះលោកហៅថា ទុតិយារូបចិត្ត ។

៣. *អកិញ្ចញ្ញាយតន* ព្រះយោគាវចរមិនបានកាន់យកនូវទុតិយារូបចិត្តមកជា - អារម្មណ៍ លោកកំណត់យកនូវបឋមារូបចិត្ត ដែលផ្សាយនៅនោះថាជា បឋមារូបចិត្តដែលផ្សាយនៅក្នុងទីនេះមិនមាន ហើយយកសេចក្តីមិនមាននោះមកជាអារម្មណ៍ បរិកម្មថា "វត្ថុតិចតួចមិនមាន ៗ " បរិកម្មទៅដរាបដល់អប្បនាចិត្តកើតឡើង អប្បនាចិត្តនោះលោកហៅថា តតិយារូបចិត្ត ។

៤. *នេវសញ្ញានាសញ្ញាយតន* ព្រះយោគាវចរដែលចំរើនឈាន មិនបានកាន់យកនូវនត្ថិភាព គឺចំណែកដែលថាមិនមាននោះមកជាអារម្មណ៍ឡើយ លោកកំណត់យកនូវសេចក្តីល្អិរបស់តតិយារូបចិត្តនោះមកជាអារម្មណ៍ បរិកម្មថា "តតិយារូបចិត្តនេះមាននៅដោយល្អិត តតិយារូបចិត្តនេះល្អិតក្រៃពេក " បរិកម្មទៅដរាបដល់អប្បនាចិត្តកើតឡើង អប្បនា–ចិត្តនោះលោកហៅថា ចតុត្ថរូបចិត្ត ។

សេចក្តីដែលសំដែងមកនេះ ជាការចំរើននូវអរូបាវចរកុសលទាំង ៤ ឯអរូបាវចរវិបាក និងអរូបាវចរកិរិយានោះក៏ដូចគ្នានឹងកុសលដែរ ថាបើនឹងចាត់ដោយភូមិ ក៏ជាអរូបាវចរភូមិផងគ្នា បើនឹងពោលដោយជាតិ អរូបាវចរកុសលជាកុសលជាតិ
អរូបាវចរវិបាក និងអរូបាវចរកិរិយា ជាអព្យាកតជាតិ អរូបាវចរកុសលជាអ្នកតាក់តែងជាតិ ភព សម្បត្តិ ជាអ្នកដឹកនាំឱ្យបដិសន្ធិ អរូបាវចរវិបាកជាតួបដិសន្ធិ ជាអ្នកសោយសម្បត្តិ ឯអរូបាវចរកុសល និងអរូបាវចរកិរិយា ក៏ដូចគ្នាមិនមានប្លែកគ្នា មានឧបមាដូចតួត្រា និងស្នាមរបស់ត្រា ឬដូចស្រមោលក្នុងកញ្ចក់និងអ្នកឆ្លុះនូវកញ្ចក់ ដូចបានពោលមកហើយនោះផ្សេងគ្នាតែទីកើត គឺអរូបាវចរកុសល កើតក្នុងសន្តានបុថុជ្ជន និងសេក្ខបុគ្គល ចំណែកឯអរូបាវចរកិរិយា កើតក្នុងសន្តានព្រះខីណាស្រព ។

*អាលម្ពណប្បភេទេន* *ចតុធា រុប្បមានសំ*
*បុញ្ញបាកក្រិយាភេទា* *បុនទ្វាទសធា ឋិតំ ។*

អរូបាវចរចិត្តមាន ៤ ប្រការ ដោយប្រភេទនៃអារម្មណ៍ លោកចាត់ម្តងទៀតមាន ១២ ប្រការព្រោះផ្សេងគ្នដោយអរូបាវចរកុសល ៤ អរូបាវចរវិបាក ៤ អរូបាវចរកិរិយា ៤ ជា១២ ប្រការដូច្នេះ ។

( អរូបាវចរចិត្ត ១២ ចប់ )

**លោកុត្តរចិត្ត ៨ គឺ មគ្គ ៤ ផល ៤ រួមគ្នាត្រូវជា ៨ ។**

*** លោកុត្តរចិត្ត ៨ គឺ :**

១. *សោតាបត្តិមគ្គចិត្ត* ចិត្តដ៏សម្បយុត្តដោយមគ្គ គឺកិរិយាស្វែងរកនូវព្រះនិព្វាននៃ–បុគ្គលដល់ហើយក្នុងដើមនៃធម៌ដូចជាខ្សែឈ្មោះសោតៈ ។

២. *សកទាគាមិមគ្គចិត្ត* ចិត្តដ៏សម្បយុត្តដោយមគ្គ គឺ កិរិយាស្វែងរកនូវព្រះនិព្វាននៃបុគ្គលដែលមកកាន់មនុស្សលោកនេះអស់វារៈម្តង ដោយអំណាចនៃបដិសន្ធិ ។

៣. *អានាគាមិមគ្គចិត្ត* ចិត្តដ៏សម្បយុត្តដោយមគ្គ គឺ កិរិយាស្វែងរកនូវព្រះនិព្វាននៃ –បុគ្គលដែលមិនមកកាន់កាមធាតុព្វដ៏ខាងក្រោម ដោយអំណាចនៃបដិសន្ធិឡើយ ។

៤. *អរហត្តមគ្គចិត្ត* ចិត្តដ៏សម្បយុត្តដោយមគ្គ គឺ កិរិយាស្វែងរកនូវព្រះនិព្វាននៃបុគ្គលមានកិរិយាធ្វើនូវបាបកម្មក្នុងទីស្ងាត់មិនមាន ។

៥. *សោតាបត្តិផលចិត្ត* ចិត្តដ៏សម្បយុត្តដោយផល គឺសេចក្តីសម្រេចនូវព្រះនិព្វាននៃ–បុគ្គលដល់ហើយក្នុងដើមនៃធម៌ដូចជាខ្សែឈ្មោះសោតៈ ។

៦. *សកទាគាមិផលចិត្ត* ចិត្តដ៏សម្បយុត្តដោយផល គឺ សេចក្តីសម្រេចនូវព្រះ–និព្វាននៃបុគ្គលដែលមកកាន់មនុស្សលោកនេះវារៈម្តង ដោយអំណាចនៃបដិសន្ធិ ។

៧. *អានាគាមិផលចិត្ត* ចិត្តដ៏សម្បយុត្តដោយផល គឺសេចក្តសម្រេចនូវព្រះ–និព្វាននៃបុគ្គលដែលមិនមកកាន់កាមធាតុព្វដ៏ខាងក្រោម ដោយអំណាចនៃបដិសន្ធិ ។

៨. *អរហត្តផលចិត្ត* ចិត្តដ៏សម្បយុត្តដោយផលចិត្ត គឺសេចក្តីសម្រេចនូវព្រះ–និព្វាននៃបុគ្គល មានកិរិយាធ្វើនូវបាបកម្មក្នុងទីស្ងាត់មិនមាន ។

លោកុត្តរចិត្ត ៨ នេះសម្តែងដោយសង្ខេប បើសម្តែងដោយពិស្តារវិញមានដល់ ៤០ គឺចែកចេញទៅដោយបញ្ចកន័យគឺ សោតាបត្តិមគ្គចិត្ត ៥ សោតាបត្តិផល–ផលចិត្ត ៥ សកទាគាមិមគ្គចិត្ត ៥ សកទាគាមិផលចិត្ត ៥ អានាគាមិមគ្គចិត្ត ៥ អានាគាមិផលចិត្ត ៥ អរហត្តមគ្គចិត្ត ៥ អរហត្តផលចិត្ត ៥ រួមគ្នាទាំងអស់ ត្រូវជាលោកុត្តរចិត្ត ៤០ គត់ ។

លោកុត្តរចិត្តនេះ មានតែកុសល និងវិបាក ឯកិរិយាចិត្តមិនមាន មគ្គចិត្តជា-កុសល ផលចិត្តជាវិបាក ។

( លោកុត្តរចិត្ត ៨ ចប់ )

រូបាវចរចិត្ត និងលោកុត្តរចិត្ត លោកចែកទៅដោយឈាន ៥ ជាបញ្ចកន័យដូចគ្នា ប្លែកតែអរូបាវចរចិត្តទាំង ៤ នោះលោករាប់បញ្ចូលទៅក្នុង បញ្ចមជ្ឈានព្រោះអង្គមាន ២ គឺឯកគ្គតា ១ ឧបេក្ខា ១ ដូចគ្នានឹងបញ្ចជ្ឈាន ។

រូបាវចរឈានទាំង ៤ គឺបឋមជ្ឈានចិត្ត ១ ទុតិយជ្ឈានចិត្ត ១ តិតិយជ្ឈានចិត្ត ១ ចតុត្ថជ្ឈានចិត្ត១, ៤ ឈាននេះលោករាប់ចិត្តបាន ១១ គ្រប់ឈានទាំងអស់ឯបញ្ចមជ្ឈាន រាប់ចិត្ត ២៣ ។

ឈានចិត្ត ១១ នោះគឺ រូបាវចរ ៣ ដែលជាកុសល ១ វិបាក ១ កិរិយា ១ លោកុត្តរ ៨ ដែលជាមគ្គចិត្ត ៤ ផលចិត្ត ៤ រួមជា ១១ បញ្ចមជ្ឈានចិត្ត ២៣ គឺ រូបាវចរបញ្ចមជ្ឈាន ៣ អរូបាវចរបញ្ចមជ្ឈាន ១២ លោកុត្តរបញ្ចមជ្ឈាន ៨ ជា ២៣ ។

រួមចិត្តសង្ខេបបញ្ចូលគ្នាទំង ៤ ភូមិគឺ អកុសលចិត្ត ១២ ដែលជាលោភមូល ៨ ទោសមូល ២ មោហមូល ២ ជា ១២ កុសល ២១ គឺ មហាកុសល ៨ រូបាវចរ-កុសល ៥ អរូបាវចរកុសល ៤ លោកុត្តរកុសល ៤ ជា ២១ វិបាកចិត្ត ៣៦ គឺ អហេតុកកវិបាក ១៥ មហាវិបាក ៨ មហគ្គតវិបាក ៩ លោកុត្តរវិបាក ៤ ជា ៣៦ កិរិយាចិត្ត ២០ គឺ អហេតុកកិរិយា ៣ មហាកិរិយា ៨ មហគ្គតកិរិយា ៩ ជា ២០ ។

ចាត់ចិត្តតាមភូមិ ៤ គឺ កាមាវចរភូមិ ៥៤ រូបាវចរភូមិ ១៥ អរូបាវចរភូមិ ១២ លោកុត្តរភូមិ ៨ បូករួមជាចិត្ត ៨៩ ដោយសង្ខេប ។

ចិត្តពិស្តារ ១២១ គឺកុសលចិត្ត ៣៧ ដែលជាមហាកុសល ៨ មហគ្គត ៩ លោកុត្តរកុសល ២០ ជា ៣៧ វិបាកចិត្ត ៥២ គឺ កាមាវចរវិបាក ២៣ មហគ្គតវិបាក ៩ លោកុត្តរវិបាក ២០ ជា ៥២ យកអកុសលចិត្ត ១២ និងកិរិយាចិត្ត ២០ បូកបញ្ចូលផងគ្នា ត្រូវជា ចិត្ត ១២១ ។

ចិត្តដោយសង្ខេប ៨៩ នោះរាប់ថា ១ យកចេតសិក ៥២ និងនិប្ផន្នរូប ១៨ និងទុក្ខ ៤ គឺជាតិ ជរា ព្យាធិ មរណៈ បូកជា ៧៥ ចាត់នាមធម៌ខាងក្នុង ៧៥ រូបធម៌ខាង ៧៥ រួម ១៥០ យកកិលេស ១០ មកគុណជា ១៥០០ ហោង ។

*ឥតិ អភិធម្មត្ថសង្គហេ*

*ចិត្តសង្គហវិភាគោ នាម បឋមោ បរិច្ឆេទោ ។*

បរិច្ឆេទជាបឋម ឈ្មោះចិត្តសង្គហវិភាគ ក្នុងអភិធម្មត្ថសង្គហ ចប់តែប៉ុណ្ណេះ ។

## **បរិច្ឆេទី ២**

ចេតសិកសង្គហវិភាគ

*ឯកុប្បាទនិរោធា ច ឯកាលម្ពណវត្ថុកា*
*ចេតោយុត្តា ទ្វិបញ្ញាស ធម្មា ចេតសិកា មតា ។*

ធម៌ ៥២ មានសេចក្តីកើត និងសេចក្តីរលត់ និងអារម្មណ៍ និងវត្ថុជាមួយគ្នាដោយចិត្ត ព្រះដ៏មានព្រះភាគត្រាស់ហៅថា **ចេតសិក** ព្រោះកើតក្នុងចិត្តដោយហេតុ ៤ យ៉ាងគឺចិត្តកើតក្នុងខណៈណា ចេតសិកក៏កើតក្នុងខណៈនោះ, ចិត្តរលត់ក្នុងខណៈណា ចេតសិកក៏រលត់ក្នុងខណៈនោះ, ចិត្តកើតក្នុងអារម្មណ៍ណា ចេតសិកក៏កើតក្នុងអារម្មណ៍នោះ, ចិត្តសំដៅយកវត្ថុណាជាអារម្មណ៍ ចេតសិកក៏សំដៅយកវត្ថុនោះជាអារម្មណ៍ ដោយហេតុ ៤ យ៉ាងដូច្នេះ ។

ចេតសិកមាន ៥២ គឺអញ្ញសមានាចេតសិក ១៣ អកុសលចេតសិក ១៤ សោភណ–ចេតសិក ២៥ ។

អញ្ញសមានាចេតសិក ១៣ នោះគឺ សព្វចិត្តសាធារណចេតសិក ៧ បកិណ្ណកចេតសិក ៦ ជា ១៣ ។

*** សព្វចិត្តសាធារណចេតសិក ៧ គឺ :**

១– *ផស្សោ* សភាពជាអ្នកធ្វើអារម្មណ៍ទាំង ៦ ឱ្យពាល់ត្រូវទ្វារទាំង ៦

២– *វេទនា* ធម្មជាតិដឹងនូវអារម្មណ៍ ឬសោយនូវអារម្មណ៍

៣–*សញ្ញា* ធម្មជាតិចាំនូវអារម្មណ៍ ឬកត់នូវអារម្មណ៍

៤– *ចេតនា* ធម្មជាតិគិតដឹកនាំចិត្ត ឬធម្មជាតិសន្សំនូវបុណ្យ និងបាប

៥– *ឯកគ្គតា* ធម្មជាតិផ្គងចិត្តឱ្យមានអារម្មណ៍តែមួយ

៦– *ជីវិតិន្ទ្រិយ* ឥន្ទ្រិយគឺជីវិតជាអ្នកញ៉ាំងសហជាតធម៌ឱ្យរស់នៅ

៧– *មនសិការ* សេចក្តីធ្វើទុកក្នុងចិត្ត ។

*** បកិណ្ណកចេតសិក ៦ គឺ :**

១– *វិតក្កោ* សភាពធ្វើចិត្តឱ្យឡើងកាន់អារម្មណ៍ ឬឱ្យត្រិះរិះអារម្មណ៍

២– *វិចារោ* សភាពពិចារណានូវអារម្មណ៍ ឬញ៉ាំងចិត្តឱ្យត្រាច់នៅក្នុងអរម្មណ៍

៣– *អធិមោក្ខោ* សភាពធ្វើឱ្យចិត្តចុះណែនក្នុងអារម្មណ៍

៤– *វីរិយំ* ធម្មជាតិឧបត្ថម្ភគាំទ្រចិត្តមិនឱ្យរួញរា

៥– *បីតិ* ធម្មជាតិធ្វើកាយ និងចិត្តឱ្យឆ្អែត

៦– *ឆន្ទោ* សភាពធ្វើឱ្យចិត្តប្រាថ្នានូវអារម្មណ៍

( អញ្ញសមានាចេតសិក ១៣ ចប់ )

*** អកុសលចេតសិក ១៤ គឺ :**

១– *មោហោ* សភាពធ្វើចិត្តឱ្យវង្វេងក្នុងអារម្មណ៍

២– *អហិរិកំ* ធម្មជាតិមិនខ្មើមអំពើទុច្ចរិត

៣– *អនោត្តប្បំ* ធម្មជាតិមិនស្លុតខ្លាចអំពើទុច្ចរិត

៤– *ឧទ្ធច្ចំ* ធម្មជាតិធ្វើឱ្យចិត្តញាប់ញ័រ ឬរាយមាយ

៥– *លោភោ* សភាពធ្វើចិត្តឱ្យជាប់ជំពាក់នៅក្នុងអារម្មណ៍

៦– *ទិដ្ឋិ* ធម្មជាតិធ្វើចិត្តឱ្យឃើញខុស ឬឱ្យយល់ខុស

៧– *មានោ* សភាពលើកខ្លួនឱ្យខ្ពស់ ឬឱ្យប្រសើរជាងគេ

៨– *ទោសោ* សភាពទ្រុស្តក្នុងអារម្មណ៍ ឬប្រទុស្ត

៩– *ឥស្សា* ធម្មជាតិច្រណែននូវសម្បត្តិនៃអ្នកដទៃ

១០– *មច្ឆរិយំ* ធម្មជាតិលាក់លៀមនូវសម្បត្តិ (សេចក្តីកំណាញ់ )

១១– *កុក្កុច្ចំ* ធម្មជាតិធ្វើចិត្តឱ្យស្តូងទៅដោយការដែលខ្លួនប្រព្រឹត្តខុស ប្រព្រឹត្តកន្លង ហើយ

១២– *ថីនំ* ធម្មជាតិធ្វើចិត្តឱ្យរួញរាមិនខ្វល់ខ្វាយ

១៣– *មិទ្ធំ* ធម្មជាតិធ្វើចិត្តឱ្យងងុយ ឱ្យងោក ឱ្យលក់

១៤– *វិចិកិច្ឆា* ធម្មជាតិធ្វើចិត្តឱ្យសង្ស័យ ឬស្ទាក់ស្ទើរ

( អកុសលចេតសិក ១៤ ចប់ )

សោភណចេតសិក ២៥ គឺ សោភណសាធារណៈ ១៩ គឺ វិរតិ ៣ អប្បមញ្ញា ២ បញ្ញិន្ទ្រិយ ១ ជា ២៥ ។

*** សោភណសាធារណចេតសិក ១៩ គឺ :**

១– *សទ្ធា* ធម្មជាតិជឿកម្ម និងផលនៃកម្ម

២– *សតិ* ធម្មជាតិធ្វើចិត្តឱ្យរឭក

៣– *ហិរិ* ធម្មជាតិខ្មាស ឬខ្ពើមអំពើទុច្ចរិត

៤– *ឱត្តប្បៈ* ធម្មជាតិស្លុតខ្លាចអំពើទុច្ចរិត

៥– *អលោភោ* សភាពមិនធ្វើចិត្តឱ្យជាប់ជំពាក់នៅក្នុងអារម្មណ៍

៦– *អទោសោ* សភាពមិនប្រទុស្ត

៧– *តត្រមជ្ឈត្តតា* ធម្មជាតិព្រងើយកន្តើយក្នុងសត្វ និងសង្ខារ

៨– *កាយបស្សទ្ធិ* សេចក្តីរំងាប់កាយ

៩– *ចិត្តបស្សទ្ធិ* សេចក្តីរំងាប់ចិត្ត

១០– *កាយលហុតា* ភាវៈនៃកាយដ៏ស្រាល

១១– *ចិត្តលហុតា* ភាវៈនៃចិត្តដ៏ស្រាល

១២– *កាយមុទុតា* ភាវៈនៃកាយដ៏ទន់

១៣– *ចិត្តមុទុតា* ភាវៈនៃចិត្តដ៏ទន់

១៤– *កាយកម្មញ្ញតា* ភាវៈនៃកាយដ៏គួរដល់ការងារ

១៥– *ចិត្តកម្មញ្ញតា* ភាវៈនៃចិត្តដ៏គួរដល់ការងារ

១៦– *កាយបាគុញ្ញតា* ភាវៈនៃកាយដ៏ស្ទាត់ជំនាញ

១៧– *ចិត្តបាគុញ្ញតា* ភាវៈនៃចិត្តដ៏ស្ទាត់ជំនាញ

១៨– *កាយុជុកតា* ភាវៈនៃកាយដ៏ត្រង់

១៩– *ចិត្តុជុកតា* ភាវៈនៃចិត្តដ៏ត្រង់

*** វិរតិចេតសិក ៣ គឺ :**

២០ – *សម្មាវាចា* ចេតនាជាហេតុពោលល្អវៀរចាកវចីទុច្ចរិត

*២១–សម្មាកម្មន្តោ* ការងារល្អវៀចាកកាយទុច្ចរិត

២២–*សម្មាអាជីវោ* ចិញ្ចឹមជីវិតល្អវៀរចាកជិនួញ ៥ ប្រការ ។

*** អប្បមញ្ញាចេតសិក ២ គឺ :**

២៣– *ករុណា* សេចក្តីអាណិតប្រុងនឹងដោះទុក្ខសត្វឱ្យរួចចាកទុក្ខ

២៤– *មុទិតា* សេចក្តីបន្ទន់ចិត្តទៅក្នុងសម្បត្តិនៃបុគ្គលដទៃ

២៥– *បញ្ញិន្ទ្រិយ* បញ្ញាជាធំជាងសហជាតធម៌ទាំងពួង ។

( សោភណចេតសិក ២៥ ចប់ )

*តេរសញ្ញមានា ច　　　　ចុទ្ទសាកុសលា តថា*

*សោភណា បញ្ចវីសាតិ　　　　ទ្វិបញ្ញាស បវុច្ចរេ ។*

អញ្ញសមានាចេតសិក ១៣ អកុសលចេតសិក ១៤ សោភណចេតសិក ២៥ រួមគ្នាជាចេតសិក ៥២ តែប៉ុណ្ណេះ ។

*តេសំ ចិត្តាវិយុត្តានំ　　　　យថាយោគមិតោ បរំ*

*ចិត្តុប្បាទេសុ បច្ចេកំ　　　　សម្បយោគោ បវុច្ចរេ ។*

សេចក្តីប្រកបព្រមដោយចេតសិកទាំងឡាយ ដែលជាធម្មជាតិមិនបានប្រាសចាកអំពីចិត្ត ដែលខ្ញុំអនុរុទ្ធាចារ្យនឹងពោលក្នុងចិត្តុប្បាទទាំងឡាយដែលផ្សេង ៗគ្នា ដោយគួរតាមប្រកបក្នុងខាងមុខអំពីចេតសិកវិភាគនេះតទៅ :

*សត្ត សព្វត្ថ យុជ្ជន្តិ　　　　យថាយោគំ បកិណ្ណកា*

*ចុទ្ទសាកុសលេស្វេវ　　　　សោភណេស្វេវ សោភណា ។*

សេចក្តីថា សព្វចិត្តសាធារណចេតសិក ៧ នោះ ឱ្យប្រកបចូលក្នុងចិត្តទាំងអស់មិនមានវៀរ បកិណ្ណកចេតសិក ៦ នោះឱ្យប្រកបចូលក្នុងចិត្តដែលនឹងគួរប្រកប អកុសល–ចេតសិក ១៤ នោះឱ្យប្រកបចូលក្នុងអកុសលចិត្តទាំង ១២ សោភណចេតសិក ២៥ នោះឱ្យប្រកបចូលក្នុងសោភណចិត្ត ៥៩ ឬ ៩១ ។

សួរថា នឹងប្រកបចេតសិកចូលក្នុងចិត្ត ហៅថាសម្បយោគនោះ តើនឹងសម្បយោគដូចម្ដេច ?

ឆ្លើយថា នឹងសម្បយោគចេតសិកចូលក្នុងនោះ នឹងមានសេចក្ដីសម្ដែងតទៅថា សម្បយោគមាន ៤ ពួកគឺ សព្វចិត្តសាធារណចេតសិក ៧ មានសម្បយោគ ១ ពួក បកិណ្ណកចេតសិក ៦ មានសម្បយោគ ៦ ពួក អកុសលចេតសិក ១៤ មានសម្បយោគ ៧ ពួក សោភណចេតសិក ២៥ មានសម្បយោគ ១ ពួក ។ បណ្ដាសម្បយោគទាំង ៤ នោះនឹងសម្ដែងនូវសម្បយោគសព្វចិត្តសាធារណចេតសិកជាមុន ។

សព្វចិត្តសាធារណចេតសិក ៧ មានសម្បយោគ ១ ពួកនោះគឺ ផស្សោ វេទនា សញ្ញា ចេតនា ឯកគ្គតា ជីវិតិន្ទ្រិយ មនសិការោ ចេតសិកទាំង ៧ នេះកើតក្នុងចិត្ត ៨៩ ឬចិត្ត ១២១ ។

(សម្បយោគសព្វចិត្តសាធារណចេតសិក ៧ ចប់ )

*** បកិណ្ណកចេតសិក ៦ មានសម្បយោគ ៦ ពួកគឺ :**

១– *វិតក្កៈ* កើតក្នុងចិត្ត ៥៥ គឺកាមាវចរចិត្ត ៥៤ លើកទ្វិបញ្ចវិញ្ញាណ ១0 ចេញសល់នៅ ៤៤ យកបឋមជ្ឈាន ៨ ជា ១១ រួមជាចិត្ត ៥៥ ជាទីកើតនៃវិតក្កចេតសិក ។

២– *វិចារៈ* កើតក្នុងចិត្ត ៦៦ គឺ ចិត្តដែលវិតក្កចេតសិកកើតនោះ ៥៥ យករូបាវចរ–ទុតិយជ្ឈាន ៣ និងលោកុត្តរទុតិយជ្ឈាន ៨ ជា ១១ រួមជាចិត្ត៦៦ ជាទីកើតវិចារចេតសិក។

៣– *អធិមោក្ខៈ* កើតក្នុងចិត្ត ៧៨ គឺ ចិត្ត ៨៩ លើកទ្វិបញ្ចវិញ្ញាណ ១0 លើកវិចិកិច្ឆា ១ ចេញ នៅគង់ ៧៨ ជាទីកើតនៃអធិមោក្ខចេតសិក ។

៤– *វីរិយៈ* កើតក្នុងចិត្ត ៧៣ គឺចិត្ត ៨៩ លើកបញ្ចទ្វារាវជ្ជនៈ ១ ទ្វិបញ្ចវិញ្ញាណ ១0 សម្បដិច្ឆន្នៈ ២ សន្តីរណៈ ៣ ជា ១៦ នៅគង់ ៧៣ ជាទីកើតនៃវីរិយចេតសិក ។

៥–*បីតិ* កើតក្នុងចិត្ត ៥១ គឺ ចិត្តពិស្តារ ១២១ លើកទុកចិត្ត ៧0 គឺសោមនស្ស ២ ឧបេក្ខា ៥៥ កាយវិញ្ញាណ ២ ចតុត្ថជ្ឈាន ១១ ជាចិត្ត ៧0នៅគង់ ៥១ ជាទីកើតនៃបីតិ–ចេតសិក ។

៦- *ឆន្ទៈ* កើតក្នុងចិត្ត ៦៩ គឺចិត្ត ៨៩ លើកយកចិត្ត ២០ ចេញគឺ អហេតុកចិត្ត ១៦ មោហមូល ២ ជា ២០ នៅគង់ ៦៩ ជាទីកើតនៃឆន្ទចេតសិក ។

*ឆសដ្ឋី បញ្ចបញ្ញាស ឯកាទសច សោឡស*
*សត្តតិ វីសតិ ចេវ បកិណ្ណកវិវជ្ជិតា ។*
*បញ្ចបញ្ញាស ឆសដ្ឋ្យ- ដ្ឋសត្តតិ តិសត្តតិ*
*ឯកបញ្ញាស ចេកូន- សត្តតីស បកិណ្ណកា ។*

សេចក្តីថា ចិត្តទាំងឡាយ ៦៦ ផង ៥៥ ផង ១១ផង ១៦ ផង ៧០ផង ២០ ផង វៀរចាកបកិណ្ណកចេតសិកដោយលំដាប់គ្នា ចិត្តទាំងឡាយ ៥៥ ផង ៦៦ ផង ៧៨ ផង៧៣ ផង ៦៩ ផង ប្រកបដោយបកិណ្ណកចេតសិកដោយលំដាប់ ៗគ្នា ។

មានអធិប្បាយក្នុងគថាទាំង ២ នោះថា វិតក្កចេតសិកវៀរចាកចិត្ត ៦៦ កើតក្នុង ៥៥ វិចារចេតសិកវៀរចាកចិត្ត ៥៥ កើតក្នុង ៦៦ អធិមោក្ខចេតសិកវៀរចាកចិត្ត ១៦ កើតក្នុងចិត្ត ៧៨ វីរិយចេតសិកវៀរចាកចិត្ត ១៦ កើតក្នុងចិត្ត ៧៣ បីតិចេតសិកវៀរចាកចិត្ត ៧០ កើតក្នុង ៥១ ឆន្ទចេតសិកវៀរចាកចិត្ត ២០ កើតក្នុងចិត្ត ៦៩ ។

( សម្បយោគបកិណ្ណកចេតសិក ៦ ចប់ )

*** អកុសលចេតសិក ១៤ សម្បយោគមាន ៧ ពួកនោះគឺ :**

១- *មោហៈ អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ* ទាំង ៤ នេះជាអកុសលសាធារណចេតសិក កើតទូទៅក្នុងអកុសលចិត្ត ១២

២- *លោភៈ* កើតក្នុងលោភមូលចិត្ត ៨

៣- *ទិដ្ឋិ* កើតក្នុងលោភចិត្តទិដ្ឋសម្បយុត្ត ៤

៤- *មានៈ* កើតក្នុងលោភចិត្តទិដ្ឋិវិប្បយុត្ត ៤

៥- *ទោសៈ ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ* ទាំង ៤ នេះកើតក្នុងទោសចិត្តបដិឃសម្បយុត្ត២

៦- *ថីនៈ មិទ្ធៈ* ទាំង ២ នេះកើតក្នុងសសង្ខារិកចិត្តទាំង ៥

៧- *វិចិកិច្ឆា* កើតក្នុងចិត្តវិចិកិច្ឆាសម្បយុត្ត ។

*សព្វាបុញ្ញេសុ ចត្តារោ* *លោភមូលេ តយោ កតា*
*ទោសមូលេសុ ចត្តារោ* *សសង្ខារេ ទ្វយន្តថា ។*
*វិចិកិច្ឆា វិចិកិច្ឆា-* *ចិត្តេ ចាតិ ចតុទ្ទស*
*ទ្វាទសាកុសលេស្វេវ* *សម្បយុជ្ជន្តិ បញ្ចធា ។*

សេចក្តីក្នុងគាថាទាំងពីរនោះថា អកុសលចេតសិកទាំង ១៤ ប្រកបចូលក្នុងអកុសលចិត្តទាំង ១២ ហើយលោកចាត់ជា ៥ ស្ថានដូច្នេះ គឺ អកុសលចេតសិកកើតក្នុងអកុសលចិត្ត ១២ ។

មាន ៤ ស្ថាន ១, អកុសលចេតសិក កើតក្នុងទោសមូលចិត្ត ៨
មាន ៣ ស្ថាន ១ , អកុសលចេតសិក កើតក្នុងទោសមូលចិត្ត ២
មាន ៤ ស្ថាន១, អកុសលចេតសិក កើតក្នុងសសង្ខារិកចិត្ត ៥
មាន ២ ស្ថាន ១, អកុសលចេតសិក កើតក្នុងវិចិកិច្ឆាសម្បយុត្ត ១
មាន ១ ស្ថាន ១ ។

(សម្បយោគអកុសលចេតសិក ១៤ ចប់ )

*** សោភណចេតសិក ២៥ សម្បយោគមាន ៤ ពួកគឺ :**

១- *សោភណសាធារណចេតសិក* ១៩ កើតក្នុងសោភណចិត្ត ៥៩

២- *វិរតិចេតសិក* ៣ កើតក្នុងចិត្ត១៦ គឺកាមាវចរកុសលចិត្ត ៨ លោកុត្តចិត្ត ៨ ជា ១៦ ។

៣- *អប្បមញ្ញាចេតសិក* ២ កើតក្នុងចិត្ត ២៨ គឺកាមាវចកុសលចិត្ត ៨ កាមាវចរកិរិយាចិត្ត ៨ មហគ្គតចិត្ត ១៥ វៀរបញ្ចមជ្ឈាន ៣ នៅ ១២ ជា ២៨ ។

៤- *បញ្ញាចេតសិក* កើតក្នុងចិត្ត ៤៧ គឺកាមាវចរញាណសម្បយុត្ត ១២ មហគ្គតៈ ២៧ លោកុត្តៈ ៨ ជា ៤៧ ។

( សម្បយោគសោភណចេតសិក ២៥ ចប់ )

សម្តែងមកក្នុងសម្បយោគ ២ ប្រការអស់សេចក្តីតែប៉ុណ្ណេះ ។

*ឯកូនវីសតិ ធម្មា* *ជាយន្តេកូនសដ្ឋិយំ*
*តយោ សោឡសចិត្តេសុ* *អដ្ឋវីសតិយំ ទ្វយំ ។*
*បញ្ញា បកាសិតា សត្ត-* *ចត្តាឡីសវិធេសុបិ*
*សម្បយុត្តា ចតុធេវំ* *សោភណេស្វេវ សោភណា ។*

សេចក្តីថា សោភណចេតសិក ១៩ កើតក្នុងចិត្ត ៥៩ វិរតិចេតសិក ៣ កើតក្នុងចិត្ត ១៦ អប្បមញ្ញចេតសិក ២ កើតក្នុងចិត្ត ២៨ បញ្ញាចេតសិក កើតក្នុងចិត្ត ៤៧ សោភណ–ចេតសិកទាំងឡាយកើតក្នុងសោភណចិត្ត ប្រកបព្រមហើយដោយប្រការ ៤ ដូចន័យដែលពោលមកហើយ ។

**ពីនេះនឹងពោលនូវយោគីចេតសិកតទៅ :**

យោគីចេតសិកមាន ២ ប្រការគឺអនិយតយោគីចេតសិក ១ និយតយោគីចេតសិក ១។ អនិយតយោគីចេតសិកនោះ ជួនកាលក៏កើតជាមួយគ្នា ជួនកាលក៏កើតផ្សេងគ្នាមិនទៀង ទើបបានឈ្មោះថា **អនិយតយោគីចេតសិក**, និយតយោគីចេតសិកនោះតែងកើតទៀងជាមួយគ្នា ឯអនិយតយោគីនោះមាន ១១ គឺ ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ ករុណា មុទិតា មានៈ ថីនៈ មិទ្ធៈ រួមគ្នាជា ១១ ចេតសិកទៀតក្រៅពី ១១ នេះ នោះមាន ៤១ ចេតសិកឈ្មោះថា **និយតយោគីចេតសិក** ព្រោះតែងតែកើតទៀងជាមួយគ្នាដោយលំដាប់ ។

*យថាវុត្តានុសារេន* *សេសានិយតយោគិនោ*
*សង្គហញ្ច បវក្ខាមិ* *តេសន្ទានិ យថារហំ ។*

ពីនេះទៅនឹងសម្តែងនូវសង្គហៈ គឺសេចក្តីរួបរួមនូវចេតសិកដោយសមគួរ សង្គហៈនោះមាន ៥ ប្រការ គឺអនុត្តរសង្គហៈ ១ មហគ្គតសង្គហៈ ១ សោភណសង្គហៈ ១ អកុសលសង្គហៈ ១ អហេតុកសង្គហៈ ១ ។

សួរថា សង្គហៈទាំង ៥ ប្រការនោះ នឹងសង្គ្រោះដោយប្រការដូចម្តេច ?

ឆ្លើយថា នឹងសង្គ្រោះពោលរួបរួមនូវអនុត្តរសង្គហៈ ដ៏ជាលោកុត្តរចិត្តជាមុនជាងសង្គហៈទាំងពួង អនុត្តរសង្គហៈនោះចែកចេញជា ៥ គឺ បឋមជ្ឈានចែកជា ៨ គឺ មគ្គ ៤ ផល ៤ ជា ៨, ទុតិយជ្ឈានចែកចេញជា ៨ គឺ មគ្គ ៤ ផល ៤ ជា ៨, តតិយជ្ឈានចែកចេញជា ៨ គឺ មគ្គ ៤ ផល ៤ ជា ៨, ចតុត្ថជ្ឈានចែកចេញជា ៨ គឺ មគ្គ ៤ ផល ៤ ជា ៨, , បញ្ចមជ្ឈានចែកចេញជា ៨ គឺ មគ្គ ៤ ផល ៤ ។

បឋមជ្ឈាន ៨ មានចេតសិកចុះ ៣៦ គឺ អញ្ញសមាន ១៣ ចុះពេញទាំងអស់មិនមាន–វៀរ សោភណចេតសិកចុះ ២៣ វៀរអប្បមញ្ញា ២ ។

ទុតិយជ្ឈាន ៨ មានចេតសិកចុះ ៣៥ គឺ អញ្ញសមានា ១២ វៀរវិតក្កៈ ១ សោភណ–ចុះ ២៣ វៀរអប្បមញ្ញា ២ ។

តតិយជ្ឈាន ៨ មានចេតសិកចុះ ៣៤ គឺ អញ្ញសមានា ១១ វៀរអប្បមញ្ញា ២ ។

ចតុត្ថជ្ឈាន ៨ មានចេតសិកចុះ ៣៣ គឺ អញ្ញសមានា ១០ វៀរវិតក្កៈ ១ វិចារៈ ១ បីតិ ១ សោភណចេតសិកចុះ ២៣ វៀរអប្បមញ្ញា ២ ។

បញ្ចមជ្ឈាន ៨ មានចេតសិកចុះ ៣៣ គឺ អញ្ញសមានា ១០ វៀរវិតក្កៈ ១ វិចារៈ ១ បីតិ ១ សោភណចេតសិកចុះ ២៣ វៀរអប្បមញ្ញា ៣ ។

( អនុត្តរសង្គហៈ ៥ ចប់ )

*** មហគ្គតសង្គហៈចែកចេញជា ៥ គឺ :**

១– *បឋមជ្ឈាន* ៣ គឺ កុសល ១ វិបាក ១ កិរិយា ១

២– *ទុតិយជ្ឈាន* ៣ គឺ កុសល ១ វិបាក ១ កិរិយា ១

៣– *តតិយជ្ឈាន* ៣ គឺ កុសល ១ វិបាក ១ កិរិយា ១

៤– *ចតុត្ថជ្ឈាន* ៣ គឺ កុសល ១ វិបាក ១ កិរិយា ១ អរូបជ្ឈាន ១២ រួមជា ១៥ ។

បឋមជ្ឈាន ៣ ចេតសិកចុះ ៣៥ គឺ អញ្ញសមានា ១៣ ចុះពេញទាំងអស់មិនមានវៀរ សោភណចេតសិកចុះ ២២ វៀរវិរតិ ៣ ។

ទុតិយជ្ឈាន ៣ ចេតសិកចុះ ៣៤ គឺ អញ្ញសមានា ១២ វៀរវិតក្កៈ ១សោភណ–ចេតសិកចុះ ២២ វៀរវិរតិ ៣ ។

តតិយជ្ឈាន ៣ ចេតសិកចុះ ៣៣ គឺ អញ្ញសមានា ១១ វៀរវិតក្កៈ ១ វិចារៈ ១ សោភណចេតសិកចុះ ២២ វៀរវិរតិ ៣ ។

ចតុត្ថជ្ឈាន ៣ ចេតសិកចុះ ៣២ គឺអញ្ញសមានា ១០ វៀរវិតក្កៈ ១ វិចារៈ ១ បីតិ ១ សោភណចេតសិកចុះ ២២ វៀរវិរតិ ៣ ។

បញ្ចមជ្ឈាន ៣ អរូបជ្ឈាន ១២ រួមជា ១៥ មានចេតសិកចុះ ៣០ គឺ អញ្ញសមានា ១០ វៀរវិតក្កៈ ១ វិចារៈ ១ បីតិ ១ សោភណចេតសិកចុះ ២០ វៀរវិរតិ ៣ អប្បមញ្ញា ២។

( មហគ្គតសង្គហៈ ៥ ចប់ )

សោភណសង្គហៈចែកចេញជា ១២ គឺ កាមាវចរកុសល ៤ កាមាវចរកិរិយា ៤ កាមាវចរវិបាក ៤ ។

កាមាវចរកុសល ៤ គឺ បឋមទុក្កៈ ១ ទុតិយទុក្កៈ ១ តតិយទុក្កៈ ១ ចតុត្ថទុក្កៈ ១ ជា ៤ ទុក្កៈ កាមវចរកិរិយា និងកាមាវចរវិបាក ក៏ចាត់ចេញទៅជាចំណែកបួន ៗ ដូចគ្នាដែរ ដែលថាទុក្កៈ ៗ នោះ ប្រែថា ពួក ២ គឺចាត់ទុក្កៈជាគូៗគ្នា ទើបហៅថាទុក្កៈក៏នឹងសម្តែងកាមាវចរកុសលដែលចាត់ជាទុក្កៈៗនោះឱ្យឃើញជាបែបយ៉ាងដូច្នេះ គឺសោមនស្សសហគតញាណសម្បយុត្តអសង្ខារិក ១ សសង្ខារិក ១ ។

តតិយទុក្កៈ គឺ ឧបេក្ខាសហគត ញាណសម្បយុត្ត អសង្ខារិក ១ សសង្ខារិក ១ ។

ចតុត្ថទុក្កៈ គឺ ឧបេក្ខាសហគត ញាណវិប្បយុត្ត អសង្ខារិក ១ សសង្ខារិក ១ ។

កាមាវចរកិរិយា និងកាមាវចរវិបាក ក៏ចាត់ទុក្កៈដូច្នេះដូចៗគ្នា ប្លែកគ្នាតែតួចេតសិកដែលចុះ ចេតសិកដែលចុះនោះច្រើនជាងគ្នាខ្លះ តិចជាងគ្នាខ្លះ អ្នកប្រាជ្ញគប្បីពិចារណានូវបែបដែលបានធ្វើទុកយ៉ាងនេះ ដូច្នេះចុះ ។

កុសលបឋមទុក្កៈ ចេតសិកចុះ ៣៨ គឺ អញ្ញសមានា ១៣ សោភណចេតសិក ២៥, កុសល–ទុតិយទុក្កៈ ចេតសិកចុះ ៣៧ គឺ អញ្ញសមានា ១៣ សោភណចេតសិក ២៤ វៀរបញ្ញា ១, កុសល–

តតិយទុក្កៈ ចេតសិកចុះ ៣៧ គឺ អញ្ញសមានា ១២ វៀរបីតិ ១ សោភណចេតសិក ២៥ , កុសល– ចតុត្ថទុក្កៈ ចេតសិកចុះ ៣៦ គឺ អញ្ញសមានា ១២ វៀរបីតិ ១ សោភណចេតសិក ២៤ វៀរ បញ្ញា ១ ។

កិរិយាបឋមទុក្កៈ ចេតសិកចុះ ៣៥ គឺអញ្ញសមានា ១៣ សោភណចេតសិក ២២ វៀរវិរតិ ៣, កិរិយាទុតិយទុក្កៈ ចេតសិកចុះ ៣៤ គឺអញ្ញសមានា ១៣ សោភណចេតសិក ២១ វៀរវិរតិ ៣ បញ្ញា ១, កិរិយាតតិយទុក្កៈ ចេតសិកចុះ ៣៤ គឺអញ្ញសមានា ១២ វៀរបីតិ ១ សោភណចេតសិក ២២ វៀរវិរតិ ៣, កិរិយាចតុត្ថទុក្កៈចេតសិកចុះ ៣៣ គឺអញ្ញសមានា១២ វៀរបីតិ ១ សោភណចេតសិក ២១ វៀរវិរតិ ៣ អប្បមញ្ញា ១ ។

វិបាកបឋមទុក្កៈ ចេតសិកចុះ ៣៣ គឺអញ្ញសមានា ១៣ សោភណចេតសិក ២០ វៀរវិរតិ ៣ អប្បមញ្ញា ២, វិបាកទុតិយទុក្កៈ ចេតសិក ៣២ គឺអញ្ញសមានា ១៣ សោភណ–ចេតសិក ១៩ វៀរវិរតិ ៣ អប្បមញ្ញា ២ បញ្ញា ១, វិបាកតតិយទុក្កៈ ចេតសិកចុះ ៣២ គឺអញ្ញសមានា ១២ វៀរបីតិ ១ សោភណចេតសិក ២០ វៀរវិរតិ ៣ អប្បមញ្ញា ២,វិបាក–ចតុត្ថទុក្កៈ ចេតសិកចុះ ៣១ គឺអញ្ញសមានា ១២ វៀរបីតិ ១ សោភណចេតសិក ១៩ វៀរវិរតិ ៣ អប្បមញ្ញា ២ បញ្ញា ១ ។

( សោភណសង្គហៈ ១២ ចប់ )

អកុសលសង្គហៈចែកចេញជា ៧ ពួក ពួកទី ១ មានចេតសិកចុះ ១៩ ពួកទី ២ មានចេតសិកចុះ ១៨ ពួកទី ៣ មានចេតសិកចុះ ២០ ពួកទី ៤ មានចេតសិកចុះ ២១ ពួកទី ៥ មានចេតសិកចុះ ២០ ពួកទី ៦ មានចេតសិកចុះ ២២ ពួកទី ៧ មានចេតសិកចុះ ១៥ ។

សង្គហៈទី ១ គឺសោមនស្សសហគត ទិដ្ឋិគតសម្បយុត្ត អសង្ខារិក សោមនស្សសហគត ទិដ្ឋិគតវិប្បយុត្ត អសង្ខារិក ។

សង្គហៈទី ២ គឺឧបេក្ខាសហគត ទិដ្ឋិគតសម្បយុត្ត អសង្ខារិក ឧបេក្ខាសហគត ទិដ្ឋិគតវិប្បយុត្ត អសង្ខារិក ។

សង្គហៈទី ៣ គឺ ទោមនស្សសហគត បដិឃសម្បយុត្ត អសង្ខារិក ។

សង្គហៈទី ៤ គឺ សោមនស្សសហគត ទិដ្ឋិគតសម្បយុត្ត សសង្ខារិក សោមនស្ស-សហគត ទិដ្ឋិគតវិប្បយុត្ត សសង្ខារិក ។

សង្គហៈទី ៥ គឺ ឧបេក្ខាសហគត ទិដ្ឋិគតសម្បយុត្ត សសង្ខារិក ឧបេក្ខាសហគត ទិដ្ឋិគតវិប្បយុត្ត សសង្ខារិក ។

សង្គហៈទី ៦ គឺ ទោមនស្សសហគត បដិឃសម្បយុត្ត សសង្ខារិក ។

សង្គហៈទី ៧ គឺ ឧបេក្ខាសហគត ឧទ្ធច្ចសម្បយុត្ត វិចិកិច្ឆាសម្បយុត្ត ។

**អធិប្បាយសេចក្តីក្នុងសង្គហៈទាំង ៧ ពួកនោះតទៅថា :**

អសង្ខារិកទី ១ មានចេតសិក ១៩ គឺ អញ្ញសមានាចេតសិក ១៣ អកុសលសាធារណៈ ៤ លោភៈ ១ ទិដ្ឋិ ១ ជា ១៩ ។

អសង្ខារិកទី ២ មានចេតសិកចុះ ១៩ ប្រហែលគ្នានឹងទី ១ ដែរប្លែកគ្នាតែខាងចុង គឺ លើកយកទិដ្ឋិចេញ ដាក់មានះបញ្ចូល ទៅជា ១៩ ។

អសង្ខារិកទី ៣ មានចេតសិកចុះ ១៨ គឺអញ្ញសមានា ១២ វៀរបីតិ ១ អកុសល-សាធារណៈ ៤ និងលោភៈ ១ ទិដ្ឋិ ១ ជា ១៨ ។

អសង្ខារិកទី ៤ មានចេតសិកចុះ ១៨ ប្រហែលគ្នានឹងទី ៣ ដែរប្លែកគ្នាតែខាងចុង គឺ លើកយកតែទិដ្ឋិចេញ ដាក់មានះបញ្ចូលទៅជា ១៨ ។

អសង្ខារិកទី ៥ មានចេតសិកចុះ ២០ គឺអញ្ញសមានា ១២ វៀរបីតិ ១ អកុសល-សាធារណៈ ៤ និងទោសៈ ១ ឥស្សា ១ មច្ឆរិយៈ ១ កុក្កុច្ចៈ ១ ជា ២០ ។

សសង្ខារិកទី ១ មានចេតសិកចុះ ២១ គឺអញ្ញសមានា ១៣ អកុសលចេតសិក ៨ គឺ មោហៈ អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ លោភៈ ទិដ្ឋិ ថីនៈ មិទ្ធៈ ជា ២០ ។

សសង្ខារិកទី ២ មានចេតសិកចុះ ២១ ប្រហែលគ្នានឹងទី ១ ដែរប្លែកគ្នាតែខាងចុង គឺលើកយកទិដ្ឋិចេញ ដាក់មានះបញ្ចូលទៅជា ២១ ។

សសង្ខារិកទី ៣ មានចេតសិកចុះ ២០ គឺអញ្ញសមានា ១២ វៀរបីតិ ១ អកុសលចេតសិក ៨ គឺ មោហៈ អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ លោភៈ ទិដ្ឋិ ថីនៈ មិទ្ធៈ ជា ២០ ។

សសង្ខារិកទី ៤ មានចេតសិកចុះ ២០ ប្រហែលគ្នានឹងទី ៣ ដែរប្លែកគ្នាតែខាងចុង គឺលើកយកទិដ្ឋិចេញ ដាក់មានៈបញ្ចូលទៅជា ២០

សសង្ខារិកទី ៥ មានចេតសិកចុះ ២២ គឺអញ្ញសមានា ១២ វៀរបីតិ ១ អកុសលចេតសិក ១០ គឺ មោហៈ អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ ទោសៈ ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ ថីនៈ មិទ្ធៈ ជា ២០ ។

មោហឧទ្ធច្ចសម្បយុត្ត មានចេតសិកចុះ ១៥ គឺអញ្ញសមានា ១១ វៀរបីតិ ១ អធិមោក្ខៈ ១ អកុសលសាធារណៈ ៣ គឺមោហៈ អហិរិកៈ អនោត្តប្បៈ និងវិចិកិច្ឆា ១ ជា ១៥ ។

( អកុសលសង្គហៈ ៧ ចប់ )

អហេតុកសង្គហៈ សង្គ្រោះដោយចេតសិកចុះក្នុងអហេតុកចិត្ត ១៨ ចែកចេញ ៤ សង្គហៈ គឺ សង្គហៈទី ១ សង្គហៈទី ២ សង្គហៈទី ៣ សង្គហៈទី ៤ ។

សង្គហៈទី ១ គឺហសិតុប្បាទចិត្ត មានចេតសិកចុះ ១២ គឺអញ្ញសមានា ១១ វៀរឆន្ទៈ ១ ។

សង្គហៈទី ២ គឺវោដ្ឋព្វនចិត្ត មានចេតសិកចុះ ១១ គឺ អញ្ញសមានា ១១ វៀរឆន្ទៈ ១ បីតិ ១ សុខសន្តីរណៈមានអញ្ញសមានាចុះ ១១ វៀរឆន្ទៈ ១ វិរិយៈ ១ ។

សង្គហៈទី ៣ គឺបញ្ចទ្វារាវជ្ជនៈ ១ អកុសលសម្បដិច្ឆន្នៈ ១ កុសលសម្បដិច្ឆន្នៈ ១ បីនេះឈ្មោះមនោធាតុតិកៈ អកុសលសន្តីរណៈ ១ កុសលសន្តីរណៈ ១ ពីរនេះឈ្មោះបដិសន្ធិបុគ្គល មានអញ្ញសមានាចុះ ១០ វៀរឆន្ទៈ ១ បីតិ ១ វិរិយៈ ១ ។

សង្គហៈទី ៤ គឺទ្វិបញ្ចវិញ្ញាណ មានសព្វចិត្តសាធារណៈចុះទាំង ៧ វៀរបកិណ្ណកៈទាំង ៦ ។

( ចប់អហេតុកសង្គហៈ ៤ ចប់ )

អនុត្តរសង្គហៈ ៥ មហគ្គតសង្គហៈ ៥ សោភណសង្គហៈ ១២ អកុសលសង្គហៈ ៧ អហេតុកសង្គហៈ ៤ រួមជាសង្គហៈ ៣៣ ។

*ឥត្ថំ ចិត្តាវិយុត្តានំ　　　　សម្បយោគញ្ច សង្គហំ*
*ញត្វា ភេទំ យថាយោគំ　　　　ចិត្តេន សមមុទ្ទិសេតិ ។*

អ្នកប្រាជ្ញដឹងហើយនូវសម្បយោគ ១៨ និងសង្គហៈ ៥ នៃចេតសិកទាំងឡាយដោយប្រការដូច្នេះហើយ គប្បីសម្តែងនូវប្រភេទនៃចេតសិកទាំងឡាយឱ្យប្រហែលនឹងចិត្តដោយសមគួរ អាចារ្យពោលហើយថា សព្វចិត្តសាធារណៈ ៧ កើតក្នុងចិត្ត ៨៩ ឬក្នុងចិត្ត ១២១ ជំនុំបកិណ្ណកចេតសិក ៦ នោះ វិតក្កៈកើតក្នុងចិត្ត ៥៥ វិចារៈកើតក្នុងចិត្ត ៦៦ អធិមោក្ខៈកើតក្នុងចិត្ត ៧៨ វីរិយៈកើតក្នុងចិត្ត ៧៣ បីតិកើតក្នុងចិត្ត ៥១ ឆន្ទៈកើតក្នុងចិត្ត ៦៩ ចេតសិកកើតក្នុងចិត្តបានប៉ុន្មាន ឱ្យរាប់ប្រហែលគ្នានឹងចិត្តប៉ុណ្ណោះ ។

*ឥតិ អភិធម្មត្ថសង្គហេ*

*ចេតសិកសង្គហវិភាគោ នាម ទុតិយោ បរិច្ឆេទោ*

បរិច្ឆេទទី ២ ឈ្មោះចេតសិកសង្គហវិភាគ ក្នុងអភិធម្មត្ថសង្គហៈចប់តែប៉ុណ្ណោះហោង ។

# បរិច្ឆេទទី ៣

## បកិណ្ណកសង្គហវិភាគ

*សម្បយុត្តា យថាយោគំ តេបញ្ញាស សភាវតោ*
*ចិត្តចេតសិកា ធម្មា តេសន្ទានិ យថារហំ ។*
*វេទនាហេតុតោ កិច្ច- ទ្វារាលម្ពនវត្ថុតោ*
*ចិត្តុប្បាទវសេនេវ សង្គហោ នាម នីយតេ ។*

សេចក្តីថា ធម៌ទាំងឡាយគឺចិត្ត ចេតសិក ជាសម្បយុត្តបច្ច័យដល់គ្នានឹងគ្នាដោយគួរដល់កិរិយាប្រកប រាប់បាន ៥៣ ដោយឈ្មោះគឺ ចិត្ត ១ ចេតសិក ៥២ ដែលរាប់ថាចិត្តច្រើនដល់ ៨៩ ឬ ១២១ នោះគឺរាប់ដោយប្រភេទនៃកុសលនិងអកុសល និងអព្យាកតៈ ដែលរាប់ញែកចេញទៅជាចំណែកយ៉ាងនេះ ទើបមានច្រើន និងរួបរួមពោលនូវចិត្ត និងចេតសិកចូលផងគ្នាដោយសង្គហៈ ៦ គឺ វេទនាសង្គហៈ ១ ហេតុសង្គហៈ ១ កិច្ចសង្គហៈ ១ ទ្វារសង្គហៈ ១ អាលម្ពណសង្គហៈ ១ វត្ថុសង្គហៈ ១ សម្តែងចេញឱ្យច្បាស់ដោយអំណាចនៃចេតសិកដោយសមគួរក្នុងបរិច្ឆេទទី ៣ ក្នុងកាលឥឡូវនេះ ។

ជិនុំសង្គហៈ ៦ នេះ វេទនាសង្គហៈចែកចេញជា ៥ ហេតុសង្គហៈចែកចេញជា ៦ កិច្ចសង្គហៈចែកចេញជា ១៤ ទ្វារសង្គហៈចែកចេញជា ៦ អាលម្ពណសង្គហៈចែកចេញជា ៦ វត្ថុសង្គហៈចែកចេញជា ៦ ។

វេទនាសង្គហៈ មាន ៣ គឺ សុខវេទនា ១ ទុក្ខវេទនា ១ ឧបេក្ខាវេទនា ១ បញ្ចូល-សោមនស្សវេទនា ១ ទោមនស្សវេទនា ១ ជា ៥, ចិត្តដែលកើតនិងរលត់ព្រមដោយសុខ-មាន ១ គឺ កាយវិញ្ញាណជាកុសលវិបាក, ចិត្តដែលកើតនិងរលត់ព្រមដោយទុក្ខមាន ១ គឺ កាយវិញ្ញាណជាអកុសលវិបាក, ចិត្តដែលកើតនិងរលត់ព្រមដោយសោមនស្សមាន ៦២ គឺ កាមាវចរ ១៨ ដែលមានលោភមូលសោមនស្ស ៤ និងកាមាវចរសោភណៈ ១២ គឺ កុសលសោមន្ស ៤ វិបាកសោមនស្ស ៤ កិរិយាសោមនស្ស ៤ ជា ១២សោមនស្សសន្តីរណៈ ១ ហសនចិត្ត ១ ជា ១៨ ចាត់យកបឋមជ្ឈាន ១១ ទុតិយជ្ឈាន ១១ តតិយជ្ឈាន ១១

ចតុត្ថជ្ឈាន ១១ ជា ៤៤ រួម ១៨ និង ៤៤ ត្រូវជា ៦២ កើតរលត់ព្រមដោយសោមនស្សចិត្ត ដែលកើតនិងរលត់ព្រមដោយទោមនស្សមាន ២ គឺទោសមូល បដិឃសម្បយុត្តទាំង ២ គឺ អសង្ខារិក ១ សសង្ខារិក ១ ហើយប្រកបដោយអកុសលចេតសិក ៤ ទៀតគឺ ទោសៈ ១ ឥស្សា ១ មច្ឆរិយៈ ១ កុក្កុច្ចៈ ១ ចិត្តដែលកើតនិងរលត់ព្រមដោយ ឧបេក្ខាមាន ៥៥ គឺ ឧបេក្ខា លោភមូល ៤ ឧបេក្ខា មោហមូល ២ ឧបេក្ខា អហេតុកៈ ១៤ ឧបេក្ខាកាមាវចរ ១២ ឧបេក្ខាបញ្ចមជ្ឈាន ២៣ រួមគ្នាជា ៥៥ ។

( វេទនាសង្គហៈ ៥ ចប់ )

ហេតុសង្គហៈ សង្គ្រោះដោយហេតុមាន ៦ គឺ លោភៈ ១ ទោសៈ ១ មូហៈ ១ ទាំង ៣ នេះជាចំណែកខាងអកុសល, អលោភៈ ១ អទោសៈ ១ អមោហៈ ១ ទាំងបីជាចំណែកខាង អកុសល និងអព្យាកតៈ ។

ចិត្ត ៨៩ ចែកចេញជា ២ ពួកគឺអហេតុកចិត្ត ១៨ ពួក ១ សហេតុកចិត្ត ៧១ ពួក ១ ។ អហេតុកចិត្ត ១៨ គឺ បញ្ចទ្វារាវជ្ជនៈ ១ ទ្វិបញ្ចវិញ្ញាណ ១០ សម្បដិច្ឆន្នៈ ២ សន្តីរណៈ ៣ វោដ្ឋវនៈ ១ ហស្សនៈ ១ រួមជា ១៨ , សហេតុកចិត្ត ៧១ គឺអកុសលចិត្ត ១២ កាមាវចរ–ចត្តិ ២៥ មហគ្គតចិត្ត ២៧ លោកុត្តរចិត្ត ៨ ជា ៧១ សហេតុកចិត្ត ៧១ នេះចាត់ចេញជា ហេតុមាន ៣ គឺ ឯកហេតុ ១ ទុហេតុ ១ ត្រៃហេតុ ១ ។

ឯកហេតុចិត្ត បានដល់ចិត្ត ២ គឺមោហមូលទាំង ២ ទុហេតុចិត្ត បានដល់ចិត្ត ២២ គឺ លោភមូល ៨ ទោសមូល ២ កាមាវចរសោភណញាណវិប្បយុត្ត ១២ ជា ២២, ត្រៃហេតុ–ចិត្តបានដល់ កាមាវចរសោភណញាណសម្បយុត្ត ១២ រូបាវចរចិត្ត ១៥ អរូបាវចរចិត្ត ១២ លោកុត្តរចិត្ត ៨ ជា ៤៧ ។

*លោភោ ទោសោ ច មោហោ ច ហេតូ អកុសលា តយោ*
*អលោភាទោសាមោហា ច កុសលាព្យាកតា តថា ។*

សេចក្តីថា អកុសលហេតុមាន ៣ យ៉ាងគឺ លោភៈសភាពជាប់ជំពាក់ក្នុងអារម្មណ៍ ១ ទោសៈ សភាពទ្រុស្តក្នុងអារម្មណ៍ ១ មោហៈ សភាពវង្វេងក្នុងអារម្មណ៍ ឬថាសេចក្តីល្ងង់

១, កុសលហេតុមាន ៣ យ៉ាងគឺ អលោភៈ សភាពមិនបានជាប់ជំពាក់ក្នុងអារម្មណ៍ ១ អទោសៈ សភាពមិនទ្រុស្តក្នុងអារម្មណ៍ ១ អមោហៈ សភាពមិនវង្វេង ឬមិនភាន់ប្រឡំក្នុងអារម្មណ៍ ១, ឯកុសលហេតុ ៣ នេះជាអព្យាកតៈ ក៏មានដែរ ។

*អហេតុកដ្ឋារសេក–        ហេតុកា ទ្វេ ទ្វាវីសតិ*
*ទ្វិហេតុកា មតា សត្ត        ចត្តាឡីស តិហេតុកា ។*

សេចក្ដីថា ចិត្តជាអហេតុក ១៨ ជាឯកហេតុកៈ ២ ចិត្តជាទុហេតុកៈ ២២ ចិត្តជាត្រៃហេតុកៈ ៤៧ ។

( ហេតុសង្គហៈ ៦ ចប់ )

កិច្ចសង្គហៈ សង្គ្រោះដោយកិច្ចមាន ១៤ គឺ បដិសន្ធិកិច្ច ១ ភវង្គកិច្ច ១ អាវជ្ជនកិច្ច ១ ទស្សនកិច្ច ១ សវនកិច្ច ១ ឃាយនកិច្ច ១ សាយនកិច្ច ១ ផុស្សនកិច្ច ១ សម្បដិច្ឆន្នកិច្ច ១ សន្តីរណកិច្ច ១ វោដ្ឋវនកិច្ច ១ ជវនកិច្ច ១ តទាលម្ពណកិច្ច ១ ចុតិកិច្ច ១ ។

**អធិប្បាយនូវកិច្ចទាំង ១៤ នោះគឺ :**

១–*បដិសន្ធិកិច្ច* ចិត្តដែលកាន់យកនូវបដិសន្ធិក្នុងកំណើត ៤ ក្នុងភព ៣ អាការៈនៃចិត្តដែលតាំងចុះជាបឋមខណៈឈ្មោះបដិសន្ធិកិច្ច សេចក្ដីថា ចិត្តដែលតទុកនូវភព និងជាតិមិនឱ្យអស់ មិនឱ្យផុតរលត់ទៅបាន បដិសន្ធិកិច្ចនោះកើតមក ជាតិ ១ ក៏មានខណចិត្ត ១ប៉ុណ្ណោះ កើតឡើងជាដើមភពដើមជាតិ ហើយក៏រលត់ទៅ ទើបបានឈ្មោះថាបដិសន្ធិកិច្ច ។

២–*ភវង្គកិច្ច* ចិត្តដែលកើតតមកអំពីបដិសន្ធិៗ កើតឡើង ១ ខណៈហើយក៏រលត់ទៅ ភវង្គចិត្តក៏កើតឡើងរឿយៗ ដរាបដល់អស់ភព អស់ជាតិ ខ្សែភវង្គមានជាប់តគ្នាទៅមិនដែលមានដាច់ឡើយ ប្រៀបដូចអណ្ដាតប្រទីប ឬខ្សែទឹកដែលហូរមិនដាច់នោះឯង ឯខ្សែ–ភវង្គនឹងដាច់នោះ ក៏ដាច់កាលដែលចិត្តឡើងមកកាន់វិថី លុះអស់វិថីចិត្ត ចិត្តក៏ធ្លាក់ចុះកាន់ខ្សែភវង្គដូចមុនជាប្រក្រតី ឯសព្ទដែលហៅថាភវង្គនោះ សេចក្ដីថាជាតួភព ឬម្ចាស់នៃភព ឧបមាដូម្ចាស់របស់ផ្ទះ ឬម្ចាស់របស់ស្រុក វិថីចិត្តនោះឧបមាដូចអ្នកដំណើរមកសួររក ឬ

ដូចអ្នកដែលមកអាស្រ័យនៅស្រុក ម្យ៉ាងទៀត ភវង្គចិត្តនោះឧបមាដូចស្ទឹង ឬទន្លេមានខ្សែទឹកដ៏ស្មើ មិនមានរលកខ្យល់មកប៉ះពាល់ត្រូវឡើយ កាលដែលវិថីចិត្តកើតឡើង ឧបមាដូចខ្យល់ព្យុះមកអំពីទិសទាំង ៨ ធ្វើឱ្យខ្សែទឹកដែលស្មើនោះប្រែចាកប្រក្រតីទៅជារលកល្អក់សាត់ទៅដូច្នោះឯង ភវង្គចិត្តជាវិបាកជាតិ និងជាវិបាអព្យាកតៈដូចគ្នានឹងបដិសន្ធិចិត្ត មិនខុសភូមិ មិនខុសជាតិ មិនខុសហេតុ ថាបើបដិសន្ធិជាអហេតុកៈ ភវង្គក៏ជាអហេតុកៈ បើបដិសន្ធិជាឯកហេតុកៈ ជាទុហេតុកៈ ជាត្រៃហេតុកៈ ដូចគ្នានឹងចិត្តក្នុងសមាបត្តិវិថី ឯចិត្តក្នុងមហាសមាបត្តិវិថីនោះ មិនមានទីកំណត់ខណចិត្តឡើយ ចំណែកអ្នកដែលចូលកាន់ សមាបត្តិនោះបើលោកប្រាថ្នានឹងចូលកាន់សមាបត្តិណា អប្បនាចិត្តក៏អាចប្រព្រឹត្តនៅបានក្នុងសមា–បត្តិនោះប៉ុណ្ណោះ ហេតុនេះទើបឈ្មោះថា ភវង្គកិច្ច ។

៣–*អាវជ្ជនកិច្ច* ចិត្តដែលឱ្យសម្រេចកិច្ចកាន់ខ្សែភវង្គដាច់ អាចកើតឡើងក្នុងដើមនៃបញ្ចទ្វារាវជ្ជនវិថី និងមនោទ្វារាវជ្ជនវិថី ទើបឈ្មោះថា អាវជ្ជនកិច្ច ។

៤–*ទស្សនកិច្ច* ចក្ខុវិញ្ញាណឱ្យសម្រេចកិច្ច គឺឃើញនូវរូបារម្មណ៍ផ្សេងៗ ទើបឈ្មោះថា ទស្សនកិច្ច ។

៥–*សវនកិច្ច* សោតវិញ្ញាណឱ្យសម្រេចកិច្ច គឺស្តាប់នូវសទ្ទារម្មណ៍ផ្សេងៗ ទើបឈ្មោះថា សវនកិច្ច ។

៦–*ឃាយនកិច្ច* ឃានវិញ្ញាណឱ្យសម្រេចកិច្ច គឺស្រូបហិតនូវគន្ធារម្មណ៍ផ្សេងៗ ទើបឈ្មោះថា ឃាយនកិច្ច ។

៧–*សាយនកិច្ច* ជីវ្ហាវិញ្ញាណឱ្យសម្រេចកិច្ច គឺក្រេបជញ្ជក់យកនូវរសារម្មណ៍ផ្សេងៗ ទើបឈ្មោះថា សាយនកិច្ច ។

៨–*ផុស្សនកិច្ច* គឺកាយវិញ្ញាណឱ្យសម្រេចកិច្ច គឺពាល់ត្រូវនូវផោដ្ឋព្វារម្មណ៍ផ្សេង ៗ ទើបឈ្មោះថា ផុស្សនកិច្ច ។

៩–*សម្បដិច្ឆន្នកិច្ច* ចិត្តដែលឱ្យសម្រេចកិច្ច គឺទទួលយកនូវអារម្មណ៍ក្នុងទ្វារទាំង ៥ ទើបឈ្មោះថា សម្បដិច្ឆន្នកិច្ច ។

១០–*សន្តីរណកិច្ច* ចិត្តដែលឱ្យសម្រេចកិច្ច គឺពិចារណានូវអារម្មណ៍ក្នុងទ្វារទាំង ៥ ទើបឈ្មោះថា សន្តីរណកិច្ច ។

១០– *វោដ្ឋវនកិច្ច* ចិត្តដែលឱ្យសម្រេចកិច្ច គឺកិរិយាកំណត់នូវអារម្មណ៍មានរូប–ជាដើម ទើបឈ្មោះថា វោដ្ឋវនកិច្ច ។

១២–*ជវនកិច្ច* ចិត្តដែលឱ្យសម្រេចកិច្ច គឺសេព ឬសោយនូវអារម្មណ៍ជាកុសល ឬ អកុសល ឬអព្យាកតៈ ទើបឈ្មោះថា ជវនកិច្ច ។

១៣–*តទាលម្ពណកិច្ច* កិច្ចដែលស្រាវយក ឬតោងយកនូវអារម្មណ៍ដែលជវនសោយហើយនោះ ទើបឈ្មោះថា តទាលម្ពណកិច្ច ។

១៤– *ចុតិកិច្ច* ចិត្តដែលឱ្យសម្រេចកិច្ច គឺឃ្លាតចាកភពជាបច្ចុប្បន្ននេះទៅ ទើបឈ្មោះថា ចុតិកិច្ច ។

(ចិត្ត ៨៩ ឬ ១២១ នោះដ៏ប្រកបដោយចិត្ត ១៤ ចប់តែប៉ុណ្ណេះ )

ស្ថានបភេទរវាង ឬទីរបស់ចិត្តមាន ១០ គឺបដិសន្ធិស្ថាន ១ ភវង្គស្ថាន ១ អាវជ្ជន–ស្ថាន ១ បញ្ចវិញ្ញាណស្ថាន ១ សម្បដិច្ឆន្នស្ថាន ១ សន្តីរណស្ថាន ១ វោដ្ឋវនស្ថាន ១ ជវន–ស្ថាន ១ តទាលម្ពណស្ថាន ១ ចុតិស្ថាន ១ ។

សេចក្តីថា ត្រង់ពាក្យដែលហៅថាស្ថានៗនោះ លោកប្រាថ្នាយកត្រង់រវាងចិត្ត ដូច–យ៉ាងបដិសន្ធិចិត្តកើតក្នុងរវាងនៃចិត្តណា រវាងនៃចិត្តនោះឯង ឈ្មោះថាបដិសន្ធិស្ថាន ឯភវង្គចិត្ត និងអាវជ្ជនចិត្ត មានសេចក្តីអធិប្បាយប្រហែលគ្នាដូច្នេះដែរ បញ្ចវិញ្ញាណមានក្នុងរវាងនៃអាវជ្ជនៈ និងសម្បដិច្ឆន្នៈ សម្បដិច្ឆន្នៈមានក្នុងរវាងវិញ្ញាណ និងសន្តីរណៈ សន្តីរណៈមានក្នុងរវាងនៃសម្បដិច្ឆន្នៈ និងវោដ្ឋវនៈ វោដ្ឋវនៈមានក្នុងរវាងនៃសន្តីរណៈ និងជវនៈ ជវនៈមាន ៤ ស្ថាន គឺមានក្នុងរវាងនៃវោដ្ឋវនៈ និងតទាលម្ពណៈ ១ មានក្នុងរវាងនៃវោដ្ឋវនៈ និងភវង្គចិត្ត ១ មានក្នុងរវាងនៃមនោទ្វារាវជ្ជនៈ និងតទាលម្ពណៈ ១ មានក្នុងរវាងនៃមនោទ្វារាវជ្ជនៈ និងភវង្គចិត្ត ១ រួមជាជវនស្ថាន ៤ យ៉ាងដូច្នេះ ។

ជវនស្ថានទី ១ មានក្នុងរវាងនៃវោដ្ឋវនៈ និងតទាលម្ពណៈនោះ បានខាងជវនចិត្ត ដែលកើតក្នុងបញ្ចទ្វារាវជ្ជនវិថី ឈ្មោះថា អតិមហន្តារម្មណ៍ ។

ជវនស្ថានទី ២ មានក្នុងរវាងនៃវោដ្ឋវនៈ និងភវង្គចិត្តនោះ បានខាងជវនចិត្តដែល កើតក្នុងបញ្ចទ្វារវិថី ឈ្មោះថា មហន្តារម្មណ៍ ។

ជវនស្ថានទី ៣ មានក្នុងរវាងមនោទ្វារាវជ្ជនៈ និងតទាលម្ពណៈនោះបានខាងជវន– ដែលកើតក្នុងមនោទ្វារវិថី ឈ្មោះថា វិភូតារម្មណ៍ ។

ជវនស្ថានទី ៤ មានក្នុងរវាងមនោទ្វារាវជ្ជនៈ និងភវង្គចិត្តនោះ បានខាងជវនចិត្ត ដែលកើតក្នុងមនោទ្វារវិថី ឈ្មោះថា អវិភូតារម្មណ៍ ។

ម្យ៉ាងទៀតក្នុងអប្បនាវិថី និងមគ្គវិថី និងផលវិថីនោះ ជវនចិត្តក៏កើតក្នុងរវាង មនោទ្វារាវជ្ជនៈ និងភវង្គចិត្តដូចគ្នា ។

តទាលម្ពណៈមាន ២ ស្ថានគឺ តទាលម្ពណៈ មានក្នុងរវាងនៃជវនចិត្ត និងភវង្គចិត្ត ១ តទាលម្ពណៈ មានក្នុងរវាងនៃជវនចិត្ត និងចុតិចិត្ត ១ ។

តទាលម្ពណៈទី ១ ដែលមានក្នុងរវាងនៃជវនចិត្ត និងភវង្គចិត្តនោះ បានខាងតទា– លម្ពណចិត្តដែលកើតក្នុងបញ្ចទ្វារវិថី ឈ្មោះថា អតិមហន្តារម្មណ៍ ។

តទាលម្ពណៈទី ២ ដែលមានក្នុងរវាងនៃជវនចិត្ត និងចុតិចិត្តនោះ បានខាងតទា– លម្ពណចិត្តដែលកើតក្នុងមនោទ្វារវិថី ឈ្មោះថា វិភូតារម្មណ៍ ។ តទាលម្ពណៈទាំង ២ នេះ បានដល់សត្វដែលដល់នូវមរណភាព មានតទាលម្ពណៈជាមុខ ។

ចុតិស្ថានមាន ៤ កន្លែង គឺចុតិចិត្តមានក្នុងរវាងនៃតទាលម្ពណៈ និងបដិសន្ធិចិត្ត ១ ចុតិចិត្តមានក្នុងរវាងនៃជវនចិត្ត និងបដិសន្ធិចិត្ត ១ ចុតិចិត្តមានក្នុងរវាងនៃភវង្គចិត្ត និង បដិសន្ធិចិត្ត ១ ឯបដិសន្ធិចិត្តនោះចែកចេញជា ២ យកមករួមគ្នាជា ៤ កន្លែង ។

ចុតិស្ថានទី ១ គឺចុតិចិត្តដែលមានក្នុងរវាងនៃតទាលម្ពណៈនិងបដិសន្ធិចិត្តនោះមាន– សេចក្តីអធិប្បាយថា សត្វពួកខ្លះ កាលនឹងដល់នូវមរណាសន្នកាល ជវនចិត្តកើត ៥ ខណៈ

ហើយរលត់ផុតទៅ តទាលម្ពណចិត្តកើតឡើង ២ ខណៈ ហើយបដិសន្ធិទៅ សត្វចុតិដូច្នេះក៏មាន ។

ចុតិស្ថានទី ២ គឺចុតិចិត្តដែលមានក្នុងរវាងនៃជវនចិត្ត និងបដិសន្ធិចិត្តនោះថា សត្វ–ពួកខ្លះកាលដល់នូវមរណាសន្នកាល ជវនចិត្តកើតឡើង ៥ ខណៈហើយរលត់ទៅ ចុតិចិត្ត–កើតឡើងខណៈ ១ ហើយសត្វពួកនោះក៏មរណៈ ហើយបដិសន្ធិតទៅ សត្វចុតិដូច្នេះក៏មាន។

ចុតិស្ថានទី ៣ គឺចុតិចិត្តដែលក្នុរវាងនៃភវង្គចិត្ត និងបដិសន្ធិចិត្តនោះថា សត្វពួកខ្លះកាលនឹងដល់នូវមរណាសន្នកាល ជវនចិត្តកើតឡើង ៥ ខណៈហើយក៏រលត់ទៅ តទាលម្ពណចិត្តកើតឡើង ២ ខណៈ ហើយករលត់ទៅ ចិត្តក៏ធ្លាក់ចុះកាន់ខ្សែភវង្គ ចុតិចិត្ត–កើតឡើងខណៈ ១ សត្វពួកនោះក៏មរណៈ ហើយបដិសន្ធិតទៅ សត្វចុតិដូច្នេះក៏មាន ។

ចុតិស្ថានទី ៤ គឺបដិសន្ធិទាំង ២ កន្លែងនោះថា សត្វពួកខ្លះកាលនឹងដល់នូវមរណា–សន្នកាល ជវនចិត្តកើតឡើង ៥ ខណៈហើយរលត់ទៅ ចត្តិក៏ធ្លាក់ចុះកាន់ខ្សែភវភង្គ ចុតិចិត្តកើតឡើងខណៈ ១ សត្វពួកនោះក៏ដល់នូវមរណៈហើយបដិសន្ធិតទៅ សត្វចុះដូច្នេះក៏មាន រួមគ្នាជាចុតិស្ថាន ៤ កន្លែងដូច្នេះ ឯបដិសន្ធិស្ថាននោះមានក្នុងរវាងនៃចុតិចិត្ត និងភវង្គចិត្ត ចុតិចិត្តមួយអន្លើនឹងបដិសន្ធិចិត្តរៀងខណៈគ្នា មិនមានចិត្តដទៃមកកើតខណ្ឌរាំងឡើយ ។

***តទង្គស្ថានមាន ៦ គឺ :**

១–*ភវង្គចិត្ត* មានក្នុងរវាងនៃបដិសន្ធិចិត្ត និងមនោទ្វារាវជ្ជនៈ គឺភវង្គចិត្តដែលកើតផុតទៅ ហើយតបដិសន្ធិមក ។

២–*ភវង្គចិត្ត* មានក្នុងរវាងនៃជវនចិត្ត និងមនោទ្វារាវជ្ជនៈ គឺភវង្គចិត្តដែលកើតក្នុងជវនវារៈ មានអារម្មណ៍ជាមហន្តារម្មណ៍ ។

៣–*ភវង្គចិត្ត* មានក្នុងរវាងតទាលម្ពណៈ និងមនោទ្វារាវជ្ជន គឺភវង្គចិត្តដែលកើត–ក្នុងតទាលម្ពណវារៈ មានអារម្មណ៍ជាអតិមហន្តារម្មណ៍ ។

៤–*ភវង្គចិត្ត* មានក្នុងរវាងនៃវោដ្ឋវនៈ និងមនោទ្វារាវជ្ជនៈ គឺភវង្គចិត្តដែលកើត–ក្នុងវោដ្ឋវនវារៈ មានអារម្មណ៍ជាបរិត្តារម្មណ៍ ។

៥–*ភវង្គចិត្ត* ដែលមានក្នុងរវាងនៃជវនចិត្ត និងចុតិចិត្ត ថាបើសត្វមរណៈចុះត្រង់ទីនេះជាចុតិមុខភវង្គ អារម្មណ៍ជាមហន្តារម្មណ៍ ។

៦–*ភវង្គចិត្ត* ដែលមានក្នុងរវាងនៃតទាលម្ពណចិត្ត និងចុតិចិត្ត បើសត្វមានមរណៈចុះត្រង់ទីនេះជាចុតិមុខភវង្គដូចគ្នា តែអារម្មណ៍នោះជាអតិមហន្តារម្មណ៍ប្លែកគ្នាដូច្នេះ ។

***អាវជ្ជនស្ថាន ២ គឺ :**

១–*បញ្ចទ្វារាវជ្ជនៈ* មានក្នុងរវាងនៃភវង្គចិត្ត និងបញ្ចវិញ្ញាណ ។

២–*មនោទ្វារាវជ្ជនៈ* មានក្នុងរវាងនៃភវង្គចិត្ត និងជវនចិត្ត ។

(ស្ថានប្រភេទ ១០ ចប់ )

ចិត្ត ១៩ គឺសន្តីរណៈ ២ មហាវិបាក ៨ រូបាវចរវិបាក ៥ អរូបាវចរវិបាក ៤ រួមគ្នាជា ១៩ ចិត្ត ។ ចិត្តទាំង ១៩ នេះមានឈ្មោះថា ៣ គឺបដិសន្ធិកិច្ចជាកិច្ចសម្រាប់កាន់យកបដិសន្ធិ ១ ភវង្គកិច្ច ជាកិច្ចសម្រាប់រស់នៅ១ ចុតិកិច្ចជាកិច្ចសម្រាប់ឃ្លាតចេញចាកខន្ធ១ ។

ចិត្ត ២ គឺបញ្ចទ្វារាវជ្ជនៈ ១ មនោទ្វារាវជ្ជនៈ ១ មានឈ្មោះតែ ១ ថាអាវជ្ជនកិច្ច ជាកិច្ចសម្រាប់ពិចារណានូវអារម្មណ៍ ឬនឹកនូវអារម្មណ៍ក្នុងបញ្ចទ្វារ ឬមនោទ្វារ ១ ។

ទ្វិបញ្ចវិញ្ញាណ គឺវិញ្ញាណ ១០ ជាកុសល ៥ ជាអកុសល ៥ នោះមានឈ្មោះ ៥ គឺចក្ខុវិញ្ញាណ ឈ្មោះថាទស្សនកិច្ច ជាកិច្ចសម្រាប់ឃើញ ១, សោតវិញ្ញាណ ឈ្មោះថា–សវនកិច្ច ជាកិច្ចសម្រាប់ឮ ១,ឃានវិញ្ញាណ ឈ្មោះថាឃាយនកិច្ច ជាកិច្ចសម្រាប់ធុំ ១, ជីវ្ហាវិញ្ញាណ ឈ្មោះថាសាយនកិច្ច ជាកិច្ចសម្រាប់លិទ្ធជញ្ជប់ ១, កាយវិញ្ញាណ ឈ្មោះថាផុស្សនកិច្ច ជាកិច្ចសម្រាប់ផ្សព្វផ្សាយ ១ ។

សម្បដិច្ឆន្នចិត្ត ២ មានឈ្មោះថាសម្បដិច្ឆន្នកិច្ច ជាកិច្ចសម្រាប់ទទួលរងយកនូវ–អារម្មណ៍ក្នុងទ្វារទាំង ៥ ។

សន្តីរណចិត្ត ៣ ឈ្មោះថាសន្តីរណកិច្ច ជាកិច្ចសម្រាប់ពិចារណានូវអារម្មណ៍ក្នុង–ទ្វារទាំង ៥ ។

មនោទ្វារាវជ្ជនចិត្ត ឈ្មោះថាវោដ្ឋវនកិច្ច ជាកិច្ចសម្រាប់កំណត់នូវអារម្មណ៍ក្នុងទ្វារទាំង ៥ កាលបើកើតក្នុងបញ្ចទ្វារ ឈ្មោះថាវោដ្ឋវនៈ កាលបើកើតក្នុងមនោទ្វារ ឈ្មោះថាមនោទ្វារាវជ្ជនៈ មនោទ្វារាវជ្ជនៈ និងវោដ្ឋវនៈនេះ ស្ថិតនៅកន្លែងតែ ១ ជាមួយគ្នា ។

ចិត្តជាកុសលអកុសល កិរិយាឱ្យសម្រេចជាជវនកិច្ច ៥៥ គឺអកុសលជវន ១២ កាមាវចរជវន ៨ កាមាវចរជវនកិរិយាជវន ៨ ហសិតុប្បាទជវន ១ រួមគ្នាជាកាមាវចរជន ២៩, មហគ្គតជវន ១៨ លោកុត្តរជវន ៨ ទៀតរួមគ្នាជាជវន ៥៥ ឈ្មោះថាជវនកិច្ច ។

មាហាវិបាក ៨ សន្តីរណៈ ៣ រួមគ្នាជា ១១ ឈ្មោះថាតទាលម្ពណកិច្ច ជាកិច្ចសម្រាប់ទាញយកនូវអារម្មណ៍នោះ ។ តាមជវន បើជវនសេព ឬសោយនូវវត្ថុណាជាអារម្មណ៍ តទាលម្ពណៈក៏សំដៅយកនូវវត្ថុនោះមកជាអារម្មណ៍តាមគ្នា ។

ឧបេក្ខាសន្តីរណចិត្ត ២ ប្រកបដោយកិច្ច ៥ គឺបដិសន្ធិកិច្ច ១ ភវង្គកិច្ច ១ ចុតិកិច្ច ១ តទាលម្ពណកិច្ច ១ សន្តីរណកិច្ច ១ ។

មហាវិបាក ៨ មានកិច្ច ៤ គឺ បដិសន្ធិកិច្ច ១ ភវង្គកិច្ច ១ ចុតិកិច្ច ១ តទាលម្ពណកិច្ច ១ ។

មហគ្គតវិបាក ៩ មានកិច្ច ៣ គឺបដិសន្ធិកិច្ច ១ ភវង្គកិច្ច ១ ចុតិកិច្ច ១ ។

សោមនស្សសន្តីរណៈដែលជាកុសលវិបាកអហេតុកៈ ១ មានកិច្ច ២ គឺសន្តីរណកិច្ច ១ តទាលម្ពណកិច្ច ១៚

មនោទ្វារាជ្ជនចិត្ត ឱ្យសម្រេចកិច្ចក្នុងទ្វារទាំង ៥ មានកិច្ច ២ គឺវោដ្ឋវនកិច្ច ១ អាវជ្ជនកិច្ច ១ ។

ចិត្តដែលសល់នៅ ៦៨ ក្នុងចិត្តមួយៗ មានកិច្ចមួយៗ គឺជវនចិត្ត ៥៥ ឱ្យសម្រេចកិច្ចគ្រប់ជវន គឺលឿនទៅ ឬសោយនូវអារម្មណ៍ជាកិច្ច មនោធាតុតិកៈ ៣ គឺបញ្ចទ្វារាវជ្ជនៈ ឱ្យសម្រេចកិច្ចកាត់ខ្សែភវង្គកើតក្នុងដើមទ្វារវិថី ។ សម្បដិច្ឆន្នៈ ឱ្យសម្រេចកិច្ចទទួលរងនូវអារម្មណ៍ក្នុងទ្វារទាំង ៥ ទ្វិបញ្ចវិញ្ញាណ គឺវិញ្ញាណ ១០ មានកិច្ច ៥ គឺទស្សនកិច្ចៗ គឺកិរយា

មើល ១ សវនកិច្ចៗ គឺកិរិយាស្តាប់ ១ ឃាយនកិច្ចៗ គឺកិរិយាហិត ឬស្រូប ១ សាយនកិច្ចៗ គឺកិរិយាលិទ្ធ ជញ្ជក់ ១ ផុស្សនកិច្ចៗ គឺកិរិយាផ្សព្វផ្សាយ ១ ។

*បដិសន្ធាទយោ នាម　　កិច្ចភេទេន ចុទ្ទស*
*ទសធា ឋានភេទេន　　ចិត្តុប្បាទា បកាសិតា ។*
*អដ្ឋសដ្ឋី តថា ទ្វេ ច　　នវដ្ឋ ទ្វេ យថាក្កមំ*
*ឯកទ្វិតិចតុបញ្ច–　　កិច្ចដ្ឋានានិ និទ្ទិសេ ។*

សេចក្តីថា កិច្ចរបស់ចិត្តមាន ១៤ មានបដិសន្ធិកិច្ចជាដើម ស្ថានរបស់ចិត្តមាន ១០ មានបដិសន្ធិស្ថានជាដើម គឺព្រះសម្មាសម្ពុទ្ធទ្រង់ប្រកាសហើយ អ្នកប្រាជ្ញគប្បីសម្តែងឡើងនូវកិច្ច និងស្ថានដោយលំដាប់ ។

ចិត្តមានកិច្ច ១ មានស្ថាន ១ មាន ៦៨ ចិត្ត, ចិត្តមានកិច្ច ២ មានស្ថាន ២ មាន ២ ចិត្ត, ចិត្តមានកិច្ច ៣ មានស្ថាន ៣ មាន ៩ ចិត្ត, ចិត្តមានកិច្ច ៤ មានស្ថាន ៤ មាន ៨ ចិត្ត , ចិត្តមានកិច្ច ៥ មានស្ថាន ៥ មាន ២ ចិត្ត ។

ជវនចិត្ត ៥៥ ទ្វិបញ្ចវិញ្ញាណ គឺវិញ្ញាណ ១០ មនោធាតុតិកៈ ៣ ជា ៦៨ មានកិច្ច ១ មានស្ថាន ១ សោមនស្សសន្តីរណៈ ១ មនោទ្វារាវជ្ជនៈ ១ ទាំង ២ នេះមានស្ថាន ២ មហគ្គតវិបាក ៩ មានកិច្ច ៣ មានស្ថាន ៣ មហាវិបាក ៨ មានកិច្ច ៤ មានស្ថាន ៤ ឧបេក្ខា–សន្តីរណៈ ២ មានកិច្ច ៥ មានស្ថាន ៥ ។

(កិច្ចសង្គហៈ ១៤ ចប់ )

*** ទ្វារសង្គហៈ សង្គ្រោះដោយទ្វារមាន ៦ ប្រការគឺ :**

១–*ចក្ខុទ្វារ* ប្រសាទដែលជ្រាបសើមទៅក្នុងភូតរូប មានសណ្ឋានប្រមាណប៉ុនក្បាលចៃ តាំងនៅក្នុងកណ្តាលប្រស្រីខ្មៅទាំង ២ ។

២–*សោតទ្វារ* ប្រសាទរូបដែលជ្រាបសើមទៅក្នុងភូតរូប មានសណ្ឋានដូចវង់ចិញ្ចៀន តាំងនៅក្នុងប្រហោងត្រចៀកទាំង ២ ។

៣– *ឃានទ្វារ* ប្រសាទរូបដែលជ្រាបទៅក្នុងភូតរូប មានសណ្ឋានដូចជើងពពែ តាំងនៅក្នុងខ្ទង់ច្រមុះ ។

៤– *ជិវ្ហាទ្វារ* ប្រសាទរូបដែលជ្រាបទៅក្នុងភូតរូប មានសណ្ឋានដូចស្រទាប់ផ្កា–ឧប្បល តាំងនៅក្នុងកណ្តាលជិវ្ហា ។

៥– *កាយទ្វារ* ប្រសាទរូបដែលជ្រាបទៅសព្វកាយ វៀរលែងតែសក់ រោម ក្រចក និងធ្មេញ ដែលដុះផុតកាយ ។

៦– *មនោទ្វារ* គឺភវង្គបរិច្ឆេទ ភវង្គបរិច្ឆេទនោះ គឺកិច្ចដែលធ្វើផ្តាច់ខ្សែភវង្គ ហើយប្រែជាវិថីចិត្តដទៃផ្សេងៗ គឺហទយវត្ថុរូបនោះឯង ។

ចិត្ត ៤៦ កើតគ្រប់ទ្វារទាំង ៥ ក្នុងទ្វារមួយៗ មាន ៤៦ ៗ ដូចគ្នា ចក្ខុទ្វារ ៤៦ សោតទ្វារ ៤៦ ឃានទ្វារ ៤៦ ជិវ្ហាទ្វារ ៤៦ កាយទ្វារ ៤៦ ឯចិត្តទាំង ៤៦ ដែលកើតក្នុងទ្វារទាំង ៥ គឺ បញ្ចទ្វារាវជ្ជនៈ ១ ចក្ខុវិញ្ញាណ ២ សម្បដិច្ឆន្នៈ ២ សន្តីរណៈ ៣ វោដ្ឋវនៈ ១, កាមាវចរជវនចិត្ត ២៩ មហាវិបាក ៨ រួមជា ៤៦ ទាំង ៤៦ ចិត្តនេះកើតក្នុងចក្ខុទ្វារ ចំណែកឯសោតទ្វារ ឃានទ្វារ ជិវ្ហាទ្វារ ក៏ដូចគ្នា ដកចក្ខុវិញ្ញានចេញ យកសោតវិញ្ញាណ ឃានវិញ្ញណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ បញ្ចូលគ្រប់ៗទ្វារតាមលំដាប់ ក្នុងទ្វារមួយមាន–ចិត្ត ៤៦ ដូចគ្នា បើពោលរួបរួមទាំង ៥ ទ្វារ គឺលោកពោលថាចិត្ត ៥៤ ជាកាមាវចរកើតក្នុងទ្វារទាំង ៥ គឺទ្វេបញ្ចវិញ្ញាណ ១០ បញ្ចទ្វារាវជ្ជនៈ ១ វោដ្ឋវនៈ ១ តទាលម្ពណៈ ១១ សម្បដិច្ឆន្នៈ ២ កាមាវចរជវន ២៩ រួមជា ៥៤ ។

ទ្វេបញ្ចវិញ្ញាណ ១០ នោះចំពោះកើតតែក្នុងទ្វាររបស់ខ្លួន ទ្វារមួយៗមានចិត្ត ២ៗ គឺ កុសលវិញ្ញាណ ១ អកុសលវិញ្ញាណ ១ រួមទាំង ៥ ទ្វារត្រូវជា១០ ឈ្មោះទ្វេបញ្ចវិញ្ញាណ ៗ នេះ ឧបមាដូចជានាយកទោវារិក គឺអ្នកដែលនៅប្រចាំការក្នុងទ្វាររបស់ខ្លួនទាំង ៥ ឯចិត្ត ៤៦ នោះដូចជាលេខបញ្ជីរដែលគេកត់ចុះឈ្មោះកូនវេន សម្រាប់ចាត់ការតាមក្រសួង–របស់ខ្លួនក្នុងទ្វារទាំង ៥ ឯចិត្ត ៤៦ នេះអ្នកប្រាជ្ញគប្បីដឹងថាជាកាមាវចរចិត្តក្នុងបញ្ចទ្វារ–វិថី ។

ចិត្តដែលកើតក្នុងមនោទ្វារវិថីនោះមាន ៦៧ គឺ មនោទ្វារាវជ្ជនៈ ១ ជវនចិត្ត ៥៥ តទាលម្ពណចិត្ត ១១, ជវនចិត្ត ៥៥ នោះគឺកាមាវចរជវន ២៩ រូបាវចរជវន ១០ អរូបាវចរជវន ៨ លោកុត្តជវន ៨ រួមជា ៥៥ ជវន, តទាលម្ពណចិត្ត ១១ គឺមហាវិបាក ៨ សន្តីរណៈ ៣ ។

ចិត្ត ១៩ គឺឧបេក្ខាសន្តីរណៈ ២ មហាវិបាក ៨ មហគ្គវិបាក ៩ ឱ្យសម្រេចកិច្ច ៣ គឺ បដិសន្ធិកិច្ច ១ ភវង្គកិច្ច ១ ចុតិកិច្ច ១ ចិត្តទាំង ១៩ នេះឈ្មោះថាទ្វារវិមុត្ត ។

ជិនុំចិត្តទាំងឡាយ ៨៩ នោះ ចិត្ត ៣៦ គឺទ្វិបញ្ចវិញ្ញាណ ១០ មហគ្គតៈ ១៨ លោកុត្តរៈ ៨ ជាឯកទ្វារិកចិត្ត គឺជាចិត្តប្រព្រឹត្តទៅក្នុងទ្វារ ១ ។

មនោធាតុតិកចិត្ត ៣ គឺបញ្ចទ្វារាវជ្ជនៈ ១ សម្បដិច្ឆន្នៈ ២ ជាបញ្ចទ្វារិកចិត្ត គឺជាចិត្តប្រព្រឹត្តទៅក្នុងទ្វារទាំង ៥ ។

ចិត្ត ៣១ គឺសោមនស្សសន្តីរណៈ ១ វោដ្ឋវនៈ ១ កាមាវចរជវន ២៩ ជាឆទ្វារិកចិត្ត គឺជាចិត្តប្រព្រឹត្តទៅក្នុងទ្វារ ៦ ។

ចិត្ត ១០ គឺឧបេក្ខាសន្តីរណៈ ២ មហាវិបាក ៨ ជាឆទ្វារិកចិត្ត គឺជាចិត្តប្រព្រឹត្តទៅ–ក្នុងទ្វារទាំង ៦ ខ្លះ ជាទ្វារវិមុត្ត គឺជាចិត្តផុតចាកទ្វារខ្លះ ។

មហគ្គតវិបាក ៩ គឺរូបាវចរវបាក ៥ អរូបាវចរវិបាក ៤ ជាទ្វារវិមុត្ត ។

*ឯកទ្វារិកចិត្តានិ        បញ្ចឆទ្វារិកានិ ច*
*ឆទ្វារិកវិមុត្តានិ        វិមុត្តានិ ច សព្វថា ។*
*សត្តីសតិ តថា តីណិ        ឯកត្តឹស យថាក្កមំ*
*ទសធានវធា ចេតិ        បញ្ចធា បរិទីបយេ ។*

ចិត្ត ៨៩ ចែកចេញជា ៥ ចំណែក គឺចិត្តដែលកើតក្នុងទ្វារតែ ១ នោះមាន ៣៦ ចិត្តដែលកើតក្នុងទ្វារទាំង ៥ នោះ ៣ ចិត្តដែលកើតក្នុងទ្វារ ៦ នោះ ៣១ ចិត្តដែលកើតក្នុង–ទ្វារទាំង ៦ ខ្លះ ផុតចាកទ្វារទាំង ៦ ខ្លះ នោះ ១០ ចិត្តដែលផុតចាកទ្វារទាំង ៦ នោះ ៩ ។

(ទ្វារសង្គហៈ ៦ ចប់ )

**និងសម្តែងអារម្មណសង្គហៈតទៅ :**

*** អារម្មណសង្គហៈ សង្គ្រោះដោយអារម្មណ៍មាន ៦ ប្រការគឺ :**

១-*រូបារម្មណ៍* រូបទាំងពួងដែលមកប្រាកដដល់ចក្ខុបសាទ

២-*សទ្ទារម្មណ៍* សំឡេងទាំងពួងដែលមកប្រាកដដល់សោតបសាទ

៣-*គន្ធារម្មណ៍* ក្លិនទាំងពួងដែលមកប្រាកដដល់ឃានបសាទ

៤-*រសារម្មណ៍* រសទាំងពួងដែលមកប្រាកដដល់ជិវ្ហាបសាទ

៥-*ផោដ្ឋព្វារម្មណ៍* សម្ផស្សទាំងពួងដែលមកប្រាកដដល់កាយបសាទ

៦-*ធម្មារម្មណ៍* អារម្មណ៍ទាំង ៦ ដែលមកប្រាកដដល់មនោទ្វារ ឯធម្មារម្មណ៍នោះមាន ៦ គឺបសាទរូប ១ សុខុមរូប ១ ចិត្ត ១ ចេតសិក ១ និព្វាន ១ បញ្ញត្តិ ១ ។

ចិត្តដែលកើតក្នុងទ្វារទាំង ៥ នោះ កាន់យកបានតែអារម្មណ៍ ៥ ក្នុងបច្ចុប្បន្នមកជាអារម្មណ៍ មិនអាចកាន់អារម្មណ៍ ៥ ក្នុងអតីត ឬអនាគតមកជាអារម្មណ៍បានឡើយ ។

ចិត្តដែលកើតក្នុងមនោទ្វារនោះ អាចកាន់យកអារម្មណ៍ទាំង ៦ ក្នុងអតីត អនាគត បច្ចុប្បន្នមកជាអារម្មណ៍បានទាំងអស់ ។

ចិត្តដែលឈ្មោះថាទ្វារវិមុត្ត កើតផុតទ្វារទាំង ៦ នោះឱ្យសម្រេចកិច្ចជាបដិសន្ធិ ភវង្គ ចុតិ កាន់យកអារម្មណ៍ទាំង ៦ បានដោយសមគួរ ។

កាមាវចរជវន កើតក្នុងមរណាសន្នវិថី ថាបើអំពើជាតិមុននោះធ្លាប់កាន់យកវត្ថុអ្វី ឬរបស់អ្វីមកជាអារម្មណ៍រឿយៗ ចិត្តដែលបដិសន្ធិ ភវង្គ ចុតិក្នុងបច្ចុប្បន្នជាតិនេះ ក៏កាន់-យកនូវវត្ថុនោះ ឬរបស់នោះមកជាអារម្មណ៍ក្នុងភពដទៃ អារម្មណ៍ដែលជាមរណាសន្ន-ជវនក្នុងជាតិមុននោះ ជាបច្ចុប្បន្នក្តី ជាអតីតក្តី ជាបញ្ញត្តិក្តី ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា កម្ម កម្មនិមិត្ត គតិនិមិត្ត នោះឯង ។

ទ្វិបញ្ចវិញ្ញាណ ១០ មានចក្ខុវិញ្ញាណជាដើម អារម្មណ ៥ មានរូបារម្មណជាដើម ក្នុងទ្វារមួយៗមានអារម្មណ៍មួយៗ គឺរូបារម្មណ៍ ជាអារម្មណ៍របស់ចក្ខុវិញ្ញាណ សទ្ទារម្មណ៍

ជាអារម្មណ៍របស់សោតវិញ្ញាណ គន្ធារម្មណ៍ ជាអារម្មណ៍របស់ឃានវិញ្ញាណ រសារម្មណ៍ ជាអារម្មណ៍របស់ជិវ្ហាវិញ្ញាណ ផោដ្ឋព្វារម្មណ៍ ជាអារម្មណ៍កាយវិញ្ញាណ ។

ចំណែកខាងមនោធាតុតិកៈ ៣ នោះតោងយកអារម្មណប្បច្ច័យ ៥ ដែលកើតក្នុង–ទ្វារវិថីទាំង ៥ មកជាអារម្មណប្បច្ច័យគ្រប់ៗ ទ្វារវិថី ឯកាមាវចរវិបាកដែលសល់នៅ គឺ សន្តីរណៈ ៣ មហាវិបាក ៨ ហសិតុប្បាទ ១ ទ្វិបញ្ចវិញ្ញាណ ១០ មនោធាតុតិកៈ ៣ ជាចិត្ត ២៥ តែងស្រាវយកបានតែអារម្មណ៍ដែលជាកាមាវចរ និងអាចតោងយកអារម្មណ៍ដែល ជារូបាវចរ អរូបាវចរ លោកុត្តរមិនបានឡើយ ។

អកុសលចិត្ត ១២ និងញាណវិប្បយុត្តកុសលចិត្ត ៤ ញាណវិប្បយុត្តកិរិយាចិត្ត ៤ រួម ជា ២០ ចិត្តទាំង ២០ នេះជួនកាលមានអារម្មណ៍ជាកាមាវចរ ជួនកាលមានអារម្មណ៍ជា–រូបាវចរ និងអរូបាវចរ តែមិនអាចនឹងកាន់យកលោកុត្តរៈមកជាអារម្មណ៍បានឡើយ ។

កាមាវចរកុសលជាញាណសម្បយុត្ត ៤ អភិញ្ញាកុសល គឺបញ្ចមជ្ឈានកុសល ១ ចិត្ត ៥ នេះជួនកាលជារូបាវចរ ជាអរូបាវចរ ជាលោកុត្តរតែមិនអាចនឹងកាន់យកនូវអរហត្ត–មគ្គចិត្ត អរហត្តផលចិត្តមកជាអារម្មណ៍បានឡើយ ។

កាមាវចរកិរិយាជាញាណសម្បយុត្ត ៤ បញ្ចមជ្ឈានកិរិយា ១ វោដ្ឋវនៈ ១ ចិត្ត ៦ នេះ កាន់យកអារម្មណ៍បានគ្រប់ចំណែកមិនវៀរចំណែកណា ១ ឡើយ វិញ្ញាណញ្ចាយតនៈ ៣ នេវសញ្ញានាសញ្ញាយតនៈ ៣, ចិត្ត ៦ នេះកាន់យកមហគ្គតៈជាអារម្មណ៍ រូបាវចរចិត្ត ១៥ និងបឋមារូបចិត្ត ៣ តតិយារូបចិត្ត ជា ២១ ចិត្ត ២១ នេះកាន់យកបញ្ញត្តិជាអារម្មណ៍ លោកុត្តចិត្ត ៨ កាន់យកព្រះនិព្វានជាអារម្មណ៍ ។

*បញ្ចវីសតិបរិតម្ហិ ឆ ចិត្តានិ មហគ្គតេ*
*ឯកវីសតិ វោហារេ អដ្ឋ និព្វានគោចរេ ។*
*វីសានុត្តរមុត្តម្ហិ អគ្គមគ្គផលជ្ជិតេ*
*បញ្ច សព្វត្ថ ឆ ចេតិ សត្តធា តត្ថ សង្គហោ ។*

អធិប្បាយថា អារម្មណសង្គហៈនេះ សង្គ្រោះដោយចិត្ត ៧ ពួកគឺ ចិត្ត ២៥ មាន–កាមាវចរជាអារម្មណ៍ ចិត្ត ៦ មានមហគ្គតៈជាអារម្មណ៍ ចិត្ត ២១ មានបញ្ញត្តិជាអារម្មណ៍ ចិត្ត ៨ មាននិព្វានជាអារម្មណ៍ ចិត្ត ២០ វៀរចាកមគ្គចាកផល ចិត្ត ៥ យកវត្ថុទាំងពួងជាអារម្មណ៍បាន វៀរតែអរហត្តមគ្គ និងអរហត្តផល ចិត្ត ៦ យកវត្ថុទាំងពួងជាអារម្មណ៍មិនបាន ។

(អារម្មណសង្គហៈ ៦ ចប់ )

**នឹងសម្តែងក្នុងវត្ថុសង្គហៈតទៅ :**

វត្ថុសង្គហៈនោះគឺ សង្គ្រោះដោយវត្ថុ, វត្ថុមាន ៦ ប្រការគឺ ចក្ខុវត្ថុ ១ សោតវត្ថុ ១ ឃានវត្ថុ ១ ជិវ្ហាវត្ថុ ១ កាយវត្ថុ ១ ហទយវត្ថុ ១ជា ៦, វត្ថុទាំង ៥ ខាងដើមតាំងអំពិចក្ខុវត្ថុដរាបដល់កាយវត្ថុនោះ ប្រាថ្នាយកបសាទរូបជាទីកើតនៃទ្វិបញ្ចវិញ្ញាណ ក្នុងវត្ថុមួយៗ មានវិញ្ញាណកើតពីរៗ ៥ វត្ថុនោះជា ១០ វិញ្ញាណ ឯហទយវត្ថុនោះប្រាថ្នាយកទឹករក្សាបេះដូងជាទីកើតនៃចិត្ត  ៧៩ ចិត្ត ៧៩ នោះគឺ អកុសលចិត្ត ១២ សម្បដិច្ឆន្នចិត្ត ២ សន្តីរណចិត្ត ៣ អហេតុកកិរិយាចិត្ត ៣ កាមាវចរសោភណចិត្ត ២៤ រូបាវចរចិត្ត ១៥ អរូបាវចរចិត្ត ១២ លោកុត្តរចិត្ត ៨ រួមជា ៧៩ ។ ចិត្ត ៧៩ នោះកើតក្នុងហទយវត្ថុ គឺវត្ថុជាទីអាស្រ័យនូវនៃទឹករក្សាបេះដូង ឯវត្ថុទាំង ៦ នេះមានព្រមតែក្នុងកាមលោក ១១ គឺ អបាយភូមិ ៤ មនុស្ស ១ កាមាវចរ ៦ ក៏ក្នុងរូបព្រហ្មមានតែវត្ថុ ៣ គឺចក្ខុវត្ថុ ១ សោតវត្ថុ ១ ហទយវត្ថុ ១ ក្នុងអរូប–ព្រហ្មមិនមានវត្ថុទាំង ៦ មិនមានរូបពណ៌ សណ្ឋាន ប្រៀបដូខ្យល់ ដែលកើតពីកិរិយាបក់ដោយផ្លិតវាលវិជ្ជនី នឹងផ្លិតស្លឹកត្នោតបាកចាកពណ៌ និងសណ្ឋាន ។

វិញ្ញាណធាតុ ៥ អាស្រ័យបសាទវត្ថុ ៥ ហើយប្រព្រឹត្តទៅដោយលំដាប់បញ្ចទ្វារាវ–ជ្ជនៈ ១ សម្បដិច្ឆន្នៈ ២ ជា ៣ ឈ្មោះថាមនោធាតុតិកៈ អាស្រ័យនូវហទយវត្ថុទើបកេិតបានមិនបានអាស្រ័យនូវបសាទវត្ថុ ៥ នោះឡើយ មនោវិញ្ញាណធាតុមាន ៣០ គឺសន្តីរណៈ ៣ មហាវិបាក ៨ សោតាបត្តិមគ្គ ១ ហស្សនៈ ១ ទោសចិត្ត ២ រូបាវចរចិត្ត ១៥ ជា ៣០ អាស្រ័យហទយវត្ថុហើយទើបប្រព្រឹត្តទៅ ចិត្តដែលអាស្រ័យបសាទ ៥ ហទយវត្ថុ ១ មាន

៤៣ គឺទ្វិបញ្ចវិញ្ញាណ គឺវិញ្ញាណ ១០ មនោធាតុតិកៈ ៣ មនោវិញ្ញាណធាតុ ៣០ រួមជា ៤៣ ចិត្ត ៤២ គឺលោភមូល ៨ មោហមូល ២ មនោទ្វារាវជ្ជនៈ ១ មហាកុសល ៨ មហាកិរិយា ៨ អរូបកុសល ៤ អរូបកិរិយា ៤ លោកុត្តរ ៧ វៀរសោតបត្តិមគ្គ ១ រួមជា ៤២ ចិត្តទាំង ៤២ នេះអាស្រ័យបសាទរូបខ្លះ ហទយវត្ថុខ្លះ មិនអាស្រ័យខ្លះ ក៏គង់ប្រព្រឹត្តទៅបាន អរូប–វិបាក ៤ នោះមិនអាស្រ័យហទយវត្ថុឡើយ ក៏អាចប្រព្រឹត្តទៅបាន ។

ក្នុងកាមភព មានធាតុចិត្ត ៧ គឺចក្ខុវិញ្ញាណ ១ សោតវិញ្ញាណ ១ ឃានវិញ្ញាណ ១ ជិវ្ហាវិញ្ញាណ ១ កាយវិញ្ញាណ ១ មនោធាតុ ១ មនោវិញ្ញាណធាតុ ១ ធាតុចិត្តទាំង ៧ នេះអាស្រ័យវត្ថុ ៦ ។

ក្នុងរូបភព មានធាតុចិត្ត ៤ គឺចក្ខុវិញ្ញាណធាតុ ១ សោតវិញ្ញាណធាតុ ១ មនោធាតុ ១ មនោវិញ្ញាណធាតុ ១ ធាតុចិត្ត ៤ នេះ អាស្រ័យនូវវត្ថុ ៣ គឺចក្ខុបសាទ ១ សោតបសាទ ១ ហទយវត្ថុ ១ ។

ក្នុងអរូបភព មានតែមនោវិញ្ញាណធាតុចំណែក ១ ព្រោះហេតុមិនមានរូបក្ខន្ធដែលនឹងជាទីអាស្រ័យនៅនោះបាន ។

*តេចត្តាឡីស និស្សាយ ទ្វេចត្តាឡីស ជាយរេ*
*អនិស្សាយ ច និស្សាយ បាការុប្បា អនិស្សិតា ។*

ចិត្តអាស្រ័យបសាទ និងហទយវត្ថុ មាន ៤៣ ចិត្តអាស្រ័យបសាទ និងហទយវត្ថុខ្លះ មិនអាស្រ័យខ្លះ មាន ៤២ អរូបវិបាក ៤ មិនអាស្រ័យបសាទ និង ហទយវត្ថុឡើយ ក៏គង់កើតឡើងបាន ។

*ឥតិ អភិធម្មត្ថសង្គហេ*

*បកិណ្ណកសង្គហវិភាគោ នាម តតិយោ បរិច្ឆេទោ*

បរិច្ឆេទទី ៣ ឈ្មោះបកិណ្ណកសង្គហវិភាគ ក្នុងអភិធម្មត្ថសង្គហ ចប់តែប៉ុណ្ណេះហោង ។

# បរិច្ឆេទទី ៤

វិថីសង្គហវិភាគ

*ចិត្តុប្បាទានមិច្ចេវំ កត្វា សង្គហមុត្តមំ*
*ភូមិបុគ្គលភេទេន បុព្វាបរនិយាមិតំ ។*
*បវត្តិសង្គហំ នាម បដិសន្ធិប្បវត្តិយំ*
*បវក្ខាមិ សមាសេន យថាសម្ភវតោ កថំ ។*

សេចក្តីថា ខ្ញុំឈ្មោះអនុរុទ្ធាចារ្យ បានសម្តែងនូវសង្គហៈ គឺប្រមូលអត្ថយ៉ាងល្អិតនៃចិត្ត និងចេតសិកដូច្នេះ ហើយនឹងពោលនូវបវត្តិសង្គហៈជាកំណត់ខាងដើម និងខាងចុងនៃចិត្តដោយប្រភេទនៃភូមិ និងបុគ្គលក្នុងបដិសន្ធិកាល និងបវត្តិកាលដោយសង្ខេប ដ៏សមគួរដល់កិរិយាបង្កើតឡើងនៃចិត្ត ។

សួរថា ដែលនឹងចែកចិត្តដោយប្រភេទនៃភូមិ និងបុគ្គលនិងកំណត់ខាងដើមនិងខាងចុងនៃចិត្ត ក្នុងបដិសន្ធិកាល និងបវត្តិកាលនោះ តើនឹងចែកដូចម្តេច?

ឆ្លើយថា នឹងចែកចិត្តដោយប្រភេទនៃភូមិ និងបុគ្គលនិងកំណត់ខាងដើមនិងខាងចុងនៃចិត្ត ក្នុងបដិសន្ធិកាល និងបវត្តិកាលនោះ ដូចមានសេចក្តីតទៅនេះ

វិថីសង្គហៈ ពោលដោយឆក្កៈមួយមាន៦ ៗដូច្នេះគឺវត្ថុ៦ មានចក្ខុវត្ថុជាដើម ទ្វារ៦ មានចក្ខុទ្វារជាដើម អារម្មណ៍៦ មានរូបារម្មណ៍ជាដើម វិញ្ញាណ៦ ចក្ខុវិញ្ញាណជាដើម វិថី ៦ មានចក្ខុទ្វារវិថីជាដើម វិសយបវត្តិ ៦ មានអតិមហន្តារម្មណ៍ជាដើម ។

វិសយបវត្តិ កាលដែប្រព្រឹត្តទៅនៃអារម្មណ៍របស់ចិត្ត ដែលផុតចាកវិថីមានប្រភេទ ៣ គឺកម្ម១ កម្មនិមិត្ត១ គតិនិមិត្ត១ វត្ថុ ៦ អារម្មណ៍ ៦ ទាំង ៣ ឆក្កៈនេះបានពោលមកហើយក្នុងខាងដើម ពីនេះនឹងពោលនូវវិសយបវត្តិ ។ វិសយបវត្តិ គឺការដែលប្រព្រឹត្តទៅនៃ-អារម្មណ៍របស់ចិត្ត បណ្ឌិតគម្បីប្រកបដោយទ្វារវិថី និងវិញ្ញាណវិថី គប្បីដឹងថាកិច្ចដែល-ប្រព្រឹត្តនៃអារម្មណ៍របស់ចិត្តនោះមាន ៦ ប្រការគឺ អតិមហន្តារម្មណ៍ ១ មហន្តារម្មណ៍ ១ បរិត្តារម្មណ៍ ១ អតិបរិត្តារម្មណ៍ ១ វិភូតារម្មណ៍ ១ អវិភូតារម្មណ៍ ១ ។

អតិមហន្តារម្មណ៍ មហន្តារម្មណ៍ បរិត្តារម្មណ៍ អតិបរិត្តារម្មណ៍ ៤ អារម្មណ៍នេះ មានក្នុងវិញ្ញាណវិថី ៥, វិភូតារម្មណ៍ អវិភូតារម្មណ៍ ២ អារម្មណ៍នេះមានក្នុងមនោវិញ្ញា–ណវិថី ។

សួរថា ធ្វើដូចម្តេចទើបនឹងបានដឹងថាជាអារម្មណ៍ ប្រព្រឹត្តទៅក្នុងបញ្ចទ្វារវិថី មនោទ្វារវិថី ?

ឆ្លើយថា នឹងបានដឹងនូវអារម្មណ៍ក្នុងបញ្ចទ្វារវិថី និងមនោទ្វារវិថីនោះត្រូវដឹងខណចិត្តជាមុនសិន ទើបនឹងដឹងនូវអារម្មណ៍ទាំង ៦ នោះដោយងាយ ។

ឯខណចិត្តនោះ ត្រូវរាប់ខណចិត្តតូច ៣ គឺ ឧប្បាទខណៈ ១ ឋិតិខណៈ ១ ភង្គខណៈ ១ ។ ខណចិត្តតូច ៣ នេះជាខណចិត្តធំ ១ ខណចិត្តធំ ១៧ ជាអាយុរូបធម៌តែមួយ អធិប្បាយថា ចិត្តរលត់ ១៧ ដងទើបរូបរលត់ម្តង ។

សេចក្តីថា អារម្មណ៍ទាំងឡាយមានរូបារមណ៍ជាដើម មកផ្ទប់នឹងប្រសាទទាំងឡាយមានចក្ខុបសាទជាដើម ហើយក៏សម្រេចកិច្ចជាអារម្មណ៍នៃវិថីចិត្តនោះជួនកាលកន្លងភង្គ–ខណៈ ១ ខណៈក៏មាន ២ ខណៈ ៣ ខណៈក៏មាន ជួនកាលកន្លងទៅ ៤.៥.៦.៧.៨.៩ ខណៈក៏មាន ជួនកាលកន្លងទៅ ១០.១១.១២.១៣.១៤.១៥ ខណៈទៅ មិនបានដូចគ្នា សេចក្តីនេះនឹងលើកឡើងមកពោលក្នុងចក្ខុវិញ្ញាណវិថីជាមុន អធិប្បាយថា រូបារម្មណ៍មកផ្ទប់នឹងចក្ខុ–បសាទ ហើយនៅមិនបានជាអារម្មណ៍នៃវិថីចិត្តមុន កន្លងភង្គខណៈ ១ ហើយទើបជាភវង្គ–ចលនៈ គឺញ័រខ្សែភវង្គខណៈ ១ ហើយទើបជាភវង្គុបច្ឆេទ គឺដាច់ខ្សែភវង្គខណៈ១ លំដាប់នោះបឋមវិថីចិត្ត គឺបញ្ចទ្វារាវជ្ជនចិត្តកើតឡើង ១ ខណៈ នឹករកនូវអារម្មណ៍ក្នុងចក្ខុទ្វារ ហើយរលត់ទៅ លំដាប់នោះចក្ខុវិញ្ញាណកើតឡើង ១ ខណៈ ឃើញនូរូបនោះដឹងច្បាស់ថាជារូបារម្មណ៍ ហើយក៏រលត់ទៅ ទើបសម្បដិច្ឆន្នចិត្តកើតឡើង ១ ខណៈនឹករកនូវអារម្មណ៍ក្នុងចក្ខុទ្វារហើយរលត់ទៅ លំដាប់នោះ ចក្ខុវិញ្ញាណកើតឡើង១ ខណៈឃើញនូវរូបដឹងច្បាស់ថាជារូបារម្មណ៍ហើយរលត់ទៅ ទើបសម្បដិច្ឆន្នចិត្តកើតឡើង ១ ខណៈ ទទួលយក–នូវរូបារម្មណ៍នោះហើយក៏រលត់ទោ សន្តីរណចិត្ត កើតឡើង ១ ខណៈពិចារណាប្រៀប–

ធៀបនូវរូបារម្មណ៍ហើយក៏រលត់ទៅ វោដ្ឋវនចិត្តកើតឡើង ១ ខណៈកំណត់កត់ត្រានូវរូបារម្មណ៍នោះហើយក៏រលត់ទៅ តាមលំដាប់គ្នា តពីនោះមក ជនិកាមាវចរជវន ២៩ កាមាវចរជវនណាមួយ មានបច្ច័យបានហើយ ទើបកើតឡើងសោយអារម្មណ៍នោះដឹង–ច្បាស់ថា ធំ តូច គ្រោត គ្រាត ល្អិត អាក្រក់ ល្អជាដើម ហើយក៏រលត់ទៅ ៗ ហើយកើត–ឡើងទៀតដល់ ៧ ខណៈទើបរលត់ទៅអស់ ទើបតទាលម្ពណចិត្តកើតឡើង ២ ខណៈតោងឬទាញយកនូវរូបារម្មណ៍តាមចវនចិត្តនោះ ហើយក៏រលត់ទៅ កាលវិថិចិត្តកើតរៀដល់តទាលម្ពណៈហើយ ចិត្តក៏ធ្លាក់ចុះកាន់ខ្សែភវង្គ ៗ ក៏រៀបរៀងនៅជាប្រក្រតីធម្មតា សេចក្តីថា កាលណារូបារម្មណ៍មកប្រាកដដល់ចក្ខុទវារវិថីហើយ មានអតីតភវង្គខណៈ ១ ភវង្គ–ចលនខណៈ ១ ភវង្គុប្បច្ឆេទខណៈ ១ ជា ៣ ខណៈកើតឡើង ហើយក៏រលត់ទៅ ទើបវិថីចិត្តកើតឡើងតាមលំដាប់ ឯវិថីចិត្តនោះមាន ៧ ប្រការគឺ បញ្ចទ្វារាវជ្ជនវិថីខណៈ ១ ចក្ខុ–វិញ្ញាណវិថីខណៈ ១ សម្បដិច្ឆន្នវិថីខណៈ ១ សន្តីរណវិថីខណៈ ១ វោដ្ឋវនវិថីខណៈ ១ ជវនវិថីខណៈ ៧ តទាលម្ពណវិថីខណៈ ២ រាប់ឈ្មោះវិថីចិត្តបាន ៧ វិថី រាប់ឈ្មោះខណ–ចិត្តបាន ១៤ ខណៈ ទើបយកភវង្គ ៣ គឺ អតីតភវង្គ ១ ភវង្គចលនៈ ១ ភវង្គុបច្ឆេទ ១ មកបញ្ចូលគ្នា ទើបបានជាខណចិត្ត ១៧ បើរូបារម្មណ៍ជាបច្ចុប្បន្ននោះមកតាំងនៅគ្រប់ខណ–ចិត្តទាំង ១៧ ដូច្នេះហើយក៏ឈ្មោះថា *អតិមហន្តារម្មណ៍* ។

ថាបើរូបមកប្រាកដដល់ចក្ខុបសាទ ហើយនៅមិនទាន់បានជាអារម្មណ៍នៃវិថីចិត្តជាដំបូង អតីតភវង្គ គឺការដែលកន្លងខ្សែភវង្គទៅដល់ ២ ខណៈ ៣ ខណៈទើបកើតភវង្គ–ចលនៈ គឺខ្សែញ័រភវង្គចូលទៅ ១ ខណៈហើយជាភវង្គុបច្ឆេទ គឺដាច់ខ្សែភវង្គ ១ ខណៈ ក៏វិថីចិត្តកើតឡើងតាមលំដាប់ គឺបញ្ចទ្វារាវជ្ជនៈ ១ ចក្ខុវិញ្ញាណ ១ សម្បដិច្ឆន្នៈ ១ សន្តីរណៈ ១ វោដ្ឋវនៈ ១ ជវន ៧ ខណៈ ហើយចិត្តក៏ធ្លាក់ចុះកាន់ខ្សែភវង្គ តទាលម្ពណៈមិនបានកើតរៀងលំដាប់គ្នា រូបារម្មណ៍ដូច្នេះថា *មហន្តារម្មណ៍* ។

បើរូបមកប្រាកដដល់ចក្ខុបសាទ ហើយនៅមិនបានជាអារម្មណ៍នៃវិថីចិត្តមុនអតីត–ភវង្គ គឺកិច្ចដែលកន្លងខ្សែភវង្គទៅ ៤ ខណៈ ៥.៦.៧.៨.៩ ខណៈខ្លះ ទើបកើតភវង្គចលនៈ

គឺញ៉័រខ្សែភវង្គចូលទៅ ១ ខណៈ ហើយភវង្គុបច្ឆេទ គឺដាច់ខ្សែភវង្គ ១ ខណៈ ទើបវិថីចិត្ត កើតឡើង គឺបញ្ចទ្វារាវជ្ជនៈ ១ ចក្ខុវិញ្ញាណ ១ សម្បដិច្ឆន្នៈ ១ សន្តីរណៈ ១, ៤ វិថីនេះកើត មួយខណៈៗ ចំណែកខាងវោដ្ឋវនវិថីនោះកើតឡើង ១ ខណៈខ្លះ គឺមានតែឧប្បាទខណៈ ឯ ឋិតិខណៈមិនមានឡើយ គឺអារម្មណ៍មិនតាំងនៅបានហើយធ្លាក់ចុះកាន់ខ្សែភវង្គជវនវិថីមិន អាចកើតឡើងបាន រូបារម្មណ៍ដូច្នេះឈ្មោះថា *បរិត្តារម្មណ៍* ។

បើរូបមកប្រាកដដល់ចក្ខុបសាទ នៅទាន់បានជាអារម្មណ៍ នៃវិថីចិត្តមុនអតីតភវង្គ គឺ កន្លងភវង្គទៅដល់ ១០ ខណៈដរាបដល់ ១៥ ខណៈ ទើបមានភវង្គចលនៈ ១ ខណៈខ្លះ ២ ខណៈ ខ្លះ ហើយភវង្គុបាតគឺ ចិត្តធ្លាក់ចុះកាន់ខ្សែភវង្គ រូបារម្មណ៍មានកម្លាំងទន់ឱ្យកើតបាន តែភវង្គចលនៈ ១ ខណៈខ្លះ ២ ខណៈខ្លះ ដូច្នេះឈ្មោះថា *អតិបរិត្តារម្មណ៍* ។

វិថីនៃអតិមហន្តារម្មណ៍ លោកហៅថា *តទាលម្ពណវារៈ* ។

វិថីនៃមហន្តារម្មណ៍ លោកហៅថា *ជវនវារៈ* ។

វិថីនៃបរិត្តារម្មណ៍ លោកហៅថា *វោដ្ឋវនវារៈ* ។

វិថីនៃអតិបរិត្តារម្មណ៍ លោកហៅថា *មោឃវារៈ* ។

វិញ្ញាណវិថី ៥ គឺចក្ខុវិញ្ញាណវិថី សោតវិញ្ញាណវិថី ឃានវិញ្ញាណវិថី ជិវ្ហាវិញ្ញាណ វិថី កាយវិញ្ញាណវិថី វិថីទាំង ៥ នេះក្នុងវិថីមួយ ៗ មានអារម្មណ៍ ៥ ដូចៗ គ្នាទាំងអស់ កាមាវចរចិត្តទាំង ៥៤ តែងកើតក្នុងបញ្ចវិញ្ញាណវិថីនេះឯង ។

( វិថីចិត្តក្នុងទ្វារទាំង ៥ ចប់ )

**សម្តែងសេចក្តីក្នុងមនោទ្វារវិថីតទៅ :**

ចិត្ត ៣៥ កើតក្នុងមនោទ្វារវិថីតែម្យ៉ាង គឺរូបាវចរចិត្ត ១៥ អរូបាវចរចិត្ត ១២ និង លោកុត្តរចិត្ត ៨ រួមគ្នាជា ៣៥ អារម្មណ៍ក្នុងមនោវិញ្ញាណវិថីដែលជាកាមាវចរនោះមាន ២ យ៉ាងគឺ វិភូតារម្មណ៍ ១ អវិភូតារម្មណ៍ ១ ។

សេចក្តីថា កាលធម្មារម្មណ៍ មកប្រាកដដល់មនោទ្វារ ហើយជាភវង្គចលនៈ គឺញ៉័រ– ខ្សែភវង្គចូលទៅ ១ ខណៈ មនោទ្វារាវជ្ជនៈកើតឡើង ១ ខណៈ នឹករកនូវអារម្មណ៍ក្នុង–

មនោទ្វារ ហើយរលត់ទៅ លំដាប់នោះ កាមាវចរជវនកើតឡើង ៧ ខណៈ ហើយរលត់ទៅ តទាលម្ពណៈកើតឡើង ២ ខណៈ ទាញតោងយកនូវអារម្មណ៍របស់កាមាវចរជវនហើយ-រលត់ទៅ ចិត្តក៏ធ្លាក់ចុះកាន់ខ្សែភវង្គ ធម្មារម្មណ៍បានវិថីចិត្តដូច្នេះឈ្មោះថា *វិភូតារម្មណ៍* ។

បើញ័រខ្សែភវង្គ ដាច់ខ្សែភវង្គ ហើយមនោទ្វារាវជ្ជនៈកើតឡើង ១ ខណៈ កាមា-វចរជវនកើតឡើង ៧ ខណៈ ហើយចិត្តក៏ធ្លាក់ចុះកាន់ខ្សែភវង្គ តទាលម្ពណចិត្តមិនអាច-កើតឡើងបាន ធម្មារម្មណ៍បានវិថីចិត្តដូច្នេះឈ្មោះថា *អវិភូតារម្មណ៍* ។

ក៏ក្នុងមនោវិញ្ញាណវិថីជាកាមវចរនេះរាប់ឈ្មោះរបស់វិថីចិត្តបាន ៣ រាប់ខណចិត្ត បាន ១០ ខណៈ គឺមនោទ្វារាវជ្ជនខណៈ ១ ជវន ៧ ខណៈ តទាលម្ពណៈ ២ ខណៈ រួមជា-វិថីចិត្តបាន ១ ខណចិត្តបាន ១០ ។

*វិថី ចិត្តានិ តីណេវ　　　ចិត្តុប្បាទា ទសេរិតា*
*វិត្ថារេន បនេត្ថក-　　　ចត្តាឡីស វិភាវយេ ។*

សេចក្តីថា វិថីចិត្ត ៣ ខណចិត្ត ១០ ព្រះសម្មាសម្ពុទ្ធសម្តែងហើយអំពីកិរិយាដែលនឹង កើតឡើងនៃចិត្ត បណ្ឌិតគប្បីសម្តែងនូវចិត្ត ៤១ ឱ្យឃើញច្បាស់ដោយពិស្តារដោយ-បការនេះ ។

(បរិត្តជវនវារៈ ចប់ )

ក្នុងអប្បនាជវនវារៈនោះ ប្រភេទនៃវិភូតារម្មណ៍ និងអវិភូតារម្មណ៍ទាំង ២ នេះមិន មាន តទាលម្ពណចិត្តមិនកើតក្នុងអប្បនាវិថីឡើយ ក្នុងដើមអប្បនាវិថីនោះ មនោទ្វារាវជ្ជនៈ កើតឡើង ១ ខណៈ ហើយរលត់ទៅ លំដាប់នោះ កាមាវចរជវនចិត្ត ៨ កាមាវចរជវន-ឯណាមួយ បានឱកាសកើតឡើងឱ្យសម្រេចកិច្ចជាជវន ជួនកាលកើតឡើង ៤ ខណៈ ជួន-កាលកើតឡើង ៣ ខណៈ តាមអភិនីហាររបស់បុគ្គលដែលជាទន្ធាភិញ្ញ ឬខិប្បាភិញ្ញាហើយ រលត់ទៅ បើអ្នកប្រតិបត្តិនេះជាទន្ធាភិញ្ញា គឺត្រាស់ដឹងយឺតយូរ ញាណសម្បយុត្តកាមាវចរ ជវនកើតឡើង ៤ ខណៈ ជាបរិកម្មជវនខណៈ ១ ឧបចារជវនខណៈ១ អនុលោមជវនខណៈ ១ គោត្រភូជវនខណៈ១ បើអ្នកប្រតិបត្តិនេះជាខិប្បាភិញ្ញា គឺត្រាស់ដឹងឆាប់រហ័ស ញាណ-

សម្បយុត្តកាមាវចរជវនកើតឡើង ១ ខណៈជាឧបចារជវនខណៈ១ ជាអនុលោមជវនខណៈ ១ ជាគោត្រភូជវនខណៈ ១ ជវនកើតឡើង ៣ ខណៈខ្លះ ៤ ខ្លះ ដូច្នេះហើយក៏រលត់ទៅ លំដាប់នោះ ជិនុំមហគ្គតជវន និងលោកុត្តរជវន ២៦ នោះ ជវនឯណាមួយយាងចុះកាន់-អប្បនាវិថីក្នុងខណៈទី ៤ ឬទី ៥ ខាងមុខអំពីគោត្រភូជវននោះដោយអំណាចដ៏សមគួរដល់អភិនីហារនៃបុគ្គល តពីនោះទៅ ចិត្តក៏ធ្លាក់ចុះកាន់ខ្សែភវង្គក្នុងទីបំផុតនៃអប្បនាឈាន ។

ថាបើអប្បនាវិថីនោះ ជាមគ្គវិថី ខណចិត្តត្រង់បរិកម្មជវនទី ១ មានអាចកំចាត់បង់នូវកិលេសដ៏គ្រោតគ្រាតបាន ឧបចារជវ៍នទី ២ អាចកំចាត់បង់នូវកិលេសយ៉ាងកណ្តាលបាន អនុលោមជវនទី ៣ អាចកំចាត់បងនូវកិលេសយ៉ាងល្អិតបាន គោត្រភូជវនទី ៤ អាចបើក-នូវចន្លោះឱ្យឃើញនូវព្រះនិព្វាន ដូចបុរសដែលមានចក្ខុល្អឃើញនូវមណ្ឌលនៃព្រះច័ន្ទដ៏-បរិសុទ្ធ គោត្រភូជវននោះតែងឱ្យសញ្ញាដល់មគ្គជវន ៗ ក៏មានព្រះនិព្វានជាអារម្មណ៍ មិន-បានឈោងតោងយកនូវកិលេសដែលខ្លួនគប្បីលះបង់នោះមកជាអារម្មណ៍ឡើយ ព្រោះគោត្រភូជវនឱ្យសញ្ញា ហើយសេចក្តីត្រង់នេះប្រៀបដូចជានាយខ្មាន់ធ្នូដ៏ឆ្លាសក្នុងវិធីបាញ់ គេយកសម្ពត់មករុំបិទភ្នែកឱ្យងងឹត ហើយគេឱ្យឡើងជាន់លើក្តារយន្តដែលវិល ហើយឱ្យ-បាញ់នូវក្តារចន្លោងដែលគេតម្រួតគ្នា១រយជាន់ ហើយគេឆ្លោងពីចម្ងាយតែម្តង ក៏ត្រូវបែកជាឯកប្បហារ ព្រោះកូនសិស្សគោះក្តារនោះឱ្យជាសញ្ញាដល់អ្នកបាញ់ដូច្នេះឯង មគ្គកើត-ឡើងខណៈ ១ ហើយក៏រលត់ទៅ ចិត្តនៅមិនទាន់ធ្លាក់ចុះកាន់ខ្សែភវង្គ ផលចិត្តកើតឡើង ២ ខណៈខ្លះ ៣ ខណៈខ្លះ តាមសមគួរដល់អភិនីហារនៃបុគ្គល ថាបើបុគ្គលជាទន្ធាភិញ្ញា ផលចិត្តកើតឡើង ២ ខណៈ បើជាខិប្បាភិញ្ញា ផលចិត្តកើតឡើង ៣ ខណៈទើបធ្លាក់ចុះកាន់ខ្សែភវង្គ ។

( មគ្គវិថី ចប់ )

ក្នុងអប្បនាវិថីមុននឹងបានលោកិយឈាននោះ ផ្សេងគ្នានឹងមគ្គវិថីត្រង់កន្លែងដែលបានឈាន លោកដែលនឹងបានមគ្គផលរហូតឡើងទៅនេះ បរិកម្មជវ៍ន និងឧបចារជវន និងអនុលោមជវន សម្លាប់កិលេសឡើងទៅជាលំដាប់ គោត្រភូជវនអាចនឹងបើកឱកាសឱ្យ

ឃើញនូវព្រះនិព្វាន មគ្គចិត្តកើតឡើងខណៈ ១ ហើយរលត់ទៅ ចិត្តក៏តាំងនៅមិនធ្លាក់ចុះកាន់ខ្សែភវង្គឡើយ ទើបផលចិត្តកើតឡើង ២ ខណៈខ្លះ ៣ ខណៈហើយធ្លាក់ចុះកាន់ខ្សែភវង្គ ។

ចំណែកខាងអ្នកដែលនឹងបានឈានជាលោកិយនោះ បរិកម្មជវន ឧចារជវន អនុ–លោមជវន មិនបានសម្លាប់កិលេសឯណាមួយឡើយ បានគ្រាន់តែរំងាប់កិលេសឱ្យល្មមបានឈានខណចិត្ត ១ ហើយចិត្តក៏ជាភវង្គបាត គឺចិត្តធ្លាក់ចុះកាន់ខ្សែភវង្គ មិនអាចនឹងឡើងរហូតទៅ កាន់មគ្គ និងផលឡើយ បើបរិកម្មជវន ឧបចារជវន អនុលោមជវន ប្រកប — ដោយសោមនស្សវេទនា អ្នកនោះក៏បានឈានជាចតុកន័យកើតឡើង បើបរិកម្មជវន ឧបចារជវន អនុលោមជវន ប្រកបដោយឧបេក្ខាវេទនា អ្នកនោះក៏បានឈានបញ្ចកន័យ ។

ឯឈានជាចតុកន័យ និងបញ្ចកន័យនោះ បណ្ឌិតគប្បីដឹងដូច្នេះថា បុថុជ្ជន ឬសេក្ខ–បុគ្គលដែលនឹងបានឈានជាចតុកន័យនោះ មានចិត្តជាសោមនស្សញាណសម្បយុត្ត កាមា–វចរកុសលកើតឡើងជាបរិកម្មជវន ឧបចារជវន អនុលោមជវន គោត្រភូជវន បើនឹងបានឈានជបញ្ចកន័យវិញនោះ មានចិត្តជាឧបេក្ខាញាណសម្បយុត្ត កាមាវចរកុសលកើតឡើងជាបរិកម្មជវន ឧបចារជវន អនុលោមជវន គោត្រភូជវន ។

ចំណែកខាងព្រះខីណាស្រពនោះ បើសោមនស្សញាណសម្បយុត្ត កាមាវចរកិរិយាកើតឡើងជាបរិកម្មជវន ឧបចារជវន អនុលោមជវន គោត្រភូជវន ហើយលោកក៏ចូលចូលកាន់ឈានជាចតុកន័យ បើឧបេក្ខាញាណសម្បយុត្ត កាមាវចរកិរិយាកើតឡើងជាបរិកម្មជវន ឧបចារជវន អនុលោមជវន គោត្រភូជវន លោកក៏ចូលកាន់ឈានជាបញ្ចក–ន័យ បណ្ឌិតគប្បីដឹងថា សោតាបត្តិផលឈាន សកទាគាមិផលឈាន មានញាណសម្បយុត្ត–កាមាវចរកុសល ជាទីទទួលរងឱ្យសម្រេចកិច្ចជាបរិកម្មជវន ឧបចារជវន អនុលោមជវនគោត្រភូជវន ដោយប្រក្រតីធម្មតាដូច្នេះ ។

ចំណែកព្រះអរហត្តផលឈាននោះ មានញាណសម្បយុត្តកាមវចរកិរិយាជាទីទទួលរងឱ្យសម្រេចកិច្ចជាបរិកម្មជវន ឧបចារជវន អនុលោមជវន គោត្រភូជវន ដូចបានពោល

មកហើយនេះឯង ។

ឯប្រភេទអប្បនាចិត្ត ៥៨ ដូចមានបាលីថាដូច្នេះ

*ទ្វត្តឹស សុខាញ្ញម្ហា ទ្វាទសោបេក្ខកា បរំ*

*សុខិតក្រិយាតោ អដ្ឋ ឆ សម្ភោន្តិ ឧបេក្ខកា ។*

សេចក្តីថា អប្បនាចិត្តប្រកបដោយសោមនស្ស ៣២ កើតខាងមុខអំពីសោមនស្ស-ញាណសម្បយុត្ត ក្នុងសន្តាននៃបុថុជ្ជន និងសេក្ខបុគ្គល គឺបឋមជ្ឈានកុសល ១ ទុតិយជ្ឈាន-កុសល ១ តតិយជ្ឈានកុសល ១ ចតុត្ថជ្ឈានកុសល ១ រួមជា ៤ ក្នុងរូបាវចរជ្ឈាន សោត-បត្តិមគ្គឈាន ៤ សោតាបត្តិផលឈាន ៤ សកទាគាមិមគ្គឈាន ៤ សកទាគាមិផលឈាន ៤ អនាគាមិមគ្គឈាន ៤ អនាគាមិផលឈាន ៤ អរហត្តមគ្គឈាន ៤ រួមគ្នាជា ៣២ ។

អប្បនាចិត្តប្រកបដោយឧបេក្ខា ១២ កើតឡើងខាងមុខអំពីឧបេក្ខាញាណសម្បយុត្ត កើតក្នុងសន្តាននៃបុថុជ្ជន និងសេក្ខបុគ្គល គឺរូបាវចរកុសល ៥ អរូបាវចរកុសល ៤ សោតាបត្តិមគ្គ ១ សកទាគាមិមគ្គ ១ អនាគាមិមគ្គ ១ រួម ១២ ។

អប្បនាចិត្ត ៨ មានក្នុងមគ្គចិត្ត ផលចិត្ត មានចំពោះក្នុងសន្តាននៃអសេក្ខបុគ្គល គឺព្រះខីណាស្រព កើតខាងមុខអំពីសោមនស្សញាណសម្បយុត្តកាមាវចរកិរិយា គឺបឋមជ្ឈាន-កិរិយា ១ ទុតិយជ្ឈានកិរិយា ១ តតិយជ្ឈានកិរិយា ១ ចតុត្ថជ្ឈានកិរិយា ១ រួមជា ៤ ក្នុង-រូបាវចរផល ៤ រួមជា ៨ ។

អប្បនាសមាធិចិត្តប្រកបដោយឧបេក្ខាក្នុងសន្តាននៃព្រះខីណាស្រព មាន ៦ កើតខាងមុខអំពីឧបេក្ខាញាណសម្បយុត្ត កាមវចរកិរិយា គឺបញ្ចមជ្ឈានកិរិយាអរហត្តផលចិត្ត ១ បញ្ចមជ្ឈានកិរិយារូបាវចរចិត្ត ១ បញ្ចមជ្ឈានកិរិយារអរូបាវចរចិត្ត ៤ រួមជា ៦ ។

*បុថុជ្ជនានំ សេក្ខានំ កាមបុញ្ញតិហេតុតោ*

*តិហេតុកាមក្រិយាតោ វីតរាគានមប្បនា ។*

សេចក្តីថា អប្បនាសមាធិចិត្តកើតដល់បុថុជ្ជន និងសេក្ខបុគ្គលនោះគឺកើតអំពីកាមា-វចរកុសលញាណសម្បយុត្តត្រៃហេតុ អប្បនាសមាធិចិត្តកើតដល់វីតរាគបុគ្គលនោះ គឺកើត

អំពីកាមាវចរកិរិយាញាណសម្បយុត្តត្រៃហេតុ អប្បនាសោមនស្សក្នុងសន្តានបុថុជ្ជន និងសេក្ខបុគ្គល ៣២ អប្បនាឧបេក្ខាក្នុងសន្តានបុថុជ្ជន និងសេក្ខបុគ្គល ១២ អប្បនាសោមនស្សក្នុងសន្តានអសេក្ខបុគ្គល ៨ អប្បនាឧបេក្ខាក្នុងសន្តានអសេក្ខបុគ្គល ៦ រួមជាអប្បនា ៥៨ ។

( សម្តែងក្នុងវិថីចិត្តប្បវត្តិ ចប់តែប៉ុណ្ណោះ )

នឹងសម្តែងនូវកាមាវចរវិបាកចិត្តដែលប្រព្រឹត្តទៅតាមអារម្មណ៍ ៣ គឺ អនិដ្ឋារម្មណ៍ ១ ឥដ្ឋារម្មណ៍ ១ អតិឥដ្ឋារម្មណ៍ ១ រួមជាអារម្មណ៍ ៣ សេចក្តីថា កាលបើអនិដ្ឋារម្មណ៍ គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ដែលជាអកុសលវិបាកកើតអំពីបាបមកប្រាកដដល់បសាទទាំង ៥ ហើយវិថីចិត្ត ៧ គឺបញ្ចទ្វារាវជ្ជនៈ ១ បញ្ចវិញ្ញាណ ១ សម្បដិច្ឆន្នៈ ១ សន្តីរណៈ ១ វោដ្ឋវនៈ ១ ជវនៈ ១ តទាលម្ពណៈ ១ រួមជាវិថីចិត្ត ៧ ជាអកុសលវិបាកកើតឡើងរងយកអារម្មណ៍ដោយលំដាប់គ្នាជាប្រក្រតីធម្មតា កាលបើ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ឥដ្ឋារម្មណ៍គឺជាកុសលវិបាកកើតអំពីបុណ្យមកប្រាកដដល់បសាទទាំង ៥ ហើយវិថីចិត្តទាំង ៧ ដែលជាកុសលវិបាកកើតអំពីបុណ្យ ក៏កើតទទួលរងយកអារម្មណ៍ដោយលំដាប់គ្នាជាប្រក្រតីធម្មតា ។

កាលអតិឥដ្ឋារម្មណ៍មកប្រាកដដល់បសាទទាំង ៥ ជាអារម្មណ៍នៃព្រះខីណាស្រពកាលឯណា ក៏ជាវារៈនៃសន្តីរណៈ និងតទាលម្ពណៈ ជាសោមនស្សកើតឡើងកាលនោះ កាមាវចរកិរិយាជវនក្នុងសន្តាននៃព្រះខីណាស្រពនោះ ថាបើប្រកបដោយសោមនស្ស តទាលម្ពណៈក្នុងទីបំផុតនៃជវននោះក៏ជាឧបេក្ខា មិនមានប្រែប្រួលឡើយតាំងនៅក្នុងសន្តានព្រៃះខីណាស្រព ប្រាសចាកសញ្ញាវិបល្លាស ។

ទោមនស្សជវន ដែលកើតក្នុងសន្តាននៃបុថុជ្ជន ដែលមានអារម្មណ៍ជាអតិមហន្តារម្មណ៍នោះ តទាលម្ពណៈដែលកើតរៀងជវនមក ក៏ត្រូវនៅឧបេក្ខាទើបនឹងកើតបាន ចិត្តធ្លាក់ចុះកាន់ខ្សែភវង្គ ភវង្គចិត្តក៏នៅជាឧបេក្ខា ព្រោះសេចក្តថា សត្វដែលមានបដិសន្ធិកើតដោយសោមនស្សវេទនានោះថា បើមានទោនស្សជវនកើតក្នុងវេលាណា តទាលម្ពណៈ ក៏មិនកើតក្នុងទីបំផុតនៃសោមនស្សជវននោះឡើយ ។

សត្វដែលមានមហាវិបាក សោមនស្សវេទនាជាបដិសន្ធិនោះ តែងមានភវង្គចិត្តជាសោមនស្សនៅក្នុងសន្តានជានិច្ច មានទៅរហូតភព រហូតជាតិដរាបដល់ត្រឹមចុតិ ៗ នោះក៏ជាសោមនស្សចិត្តដើម ដែលបដិសន្ធិយ៉ាងណា ភវង្គចិត្ត និងចុតិចិត្តក៏យ៉ាងនោះ សត្វដែលបដិសន្ធដោយសោមនស្សនោះ ថាបើកើតក្នុងត្រកូលតិរ្ថិយ៍មិច្ឆាទិដ្ឋិ បានឃើញនូវសរីរកាយនៃព្រះដ៏មានព្រះភាគ ដែលប្រកបដោយទ្វត្តឹសមហាបុរិសលក្ខណៈ និងអសីត្យានុព្យញ្ជនៈដ៏ល្អលើសបំផុតគួរជាទីនាំមកនូវសេចក្ដីជ្រះថ្លាជាអតិឥដ្ឋារម្មណ៍ គឺថាអារម្មណ៍ជាទីប្រាថ្នាក្រៃពេក ចិត្តតិរ្ថិយ៍ក៏ជាចិត្ត ឫស្យា គ្រាកាលបានឃើញហើយ ក៏មានទោមនស្សចិត្ត កិច្ចខាងដើមតាំងអំពីព្រះពុទ្ធរូបមកប្រាកដដល់ចក្ខុបសាទ អតីតភវង្គខណៈ ១ ភវង្គចលនខណៈ ១ ភវង្គុប្បច្ឆេទខណៈ ១ ជា ៣ ខណៈ កើតឡើងហើយដល់រលត់ទៅលំដាប់នោះវិថីចិត្ត គឺបញ្ចទ្វារាវជ្ជនៈ ១ ចក្ខុវិញ្ញាណ ១ សម្បដិច្ឆនៈ ១ សន្តីរណៈ ១ ជា ៤ ខណៈកើតឡើងតាមលំដាប់ជាកុសលវិបាកទាំងអស់ ព្រោះព្រះពុទ្ធជាម្ចាស់ជាអតិឥដ្ឋារម្មណ៍ លុះកាលសន្តីរណៈរលត់ទៅហើយ វោដ្ឋវនចិត្តជាអហេតុកកិរិយាប្រកបដោយឧបេក្ខាក៏កើតឡើង កាលដែលវោដ្ឋវនចិត្តរលត់ទៅហើយ ទើបទោមនស្សជវនកើតឡើងគ្រប់ ៧ ខណៈហើយរលត់ទៅវាក៏ជាតទាលម្ពណវារៈដែលជាឧបេក្ខានឹងមកកើត ក៏កើតមិនបាន ព្រោះព្រះពុទ្ធរូបជាអតិឥដ្ឋារម្មណ៍ចំពោះកើតបានតែតទាលម្ពណៈដែលជាសោមនស្ស ៗ ក៏កើតមិនបាន ព្រោះតទាលម្ពណៈដែលជាសោមនស្សមិនអាចកើតរៀងខណៈ មួយអន្លើដោយទោមនស្សជវនកាលតទាលម្ពណៈដែលជាសោមនស្សមិនកើតហើយ ចិត្តនឹងធ្លាក់ចុះកាន់ភវង្គ ក៏ធ្លាក់ចុះមិនបាន ព្រោះសោមនស្សរបស់តិរ្ថិយ៍ជាសោមនស្សភវង្គនោះ ក៏ជាសោមនស្សមិនអាចនឹងលះបង់នូវបដិសន្ធិដើមចុះកាន់ភវង្គឧបេក្ខាឡើយ កាលចិត្តមិនចុះកាន់ភវង្គឧបេក្ខាហើយឧបេក្ខាសន្តីរណចិត្តប្រារព្ធអារម្មណ៍ចំណែកឯណាមួយដែលជាកាមាវចរដែលតិរ្ថិយ៍សន្សំមកហើយអំពីកាលមុន ក៏កើតឡើងក្នុងទីបំផុតនៃទោមស្សជវន កាលឧបេក្ខាសន្តីរណៈកើតរាំងរាចូលក្នុងលំដាប់នៃទោមនស្សជវន ហើយចិត្តទើបធ្លាក់ចុះកាន់ភវង្គសោមនស្សបានសេចក្ដីនេះជាសន្តាននៃតិរ្ថិយ៍ ដែលមានបដិសន្ធិជាសោមនស្សដែលបានឃើញនូវ-

អតិឥដ្ឋារម្មណ៍ គឺព្រះបរមរូបព្រះពុទ្ធជាម្ចាស់ក៏មានសេចក្តីទោមនស្សប្តូស្សានោះ ។

ម្យ៉ាងទៀត ព្រះអដ្ឋកថាចារ្យទាំងឡាយ លោកតែងប្រាថ្នាយកតទាលម្ពណចិត្ត ដែលមានក្នុងទីបំផុតនៃកាមាវចរជវន ក្នុងកាមាវចរធម៌ទាំងឡាយដែលកើតជាអារម្មណ៍នៃកាមាវចរសត្វ តទាលម្ពណនោះ ចំពោះយកអារម្មណ៍ជាកាមាវចរ បើអារម្មណ៍ជារូបាវចរ និងអរូបាវចរ និងលោកុត្តរ ហើយក៏នឹងស្រាវយកមិនបាន ។

*កាមេជវនសត្តាល- ម្ពនានំ និយមេ សតិ*

*វិភូតេតិមហន្តេ ច តទាលម្ពនមិរិតំ ។*

សេចក្តីថា នឹងកំណត់កាមាវចរជវន ១ កាមាវចរសត្វ ១ កាមារម្មណ៍ ១ ទាំង ៣ នេះជាទីបំផុតនៃតទាលម្ពណៈ លោកហៅថា តទាលម្ពណៈតែងកើតក្នុងអារម្មណ៍ ២ យ៉ាង គឺ វិភូតារម្មណ៍ ១ អតិមហន្តារម្មណ៍ ១ កាមាវចរជវនកាន់យកវត្ថុណាជាអារម្មណ៍ តទាលម្ពណៈក៏កាន់យកវត្ថុនោះមកជាអារម្មណ៍ ប្រៀបដូចវល់ទឹកដែលជាប់តាមកន្សៃទូក ក្នុងកាលដែលមនុស្សអុមប្តូចែវបណ្តែតទៅ ម្យ៉ាងទៀត ប្រៀបដូចពាលទារកប្រាថ្នាចេញទៅក្រៅផ្ទះ តែងតាមមាតាបិតាចេញទៅ ។

( កំណត់តទាលម្ពណៈ ១១ ចប់ )

**នឹងកំណត់សម្តែងការដែលកំណត់ជវនតទៅ :**

ក្នុងជវនទាំងឡាយនោះ កាមវចរជវនតែងលឿនទៅក្នុងកាមវចរវិថី ៧ ខណៈ ៦ ខណៈ ៥ ខណៈខ្លះ, ៧ខណៈនោះកើតដោយប្រក្រតីធម្មតា, ៦ខណៈនោះកើតក្នុងកាលសត្វសន្លប់ក, ៥ ខណៈនោះកើតក្នុងកាលសត្វទៀបមរណាសន្ន គឺជិតស្លាប់ អាចារ្យទាំងឡាយពោលថា កាមាវចរជវនជាបច្ចវេក្ខណចិត្តនៃព្រះដ៏មានព្រះភាគតែងមានក្នុងកាលទាំងឡាយ កាលធ្វើយមកបាដិហារ្យជាដើមប្រព្រឹត្តទៅឆាប់រហ័សពេកណាស់ កើតបានត្រឹម ៤ ខណៈ ៥ ខណៈដែលទ្រង់បណ្តាលទរទឹកទរភ្លើងបាន ។

មហគ្គតជវននៃបុគ្គលដែលរៀនកម្មដ្ឋាន នឹងបានសម្រេចបឋមជ្ឈានក្តី អភិញ្ញាជន គឺបញ្ចមជ្ឈានឱ្យសម្រេចឥទ្ធិឫទ្ធិផ្សេងៗក្តីកើតត្រឹមតែ ១ ខណៈប៉ុណ្ណោះហើយ ចិត្តក៏ធ្លាក់ចុះ ក៏

ធ្លាក់ចុះកាន់ភវង្គ ។

ក្នុងអប្បនាវិថី ឈានចិត្តកើតខណៈ ១ ដូចគ្នាទាំងអស់ សេចក្តីថា កិរិយាដែលនឹង-កើតឡើងនៃមគ្គ ៤ មានសោតាបត្តិមគ្គជាដើម ប្រព្រឹត្តទៅក្នុងខណចិត្តតែ ១ ដូចគ្នាអំពីមុខមគ្គចិត្តនោះ ផលចិត្តដែលកើតក្នុងមគ្គវិថីនោះកើតមានកំណត់ ២ ខណៈខ្លះ ៣ ខណៈខ្លះ ខាងមុខអំពីផលចិត្តនោះ ចិត្តក៏ធ្លាក់ចុះកាន់ភវង្គ ។

នាកាលព្រះអនាគាមិបុគ្គល និងព្រះអរហន្តដែលលោកនឹងចូលកាន់និរោធសមាបត្តិនោះ អរូបជវន ៤ កើត ២ ខណៈ ទើបដល់និរោធ និរោធខាងខាងមុខអំពីចតុត្ថារូបជវន ព្រះអនាគាមិបុគ្គល កាលនឹងចេញចាកនិរោធនោះ អនាគាមិផលជវនកើតខណចិត្ត ១ ចិត្តក៏ធ្លាក់ចុះកាន់ភវង្គ ព្រះអរហន្តកាលនឹងចេញចាកនិរោធនោះ អរហត្តផលជវនកើតឡើងខណចិត្ត ១ ទើបចិត្តក៏ធ្លាក់ចុះកាន់ភវង្គ និងកំណត់វិថីចិត្តក្នុងសមាបត្តិទាំងពួងនោះកំណត់មិនបានឡើយ ដូចភវង្គបាត ក៏មិនមានកំណត់ដែរ ព្រោះថា វិថីចិត្តច្រើនណាស់ ទុកជាសមាបត្តិដទៃៗ ក្រៅចាកនិរោធក៏គង់កំណត់ជវនមិនបាន ព្រោះអប្បនាជវនច្រើនពេក-ណាស់ បណ្ឌិតគប្បីដឹងតាមបាទព្រះគាថានេះចុះ ។

*សត្តក្ខត្តុំ បរិត្តានិ　　　មគ្គាភិញ្ញា សកឹ មតា*
*អវសេសានិ លព្ភន្តិ　　　ជវនានិ ពហូនិបិ ។*

សេចក្តីថា កាមាវចរជវននោះ លឿនទៅ ៧ ខណៈទើបធ្លាក់ចុះកាន់ភវង្គក៏ឯមគ្គ-ជវន អភិញ្ញាជវន មហគ្គជវន ទាំង ៣ នេះ លឿនទៅបានខណចិត្ត ១ ទើបធ្លាក់ចុះកាន់ភវង្គ ផលជវននោះកាលមុននឹងបានក្នុងមគ្គវិថីកើត ២ ខណៈខ្លះ ៣ ខណៈខ្លះ កាលដែលព្រះអនាគាមិបុគ្គល ឬព្រះអរហន្ត ចេញចាកនិរោធនោះកើត ១ ខណៈ ឯជវនក្រៅចាកទីដែលពោលមកនេះនោះលឿនទៅច្រើនខណៈណាស់ នឹងអាចកំណត់មិនបានឡើយ ។

( កំណត់ជវនក្នុងវិថីចិត្ត ចប់ )

**ពីនេះនឹងសម្ដែងនូវបុគ្គលបភេទនោះ**

សត្វដែលជាអហេតុកៈ ទុហេតុកៈនោះ ជាសត្វមានបុណ្យតិច មិនបានសម្រេចកិរិយាជវន និងអប្បនាជវន ទុកជាកើតក្នុងសុគតិភពក្តី ចិត្តដែលជាកាមាវចរវិបាកញាណសម្បយុត្តក៏មិនមានក្នុងសន្តាន បើជាអហេតុកសត្វក្នុងទុគតិវិញ ក៏រឹតតែអាក្រក់ ១ រយគុណ ១ ពាន់គុណទៀត ព្រោះចិត្តដែលជាមហាវិបាកញាណសម្បយុត្ត មិនមានក្នុងសន្តាន ។

លោកដែលជាត្រៃហេតុ មានត្រៃហេតុកជាបដិសន្ធិបញ្ញាកើតព្រមដោយបដិសន្ធិចិត្តនោះ បើនឹងចំរើនព្រះកម្មដ្ឋាន ក៏នឹងបានសម្រេចមគ្គ និងផលចាព្រះខីណាស្រព ដាច់ចាកកុសលជវន និងអកុសលជវន មានតែកិរិយាជវន និងអរហត្តផលជវនប៉ុណ្ណោះក្នុងសន្តានរបស់លោកនោះ ។

បុគ្គលដែលជាត្រៃហេតុនៅជាបុថុជ្ជននៅឡើយ ក៏មិនមានកិរិយាជវនក្នុងសន្តាន លោភជវនជាទិដ្ឋិសម្បយុត្តសោមនស្ស ២ និងមោហជវនសម្បយុត្តវិចិកិច្ឆា និងកិរិយាជវនក្តី ក៏តែងមិនមានក្នុងសន្តាននៃសេក្ខបុគ្គល គឺព្រះសោតាបន្ន សកទាគាមិ អនាគាមិបុគ្គលនោះឡើយ ឯអនាគាមិបុគ្គលនោះក្នុងសន្តានលោកតែងមិនមានបដិឃជវននិងកិរិយាជវន និងលោភជវនជាទិដ្ឋិសម្បយុត្ត និងមោហជវនជាវិចិកិច្ឆាសម្បយុត្ត ។

លោកុត្តរជវននោះ មានកំណត់កើតជាចំណែកៗគ្នា សោតាបត្តិផលជវនចំពោះតែក្នុងសន្តានព្រះសោតាបន្នបុគ្គលនោះ កាលបើដល់សកទាគាមិផលហើយ សោតាបត្តិផលជវនក៏ដាច់ទៅ កើតមានតែសកទាគាមិផលជវនក្នុងសន្តាន កាលបើដល់អនាគាមិផលហើយ សកទាគាមិផលជវនក៏ដាច់ទៅ មានតែអនាគាមិផលជវន កាលបើបានសម្រេចជាព្រះអរហត្តផលហើយ អនាគាមិផលជវន ក៏ដាច់ទៅ មានតែអរហត្តផលជវនក្នុងសន្តាន អសេក្ខបុគ្គលបានអរហត្តផលហើយ កាលនៅក្នុងកាមភព មានចិត្តប្រព្រឹត្តទៅក្នុងសន្តាន ៤៤ គឺកាមាវចរវិបាក ២៣ កិរិយាចិត្ត ២០ អរហត្តផល ១ រួមជា ៤៤ ដូច្នេះ ។

*អសេក្ខានំ ចតុចត្តា- ឡីស សេក្ខានមុទ្ទិសេ*
*ឆឡញ្ញាសាវសេសានំ ចតុប្បញ្ញាស សម្ភវា ។*

សេចក្តីថា សេក្ខបុគ្គល ៧ ពួកមានចិត្តប្រព្រឹត្តទៅក្នុងសន្តាន ៥៦ គឺកាមាវចរវិបាក ៣២ អាវជ្ជនចិត្ត ២ កុសលចិត្ត ២១ អកុសលចិត្ត ៨ វៀរលោភមូលសោមនស្សទិដ្ឋិសម្ប-យុត្ត ២ វិចិកិច្ឆា ១ រួមជា ៥៥ ចំណែកព្រះសោតាបន្នបុគ្គលយកសោតបន្នចិត្ត ១ ដាក់មកបញ្ចូលទៀតជា ៥៦ សកទាគាមិឬអនាគាមិ យកសកទាគាមិចិត្ត ឬអនាគាមិចិត្តដាក់បញ្ចូលមួយៗទៀតជា ៥៦ ចិត្តស្មើគ្នាទាំងអស់ បុគ្គលដែលសល់ក្រៅពីនោះ មានចិត្តប្រព្រឹត្តទៅក្នុងសន្តាន ៥៤ គឺកាមាវចរវិបាក ២៣ អាវជ្ជនៈ ២ លោកិយកុសល ១៧ អកុសលចិត្ត ១២ រួមជា ៥៤ ។

( សម្តែងក្នុងបុគ្គលបភេទ ចប់ )

**នឹងសម្តែងចំណែកភូមិតទៅ :**

ក្នុងកាមាវចរភូមិនោះ វិថីចិត្តប្រព្រឹត្តទៅក្នុងសន្តានសត្វដែលកើតក្នុងសុគតិភព និងទុគ្គតិភព ក៏កើតដោយគួរដល់បុគ្គលគឺបុថុជ្ជន និងសេក្ខបុគ្គល និងអសេក្ខបុគ្គលក្នុងរូបភពនោះមិនមានបដិឃជវន និងតទាលម្ពណចិត្ត ក្នុងរូបភពនោះមិនមានសោតាបត្តិមគ្គចិត្ត ១ មិនមានរូបាវចរចិត្ត ១៥ មិនមានហស្សនចិត្ត ១ ព្រោះមិនមានរូបារម្មណ៍ឱ្យកើតរីករាយបានឡើយ សត្វក្នុងអរូបភពជាន់ខាងលើ មិនមានហេដ្ឋិមារូបចិត្តជាន់ទាប ម្យ៉ាងទៀត សត្វដែលកើតក្នុងភពទាំងពួង បើប្រាសចាកបសាទទ្វានោះៗហើយ ក៏ប្រាសចាកវិថីចិត្តដែលតែងកើតសម្រាប់ទ្វារនោះៗដែរ សត្វដែលកើតក្នុងអសញ្ញីភបនោះ មិនមានចិត្តប្បវត្តិ គឺកិរិយាប្រព្រឹត្តទៅនៃចិត្តនោះឡើយ មានតែចិត្តដែលរំងាប់ស្ងប់ស្ងាត់នៅសល់ ៥០០ កប្បលុះចុតិវិបាកអសញ្ញិភពមកវេលាណា ទើបមានចិត្តប្រព្រឹត្តទៅក្នុងភពទាំង ៣ ។

*អសីតិ វិថិចិត្តានិ　　　កាមេ រូបេ យថារហំ*
*ចតុសដ្ឋី តថារូបេ　　　ទ្វេចត្តាឡីស លព្ភរេ ។*

សេចក្តីថា ចិត្ត ៨០ ប្រព្រឹត្តទៅក្នុងកាមភព គឺចិត្ត ៨៩ លើកមហគ្គតចិត្ត ៩ ចេញនៅសល់ ៨០ ចិត្ត ៦៤ ប្រព្រឹត្តទៅក្នុងរូបភពគឺចិត្ត ៨៩ លើកតទាលម្ពណៈ ៨ គឺមហាវិបាក ៨ លើកបដិឃចិត្ត ២ លើកឃានវិញ្ញាណ ១ ជិវ្ហាវិញ្ញាណ ១ កាយវិញ្ញាណ ១ ចំណែកកុសល

៣ ចំណែកអកុសល ៣ ជា ៦ លើកមហគ្គតវិបាក ៩ ចេញរួមចិត្តដែលលើកចេញទាំងអស់ត្រូវ ២៥ គង់តែ ៦៤ ចិត្ត ៤៣ ប្រព្រឹត្តទៅក្នុងអរូបភព គឺចិត្ត ៨៩ លើក ៤៧ ចេញគឺលើកបដិឃចិត្ត ២ ទ្វិបញ្ចវិញ្ញាណ ១០ មនោធាតុតិកៈ ៣ ហសិតុប្បាទចិត្ត ១ តទាលម្ពណចិត្ត ១១ សោតាបត្តិមគ្គចិត្ត ១ រូបាវចរ ១៥ លើកអរូបវិបាក ៤ រួមចិត្តដែលលើកចេញទាំងអស់ត្រូវ ៤៧ នៅគង់ ៤២ ។

( ចំណែកចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ចប់ )

កិរិយាប្រព្រឹត្តនៃចិត្ត ប្រកបមិនដាច់ក្នុងទ្វារទាំង ៦ កើតសមគួរដល់ទ្វារនិងភពនោះ ៗ កំណត់ចិត្តដែលធ្លាក់ចុះកាន់ភវង្គ បើធ្លាក់ចុះក្នុងទីណា ក៏រាប់ជាវិថីចិត្តបានក្នុងទីនោះ ឯវិថីចិត្តហើយនឹងខ្សែភវង្គនេះ តែងប្រព្រឹត្តទៅមិនដែលដាច់ដរាបដល់អស់អាយុ ដោយប្រការដូច្នេះ ។

*ឥតិ អភិធម្មត្ថសង្គហេ*

*វិថិសង្គហវិភាគោ នាម ចតុត្ថោ បរិច្ឆេទោ*

បរិច្ឆេទជាគំរប់ ៤ ឈ្មោះវិថីសង្គហវិភាគ ក្នុងអភិធម្មត្ថសង្គហៈ

ចប់ដោយប្រការដូច្នេះ

## បរិច្ឆេទទី ៥

### វិថីមុត្តកសង្គហវិភាគ

*វិថិចិត្តវសេនេវំ បវត្តិយមុទិរិតោ*

*បវត្តិសង្គហោ នាម សន្ធិយន្ទានិ វុច្ចតិ ។*

ឈ្មោះថាការរួបរួមពោលនូវកិរិយាប្រព្រឹត្តទៅនៃចិត្ត ដោយអំណាចនៃវិថីចិត្ត–ដែលព្រះមានជ័ព្រះភាគសម្តែងហើយក្នុងបវត្តិកាល ខ្ញុំឈ្មោះអនុរុទ្ធាចារ្យនឹងពោលក្នុងបដិសន្ធិកថា ក្នុងកាលឥឡូវនេះ បណ្ឌិតគប្បីដឹងនូវពួកបួន១ដង ក្នុងវិថីមុត្តសង្គហៈដូច្នេះគឺ ភូមិចតុកៈ ១ បដិសន្ធិចតុកៈ កម្មចតុកៈ ១ មរណចតុកៈ ១ រួមជា ៤ ពួក ។

ភូមិចតុកៈ ៤ គឺ អបាយភូមិ ១ កាមសុគតិភូមិ ១ រូបាវចរភូមិ ១ អរូបាវចរភូមិ ១ អបាយភូមិ ៤ គឺនរក ១ ប្រេតវិស័យ ១ តិរច្ឆាន ១ អសុរកាយ ១ , កាមសុគតិភូមិ ៧ គឺ មនុស្ស ១ កាមាវចរសួគ៌ ៦, កាមាវចរភូមិ ១១ គឺ អបាយភូមិ ៤ កាមសុគតិ ៧, រូបាវចរ–ភូមិ ១៦ គឺព្រហ្មបារិសជ្ជា ១ ព្រហ្មបរោហិតា ១ មហាព្រហ្មា ១ បីនេះឈ្មោះបឋមជ្ឈានភូមិ បរិត្តាភា ១ អប្បមាណាភា ១ អភស្សរា ១ បីនេះឈ្មោះទុតិយជ្ឈានភូមិ, បរិត្តសុភា ១ អប្បមាណសុភា ១ សុភកិណ្ហា ១ បីនេះឈ្មោះតតិយជ្ឈានភូមិ, វេហប្ផលា ១ អសញ្ញិសត្តា ១ បញ្ចសុទ្ធាវាសា ១ បីនេះឈ្មោះចតុត្ថជ្ឈានភូមិ, បញ្ចសុទ្ធាវាស ៥ នោះគឺអវិហា ១ អតប្បា ១ សុទស្សា ១ សុទស្សិ ១ អកនិដ្ឋកា ១, អរូបាវចរភូមិ ៤ គឺ អាកាសានញ្ចាយតនៈ១ វិញ្ញាណញ្ចាយតនៈ ១ អាកិញ្ចញ្ញាយតនៈ ១ នេវសញ្ញានាសញ្ញាយតនៈ ១ ។

*បុថុជ្ជនាទលព្ភន្តិ សុទ្ធាវាសេសុ សព្វថា*

*សោតាបន្នា ច សកទា– គាមិនោ ចាបិ បុគ្គលា ។*

*អរិយា នោបលព្ភន្តិ អសញ្ញាបាយភូមិសុ*

*សេសដ្ឋានេសុ លព្ភន្តិ អរិយានរិយាបិ ច ។*

សេចក្តីថា បុថុជ្ជន និងសោតាបន្នៈនិងសកទាគាមិបុគ្គល មិនកើតក្នុងសុទ្ធាវាសទាំង៥ ឡើយដោយបការទាំងពួង ឯព្រះអរិយបុគ្គលគឺព្រះសោតាបន្ន សកទាគាមិ អនាគាមិ មិន–កើតក្នុងអសញ្ញិភព និងអបាយភូមិ ៤ ដែលសល់អំពីនោះគឺមនុស្ស ១ កាមាវចរ ៦ បឋម–

ជ្ឈានភូមិ ៣ ទុតិយជ្ឈានភូមិ ៣ តតិយជ្ឈាន ៣ វេហប្ផលា ១ អរូបភូមិ ៤ រួមគ្នា ២១ ភូមិ ព្រះអរិយបុគ្គល និងបុថុជ្ជនកើតបានជាមួយគ្នាទាំងអស់ ។

( សម្តែងក្នុងភូមិចតុក: ចប់ )

**នឹងសម្តែងនូវបដិសន្ធិចតុក:តទៅ:**

បដិសន្ធិមាន ៤ គឺអបាយបដិសន្ធិ ១ កាមសុគតិបដិសន្ធិ ១ រូបាវចរបដិសន្ធិ ១ អរូបាវចរបដិសន្ធិ ១ អរូបាវចរបដិសន្ធី ១ ។

អកុសលវិបាកវិញ្ញាណ គឺសន្តីរណចិត្តប្រកបដោយឧបេក្ខាវេទនា ជាតួបដិសន្ធិ ភវង្គ ចុតិ ក្នុងអបាយភូមិទាំង ៤ ចិត្តបដិសន្ធក្នុងអបាយភូមិ ៤ មានចំណែកតែ ១ ប៉ុណ្ណោះ ។

កុសលវិបាកវិញ្ញណ គឺសន្តីរណចិត្តប្រកបដោយឧបេក្ខាវេទនា ជាតួបដិសន្ធិ ភវង្គ ចុតិ របស់មនុស្សទាំងឡាយមានមនុស្សខ្វាក់អំពីកំណើត និងថ្លង់អំពីកំណើតនិងខ្មើយជាដើម ពួក ១ និងវិនិបាតិកាសុរ ដែលរាប់បញ្ចូលក្នុងភូមិទេវតាក្នុងកាមសុគតិពួក ១ ។

មហាវិបាក ៨ ជាតួបដិសន្ធិ ភវង្គ ចុតិ របស់មនុស្សដែលមានបុណ្យពួក ១ និងទេវតាក្នុងជាន់កាមាវចរ ៦ ក្នុងកាមសុគតិពួក ១ ។

ក្នុងកាមសុគតិ មានបដិសន្ធិចិត្ត ៩ គឺកុសលវិបាកសន្តីរណចិត្ត ជាបដិសន្ធិ ភវង្គ ចុតិ របស់មនុស្សមិនមានបុណ្យពួក ១ និងវិនិបាតិកាសុរ ពួក ១ មហាវិបាក ៨ ជាតួបដិសន្ធិ ១ ភវង្គ ចុតិ របស់មនុស្សដែលមានបុណ្យ និងទេវតាក្នុងឆកាមវចរសួគ៌ រួមគ្នាជាបដិសន្ធិចិត្ត ៩ ប្រការ យកអបាយកបដិសន្ធិដាក់បញ្ចូល ១ ទៀតជា ១០ រួមចូលគ្នាជាកាមាវចរបដិសន្ធិ ១០ ប្រការ អបាយភូមិ ១ មនុស្ស ១ វិនិបាតិកាសុរ ១ សត្វដែលកើតក្នុងទី ៣ នេះមិនមានកំណត់អាយុ ។

អាយុទេវតាក្នុងជាន់ចាតុមហារាជិកា ៥០០ ឆ្នាំទិព្វត្រូវជា ៩.០០០.០០០ ( ៩ លាន) ឆ្នាំមនុស្ស អាយុទេវតាក្នុងជាន់តាវតឹង្ស ១.០០០ ឆ្នាំទិព្វ ត្រូវជា ៣៦.០០០.០០០ ( ៣ កោដិ ៦ លាន ) ឆ្នាំមនុស្ស អាយុទេវតាក្នុងជាន់យាមា ២.០០០ ឆ្នាំទិព្វត្រូវជា ១៤៤.០០០.០០០

( ១៤ កោដិ ៤ លាន ) ឆ្នាំមនុស្ស អាយុទេវតាក្នុងជាន់តុសិត ៤000 ឆ្នាំទិព្វត្រូវជា ៥៧៦.000.000 ( ៥៧ កោដិ ៦ លាន ) ឆ្នាំមនុស្ស អាយុទេវតាជាន់និម្មានរតី ៨.000 ឆ្នាំ-ទិព្វត្រូវជា ២៣0៤.000.000 ( ២៣0 កោដិ ៤ លាន ) ឆ្នាំមនុស្ស អាយុទេវតាក្នុងជាន់បរិនិម្មិតវសវតី ១៦.000 ត្រូវជា ៩២១៦.000.000 ( ៩២១ កោដិ ៦ លាន ) ឆ្នាំមនុស្ស ។

ឯវិធីដែលនឹងគិតអាយុទេវតាក្នុងជាន់ទាំង ៦ នោះ ត្រូវតាំងអាយុទេវតាក្នុងជាន់ចាតុមហារាជិកា ៩.00.000 ឆ្នាំមនុស្សទុក ហើយយក ៤ គុណបានលព្ធ ៣៦.000.000 ជាអាយុទេវតាក្នុងជាន់ឈ្មោះតាវតឹង្ស ហើយតាំង ៣៦.000.000 ទុកយក ៤ គុណទៀតបាន-លព្ធប៉ុន្មាន ក៏ត្រូវជាអាយុទេវតាក្នុងជាន់ឈ្មោះយាមាត្រូវយក ៤ គុណគ្រប់ជាន់ទាំង ៦ ដូចគ្នា ។

*នវសតញ្ចេកវីស　　　វស្សានំ កោដិយោ តថា*
*វស្សាសតសហស្សានិ　　　សដ្ឋិញ្ច វសវត្តិសុ ។*

សេចក្តីថា អាយុទេវតាក្នុងជាន់ឈ្មោះវសវតីនោះ ១៦.000 ឆ្នាំទិព្វគិតជាឆ្នាំមនុស្សលោកនេះត្រូវ ៩២១ កោដិ និង ៦ លានឆ្នាំ ( ៩២១៦.000.000 ) ។

( កាមាវចរបដិសន្ធិ ១០ ចប់ )

ក្នុងរូបភពមានបដិសន្ធិ ៦ យ៉ាងគឺ បដិសន្ធិដោយចិត្ត ៥ យ៉ាងបដិសន្ធិដោយរូប ១ យ៉ាងរួមគ្នា ៥ យ៉ាង បឋមជ្ឈានវិបាកសម្រេចកិច្ចជាតួបដិសន្ធិ ភវង្គ ចុតិ ក្នុងបឋមជ្ឈានភូមិ ទុតិយជ្ឈានវិបាក តតិយជ្ឈានវិបាក សម្រេចកិច្ចជាតួបដិសន្ធិ ភវង្គ ចុតិ ក្នុងតតិយជ្ឈានភូមិ បញ្ចមជ្ឈានវិបាកឱ្យសម្រេចកិច្ចជាតួបដិសន្ធិ ភវង្គ ចុតិ ក្នុងចតុត្ថជ្ឈានភូមិ ឯអសញ្ញិសត្វមិនបានបដិសន្ធិដោយចិត្តឡើយ គឺ បដិសន្ធិដោយរូបហៅថារូបបដិសន្ធិ កាលបើបដិសន្ធិកើតឡើងនោះយ៉ាងណា វេលាដល់រស់នៅ ឬស្ថិតនៅក៏យ៉ាងនេះ គឺថា កាលដែលអង្គុយ ឬដេក ឬឈរ វេលាដល់តាំងនៅក៏អង្គុយ ឬដេក ឬឈរ ដូចកាលដែលកើតនោះឯង ដរាបដល់អស់អាយុ ៥00 កប្ប សេចក្តីថាព្រះយោគីពួកនេះ កាលនៅជាមនុស្សនៅឡើយ បានធ្វើ

សេចក្តីព្យាយាមបានសម្រេចអភិញ្ញាសមាបត្តិ កាលចុតិចាកជាតិមនុស្សនោះទៅដោយឥរិយាបថណា វេលាដល់ទៅបដិសន្ធិដោយរូប ក៏មានឥរិយាបថយ៉ាងនោះឯង ជាហេតុប្រព្រឹត្តនៅដូច្នេះឯង កាលបើបដិសន្ធិដោយរូប ហើយក្នុងបវត្តិកាលកើតសមុដ្ឋានរូបដ៏វិសេស សទ្ទនវកកលាបក៏មិនមាន កាលដែលចុតិ ក៏ចុតិដោយរូប, រូបនោះក៏សូន្យបាត់ទៅក្នុងវេលាដែលចុតិនោះឯង ។

( សម្តែងក្នុងរូបាវចរបដិសន្ធិ ៦ ចប់ )

**សម្តែងអំពីអាយុទេវតាក្នុងស្ថានព្រហ្មដូចតទៅ :**

អាយុព្រហ្មក្នុងជាន់ឈ្មោះព្រហ្មបារិសជ្ជា ១ ចំហៀងកប្ប គឺយកអាយុវិវដ្តដ្ឋាយិកប្បមកបែងចែកជា ៣ ភាគចោល ២ ភាគ យក ១ ភាគជាប្រមាណនៃអាយុព្រហ្មក្នុងជាន់ព្រហ្មបារិសជ្ជានោះឯង ព្រហ្មបរោហិតាមានអាយុចុះកន្លះវិវដ្តដ្ឋាយិកប្ប មហាព្រហ្មអាយុ ១កប្ប បរិត្តាព្រហ្ម អាយុ ២ កប្ប អប្បមាណាភាព្រហ្មអាយុ ៤ កប្ប អភស្សរាព្រហ្មអាយុ ៨ កប្ប បរិត្តសុភាព្រហ្មអាយុ ១៦ កប្ប អប្បមាណសុភាព្រហ្មអាយុ ៣២ កប្ប សុភកិណ្ហាព្រហ្មអាយុ ៦៤ កប្ប វេហប្ផលាព្រហ្ម ១ អសញ្ញិសត្វ ១ ទាំង ២ នេះអាយុ ៥00 កប្ប អវិហាព្រហ្មអាយុ ១.000 កប្ប អាតប្បាព្រហ្មអាយុ ២.00កប្ប សុទ្ទស្សាព្រហ្មអាយុ ៤.000 កប្ប សុទ្ទស្សីព្រហ្មអាយុ ៨.000 កប្ប អកនិដ្ឋកាព្រហ្មអាយុ ១៦.000 កប្ប ។

អរូបភូមិទី ១ បឋមារូបវិបាកឱ្យសម្រេចកិច្ចជាតួបដិសន្ធិ ភវង្គ ចុតិ អរូបភូមិទី ២ ទុតិយារូបវិបាកឱ្យសម្រេចកិច្ចជាតួបដិសន្ធិ ភវង្គ ចុតិ អរូបភូមិទី ៣ តតិយារូបវិបាកឱ្យសម្រេចកិច្ចជាតួបដិសន្ធិ ភវង្គ ចុតិ អរូបភូមិទី ៤ ចតុត្ថារូបវិបាកឱ្យសម្រេចកិច្ចជាតួបដិសន្ធិ ភវង្គ ចុតិ ។

អរូបព្រហ្មទី ១ មានអាយុ ២ ម៉ឺនមហាកប្ប អរូបព្រហ្មទី ២ មានអាយុ ៤ ម៉ឺនមហាកប្ប អរូបព្រហ្មទី ៣ មានអាយុ ៦ ម៉ឺនមហាកប្ប អរូបព្រហ្មទី ៤ មានអាយុ ៨៤.000 (ប្រាំបីម៉ឺនបួនពាន់) មហាកប្ប ។

*បដិសន្ធិ ភវង្គញ្ច          តថា ចវនមានសំ*
*ឯកមេវ តថេវេក-          វិសយញ្ចេកជាតិយំ ។*

សេចក្តីថា ចិត្ត ៣ គឺបដិសន្ធិ ១ ភវង្គ ១ ចុតិ ១ ទាំង ៣ នេះប្រព្រឹត្តទៅក្នុងអារម្មណ៍ជាមួយក្នុងជាតិជាមួយ ដូចគ្នាតែ ១ មិនមានប្លែកគ្នា មិនមានខុសគ្នាឡើយ គឺដូចគ្នាដោយភូមិ និងជាតិ និងសម្បយុត្តធម៌ជាដើម ។

( បដិសន្ធិចតុក្កៈ ៤ ចប់ )

**សំម្តែងអំពីកម្មចតុក្កៈតទៅ :**

* កម្ម បើសម្តែងដោយកិច្ចមាន ៤ យ៉ាងគឺ :

១-*ជនកកម្ម* កម្មដែលជាកុសល ឬអកុសលឱ្យសម្រេចកិច្ចជាបដិសន្ធិ ចិត្តគឺញុំាងសត្វឱ្យកើត ។

២-*ឧបត្ថម្ភកកម្ម* ជាកុសលឬអកុសលដែលជួយគាំទ្រផលកម្មដែលឱ្យផលមុននោះ ។

៣-*ឧបបីឡិកកម្ម* កម្មជាកុសល ឬជាអកុសលដែលចូលបៀតបៀននូវផលកម្មដែលឱ្យផលមុននោះ ។

៤-*ឧបឃាដកកម្ម* កម្មជាកុសល ឬជាអកុសលដែលចូលទៅសម្លាប់បង់នូវកម្មដែលឱ្យផលមុននោហ ហើយឱ្យផលដោយខ្លួនឯង ។

* កម្ម បើសម្តែងដោយលំដាប់ ដែលឱ្យផលនោះមាន ៤ យ៉ាងគឺ :

១-*គរុកម្ម* កម្មជាកុសល ឬអកុសលយ៉ាងធ្ងន់យ៉ាងធំ ចំណែកខាងកុសលបានខាងឈានសមាបត្តិ ចំណែកខាងអកុសលបានខាងបញ្ចានន្តរិយកម្ម ។

២-*អាសន្នកម្ម* កម្មជាបុណ្យ ឬជាបាបដែលបុគ្គលធ្វើក្នុងកាលជិតមរណភាព ហើយរឭកចាំបាន ។

៣-*អាចិណ្ណកម្ម* កម្មដែលល្អ ឬអាក្រក់ដែលបុគ្គលធ្វើតែម្តងហើយសន្សំនឹករឿយៗមិនដាច់ មិនមានភ្លេច ។

៤-*កដត្តាកម្ម* កម្មជាកុសល ឬអកុសលដែលមានកម្លាំងទន់ទាបថោកថយ ។

* កម្ម បើសម្តែងដោយកាលកំណត់ឱ្យផលនោះមាន ៤ យ៉ាងគឺ :

១-*ទិដ្ឋធម្មវេទនីយកម្ម* កម្មជាកុសល ឬអកុសលដែលអាចឱ្យនូវផលក្នុងរវាង ៧ថ្ងៃ ឬបច្ចុប្បន្នជាតិនេះ ។

២-*ឧបបជ្ជវេទនីយកម្ម* កម្មជាកុសល ឬអកុសលដែលឱ្យផលក្នុងជាតិជាលំដាប់ គឺជាតិទី ២ នោះ បើចំណែកខាងបុណ្យ គឺឈានសមាបត្តិបើចំណែកខាងបាប គឺបញ្ចានន្តរិយកម្ម ។

៣-*អបរាបរវេទនីយកម្ម* កម្មជាកុសល ឬអកុសលដែលប្រព្រឹត្តជាប់ទៅតាមបុគ្គល ដូចស្រមោលតាមរូប ឬដូចសុនខ (ឆ្កែ)តាមម្រឹក ។

៤-*អហោសិកម្ម* កម្មជាកុសល ឬអកុសលដែលកន្លងហួសទៅមិនឱ្យផលដល់អ្នក-ដែលធ្វើនោះឡើយ ដូចកម្មរបស់ព្រះខីណាស្រព ។

កម្មមាន ៤ យ៉ាងទៀតដោយហេតុដែលឱ្យផល គឺអកុសលចិត្តឱ្យផលជាទុក្ខក្នុង-អបាយភូមិ ១ កាមវចរកុសលកម្មឱ្យផលជាសុខក្នុងកាមសុគតិភព ១ រូបាវចរកុសលកម្មឱ្យផលជាសុខក្នុងរូបភព ១ អរូបាវចរកុសលឱ្យផលជាសុខក្នុងអរូបភព ១ ។

អកុសលនោះចែកចេញជាកម្មមាន ៣ គឺកាយកម្ម ១ វចីកម្ម ១ មនោកម្ម ១ ជាទ្វារមាន ៣ គឺកាយទ្វារ ១ វចីទ្វារ ១ មនោទ្វារ ១ ។

សួរថា អកុសលដែលញែកចេញជាកម្មជាទ្វារនោះ អធិប្បាយយ៉ាងណា?

ឆ្លើយថា អកុសលដែលញែកចេញជាកម្ម ជាទ្វារនោះ គឺញែកចេញដោយកម្មបថ ១០ ប្រការ កាយកម្មប្រព្រឹត្តទៅក្នុងកាយទ្វារ ៣ គឺបាណាតិបាត ១ អទិន្នាទាន ១ កាមេសុ-មិច្ឆាចារ ១ វចីកម្មប្រព្រឹត្តទៅក្នុងវចីទ្វារ ៤ គឺមុសាវាទ ១ ផរុសវាទ ១ បេសុញ្ញវាទ ១ សម្ផប្បលាប ១ មនោកម្មប្រព្រឹត្តទៅក្នុងមនោទ្វារ ៣ គឺអភិជ្ឈា ១ ព្យាបាទ ១ មិច្ឆាទិដ្ឋិ ១ អកុសលកម្មបថទាំង ១០ នេះកើតអំពីអកុសលមូលទាំង ៣ បាណាតិបាត ១ ផរុសវាទ ១ ព្យាបាទ ១ បីនេះកើតអំពីទោសមូល កាមេសុមិច្ឆាចារ ១ អភិជ្ឈា ១ មិច្ឆាទិដ្ឋិ ១ បីនេះកើតអំពីលោភមូល អទិន្នាទាន ១ មុសាវាទ ១ បេសុញ្ញវាទ ១ សម្ផលាប ១ បួននេះកើត

អំពីមូលទាំង ៣ គឺលោភមូល ទោសមូល មោហមូល រាប់ដោយអំណាចចិត្តុប្បាទ ។

អកុសលកម្មមាន ១២ គឺលោភមូល ៨ ទោសមូល ២ មោហមូល ២ កាមាវចរ-កុសលមាន ៣ ប្រការ ដោយអំណាចនៃកម្មនិងទ្វារគឺថា កាមាវចរកុសលប្រព្រឹត្តទៅក្នុងកាយទ្វារ ហៅថាកាយកម្មជាកុសល ប្រព្រឹត្តទៅក្នុងវចីទ្វារ ហៅថាវចីកម្មជាកុសល ប្រព្រឹត្តទៅក្នុងមនោទ្វារ ហៅថា មនោកម្មជាកុសល ។

ម្យ៉ាងទៀត កាមាវចរកុសលមាន ៣ ប្រការ ប្រព្រឹត្តទៅដោយអំណាចនៃកម្ម និងទ្វារ គឺទានមយៈ ១ សីលមយៈ ១ ភាវនាមយៈ ១ ឯកាមាវចរកុសលនេះបើចាត់ដោយចិត្តុប្បាទ នោះមាន ៨ គឺសោមនស្សចិត្ត ៤ ឧបេក្ខាចិត្ត ៤ ដែលជាចិត្តប្រារព្ធធ្វើនូវកុសលកម្ម មាន-ទាន និងសីលជាដើម ។

កាមាវចរកុសលនេះ តែងឱ្យសម្រេចកិច្ចជាបុញ្ញកិរិយាវត្ថុ ១០ យ៉ាងគឺ

១-*ទានៈ* កិរិយាឱ្យនូវវត្ថុគឺបុគ្គលគប្បីឱ្យ ។

២-*សីលៈ* កិរិយារក្សានូវការប្រក្រតី ឬរក្សានូវសេចក្ដីសង្រួម ។

៣-*ភាវនា* កិរិយាចម្រើននូវសមថកម្មដ្ឋាន ឬវិបស្សនាកម្មដ្ឋាន ។

៤-*អបចាយនៈ* កិរិយាប្រព្រឹត្តកោតក្រែងដល់ត្រកូលដ៏ជាធំ ។

៥-*វេយ្យាវច្ចៈ* កិរិយាខ្វល់ខ្វាយក្នុងការកុសល ។

៦-បត្តិទានៈ កិរិយាឱ្យនូវចំណែកបុណ្យដល់សត្វទាំងពួង ។

៧-*បត្តានុមោទនៈ* កិរិយាត្រេកអរតាមនូវចំណែកបុណ្យដែលអ្នកដទៃគេចែកឱ្យ ឬគេធ្វើ ។

៨-*ធម្មសវនៈ* កិរិយាស្ដាប់នូវធម៌ដែលគេសម្ដែង ឬនិយាយប្រាប់ ឬពន្យល់ ។

៩-*ធម្មទេសនា* កិរិយាសម្ដែងនូវធម៌ឱ្យអ្នកដទៃស្ដាប់ ។

១០-*ទិដ្ឋុជុកម្ម* កិរិយាធ្វើនូវទិដ្ឋិឱ្យត្រង់ល្អ គឺថាជាសម្មាទិដ្ឋិ ។

បុញ្ញកិរិយាវត្ថុ ១០ ប្រការ នេះកើតដោយកាមាវចរកុសលចិត្ត ៨ យ៉ាង កាមាវចរ-កុសល ៨ យ៉ាងនេះផ្សំនឹងអកុសលចិត្ត ១២ ជា ២០ សង្គ្រោះថាជាកាមាវចរកម្ម ២០ ប្រការដូច្នេះ ។

ចំណែករូបាវចរកុសលនោះជាមនោកម្មតែម្យ៉ាង ដ៏ហើយទៅដោយភាវនាដល់នូវអប្បានឈានទាំង ៥ ប្រការ ដោយប្រភេទនៃអង្គឈាន ។

អរូបាវចរកុសលក៏ជាមនោទ្វារតែម្យ៉ាង ដល់ហើយនូវអប្បនាឈាន ដ៏ហើយដោយភាវនាមាន ៤ យ៉ាងដោយប្រភេទនៃអារម្មណ៍ មានអាកាសានញ្ចាយតនារម្មណ៍ជាដើម ។

អកុសលចិត្ត ១២ លើកឧទ្ធច្ចសម្បយុត្តមោហមូលចេញនៅសល់ ១១ ញុំាំងបដិសន្ធិឱ្យកើតក្នុងអបាយភូមិ ៤ ។

អកុសលទាំង ១២ ញុំាំងអកុសលវិបាកទាំង ៧ ឱ្យកើតក្នុងកាមលោក និងរូបលោកក្នុងបវត្តិកាលដោយសមគួរ ។

កាមាវចរកុសលចិត្ត ៨ ញុំាំងបដិសន្ធិចិត្តឱ្យកើតក្នុងកាមសុគតិភូមិខាងមុខអំពីបដិ-សន្ធិនោះទៅញុំាំងមហាវិបាក ៨ និងកុសលវិបាកអហេតុកៈ ៨ ទាំងអស់ឱ្យកើតក្នុងកាម-លោក និងរូបលោកក្នុងបវត្តិកាលដោយសមគួរ ។

កាមាវចរកកុសលដែលជាញាណសម្បយុត្ត ៤ ហៅថាត្រៃហេតុកៈដែលជាញាណ-វិប្បយុត្ត ៤ ហៅថា ទុហេតុកៈ ( ញាណសម្បយុត្ត ៤ នោះចែកចា ២ សោមនស្សញាណ-សម្បយុត្ត ២ ជាត្រៃហេតុកៈយ៉ាងឧក្រឹដ្ឋ (យ៉ាងខ្ពស់) ឧបេក្ខាញាណសម្បយុត្ត ២ ជាត្រៃ-ហេតុកៈជា ឱមកៈ (យ៉ាងទាប ) ។

ត្រៃហេតុកកុសលជាឧក្រិដ្ឋនោះឱ្យបដិសន្ធិជាត្រៃហេតុហើយញុំាំងវិបាក ១៦ គឺមហាវិបាក ៨ ហេតុកកុសលវិបាក ៨ឱ្យកើតក្នុងបវត្តិកាលគឺកាលដែលតអំពីបដិសន្ធិកាលនោះ។

ត្រៃហេតុកកុសលជាឱមកៈ និងទុហេតុកកុសលជាឧក្រឹដ្ឋនោះ ឱ្យបដិសន្ធិជាទុហេតុហើយញុំាំងវិបាក ១២ គឺញាណវិប្បយុត្ត ៤ កុសលវិបាកអហេតុកៈ ៨ លើកត្រៃហេតុ ៤ គឺញាណសម្បយុត្ត ៤ ចេញឱ្យកើតក្នុងបវត្តិកាល ។

*អសង្ខារំ សង្ខារ-　　　　វិបាកានិ ន បច្ចតិ*

*សសង្ខារមសង្ខារ-　　　　វិបាកានីតិ កេចិ ន ។*

សេចក្តីថា កេចិអាចារ្យពោលថា កាមវចរកុសលចិត្តជាអសង្ខារិក មិនឱ្យផលជាសសង្ខារិកបានឡើយ សសង្ខារិកមិនអាចឱ្យផលជាអសង្ខារិកបាន ចំពោះឱ្យផលតាមជាតិរបស់ខ្លួន ជាសភាពយ៉ាងណាក៏ឱ្យផលយ៉ាងនេះព្រះអនុរុទ្ធាចារ្យលោកពោលគាថាទុកថា :

*តេសំ ទ្វាទស បាកានិ　　　　ទសដ្ឋ ច យថាក្កមំ*

*យថាវុត្តានុសារេន　　　　យថាសម្ភវមុទ្ទិសេ ។*

សេចក្តីថា អ្នកប្រាជ្ញគប្បីសម្តែងនូវភាវៈនៃកាមាវចរកុសលដែលជាអសង្ខារិក និងសសង្ខារិក និងកើតឡើងយ៉ាងណាដោយសេចក្តីដែលកេចិអាចារ្យពោលទុកថា កាមាវចរកុសលជាញាណសម្បយុត្តអសង្ខារិកជាត្រៃហេតុឧក្រឹដ្ឋ ឱ្យត្រៃហេតុកបដិសន្ធិ ហើយឱ្យកើតអសង្ខារិក ៤ កុសលវិបាកហេតុកៈ ៨ ជា ១២ ក្នុងបវត្តិកាល ។

( អសង្ខារិក ចប់ )

កាមាវចរកុសលញាណសម្បយុត្ត សសង្ខារិកត្រៃហេតុឧក្រឹដ្ឋ ឱ្យត្រៃហេតុកបដិសន្ធិហើយ ឱ្យកើតសសង្ខារិកវបាក ៤ កុសលវិបាកាហេតុកៈ ៨ ជា ១២ ក្នុងបវត្តិកាល ។

សសង្ខារិកត្រៃហេតុកៈ　　ឱមកៈនិងសសង្ខារិកទុហេតុកៈឧក្រឹដ្ឋឱ្យទុហេតុកបដិសន្ធិហើយឱ្យកើតញាណវិប្បយុត្តសសង្ខារិក ២ កុសលវិបាកអហេតុកៈ ៨ ជា១០ក្នុងបវត្តិកាល។

សសង្ខារិកឱមកទុហេតុ ឱ្យអហេតុកបដិសន្ធិហើយឱ្យកើតកុសលវិបាកអហេតុកៈ ៨ ជាលំដាប់គ្នាក្នុងបវត្តិកាល ។

( សសង្ខារិក ចប់ )

អ្នកដែលចម្រើនរូបាវចរកុសលមានបឋមជ្ឈានជាដើម　　តែងទៅកើតក្នុងព្រហ្ម-លោកមានព្រហ្មបារិសជ្ជាជាដើម តាមលំដាប់ដូច្នេះ :

បឋមជ្ឈានជាបរិត្តយ៉ាងទន់ ទៅកើតក្នុងជាន់ព្រហ្មបារិសជ្ជា, បឋមជ្ឈានជាមជ្ឈិមយ៉ាងកណ្តាលទៅកើតក្នុងជាន់ព្រហ្មបរោហិតា, បឋមជ្ឈានជាបណីតយ៉ាឧក្រឹដ្ឋទៅកើតក្នុង

ជាន់មហាព្រហ្ម ។

ទុតិយជ្ឈាន តតិយជ្ឈានជាបរិត្ត ទៅកើតក្នុងជាន់ឈ្មោះបរិត្តាភា, ទុតិយជ្ឈាន តតិយជ្ឈានជាមជ្ឈិម ទៅកើតក្នុងជាន់ឈ្មោះអប្បមាណាភា, ទុតិយជ្ឈាន តតិយជ្ឈានជាបណីត ទៅកើតក្នុងជាន់ឈ្មោះអភស្សរា ។

ចតុត្ថជ្ឈានជាបរិត្ត ទៅកើតក្នុងជាន់ឈ្មោះបរិត្តសុភា, ចតុត្ថជ្ឈានជាមជ្ឈិមទៅកើតក្នុងជាន់ឈ្មោះអប្បមាណសុភា, ចតុត្ថជ្ឈានជាបណីតទៅកើតក្នុងជាន់ឈ្មោះសុភកិណ្ហា ។

បញ្ចមជ្ឈានមិននឿយណាយចាកចិត្ត ទៅកើតក្នុងជាន់ឈ្មោះវេហប្ផលា បញ្ចមជ្ឈាននឿយចាកចិត្ត ទៅកើតក្នុងជាន់ឈ្មោះអសញ្ញិសត្វ ព្រះអនាគាមិបុគ្គលទាំងឡាយតែងទៅកើតក្នុងជាន់សុទ្ធាវាសទាំង ៥ ។

( រូបាវចរកុសលកម្ម ចប់ )

អរូបកុសលកម្ម ព្រះអនាគាមិបុគ្គល និងបុថុជ្ជនដែលបានចម្រើនអរូបាវចរកុសល គឺអរូបាវចរឈានទាំង ៤ នោះក៏ទៅកើតក្នុងអរូបភូមិទាំង ៤ តាមលំដាប់នៃអរូបឈានដែលខ្លួនបាន ។

*ឥត្ថំ មហគ្គតំ បុញ្ញំ យថាភូមិវវត្ថិតំ*
*ជនេតិ សទិសំ បាកំ បដិសន្ធិប្បវត្តិយំ ។*

មហគ្គតកុសល គឺកុសលដែលចម្រើនរូបឈាន និងអរូបឈាននេះតែងឱ្យកើតវិបាកកំណត់តាមភូមិដូចគ្នាក្នុងបដិសន្ធិកាល និងបវត្តិកាល ។

( អរូបាវចរកុសលកម្ម និងកម្មចតុកៈ ចប់ )

**អំពីនេះនឹងសម្ដែងនូវមរណចតុកៈ ៤ ប្រការតទៅ :**

សេចក្ដីកើតឡើងនៃមរណៈមាន ៤ គឺមរណៈដោយអស់អាយុ ១ មរណៈដោយអស់បុណ្យ ១ មរណៈដោយអាយុនិងបុណ្យទាំង ២ នេះចុះព្រមគ្នា ១ មរណៈដោយកម្មចូលទៅកាត់បង់ ១ ។

ក្នុងកាលនៃសត្វដែលជិតនឹងមរណៈនោះ ជួនកាលមានកម្មគឺកុសល ឬអកុសលដែលនឹងឱ្យបដិសន្ធិក្នុងភពខាងមុខមកប្រាកដជាអារម្មណ៍ខ្លះ ជួនកាលមានកម្មនិមិត្តគឺវត្ថុដែលជា

គ្រឿងធ្វើកុសល ឬអកុសលមានរូបជាដើម ដែលខ្លួនធ្លាប់បានហើយ កាលវេលាធ្វើកម្មគឺកុសល ឬអកុសល គ្រឿងដែលធ្វើនោះក៏មកប្រាកដជាអារម្មណ៍ខ្លះ ជួនកាលមានគតិនិមិត្តគឺគ្រឿងបរិភោគដែលខ្លួននឹងគប្បីបានក្នុងភព ដែលនឹងទៅកើតជាលំដាប់ មកប្រាកដជាអារម្មណ៍ខ្លះ សត្វដែលនឹងជិតស្លាប់អារម្មណ៍ ៣ យ៉ាងគឺ កម្ម ១ កម្មនិមិត្ត ១ គតិនិមិត្ត ១ ចំណែកឯណាមួយគង់នឹងមានមកប្រាកដក្នុងទ្វារឯណាមួយមិនខាន ដោយកម្លាំងនៃកម្មជាកុសល ឬអកុសលដោយពិត ។

កម្មដែលជាកុសលនោះ គឺខ្លួនធ្លាប់ឱ្យទាន រក្សាសីល ស្តាប់ធម៌ និងចម្រើនភាវនាធ្លាប់ធ្វើយ៉ាងណា ក៏ប្រាកដដូចកំពុងធ្វើយ៉ាងនោះ មរណាសន្នជវនក៏កាន់យកជាអារម្មណ៍។

កម្មចំណែកខាងអកុសលនោះគឺ ខ្លួនធ្លាប់សម្លាប់សត្វ លួចទ្រព្យ ឆបំបាត់និងវាយដំសំពងចងសត្វទាំងពួងយ៉ាងណា ក៏ប្រាកដក្នុងទ្វារដូចកំពុងធ្វើយ៉ាងនោះ មរណាសន្នជវនក៏កាន់យកជាអារម្មណ៍ ។

កម្មនិមិត្តចំណែកកុសលនោះគឺ នឹងឃើញគ្រឿងដែលធ្វើកុសលក្នុងបច្ចុប្បន្នជាតិនេះមានសំពត់ និងគ្រឿងសក្ការៈផ្សេងៗជាដើមមកប្រាកដក្នុងទ្វារ មរណាសន្នជវនក៏កាន់យកជាអារម្មណ៍ ។

កម្មនិមិត្តចំណែកអកុសលនោះគឺ នឹងឃើញគ្រឿងដែលបៀតបៀនសត្វផ្សេងៗដែលខ្លួនធ្លាប់យកទៅធ្វើក្នុងជាតិនេះមានដាវ លំពែង មង និងអញ្ចងជាដើមមកប្រាកដក្នុងទ្វារមរណាសន្នជវនក៏កាន់យកជាអារម្មណ៍ ។

គតិនិមិត្តមាន ២ យ៉ាងគឺសុគតិ ១ ទុគ្គតិ ១ ។ សុគតិ គឺដំណើរដែលនឹងទៅល្អនោះ គឺនឹងឃើញវិមានប្រាសាទ, ទិព្វសម្បត្តិ និងនាងទេវអប្សរជាដើមសុទ្ធតែចំណែកដែលល្អ ។

ទុគ្គតិ គឺដំណើរដែលនឹងទៅសោយទុក្ខនោះគឺ នឹងឃើញអណ្តាតភ្លើងនាយនិរយបាល ឆ្កែ និងត្មាតជាដើមដែលនឹងមកបៀតបៀនខ្លួន ធម្មជាតិ ឬអារម្មណ៍ឯណាមួយ គង់នឹងមកប្រាកដក្នុងទ្វារជាអារម្មណ៍នៃមរណាសន្នជវន ហើយក៏ជាអារម្មណ៍នៃបដិសន្ធិ ភវង្គចុតិ ក្នុងភពខាងមុខតទៅ ។

កម្មដែលនឹងមកប្រាកដនោះគឺ មកប្រាកដក្នុងមនោទ្វារ មិនប្រាកដដល់ទ្វារទាំង ៥ នោះឡើយ កម្មនោះប្រាថ្នាយកកម្មជាអតីត ដែលធ្វើហើយយ៉ាងណាក៏ឃើញដូចកំពុងធ្វើយ៉ាងនោះឯង ។

កម្មនិមិត្តនោះមាន ២ យ៉ាងគឺជាអតីត ១ បច្ចុប្បន្ន ១, កម្មនិមិត្តជាអតីតនោះប្រាកដក្នុងមនោទ្វារ, កម្មនិមិត្តជាបច្ចុប្បន្ននោះប្រាកដក្នុងទ្វារទាំង ៥ ។

គតិនិមិត្តជាកុសល ឬជាអកុសលនោះ ប្រាកដក្នុងមនោទ្វារតែម្យ៉ាង ដូចគ្នានឹងកម្មនោះផង, កាលកម្ម កម្មនិមិត្ត គតិនិមិត្តមកប្រាកដហើយ ខាងមុខអំពីនោះមរណាសន្នជវនក៏ទាញតោងយកនូវហេតុ ៣ ហេតុចំណែកណាមួយជាអារម្មណ៍ មិនខានឡើយ ។

សត្វនោះក៏ឱនចិត្តទៅកាន់ភពដ៏គួរនឹងកើត សមគួរដល់កម្មជាបុណ្យ ឬជាបាប ដែលនឹងឱ្យដល់នូវសេចក្ដីបរិសុទ្ធ និងសៅហ្មង ។

ចិត្តសន្តានគឺមរណាសន្នជវន ក៏ប្រព្រឹត្តទៅរឿយៗដោយច្រើន អ្នកប្រាជ្ញគប្បីដឹងថា កុសលាកុសលដែលនឹងប្រាកដក្នុងមនោទ្វារវិថីនោះ មាននាមថាជនកកម្ម ជាមរណាសន្ន–វិថី ជាភ្នាក់ងារតាក់តែងជាតិ ភពថ្មីឱ្យដោយសមគួរដល់កម្លាំងក្នុងទីបំផុតនៃជវន ជួនកាលចុតិចិត្តកើតក្នុងទីបំផុតនៃតទាលម្ពណៈ ជួនកាលចុតិចិត្តកើតក្នុងទីបំផុតនៃភវង្គ ។

ចុតិចិត្តនោះកើតក្នុងទីបំផុតនៃបច្ចុប្បន្នភព កើតឡើងខណៈ ១ ហើយក៏រលត់ទៅក៏ជាបំផុតចប់អស់បច្ចុប្បន្នជាតិចុះក្នុងខណៈនៃចុតិចិត្តកើតឡើងប៉ុណ្ណោះ ។

ក្នុងខណៈចុតិចិត្តកើតឡើងខណៈ ១ ហើយរលត់ទៅនោះ បដិសន្ធិចិត្ត ក៏កើតតទៅក្នុងភពខាងមុខ ទាញតោងយកអារម្មណ៍នៃមរណាសន្នជវន ៧ កាន់យកចំណែកឯណាជាអារម្មណ៍ បដិសន្ធិចិត្តនោះក៏កាន់យកចំណែកនោះជាអារម្មណ៍បដិសន្ធិចិត្តក្នុងភពថ្មីនោះ ជួនកាលប្រកបដោយកម្មជរូប ជួនកាលក៏មិនប្រកបដោយកម្មជរូប ។

ដែលប្រកបដោយកម្មជរូបនោះ គឺបដិសន្ធិក្នុងបញ្ចវោការភព គឺភពដែលមាខន្ធ ៥ ដែលមិនប្រកបដោយកម្មជរូបនោះ គឺអរូបភព ។

បដិសន្ធិក្នុងភពថ្មីនោះ មានកុសលាកុសលគឺអវិជ្ជានុសយៈព័ទ្ធជុំវិញហើយមានដែលមានតណ្ហានុសយៈជាមូលឱ្យកើតឡើង មានចេតសិកទាំងឡាយជាអ្នកឧបត្ថម្ភដឹកនាំបដិសន្ធិចិត្តឱ្យកើតឡើងមុន ដោយភាវៈមានសហជាតធម៌ជាប្រធានវិបាកចិត្តហៅថាបដិសន្ធិដោយអំណាចដែលតមិនឱ្យដាច់ក្នុងភពខាងមុខ ឱ្យកើតឡើងតាំងនៅក្នុងភពជាលំដាប់ ។

ក្នុងមរណាសន្នវិថីនោះ ជវនចិត្តមានកម្លាំងទន់ប្រាកដត្រឹម ៥ ខណៈព្រោះហេតុនោះ កម្ម កម្មនិមិត្ត និងគតិនិមិត្ត មកប្រាកដតាំងនៅមិនកន្លង ១៧ ខណចិត្ត ចុតិចិត្តក៏កើតឡើងសត្វនោះក៏ច្យុត គឺថាល្អិលឃ្លាតចេញចាកភវង្គ ចិត្តក៏ឈានទៅតាំងបដិសន្ធិក្នុងភពខាងមុខ អាស្រ័យកម្ម កម្មនិមិត្ត និងគតិនិមិត្តមកប្រាកដតាំងនៅមិនទាន់គ្រប់ ១៧ ខណចិត្តអារម្មណ៍នៅបច្ចុប្បន្ន ។

បដិសន្ធិក្នុងភពថ្មី និងភវង្គចិត្តមុខបដិសន្ធិក៏មានបច្ចុប្បន្នារម្មណ៍ក្នុងភពនេះជាអារ-ម្មណ៍លឿនរហូតទៅដល់ភពខាងមុខនេះ ដូចសំឡេងស្គរដែលបុគ្គលវាយក្នុងទីឯណោះហើយលឿនរហូតក្នុងទៅទីឯណោះ កាមាវចរបដិសន្ធិមានកម្ម កម្មនិមិត្ត និងគតិនិមិត្តជាបច្ចុប្បន្នារម្មណ៍ផង ជាអតីតារម្មណ៍ផង ប្រព្រឹត្តក្នុងទ្វារទាំង ៦ កម្មនោះជាអតីតកាន់យកនូវអារម្មណ៍ដោយមនោទ្វារចំណែក ១ កាមាវចបដិសន្ធិទាំងឡាយមានកម្ម កម្មនិមិត្ត និងគតិនិមិត្តជាអារម្មណ៍ជាអារម្មណ៍ទាំងពួងនោះ បណ្ឌិតប្បីដឹងដោយបការដូច្នេះឯង ។

រូបាវចរបដិសន្ធិ មានតែកម្មនិមិត្តចំណែក ១ គឺកសិណបញ្ញត្តិជាអារម្មណ៍ ។

អរូបាវចរបដិសន្ធិ មានតែកម្មនិមិត្តចំណែក ១ គឺអាកាសានញ្ចាយតនបញ្ញត្តិជាដើមជាអារម្មណ៍ ។

អសញ្ញីសត្វបដិសន្ធិដោយជីវិតនវកៈ ព្រោះហេតុនោះបដិសន្ធិរបស់អសញ្ញិសត្វបានឈ្មោះថារូបបដិសន្ធិ ។

អរូបព្រហ្មឈ្មោះថា អរូបបដិសន្ធិ ។

សត្វដទៃក្រៅចាកអសញ្ញី និងអរូបនោះ ឈ្មោះថារូបារូបបដិសន្ធិ ព្រោះហេតុថាមានទាំងរូប ទាំងនាម ។

លក្ខណចុតិ និងបដិសន្ធិ កើតជាលំដាប់គ្នា និងមិនជាលំដដាប់គ្នានោះ អ្នកប្រាជ្ញគប្បីដឹងតាមគាថានេះ :

*អរូប្បចុតិយា ហោន្តិ* *ហេដ្ឋិមារូប្បវជ្ជិតា*
*បរមារូប្បសន្ធិ ច* *តថា កាមេតិហេតុកា ។*
*រូបាវចរចុតិយា* *អហេតុរហិតា សិយុំ*
*សព្វា កាមតិហេតុម្ហា* *កាមេស្វេវ បនេតរា ។*

សត្វដែលចុតិចាកអរូបព្រហ្មហើយ នឹងកើតក្នុងអរូបព្រហ្មទៀត តែងកើតក្នុងអរូបព្រហ្មជាន់លើ ធម្មតាអរូបបដិសន្ធិនឹងកើតខាងមុខនៃចុតិនោះ តែងវៀរអរូបព្រហ្មជាន់-ទាប ព្រោះហេតុអ្នកដែលចម្រើនភាវនានោះ តែងនឿយណាយចាកឈានជាន់ទាបជា — ប្រក្រតីធម្មតា បើចុតិចាកអរូបខាងមុខនៃឧបចារជវននិងអនុលោមជវន បើកើតក្នុងកាមភព កើតជាត្រៃហេតុកៈ សត្វទាំងឡាយបើចុតិចាករូបភពមកកើតក្នុងកាមភព មកកើតជាត្រៃហេតុខ្លះ ទុហេតុខ្លះ មិនកើតជាអហេតុកៈ សត្វនឹងមិនកើតក្នុងអបាយភូមិឡើយ ព្រោះកម្លាំងឈានខ្លាំងជាងកាមាវចរកុសល ។

កាលដើម សត្វអហេតុ ទុហេតុ ត្រៃហេតុ លុះចុតិទៅកើតក្នុងភព ៣ ក៏ជាត្រៃហេតុខ្លះ ទុហេតុខ្លះ អហេតុខ្លះ ចំណែកសត្វក្នុងកាមាវចរទាំងឡាយ ដើមជាទុហេតុកខ្លះ អហេតុខ្លះ លុះចុតិទៅកើតក្នុងកាមភពទៀត បដិសន្ធិជាត្រៃហេតុខ្លះ ជាទុហេតុខ្លះ ជាអហេតុខ្លះ ដោយអធិប្បាយថា ខាងមុខអំពីចុតិជាត្រៃហេតុ ៣ នោះគឺកើតជាត្រៃហេតុខ្លះ ទុហេតុខ្លះ អហេតុខ្លះ បើកាមាវចរចុតិជាទុហេតុ អហេតុបដិសន្ធិជាទុហេតុខ្លះ ជាអហេតុខ្លះ ។

អ្នកដែលចុតិចាករូបភពនោះ តែងបដិសន្ធិក្នុងមនុស្ស និងឆកាមាវចរនិងរូបភព និងអរូបភព ។

បើចុតិចាកមនុស្ស និងឆកាមាវចរ បដិសន្ធិមិនទៀង ជួនកាលកើតក្នុងអបាយខ្លះ ក្នុងមនុស្សខ្លះក្នុងឆកាមាវចរខ្លះ ក្នុងរូបភពខ្លះ ក្នុងអរូបភពខ្លះ តាមគួរដល់បុណ្យនិងបាប ក្នុងមរណាសន្នវិថី ។

បើចុតិចាកអបាយ កើតក្នុងអបាយខ្លះ ក្នុងមនុស្សខ្លះ ក្នុងឆកាមាវចរខ្លះ តែមិនអាច កើតក្នុងព្រហ្មលោកបាន ព្រោះសត្វក្នុងអបាយមិនអាចចម្រើនឈានសមាបត្តិបានឡើយ ។

( សម្តែងលំដាប់ចុតិបដិសន្ធិ ក្នុងវិថីមុត្តសង្គហៈ ចប់ )

កាលសត្វទាំងឡាយមានបដិសន្ធិកាន់យកយ៉ាងនេះហើយបដិសន្ធិកើតខណៈ ១ ហើយ ក៏រលត់ទៅ កាលវិថីចិត្តដទៃមិនមានចិត្តដែលបដិសន្ធិនោះឯង តោងយកនូវអារម្មណ៍នោះ ដាច់ស្ងប់ចុះ ហើយត្រឡប់ជាភវង្គសន្តតិដោយភាវៈជាអង្គនៃភព ហើយប្រព្រឹត្តទៅអស់ជាតិ រហូតដល់ចុតិចិត្តកើតឡើងទៀត ភវង្គកើតឡើងមិនដាច់ ប្រព្រឹត្តទៅដូចខ្សែទឹកហូរ ។

ក្នុងទីបំផុតនៃជាតិមុននោះ ចុតិចិត្តកើតឡើងខណៈ ១ ហើយក៏រលត់ទៅ ចិត្តទាំង-ឡាយ មានបដិសន្ធិចិត្តជាដើម ក៏កើតតៗគ្នាទៅខាងមុខអំពីចុតិចិត្តរលត់ហើយនោះ វិល-ទាំងជាតិទាំងភព មិនដឹងអស់ មិនដឹងផុត ដូចចក្ររថគឺកង់រទេះដែលវិលទៅតាមដានជើង សេះ ជើងគោដូច្នោះឯង ។

*បដិសន្ធភវង្គវិថិយោ ចុតិ ចេហ តថា ភវន្តរេ*
*បុន សន្ធិភវង្គមិច្ចយំ បរិវត្តតិ ចិត្តសន្តតិ ។*
*បដិសង្ខាយ បនេតមទ្ធុវំ អធិគន្ត្វា បទមច្ចុតម្ពុធា*
*សុសមុច្ឆិន្នសិនេហពន្ធនា សមមេស្សន្តិ ចិរាយ សុព្វតោ ។*

បដិសន្ធិនិងភវង្គចិត្តនិងវិថីចិត្តនិងចុតិចិត្តក្នុងជាតិនេះជាប់គ្នាយ៉ាងណាក្នុងភពខាង-មុខៗតទៅទៀត ក៏ជាប់គ្នាយ៉ាងនោះឯង អ្នកប្រាជ្ញទាំងឡាយមកពិចារណាឃើញសង្ខារ-នេះមិនទៀង មិនឋិតថេរលោកក៏ធ្វើព្យាយាមក្នុងសមថៈនិងវិបស្សនាបានដល់នូវនិព្វាន ជាធម៌ដ៏មិនចុតិ លោកមានធម៌ជាគ្រឿងចងគឺសេចក្តីសិនេហាកាត់ដាច់ស្រេចហើយ លោក-មានវត្តប្រតិបត្តិដ៏ល្អមកយូរហើយ និងដល់នូវធម៌ជាគ្រឿងរំងាប់រំលត់កិលេស ឈ្មោះថា ខន្ធបរិនិព្វានរំលត់កម្មជរូប និងវិបាកខន្ធ មិនតភពថ្មីទៀត សោយវិមុត្តិសុខប្រសើរជាង សុខទាំងពួង ។

*ឥតិ អភិធម្មត្ថសង្គហេ*

*វិថីមុត្តសង្គហវិភាគោ នាម បញ្ចមោ បរិច្ឆេទោ*

បរិច្ឆេទទី ៥ ឈ្មោះវិថីមុត្តសង្គហវិភាគ ក្នុងអភិធម្មត្ថសង្គហៈ

ចប់តែប៉ុណ្ណេះហោង

ការដែលបែងចែករួបរួមចិត្ត ចេតសិក ក្នុងអភិធម្មត្ថសង្គហៈ

ក៏អស់សេចក្ដីតែប៉ុណ្ណេះ ។

# បរិច្ឆេទទី ៦

## រូបសង្គហវិភាគ

*ឯត្តាវតា វិភត្តា ហិ សប្បភេទប្បវត្តិកា*
*ចិត្តចេតសិកា ធម្មា រូបន្ទានិ បវុច្ចតិ ។*
*សមុទ្ទេសា វិភាគា ច សមុដ្ឋានា កលាបតោ*
*បវត្តិកមតោ ចេតិ បញ្ចធា តត្ថ សង្គហោ ។*

ធម៌ទាំងឡាយគឺ ចិត្ត និងចេតសិកប្រព្រឹត្តទៅមួយអន្លើដោយប្រភេទនិងបវត្តិកាល បានសម្តែងមកហើយក្នុងបរិច្ឆេទទាំង ៥ មានប្រមាណប៉ុណ្ណោះ ។

ឥឡូវនេះ នឹងរួបរួមនូវរូបពោលនូវប្រភេទនៃន័យ ៥ ប្រការគឺ សមុទ្ទេសន័យ ១ វិភាគន័យ ១ សមុដ្ឋានន័យ ១ កលាបន័យ ១ បវត្តិកមន័យ ១ ។

ក្នុងបរិច្ឆេទទី ១ និងទី ២ សម្តែងនូវប្រភេទនៃចិត្ត និងចេតសិកដោយន័យ ៣ យ៉ាង គឺឧទ្ទេសន័យ ១ និទ្ទេសន័យ ១ បដិទេសន័យ ១ ។ ឧទ្ទេសន័យនោះសម្តែងដោយសង្ខេបថា ចិត្ត ចេតសិកប្រព្រឹត្តទៅក្នុងភូមិ ៤, និទ្ទេសន័យនោះសម្តែងដោយសរុបរួមពោលថា ចិត្ត ចេតសិក ជាកាមាវចរ រូបាវចរ អរូបាវចរ និងលោកុត្តរប៉ុណ្ណោះៗ ។ បដិទេសន័យនោះ សម្តែងពិស្តារជាសម្បយោគ និងសង្គហៈថាចេតសិកប៉ុណ្ណោះ កើតក្នុងចិត្តប៉ុណ្ណោះ ។

ក្នុងបរិច្ឆេទទី ៣ សម្តែងអំពីវេទនាសង្គហៈ និងហេតុ និងចិត្ត និងទ្វារនិងអារម្មណ៍ និងវត្ថុសង្គហៈ ។

ក្នុងបរិច្ឆេទទី ៤ ទី ៥ សម្តែងអំពីបវត្តិសង្គហៈគឺអាការចិត្ត និងចេតសិកកើតក្នុង បដិសន្ធិកាល និងបវត្តិកាលរហូតដល់ចុតិចិត្តកើតឡើង ។

ក្នុងបរិច្ឆេទទី ៦ នេះ សម្តែងដោយន័យ ៥ គឺសមុទ្ទេសន័យ សម្តែងដោយសង្ខេប ១, វិភាគន័យសម្តែងដោយចំណែកចេញ ១, សមុដ្ឋានន័យសម្តែងអំពីបច្ច័យជាហេតុឱ្យកើតរូប ១, កលាបន័យសម្តែងអំពីរូបដែលកើតព្រមៗគ្នាជាពួក ១, បវត្តិកមន័យសម្តែងអំពីរូប ដែលកើតដោយលំដាប់នៃភព និងកាល និងសត្វ ។

ឥឡូវនេះ នឹងសម្ដែងសមុទ្ទេសន័យ ពោលដោយសង្ខេបនោះមុន រូបនោះមាន ២ ពួកគឺ មហាភូតរូប ១ ឧបាទាយរូប ១ ហើយសង្គ្រោះចេញទៅទៀតចាត់ជា ១១ ពួក ។

សួរថា រូបចាត់ជា ១១ ពួកនោះ ដូចម្ដេចខ្លះ?

ឆ្លើយថា រូប ១១ ពួកនោះគឺ មហាភូតរូប ១ បសាទរូប ១ គោចររូប ១ ភាវរូប ១ ហទយរូប ១ ជីវិតរូប ១ អាហាររូប ១ បរិច្ឆេទរូប ១ វិញ្ញត្តិរូប ១ វិការរូប ១ លក្ខណរូប ១ ជារូប ១១ ពួកដូច្នេះ ។

មហាភូតរូប ៤ គឺ បថវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ ជាមហាភូតរូប ៤ ។

បសាទរូប ៥ គឺ ចក្ខុបសាទ ១ សោតបសាទ ១ ឃានបសាទ ១ ជិវ្ហាបសាទ ១ កាយបសាទ ១ ។

ធាតុ ៤ នោះទំនុកបំរុងប្រសាទទាំង ៥ ទុកមិនឱ្យវិនាសគឺ បថវីធាតុទ្រទ្រង់ទុកមិនឱ្យធ្លាក់ទៅ, អាបោធាតុផ្គងទុកមិនឱ្យខ្ចាត់ខ្ចាយរាត់រាយទៅ, តេជោធាតុអប់កំដៅទុកមិនឱ្យហើមស្អុយរលួយទៅ, វាយោធាតុបក់ត្រឡប់ទៅមកក្នុងខាងឆ្វេង ខាងស្ដាំ ដូចស្រីភីលៀង ឬមេដោះទាំង ៤ នាក់ដែលថែទាំទំនុកបំរុងព្រះរាជកុមារនាងមួយបីពរ នាងមួយស្រង់-ជម្រះឱ្យអស់មន្ទិល នាងមួយយកសុគន្ធរសមកលាបស្រឡាបប្រស់ព្រំ នាងមួយបោស-អង្អែលបក់ផាត់ថ្វាយ ។

គោចររូបមាន ៧ គឺ រូប ១ សទ្ទៈ ១ គន្ធៈ ១ រសៈ ១ ផោដ្ឋព្វៈ ១ តែផោដ្ឋព្វៈនោះចែកចេញជា ៣ គឺបថវី ១ តេជោ ១ វាយោ ១ ត្រូវជា ៧ ។

អាបោធាតុនោះមិនរាប់ជាគោចររូបឡើយ ព្រោះល្អិតក្រៃពេកណាស់ដូចទឹកដែលអាស្រ័យជីកង្វួតសព្វថ្ងៃនេះ មានបថវីរក្សាទុកនៅ ទើបចាប់ពាល់ត្រូវបាន បើមិនមានបថវីធាតុលាយឡំផង ទំនើងតែអាបោធាតុម្យ៉ាងហើយ ក៏សាបសូន្យជ្រួតជ្រាបទៅក្នុងភាជនៈអស់មិនមានសល់ នឹងចាប់ពាល់ត្រូវក៏មិនបាន ព្រោះហេតុនេះ ទើបលើកអាបោធាតុចេញមិនរាប់យកជាផោដ្ឋព្វារម្មណ៍ឡើយ ។

ភាវរូប ២ គឺឥត្ថីភាវរូប ប្រកាសភេទស្រីឱ្យប្រាកដ ១ បុរិសភាវរូប ប្រកាសភេទ - ប្រុសឱ្យប្រាកដ ១ ។

ហទយរូប គឺទឹកឈាមដែលរក្សាបេះដូងប្រមាណ ១ ទូកដៃយាំងនៅក្នុងទីចន្លោះល្មមចុះគ្រាប់បុសនាគ នៅខាងក្នុងសាច់បេហដូង ១ ។

ជីវិតរូប គឺជីវិតិន្ទ្រិយ គឺធម្មជាតិដែលចិញ្ចឹមរក្សាទុកកម្មជរូបដែលកើតព្រមនឹងខ្លួន ១ អាហាររូប គឺកវឡិង្ការាហា ១ ។

រូបដែលពោលមកនេះ ១៨ គោចររូប ៧ នោះឱ្យរាប់យកតែ ៤ គឺរូប ១ សទ្ទ: ១ គន្ធ: ១ រស: ១ ឯបថវី តេជោ វាយោ ៣ នេះ ឱ្យរាប់ចូលក្នុងមហាភូតរូបទើបរាប់ថា មហាភូតរូប ៤ បសាទ ៥ គោចររូប ៤ ភាវរូប ២ ហទយរូប ១ ជីវិតរូប ១ អាហាររូប ១ ជារូប ១៨ ។

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ត្រាស់ទុកថា រូបបានឈ្មោះហៅដោយអត្ថ ៥ ប្រការគឺ សភាវរូប ១ លក្ខណរូប ១ និប្ផន្នរូប ១ រូបរូប ១ សម្មសនរូប ១ ជា ៥ ។

ហៅថា សភាវរូបនោះ សេចក្តីថា រឹង ជ្រួតជ្រាប អប់កំដៅ និងបក់ឱ្យញ័រជាប្រក្រតីធម្មតានៃខ្លួន បានខាងមហាភូតទាំង ៤ នោះឯង ។

ហៅថា លក្ខណរូបនោះ សេចក្តីថាប្រកបដោយអនិច្ចាទិលក្ខណៈកើតហើយរលត់ទៅ មិនយឺនយូរឋិតថេរឡើយ ។

ហៅថា និប្ផន្នរូបនោះ សេចក្តីថា សម្រេចដោយបច្ច័យគឺកុសលាកុសល អវិជ្ជា និងតណ្ហាប្រជុំតាក់តែង ។

ហៅថា រូបរូបនោះ សេចក្តីថា បង្កើតប្លែកៗ ផ្សេងៗ និងវិនាសដោយក្តៅ និងត្រជាក់ជាដើម ។

ហៅថា សម្មនរូបនោះ សេចក្តីថា គួរដល់ព្រះយោគាវចរនឹងគប្បីពិចារណាយកជាអារម្មណ៍ នៃសមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន ។

នៅមានរូប ១០ ទៀតគឺ បរិច្ឆេទរូប ១ វិញ្ញត្តិរូប ២ វិការរូប ៣ លក្ខណរូប ៤ ។

បរិច្ឆេទរូប ១ នោះគឺ បានដល់ទីដ៏ជាចន្លោះនៅក្នុងកាយ មានប្រហោងច្រមុះ និងប្រហោងត្រចៀកជាដើម ។

វិញ្ញត្តិ ២គឺកាយវិញ្ញត្តិ ៤ វចីវិញ្ញត្តិ ១ ។ កាយវិញ្ញត្តិនោះ គឺរូបដែលជាបច្ច័យឱ្យសម្រេចឥរិយាបថ ៤ ដោយវាយោធាតុដ៏កើតអំពីចិត្ត ។ វចីវិញ្ញត្តិនោះ គឺរូបដែលជាបច្ច័យឱ្យបថវីធាតុដែលកើតអំពីឧប់ឧបាទិណ្ណករូប ជាទីកើតអក្សរឱ្យពោលភាសាផ្សេងៗ ។

វិការរូប ៣ នោះគឺ រូបស្សលហុតា ភាវៈនៃរូបស្រាលរហ័ស ១ រូបស្សមុទុតា ភាវៈនៃរូបទន់ រូបមិនរឹង ១ រូបស្សកម្មញ្ញតា ភាវៈនៃរូបគួរក្នុងទីធ្វើការបានដូចប្រាថ្នា ១ ត្រូវជា ៣ ប្រការ ។

លក្ខណរូប ៤ នោះគឺ រូបស្សឧបចយោ សេចក្ដីសន្សំនៃរូបជាបឋម តាំងតែពីបដិសន្ធិមកដរាបដល់កើតចក្ខុទសកៈ សោតទសកៈ ប្រការ ១, រូបស្សសន្តតិរូប ដែលកើតអំពីនោះទៅនៅមិនទាន់ដល់គ្រាំគ្រា ហៅថាការតនៃរូប ប្រការ ១, រូបស្សជរតា សេចក្ដីគ្រាំគ្រានៃរូបទាំង ២ នោះប្រការ ១, រូបស្សអនិច្ចតា ភាវៈនៃរូបទាំង ៣ នោះជារូបមិនទៀង មិនឃើនយូរឋិតថេរប្រការ ១ ។

ឧច្ចយរូប ១ សន្តតិរូប ១ រូប ២ ប្រការនេះ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ហៅថាជាតិរូប ។

( សម្ដែងមកក្នុងសមុទ្ទេសន័យ ចប់ )

**អំពីនេះនឹងសម្ដែងក្នុងវិភាគន័យតទៅ :**

រូបទាំងអស់នេះមានដល់ ៣៨ បើនឹងថាជារូបតែ ១ ក៏បានដោយសេចក្ដីថា រូបមិនប្រាកដដោយហេតុ ៦ ប្រការមានលោភៈជាដើម រូបកលាបៈនេះប្រកបដោយបច្ច័យអាស្រ័យដោយបច្ច័យ ទើបកើតអាសវៈនៅក្នុងអំណាចជរា ព្យាធិ កើតរលត់ដូចគ្នាទាំងអស់ រូបទាំងពួងនោះគឺ អវិជ្ជា តណ្ហាប្រជុំតាក់តែងគាំទ្រដល់លោកជាកាមាវចរម្យ៉ាង រូបកើតអំពីបច្ច័យគឺ អវិជ្ជា តណ្ហា កម្ម និងអាហារ មិនតោងយកអ្វីជាអារម្មណ៍បាន រូបនោះព្រះ - អរិយជាម្ចាស់មិនអាចកាត់ឱ្យដាច់បានឡើយ ។

រូប ២៨ ប្រការ នោះ កាលសម្ដែងចេញដោយឱកាសមានខាងក្នុង ខាងក្រៅជាដើម ក៏មានប្រភេទដ៏ច្រើន គឺចាត់ចេញទៅយ៉ាងនេះគឺ បសាទរូប ៥ ឈ្មោះ អជ្ឈត្តិករូបនៅសល់ ២៣ ឈ្មោះពាហិររូប បសាទ ៥ ហទយរូប ១ ជា ៦ ឈ្មោះវត្ថុរូប នៅសល់ ២២ឈ្មោះ អវត្ថុរូប បសាទរូប ៥ វិញ្ញត្តិរូប ២ ជា ៧ ឈ្មោះទ្វាររូប នៅសល់ ២១ ឈ្មោះអទ្វាររូប បសាទរូប ៥ ភាវរូប ២ ជីវិតរូប ១ ជា ៨ ឈ្មោះឥន្ទ្រិយរូប នៅសល់រូប ២០ ឈ្មោះថា អនិន្ទ្រិយរូប បសាទរូប ៥ វិសយរូប ៧ ជា ១២ មានឈ្មោះ ៣ យ៉ាងគឺ ឱឡារិករូប ១ សន្តិករូប ១ សប្បដិឃរូប ១ នៅសល់រូប ១៦ មានឈ្មោះ ៣ យ៉ាងគឺសុខុមរូប ១ ទូររូប ១ អប្បដិឃរូប ១ កលាប ៨ អាកាសរូប ១ បសាទ ៥ ហទយ ១ ជីវិត ១ ភាវរូប ១ ជា ១៨ ឈ្មោះ ២ យ៉ាងគឺ កម្មជរូប ១ ឧបាទិណ្ណករូប ១ នៅសល់រូប ១០ មានឈ្មោះ ២ យ៉ាងគឺ នេវកម្មជរូប ១ អនុបាទិណ្ណករូប ១ រូបាយតនៈ ១ ឈ្មោះសនិទស្សនរូប នៅសល់រូប ២៧ ឈ្មោះអនិទស្សនរូប បសាទរូប ៥ ឈ្មោះគោចរគាហិករូប នៅសល់រូប ២៣ ឈ្មោះថា អគោចរគាហិករូប ។

ចក្ខុបសាទ ១ សោតបសាទ ១ ទាំង ២ នេះទៅទទួលយករូបារម្មណ៍ សទ្ទារម្មណ៍ ក្នុងទីឆ្ងាយបាន ឃានបសាទ ជិវ្ហាបសាទ កាយបសាទ ទាំង ៣ នេះកាលគន្ធារម្មណ៍ រសា-រម្មណ៍ ផោដ្ឋព្វារម្មណ៍ មកផ្ទប់ភូតរូបដែលអាស្រ័យមុន ទើបទទួលអារម្មណ៍នោះបាន ប្រសាទទាំង ៥ ទទួលយកអារម្មណ៍បានស្មើគ្នា ទើបឈ្មោះថាគោចរគាហិករូប វណ្ណៈ ១ គន្ធៈ ១ រសៈ ១ ឱជៈ ១ ភូតរូប ៤ ជា ៨ ឈ្មោះថា អវិនិព្ភោគរូប នៅសល់ ២០ ឈ្មោះថា វិនិព្ភោគរូប ។

*ឥច្ចេវមដ្ឋវីសតិ        វិធម្បិ ច វិចក្ខណា*
*អជ្ឈត្តិកាទិភេទេន        វិភជន្តិ យថារហំ ។*

វិចក្ខណបណ្ឌិតទាំងឡាយលោកចែករូប ២៨ ចេញទៅដោយប្រភេទមានអជ្ឈត្តិក-រូបជាដើម ដោយសមគួរ ដោយប្រការដូច្នេះ ។

( ចប់វិភាគន័យ )

**អំពីនេះនឹងសម្តែងនូវសមុដ្ឋានន័យតទៅ :**

រូបសមុដ្ឋានមាន ៤ គឺកម្ម ១ ចិត្ត ១ ឧតុ ១ អាហារ ១ ជា ៤ , កម្មគឺ កុសល និងអកុសលញ៉ាំងរូបឱ្យកើតមាន ២៥ គឺកាមាវចរកុសល ៨ រូបាវចរកុសល ៥ អកុសល ១២ ជា ២៥ កម្មជរូបកើតអំពីកុសល និងអកុសលនោះ កើតព្រមដោយខណៈ ៣ គឺឧប្បាទខណៈ ១ ឋិតិខណៈ ១ ភវង្គខណៈ ១ មានតាំងពីបដិសន្ធិខណទៅគ្រប់ៗខណចិត្ត កើតក្នុងអជ្ឈត្តិក–សន្តាន ។

ចិត្តតាំងរូបឱ្យកើតនោះ ឱ្យកើតតាំងអំពីបឋមភវង្គខាងមុខនៃបដិសន្ធិទៅមាន ៧៥ ចិត្ត គឺចិត្ត ៨៩ នោះលើកទ្វិពញ្ចវិញ្ញាណ ១០ និងអរូបវិបាក ៤ នោះចេញជា ១៤ នៅ ៧៥ ចិត្តជាទីញ៉ាំងរូបឱ្យកើត ។

ចិត្ត ៧៥ នោះអប្បនាជវនចិត្ត ជាអ្នកឧបត្ថម្ភគាំទ្រឱ្យតាំងនៅក្នុងឥរិយាបថបានជាប្រក្រតី កាលកើតភ័យផ្សេងៗ មានភ្លើងឆេះនិងដំរី ខ្លា ចោរ ពស់ កាច មកប្រទុស្ត អប្បនាជវនចិត្ត ក៏ហាមអន្តរាយបាន មិនឱ្យមានមកដល់ ព្រះយោគាវចរ ឧបត្ថម្ភគាំទ្រឱ្យឥរិយាបថជាប្រក្រតី មិនឱ្យកំរើកបាន ។

ចិត្ត ២៣ គឺវោដ្ឋវនៈ ១ កាមាវចរជវន ២៩ អភិញ្ញាជវន ២ ឱ្យសម្រេចកាយវិញ្ញត្តិ វចីវិញ្ញត្តិ អភិញ្ញាជវន ឱ្យសម្រេចឥទ្ធិប្បាដិហារបាន ។

កាមាវចរសោមនស្សជវន ១៣ គឺក្នុងលោភមូល ៤ មហាកុសល ៤ មហាកិរិយា ៤ អហេតុកកិរិយា ១ ជា ១៣ ញ៉ាំងហស្សនចិត្ត គឺចិត្តរីករាយឱ្យកើតបុថុជ្ជនសើចញញឹម–ញញែមដោយមហាកុសល ៤ លោភមូលទិដ្ឋិវិប្បយុត្ត ២ អសេក្ខបុគ្គលញញឹមញញែមដោយមហាកិរិយា ៤ ហសិតុប្បាទ ១ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ញញឹមដោយមហាកិរិយា ៤ ។

ចិត្ត ៧៥ ញ៉ាំងរូបឱ្យកើតនោះ គឺកាមាវចរ ៥៤ លើកទ្វិបញ្ចវិញ្ញាណ ១០ ចេញនៅ ៤៤ រូបាវចរ ១៥ អរូបាវចរ ១២ លើកអរូបាវចរវិបាក ៤ ចេញនៅ ៨ លោកុត្តរចិត្ត ៨ ជា ៧៥ ញ៉ាំងចិត្តជរូបឱ្យកើត ។

តេជោធាតុមាន ២ ប្រការគឺ សីតឧតុ ពេលត្រជាក់ ១ ឧណ្ហឧតុ ពេលធ្វើឱ្យក្តៅ ១ ភ្លើងធាតុទាំង ២ នេះ ញាំងឧតុជរូបឱ្យកើត ចាប់ដើមអំពីឋិតិខណៈនៃបដិសន្ធិចិត្តគ្រប់ៗខណចិត្ត ។

ភ្លើងធាតុក្នុងខាងក្នុងសន្តានសត្វ ញាំងឧតុជរូបខាងក្នុងឱ្យកើតភ្លើងធាតុខាងក្រៅ គឺភ្លើងធាតុក្នុងដើមឈើ ដើមអន្លក់ ដើមស្មៅ ភ្នំ និងអាកាសជាដើម ញាំងឧតុជរូបខាងក្រៅឱ្យកើត ។

អាហារឱ្យកើតរូបនោះ បើសត្វកើតក្នុងគភ៌នៃមាតា ឱជៈនៃអាហារដែលមាតាបិតាបរិភោគចូលទៅនោះ ក៏ជ្រួតជ្រាបចូលទៅឱ្យកើតរូបនៃទារកក្នុងឋិតិខណៈ ។

បើសត្វកើតជាសំសេទជៈ ឧបបាតិកៈ កាលកើតនោះមានរូបកាយគ្រប់បរិបូណ៌ហើយ តែនៅមិនទាន់បានបរិភោគអ្វីនីមួយឡើយ បានតែសេម្ហៈគឺស្លេស្ម និងខេឡៈ គឺទឹកមាត់នៃខ្លួនកន្លងបំពង់កណ្ឋទៅហើយ ឱជៈ សេម្ហៈ និងខេឡៈ ក៏ជ្រួតជ្រាបទៅជាអាហារជរូប ។

ហទយរូប ១ ឥន្ទ្រិយរូប ៨ ជា ៩ ឈ្មោះកម្មជរូប វិញ្ញត្តិរូបទាំង ២ ឈ្មោះថាចិត្តជរូប ។

សំឡេងមានសមុដ្ឋាន ២ គឺចិត្ត ១ រដូវ ១ សំឡេងមានវិញ្ញាណជាចិត្តជរូប សំឡេងមិនមានវិញ្ញាណ គឺសំឡេងអាកាស សំឡេងខ្យល់ សំឡេងតូរ្យតន្ត្រីជាដើមជា ឧតុជរូប ។

លហុតាទិត្រយរូបមានសមុដ្ឋាន ៣ គឺរដូវ ១ ចិត្ត ១ អាហារ ១ អវិនិព្ភោគរូប ៨ អាកាសធាតុ ១ ជា ៩ មានសមុដ្ឋាន ៤ គឺកម្ម ១ ចិត្ត ១ រដូវ ១ អាហារ ១ លក្ខណរូប ៤ មិនមានសមុដ្ឋានឡើយ រូប ២៨ មានសមុដ្ឋាន ១ ខ្លះ ២ ខ្លះ ៣ ខ្លះ ៤ ខ្លះផ្សេងៗគ្នាដូច្នេះ ។

*អដ្ឋារស បណ្ណារស តេរស ទ្វាទសាតិ ច*
*កម្មចិត្តោតុកាហារ- ជានិ ហោន្តិ យថាក្កមំ ។*

រូប ២៨ កើតអំពីកម្ម និងចិត្ត និងរដូវ និងអាហារ ដោយលំដាប់ដូច្នេះគឺជាកម្មជរូប ១៨ ចិត្តជរូប ១៥ ឧតុជរូប ១៣ អាហារជរូប ១២ គិតរួមគ្នាសមុដ្ឋានជារូប ៥៨ដោយពិស្តារ ។

រូបកើតអំពីកម្ម ១៨ គឺហទយរូប ១ ឥន្ទ្រិយរូប ៨ អវិនិព្ភោគរូប ៨ អាកាសធាតុ ១ ជា ១៨ រូបកើតអំពីចិត្ត ១៥ គឺវិការរូប ៣ វិញ្ញត្តិរូប ២ សទ្ទរូប ១ អវិនិព្ភោគរូប ៨ អាកាសធាតុ ១ ជា ១៥ រូបកើតអំពីរដូវ ១៣ គឺសទ្ទរូប ១ វិការរូប ៣ អវិនិព្ភោគរូប ៨ អាកាសធាតុ ១ ជា ១៣ រូបកើតអំពីអាហារ ១២ គឺវិការរូប ៣ អវិនិព្ភោគរូប ៨ អាកាសធាតុ ១ ជា ១២ ។

*ជាយមានទិរូបានំ សភាវត្តា ហិ កេវលំ*

*លក្ខណានិ ន ជាយន្តិ កេហិចីតិ បកាសិតំ ។*

អាចារ្យពួក ១ ពោលថាលក្ខណរូប៤ មិនមានសមុដ្ឋានឡើយព្រោះជារូប កាលកើតក៏កើតឯង កើតឡើងហើយក៏តគ្នាទៅជារូបមិនទៀង តែងវិនាសទៅជាធម្មតាជាប្រក្រតី ។

( សម្តែងក្នុងសមុដ្ឋានន័យ ចប់ )

**អំពីនេះនឹងសម្តែងនូវកលាបន័យតទៅ :**

រូបធម៌ទាំងឡាយមានទីកើតទីរលត់ជាមួយគ្នា មាននិស្ស័យគឺសមុដ្ឋានស្មើជាមួយគ្នា ប្រព្រឹត្តទៅព្រមគ្នា ឈ្មោះរូបកលាបៈមានា ២១ ប្រការគឺកម្មជ្ជកលាបៈ ៩ ចិត្តជ្ជកលាបៈ ៦ ឧតុជ្ជកលាបៈ ៤ អាហារជ្ជកលាបៈ ២ រួមជា ២១ ។

កម្មជ្ជកលាបៈកើតខាងក្នុង ៩ គឺ ចក្ខុទសកៈ ១ សោតទសកៈ ១ ឃានទសកៈ ១ ជិវ្ហា-ទសកៈ ១ កាយទសកៈ ១ ឥត្ថីភាវទសកៈ ១ បុរិសភាវទសកៈ ១ វត្ថុទសកៈ១ ជីវិតនវកៈ១ ។

ចិត្តជ្ជកលាបៈកើតខាងក្នុង ៦ គឺសុទ្ធដ្ឋកៈ១ កាយវិញ្ញត្តិនវកៈ១ វចីវិញ្ញត្តិសទ្ទទសកៈ១ សហុតាទិត្រយេកាទសកៈ ១ កាយវិញ្ញត្តិលហុតាទិត្រយទ្វាទសកៈ ១ វចីវិញ្ញត្តិសទ្ទលហុតា-ទិត្រយតេរសកៈ ១ ។

ឧតុជ្ជកលាបៈកើតខាងក្នុង ៤ គឺសុទ្ធដ្ឋកៈ ១ សទ្ទនវកលហុតាទិឯកាទសកៈ ១ សទ្ទ-លហុតាទិទ្វាទសកៈ ១ ។

អាហារជ្ជកលាបៈកើតខាងក្នុង ២ គឺសុទ្ធដ្ឋកៈ ១ លហុតាទិឯកាទសកៈ ១ ឯអាកាស-ធាតុ ១ លក្ខណរូប ៤ មិនជាអង្គនៃកលាបៈ ។

ឧតុសមុដ្ឋានកលាបៈជាខាងក្រៅមាន ២ គឺសុទ្ធដ្ឋកៈ ១ សទ្ទនវកៈ ១ កលាបៈទាំងពួងដែលសល់នោះ ប្រព្រឹត្តទៅក្នុងខាងក្នុងទាំងអស់ ។

*កម្មចិត្តោតុកាហារ- សមុដ្ឋានា យថាក្កមំ*
*នវ ឆ ចតុរោ ទ្វេតិ កលាបា ឯកវីសតិ ។*
*កលាបានំ បរិច្ឆេទ- លក្ខណត្តា វិចក្ខណា*
*ន កលាបង្គមិច្ចាហុ អាកាសំ លក្ខណានិ ច ។*

កលាបៈ ២១ គឺកម្មជ្ជកលាបៈ ៩ ជាចិត្តជ្ជកលាបៈ ៦ ជាឧតុជ្ជកលាបៈ ៤ ជាអាហារ-ជ្ជកលាបៈ ២ ដោយលំដាប់ តែអាកាសរូប និងលក្ខណរូប អ្នកប្រាជ្ញជាអ្នកឃើញច្បាស់ទាំងឡាយពោលថា មិនជាអង្គនៃកលាបៈ ព្រោះអាកាសក៏ជាទីកំណត់លក្ខណៈក៏ជាគ្រឿង-សំគាល់របស់កលាបៈ ហើយខ្លួនឯងនឹងកំណត់សំគាល់ខ្លួនឯងមិនបាន ។

( សទ្ទជាតិជាគ្រឿងប្រកបនូវកលាបសមុដ្ឋាន ចប់ )

**អំពីនេះនឹងសម្តែងនូវបវត្តិកមន័យតទៅ :**

សត្វទាំងឡាយក្នុងកាមភពដែលមានឥន្ទ្រិយបរិបូណ៌តែងបានរូប ២៨ នេះគ្រប់ក្នុងបវត្តិកាលខាងមុខអំពីបដិសន្ធិកាល សំសេទជសត្វ និងឧបបាតិកសត្វ ២ ពួកនេះតែងបានរូបកលាបៈគ្រប់ក្នុងវេលាបដិសន្ធិ ។

ថាដោយយ៉ាងទាប បើភ្នែកខ្វាក់ ត្រចៀកថ្លង់ ឬថាខ្ទើយអំពីកំណើតនោះចក្ខុទសកៈ និងសោតទសកៈ និងភាវទសកៈមិនមានឡើយ ហេតុដូច្នេះបណ្ឌិតគប្បីដឹងនូវកិរិយាថយចុះ ឬសាបសូន្យនៃកលាបៈដោយអំណាចនៃទសកៈទាំងឡាយនោះ ។

ចំណែកគព្ភសេយ្យកសត្វគឺសត្វដែលដេកក្នុងគភ៌មាតាទាំងឡាយ កាលបដិសន្ធិបានរូបកលាបៈ ៣ គឺកាយទសកៈ ១ ភាវទសកៈ ១ វត្ថុទសកៈ ១ ជួនកាលក្នុងបដិសន្ធិកាលនោះភាវទសកៈមិនមានសត្វនោះជាខ្ទើយ មានតែរូប ២ គឺកាយទសកៈ ១ វត្ថុទសកៈ ១ ។

រូបកាយបដិសន្ធិជាដំបូងនេះលោកហៅថា កលលរូបជាដុំមូលមានពណ៌ដូចដំណក់ប្រេងល្ងដ៏ថ្លាដែលជាប់នៅ នៅចុងរោមទ្រាយចាមរី ដែលបុគ្គលរលាស់ចោលអស់ ៧-

គ្រា ប្រេងដែលសល់ចោលជាប់នៅនឹងចុងរោមទ្រាយចាមរីនោះ ប៉ុនគ្នានឹងរូបនៃសត្វកាលបដិសន្ធិជាដំបូងនៅក្នុងគភ៌មាតា លុះកន្លងមក ៧ ថ្ងៃកលលរូប ក៏ប្រែជាអម្ពុទគឺទន់បន្តិច ឡើងធំបន្តិច ឡើងពណ៌ដូចទឹកលាងសាច់លុះកន្លងមក ៧ ថ្ងៃទៀត រូបនោះ រូបនោះក៏ប្រែចាកអម្ពុទរូប កើតជាបេសិរូប គឺជាដុំសាច់ពណ៌ដូចសំណដែលរលាយ លុះកន្លងមក ៧ ថ្ងៃទៀត បេសិករូប ក៏ប្រែទៅជាឃនរូបខន់ឡើងជាដុំ ដូចពងមាន់ លុះកន្លងមក ៧ ថ្ងៃទៀត ឃនរូបនោះចាស់ខន់បន្តិចឡើង ក៏បែកជាពក ៥ គឺជាដៃ ២ ជើង ២ ក្បាល ១ លុះ-កន្លងមក ៧ ថ្ងៃទៀតរូបនោះក៏ប្រែចំរើនធំឡើង កើតជាសរីរៈសព្វទាំងអស់ គ្រប់ចំណែកទាំងឡាយមានកេសាជាដើម ក៏បង្កើតប្រាកដគ្រប់ចំណែកដោយល្អិតក្រៃពេក សត្វបដិសន្ធិលុះគ្រប់ ៧ ថ្ងៃហើយ រូបនោះចេះតែប្រែទៅៗជាលំដាប់គ្នា កាលដល់ ៧ ថ្ងៃ ៥ ដង គិតជា ៣៥ ថ្ងៃ សត្វបដិសន្ធិបាន ៣៥ ថ្ងៃនោះ ឈ្មោះថាបដិសន្ធិកាល សត្វបដិសន្ធិផុតពី ៣៥ ថ្ងៃមកហើយជាចំណែកក្នុងបវត្តិកាល ដរាបដល់អាយុ កាលផុតពិ ៣៥ ថ្ងៃមកហើនោះ ក៏កើតជាទសកៈទាំងឡាយ មានចក្ខុទសកៈជាដើម ដោយលំដាប់ ។

សេចក្តីថា កាលសត្វបដិសន្ធិកន្លងចូល៣៦ ថ្ងៃ ៣៧ថ្ងៃ ៣៨ ថ្ងៃទៅហៅថា បវត្តិកាល ក៏កើតចក្ខុទសកៈតាំងនៅក្នុង ៧ ថ្ងៃគ្រប់បរិបូណ៌ ហើយកើតសោតទសកៈ តាំងនៅក្នុង ៧ ថ្ងៃគ្រប់បរិបូណ៌ អំពីនោះមកក៏កើតឃានទសកៈតាំងនៅក្នុង ៧ ថ្ងៃគ្រប់បរិបូណ៌កើតជីវ្ហា-ទសកៈ តាំងនៅក្នុង ៧ ថ្ងៃបរិបូណ៌ជា ៧ ថ្ងៃ ៩ ដងត្រូវជា ៦៣ ថ្ងៃពោលដូច្នេះនេះ ដោយសត្វដែលមានឥន្ទ្រិយបរិបូណ៌ ។

បើសត្វមានបាបកម្ម ខ្វាក់អំពីកំណើត ឬថ្លង់អំពីកំណើត កាលដល់ថ្ងៃគំរប់ ៣៦ ទៅដល់ ៤៣ ជាទីកើតចក្ខុ និងសោតៈ ចក្ខុទសកៈ និងសោតទសកៈ ក៏មិនកើតតាមធម្មតា ។

កម្មជ្ជសមុដ្ឋានរូប ១៨ កើតតាំងតែអំពីឧប្បាទខណៈនៃបដិសន្ធិចិត្តទៅ ។

ចិត្តជ្ជសមុដ្ឋានរូប ១៥ កើតតាំងតែអំពីភវង្គចិត្តទី ២ បន្ទាប់ពីបដិសន្ធិចិត្តទៅ ។

ឧតុជ្ជសមុដ្ឋានរូប ១៣ កើតតាំងតែអំពីឋិតិខណៈនៃបដិសន្ធិចិត្តនោះ ទៅអាហារជ្ជ-រូប ១២ កើតអំពីឱជអាហារដែលមាតាបរិភោគឱ្យកើតជាសមុដ្ឋានរូបក្នុងឋិតិខណៈ ។

ការកំណត់នៃរូបកលាបៈ ៤ ប្រការ កើតក្នុងសន្តានសត្វក្នុងកាមលោកកើតជាប់ៗគ្នាទៅមិនចេះដាច់ ដូចជាអណ្តាតប្រទីប និងខ្សែទឹកហូរមិនចេះដាច់ដរាបដល់អស់អាយុ ។

កាលសត្វនឹងជិតស្លាប់នៅ ១៧ ខណចិត្តទៀតនឹងដល់ចុតិចិត្ត កម្មជរូបមិនកើតឡើងរាប់ចុតិចិត្តនោះថយក្រោយចុះទៅ ១៧ ខណៈឋិតិខណៈនៃចិត្តទី ១៧ នោះកម្មជរូបមិនកើតឡើងអំពីនោះមករហូតដល់ចុតិចិត្ត កម្មជរូបដែលកើតមុនៗនោះមានអាយុថយមិនដល់ ១៧ ខណចិត្ត ហើយក៏រលត់ចុះដោយលំដាប់ៗគ្នា កម្មជរូបដែលកើតបំផុតខាងក្រោយ កើតក្នុងឧប្បាទខណៈនៃខណចិត្តទី ១៧ ដែលរាប់ថយក្រោយចុះតែត្រឹមនោះ ព្រោះខ្យល់–អស្សាសៈ បស្សាសៈកើតអំពីចិត្ត អស់ចិត្តហើយក៏អស់ទៅជាមួយគ្នា តែចិត្តជរូបដទៃៗ ក្រៅចាកខ្យល់អស្សាសៈ បស្សាសៈដែលមានអាយុមិនថយចាក ១៧ ខណចិត្តនោះមិនរលត់ព្រមគ្នាដោយចុតិចិត្តកើតឡើងនៅទៅរហូតគ្រប់ ១៧ ខណចិត្តទើបរលត់ ចិត្តជរូបរលត់ហើយអាហារជរូបទើបរលត់ក្នុងខាងក្រោយ នៅតែឧតុសមុដ្ឋានរូបដែលដែលកើតអំពីភ្លើងធាតុសត្វដែលស្លាប់ចុះថ្មីៗនោះ ទើបនៅមានកាយក្តៅឧណ្ហៗ ព្រោះឧតុសមុដ្ឋានរូបនៅកើតតៗនៅក្នុងកឡេវរៈនៃសត្វស្លាប់ហើយនោះ ។

*ឥច្ចេវំ មតសត្តានំ  បុនទេវ ភវន្តរេ*

*បដិសន្ធិមុបាទាយ  តថារូបំ បវត្តតិ ។*

សត្វដែលចុតិហើយយ៉ាងនេះ លុះទៅកាន់យកបដិសន្ធិក្នុងភពដទៃហើយ ក៏កើតជាសមុដ្ឋានរូបទាំង ៤ ដូចដែលពោលមកហើយ ។

រូបព្រហ្ម ១៥ លើកយកអសញ្ញិសត្វចេញមានបសាទរូប ២ គឺចក្ខុ ១ សោតៈ ១ ឯឃានៈ ជិវ្ហា កាយ មិនមានឃានវិញ្ញាណទាំង ២ នេះមាននៅខ្យល់អស្សាសៈបស្សាសៈ និងអាហារជកលាបក៏មិនមាន គឺឆ្អែតទៅដោយបីតិ និងសុខ ។

កាលបដិសន្ធិជាឧបបាតិកកំណើតហើយមានកម្មជរូប ៤ គឺចក្ខុទសកៈ១ សោតទសកៈ ១ វត្ថុទសកៈ ១ ជីវិតនវកៈ ១ ក្នុងបវត្តិកាលមានរូបកលាបៈ ១៤ គឺ កម្មជកលាបៈ ៤ ចិត្ត–ជកលាបៈ ៦ ឧតុជកលាបៈ ៤ ជា ១៤ កលាបៈ ។

អសញ្ញិព្រហ្ម កាលបដិសន្ធិមានជីវិតនវកៈជាសមុដ្ឋានកលាបៈក្នុងបវត្តិកាលមានរូប-កលាបៈ ៣ គឺកម្មជកលាបៈ ១ ឧតុជកលាប ២ គឺសុទ្ធដ្ឋកៈ ១ លហុតាទិឯកាទសកៈ ១ ជា ៣ កលាបៈសល់នៅក្នុងសន្តាននៃអសញ្ញិព្រហ្ម ។

រូបធម៌កើតមានដល់សត្វ ៣ ពួកគឺកាមភព ១ រូបភព ១ អសញ្ញិភព ១ ប្រព្រឹត្តទៅក្នុងកាលទាំង ២ គឺបដិសន្ធិកាល ១ បវត្តិកាល ១ ។

*អដ្ឋវីសតិ កាមេសុ* *ហោន្តិ តេវីស រូបិសុ*
*សត្តរ សេវាសញ្ញីនំ* *អរូបេ នត្ថិ កិញ្ចិបិ ។*
*សទ្ទោ វិការោ ជរតា* *មរណញ្ចោបបត្តិយំ*
*ន លព្ភតិ បវត្តេ តុ* *នកិញ្ចិបិ ន លព្ភតិ ។*

ក្នុងកាមភពមានរូប ២៨ ក្នុងរូបភពមានរូប ២៣ គឺលើករូប ៥ ចេញ រូប ៥នោះគឺឃានៈ ១ ជីវ្ហា ១ កាយ ១ ភាវរូប ១ អាហារជរូប ១ ។

ក្នុងអសញ្ញិព្រហ្មមានរូប ១៧ គឺជីវិតនវកៈ ៩ លហុតារូប ១ មុទុតារូប ១ កម្មញ្ញតា-រូប ១ ឧច្ចយតារូប ១ សន្តតិរូប ១ ជរតារូប ១ អនិច្ចារូប ១ អាកាសធាតុ ១ ។

ក្នុងអរូបព្រហ្ម ក្នុងខណបដិសន្ធិ និងបវត្តិកាល មិនមានសទ្ទរូប ១ វិការរូប ១ ជរតារូប ១ ព្រោះមិនមានរូបចំណែកឯណាមួយឡើយ ។

( សម្តែងលំដាប់កាលប្រព្រឹត្តទៅនៃរូបធម៌ អស់សេចក្តីប៉ុណ្ណោះ )

**អំពីនេះនឹងសម្តែងនូវព្រះនិព្វានតទៅ :**

ព្រះនិព្វានជាលោកុត្តរធម៌ អ្នកមានអភិនិហារគប្បីធ្វើឱ្យច្បាស់ដោយមគ្គញ្ញាណ ៤ ជាអារម្មណ៍នៃមគ្គ និងផល ព្រះសម្មាសម្ពុទ្ធជាម្ចាស់ត្រាស់ហៅថា និព្វាននោះ ព្រោះចេញចាកតណ្ហាជាគ្រឿងដោតក្រង ។

ពោលដោយសភាពបរមត្ថធម៌មានចំណែក ១ ដោយបរិយាយជា ២ យ៉ាង ៣ យ៉ាងក៏មាន ។

និព្វានមាន ២ យ៉ាងនោះគឺ សឧបាទិសេសនិព្វាន រលត់តែកិលេស បញ្ចក្ខន្ធនៅមិនទាន់រលត់ ១ អនុបាទិសេស រលត់កិលេសផង បញ្ចក្ខន្ធក៏រលត់ផង ១ ជានិព្វាន ២ យ៉ាង ។

និព្វានមាន ៣ យ៉ាងនោះគឺ សុញ្ញតនិព្វាន ជាអារម្មណ៍នៃអរិយមគ្គដែលកើតឡើងក្នុងលំដាប់នៃវុដ្ឋានគាមិនីវិបស្សនា មានអនត្តារម្មណ៍ ១ អនិមិត្តនិព្វាន ជាអារម្មណ៍នៃ-អរិយមគ្គដែលកើតឡើងក្នុងលំដាប់នៃវុដ្ឋានគាមិនីវិបស្សនាមានអនិច្ចៈជាអារម្មណ៍ ១ អប្បណិហិតនិព្វាន ជាអារម្មណ៍នៃអរិយមគ្គដែលកើតឡើងក្នុងលំដាប់នៃវុដ្ឋានគាមិនី-វិបស្សនា មានទុក្ខជាអារម្មណ៍ ១ ។

*បទមច្ចុតមច្ចន្តំ　　　អសង្ខតមនុត្តរំ*
*និព្វានមីតិ ភាសន្តិ　　　វានមុត្តា មហេសយោ ។*

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ព្រះអង្គស្វែងរកនូវគុណដ៏ធំ ព្រះអង្គផុតហើយបានចាកផុតតណ្ហាជាគ្រឿងដោតក្រង ព្រះអង្គពោលនូវអនុត្តរធម៌ដែលជាធម៌គឺមិនប្រជុំតាក់តែងបានមិនមានស្លាប់ ជារបស់ទៀង ជាទីទៅនៃព្រះអរិយៈទាំងឡាយដោយវិជ្ជាមានបញ្ញត្តិថាជានិព្វាន ។

*ឥតិ ចិត្តំ ចេតសិកំ　　　រូបំ និព្វានមិច្ចបិ*
*បរមត្ថំ បកាសេន្តិ　　　ចតុធា វ តថាគតា ។*

ព្រះតថាគតទាំងឡាយត្រាស់សម្ដែងនូវព្រះបរមត្ថធម៌ដោយសង្ខេបជា ៤ ប្រការគឺ ចិត្ត ១ ចេតសិក ១ រូប ១ និព្វាន ១ ប៉ុណ្ណេះ ដោយន័យដែលបានពោលមកហើយ ។

*ឥតិ អភិធម្មត្ថសង្គហេ*

*រូបសង្គហវិភាគោ នាម ឆដ្ឋោ បរិច្ឆេទោ*

បរិច្ឆេទទី ៦ ឈ្មោះរូបសង្គហវិភាគ ក្នុងអភិធម្មត្ថសង្គហៈ

ចប់តែប៉ុណ្ណេះហោង ។

## បរិច្ឆេទទី ៧

### សមុច្ចយសង្គហវិភាគ

*ទ្វាសត្តតិវិធា វុត្តា  វត្ថុធម្មា សលក្ខណា*
*តេសន្ទានិ យថាយោគំ  បវក្ខាមិ សមុច្ចយំ ។*

វត្ថុធម៌មាន ៧២ ប្រការគឺចិត្ត ១ ចេតសិក ៥២ និប្ផន្នរូប ១៨ និព្វាន ១ ជា ៧២ ។

សេចក្តីថា ចិត្ត ៨៩ បំព្រួញយកតែ ១ ចេតសិកមានលក្ខណៈផ្សេងៗគ្នារាប់ទៅនៅគង់ ៥២ ដដែល អនិប្ផន្នរូប ១០ រាប់បំព្រួញចូលក្នុងនិប្ផន្នរូប ១៨ និព្វានរាប់ជា ១ មិនរាប់ជា ២ ជា ៣ ឡើយ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា ប្រព្រឹត្តទៅមួយអន្លើដោយលក្ខណៈជាគ្រឿងកំណត់ ខ្ញុំឈ្មោះអនុរុទ្ធាចារ្យនឹងពោលនូវសមុច្ចយសង្គហៈគឺសេចក្តីកើតព្រមនៃវត្ថុធម៌ទាំងឡាយនោះ ដោយសមគួរដល់កិរិយាប្រកបក្នុងកាលឥឡូវនេះ ។

សមុច្ចយសង្គហៈមាន ៤ គឺអកុសលសង្គហៈ ១ មិស្សកសង្គហៈ ១ ពោធិបក្ខិយសង្គហៈ ១ សព្វសង្គហៈ ១ ។

សួរថា សមុច្ចយសង្គហៈ ៤ ប្រការ នោះនឹងអធិប្បាយយ៉ាងណា ?

ឆ្លើយថា នឹងត្រូវពោលពាក្យអធិប្បាយក្នុងអកុសលសង្គហៈ ៩ កងមុនទើបនឹងដឹងសមុច្ចយសង្គហៈបាន ។

អាសវធម៌គ្រឿងត្រាំ ៤ យ៉ាងគឺកាមាសវៈ គ្រឿងត្រាំគឺសេចក្តីប្រាថ្នាក្នុងវត្ថុកាមកិលេសកាម ១ ភវាសវៈ គ្រឿងត្រាំគឺសេចក្តីពេញចិត្តក្នុងរូបភព អរូបភព ១ ទិដ្ឋាសវៈ គ្រឿងត្រាំគឺមិច្ឆាទិដ្ឋិ ៦២ មួយ អវិជ្ជាសវៈ គ្រឿងត្រាំគឺ អវិជ្ជា ៤ អវិជ្ជា ៨ មួយ ។

ឱឃៈ គឺ អន្លង់មានរាគៈជាដើម កើតច្រើនឡើងដូចអន្លង់ទឹក ៤ យ៉ាងគឺកាមោឃៈ ១ ភវោឃៈ ១ ទិដ្ឋោឃៈ ១ អវិជ្ជោឃៈ ១ ។

យោគៈ គ្រឿងប្រកបសត្វទុកមាន ៤ យ៉ាងគឺកាមយោគៈ ១ ភវយោគៈ ១ ទិដ្ឋយោគៈ ១ អវិជ្ជាយោគៈ ១ ។

គន្ថៈ គ្រឿងចងរូបកាយទុកនឹងនាមកាយ ចងអនាគតកាយទុកនឹងបច្ចុប្បន្នកាយមាន– ៤ យ៉ាងគឺ អភិជ្ឈាកាយគន្ថៈ សេចក្តីលោភក្លៀវក្លាគិតយកទ្រព្យអ្នកដទៃ ១ ព្យាបាទកាយ–

គន្ថៈ ទោសក្បៀវក្លាគិតចងពៀរ ១ សីលព្វតបរាមាសកាយគន្ថៈកាន់លទ្ធិក្រៅពុទ្ធសាសនា ១ ឥទំសច្ចាភិនិវេសកាយគន្ថៈ កាន់មាំថាចំណែកនេះជារបស់ពិត ១ ។

ឧបាទានៈ កិរិយាកាន់យកមាំ ៤ យ៉ាងគឺ កាមុបាទាន ១ ទិដ្ឋុបាទាន ១ សីលព្វតុបា-ទាន ១ អត្តវាទុបាទាន ១ ។

នីវរណៈ គ្រឿងរារាំងផ្លូវល្អ ៦ យ៉ាងគឺ កាមឆន្ទៈ ១ ព្យាបាទៈ ១ ថីនមិទ្ធៈ ១ ឧទ្ធច្ច-កុក្កុច្ចៈ ១ វិចិកិច្ឆា ១ អវិជ្ជា ១ ។

អនុសយៈធម៌អាក្រក់ដេកក្នុងសន្តាន បើមិនមានហេតុ មិនមានបច្ច័យ ក៏ស្ងប់នៅ លុះមានហេតុមានបច្ច័យ ក៏គង់កើតផ្សាយឡើងតាមហេតុ នឹងបច្ច័យដែលមានមកនោះមាន ៧ យ៉ាងគឺ កាមរាគានុសយ ១ ភវរាគានុសយ ១ បដិសំយោជនៈក្នុងព្រះសូត្រ ១០ យ៉ាងគឺ កាមរាគ ១ រូបរាគ ១ អរូបរាគ ១ បដិឃៈ ១ មានៈ ១ ទិដ្ឋិ ១ សីលព្វតបរាមាសៈ ១ វិចិកិច្ឆា ១ ឧទ្ធច្ចៈ ១ អវិជ្ជា ១ ។

សំយោជនៈក្នុងអភិធម្ម ១០ យ៉ាងគឺ កាមរាគ ១ ភវរាគ ១ បដិឃៈ ១ មានៈ ១ ទិដ្ឋិ ១ សីលព្វតបរាមាសៈ ១ វិចិកិច្ឆា ១ ឥស្សា ១ មច្ឆរិយៈ ១ អវិជ្ជា ១ ។

កិលេស ១០ យ៉ាងគឺ លោភ ១ ទោសៈ ១ មោហៈ ១ មានៈ ១ ទិដ្ឋិ ១ វិចិកិច្ឆា ១ ថីនមិទ្ធៈ ១ ឧទ្ធច្ចៈ ១ អហិរិកៈ ១ អនោត្តប្បៈ ១ ។

បើពោលដោយវត្ថុ ដែលជាទីកើតនៃជាតិ នឹងតណ្ហាមាន ៨ ប្រការ គឺ កាមាសវៈ ១ ភវាសវៈ ១ កាមោឃៈ ១ ភវោឃៈ ១ កាមយោគៈ ១ ភវយោគៈ ១ កាមរាគានុសយៈ ១ ភវរាគានុសយៈ ១ ។

បើពោលដោយវត្ថុដែលជាទីកើតនៃទិដ្ឋិចរិតមាន ៣ ប្រការគឺ សីលព្វតបរាមាសៈ កាន់យកសីល នឹងវត្តខាងក្រៅ ១ ឥទំសច្ចាភិនិវេសៈ កាន់មាំថា ចំណែកនេះជារបស់ពិត ១ អត្តវាទៈ ពោលថាមានខ្លួនប្រាណនៅក្នុងអត្តភាព ១ ។

សត្វកើតនៅក្នុងភព ៣ មានចរិត ២ យ៉ាងគឺ តណ្ហាចរិត ១ ទិដ្ឋិចរិត ១ តណ្ហាចរិត នាំសត្វទៅកាន់សុគតិច្រើន ទិដ្ឋិចរិតនាំសត្វទៅកាន់ទុគ្គតិច្រើន ។

*អាសវោឃាចយោគាច* *តយោគន្ថាចវត្ថុតោ*
*ឧបាទានាទុវេធម្មា* *អដ្ឋនីវរណាសិយុំ ។*
*ឆឡេវានុសយាហោន្តិ* *នវសំយោជនាមតា*
*ក្លេសាទសេតិវុត្តោយំ* *នវធាបាបសង្គហោ ។*

អាចារ្យលោករួបរួមកាមាសវៈ ១ ភវាសវៈ ១ ទាំង ២ នេះបញ្ចូលគ្នាជា ១ រាប់ថា អាសវៈមាន ៣ ។

ឱឃៈ ២ យ៉ាងគឺ កាមោឃៈ ១ ភវោឃៈ ១ រួមជា ១ រាប់ថាឱឃៈ មាន ៣ យោគៈ ក៏រាប់ជា ៣ ដូចឱឃៈ ។

គន្ថៈ ២ យ៉ាងគឺ សីលព្វតបរាមាសៈ ១ ឥទំសច្ចាភិនិវេសៈ ១ រាប់ជា ១ ទើបចាត់ថា គន្ថៈ មាន ៣ ។

ឧបាទាន ៣ យ៉ាងគឺ ទិដ្ឋុបាទាន ១ សីលព្វតុបាទាន ១ អត្តវាទុបាទាន ១ រួមជា ១រាប់ថាឧបាទាន មាន ២ ។

នីវរណៈដើមមាន ៦ យ៉ាង ញែកថីនៈ ១ មិទ្ធៈ ១ ញែកឧទ្ធច្ចៈ ១ កុក្កុច្ចៈ ១ ទើបជា៨។

អនុសយៈដើមមាន ៧ រួមកាមរាគានុសយៈ នឹងភវរាគានុសយៈ ទាំង ២ ចូលជា ១ រាប់ថាអនុសយៈ មាន ៦ យ៉ាង ។

សំយោជនៈក្នុងអភិធម្ម ១០ កាមសំយោជនៈ ២ នេះរួម ជា ១ ទើបរាប់ថាសំយោ-ជនៈ មាន ៩ ។

កិលេស ១០ នោះរាប់គង់ ១០ តាមដើម

(សំដែងក្នុងអកុសលសង្គហៈ ៩ កងចប់)

មិស្សកសង្គហៈនោះ សំដែងពីកុសល អកុសល នឹងអព្យាកតៈច្រឡំគ្នាមាន ៧ កងគឺ ហេតុមាន ៦ គឺលោភៈ ១ ទោសៈ ១ មោហៈ ១ អលោភៈ ១ អទោសៈ ១ អមោហៈ ១

អង្គឈានមាន ៧ ប្រការគឺ វិតក្កៈ ១ វិចារៈ ១ បីតិ ១ ឯកគ្គតា ១ សោមនស្ស ១ ទោមនស្ស១ ឧបេក្ខា ១ ។

ដីកាចារ្យវិសជ្ជនាថា ទោមនស្សជាគ្រឿងដុត ជាចំណែកអកុសល លើកមកទុកទីនេះ ដើម្បីនឹងឱ្យឃើញថា ឈាននោះជ្រះថ្លារុងរឿងល្អ ដូចព្រះអាទិត្យកំចាត់បង់នូវងងឹតឱ្យភ្លឺស្វាងទួទៅក្នុងលោក ដុតកិលេសឱ្យស្ងួតហួតហែងទៅបាន ។

ទោមនស្សនេះ បើមាននៅក្នុងចិត្តហើយ ក៏ដុតហទយវត្ថុឱ្យស្ងួតបានដូចគ្នា ឈានៈសព្ទនោះប្រែថាដុត ហើយនឹងឱ្យឃើញថា ទោមនស្សជាគូគ្នានឹងសោមនស្ស ម៉្យាងទៀតប្រាថ្នាយកទោមនស្សដែលកើតដល់ព្រះយោគាវចរជាអ្នកសាបសូន្យចាកឈាន មានសេ-ចក្តីទោមនស្សតូចចិត្ត ។

អង្គមគ្គ ១២ ប្រការគឺ សម្មាទិដ្ឋិ ១ សម្មាសង្កប្បៈ ១ សម្មវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១ សម្មសតិ ១ សម្មាសមាធិ ១ មិច្ឆាទិដ្ឋិ ១ មិច្ឆាសង្កប្បៈ ១ មិច្ឆាវាយាមៈ ១ មិច្ឆាសមាធិ ១ ។

ឥន្ទ្រិយមាន ២២ ប្រការគឺ ចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ ឥត្ថិន្ទ្រិយ ១ បុរិសិន្ទ្រិយ ១ ជីវិតិន្ទ្រិយ ១ មនិន្ទ្រិយ ១ សុខិន្ទ្រិយ ១ ទុក្ខិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ១ ទោមនស្សិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ សទ្ធិន្ទ្រិយ ១ វិរិយិន្ទ្រិយ ១ សតិន្ទ្រិយ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ អនញ្ញតញ្ញស្សាមីតិន្ទ្រិយ ១ អញ្ញិន្ទ្រិយ ១ អញ្ញតាវិន្ទ្រិយ ១ ។

ជាលោកុត្តរឥន្ទ្រិយ ៣ ប្រការគឺ អនញ្ញតញ្ញស្សាមីតិន្ទ្រិយបានដល់សោតាបត្តិមគ្គញាណជាធំក្នុងកិរិយាញ៉ាំងអធ្យាស្រ័យនៃអ្នកប្រតិបត្តិឱ្យសំគាល់ទុកក្នុងចិត្តថានឹងបានព្រះនិព្វានជាក់ច្បាស់ក្នុងអរិយសច្ចថា របស់ដែលយើងមិនធ្លាប់ដឹង មិនធ្លាប់ឃើញ យើងក៏បានដឹងបានឃើញជាអស្ចារ្យ ដូច្នេះប្រការ ១ អញ្ញិន្ទ្រិយបានដល់លោកុត្តរៈ ៦ ពួក តាំងអំពីសោតាបត្តិផលរហូតដល់អរហត្តមគ្គជាធំឱ្យមានអធ្យាស្រ័យចងមាំ សំគាល់ដូចសោតាបត្តិមគ្គមិនកន្លងដែន ដែលសោតាបត្តិមគ្គរំពឹងឃើញថា យើងគង់នឹងបាននិព្វានជាប្រាកដ របស់ដែល

មិនធ្លាប់ដឹង មិនធ្លាប់ឃើញ ក៏បានដឹង បានឃើញ ដូច្នេះប្រការ ១ អញ្ញតាវិន្ទ្រិយបានដល់ព្រះអរហត្តផលញាណ ជាធំក្នុងសន្តានបានត្រាស់ដឹងព្រះចតុរារិយសច្ច ហើយ នឹងសម្រាន្តនៅជាសុខដូច្នេះប្រការ ១ ។

ពលៈ ៩ ប្រការគឺ សទ្ធាពលៈ ១ វិរិយពលៈ ១ សតិពលៈ ១ សមាធិពលៈ ១ បញ្ញាពលៈ ១ ហិរិពលៈ ១ ឱត្តប្បពលៈ ១ អហិរិកពលៈ ១ អនោត្តប្បពលៈ ១ ។

អធិបតិ ៤ ប្រការគឺ ឆន្ទាធិបតិ ១ វិរិយាធិបតិ ១ ចិត្តាធិបតិ ១ វីមំសាធិបតិ ១ ។

ពលៈ ១ អធិបតិ ១ ទាំង ២ នេះ នឹងមានពិស្តារក្នុងបរិច្ឆេទទី ៨ ។

អាហារមាន ៤ ប្រការគឺ កវឡិង្ការាហារ ១ ផស្សាហារ ១ មនោសញ្ចេតនាហារ ១ វិញ្ញាណាហារ ១ ។

ឥន្ទ្រិយទាំង ២២ ដែលពោលមកហើយនោះ សោតាបត្តិមគ្គញាណឈ្មោះថា អនញ្ញតញ្ញស្សាមីតិន្ទ្រិយ អរហត្តផលញាណ ឈ្មោះថា អញ្ញតាវិន្ទ្រិយញាណ ៦ ក្នុងកណ្តា-លឈ្មោះថា អញ្ញិន្ទ្រិយ ។

ជីវិតិន្ទ្រិយមាន ២ ប្រការគឺ រូបជីវិតិន្ទ្រិយ ប្រការ ១ អរូបជីវិតិន្ទ្រិយ ប្រការ១ ។

ឯកគ្គតាចេតសិក កើតព្រមដោយវិញ្ញាណទាំង ៥ មានចក្ខុវិញ្ញាណជាដើម មិនអាច-ក្លាហានជាអង្គឈានឡើយ បានឯកគ្គតាចិត្តមិនមានវីរិយៈកើតព្រមផងមាននៅ ១៦ ចិត្តគឺ បញ្ចទ្វារាវជ្ជនៈ ១ ទ្វិបញ្ចវិញ្ញាណ ១០ សម្បដិច្ឆន្នចិត្ត ២ សន្តីរណចិត្ត ៣ ជា ១៦ ។

ឯកគ្គតាចិត្តមិនមានវីរិយៈកើតព្រមផង, ១៦ ចិត្តនេះមិនអាចក្លាហានជាសមាធិពលៈ កើតឡើងបាន ។

អង្គនៃមគ្គតែងមិនមានក្នុងអហេតុកចិត្តទាំងឡាយ ឯកគ្គតាចិត្តក្នុងវិចិកិច្ឆា និងក្នុង លោភមូល មិនអាចជាមិច្ឆាសមាធិ និងសមាធិន្ទ្រិយ និងសមាធិពលៈបានឡើយ ។

អធិបតីទាំង ៤ មិនកើតឡើងព្រមគ្នា ចំពោះកើតឡើងតែម្តង១ ៗ ហើយចំពោះកើត តែទុហេតុកជវន និងត្រៃហេតុកជវន ឆន្ទាធិបតិ ១ វីរិយាធិបតិ ១ ចិត្តាធិបតិ ១ មានក្នុង ទុហេតុកជវន វីមំសាធិបតីចំពោះមានក្នុងត្រៃហេតុកជវន ។

*ឆ ហេតូ បញ្ចសានង្គា　　　　មគ្គង្គា នវ វត្ថុតោ*
*សោឡសិន្ទ្រិយធម្មា ច　　　　ពលធម្មា នវេរិតោ ។*
*ចត្តារោធបតី វុត្តា　　　　តថាហារាតិ សត្តធា*
*កុសលាទិសមាកិណ្ណោ　　　　វុត្តោ មិស្សកសង្គហោ ។*

ការរាប់បរមត្ថធម៌ដែលវិសជ្ជនាទុក ៧ កងនោះ លោកឱ្យរាប់ដូច្នេះគឺ ហេតុ ៦ គង់នៅដដែល អង្គឈាន ៧ រាប់យកតែ ៥ វិញ គឺសោមនស្ស ទោមនស្ស ឧបេក្ខា ទាំង ៣នេះជាជាតិវេទនាជាមួយគ្នា រួមជា ១ ។

អង្គមគ្គ ១២ រាប់យកតែ ៨ គឺមិច្ឆាសង្កប្បៈ សម្មាសង្កប្បៈ រួមជាមួយ ព្រោះជាជាតិវិតក្កៈជាមួយគ្នា មិច្ឆាវាយាមៈ សម្មវាយាមៈ ជាមួយគ្នាព្រោះជាតិវីរិយៈជាមួយគ្នា មិច្ឆាសម្មាធិ សម្មាសមាធិរួមជាមួយ ព្រោះជាជាតិឯកគ្គតាជាមួយគ្នា ។

ឥន្ទ្រិយ ២២ រាប់យកតែ ១៦ រួមសុខ ១ ទុក្ខ ១ សោមនស្ស ១ ទោមនស្ស ១ ឧបេក្ខា ១ ទាំង ៥ នេះរួមជា ១ ព្រោះជាជាតិវេទនាជាមួយគ្នា បញ្ញិន្ទ្រិយ ១ អនញ្ញតញ្ញស្សាមីតិន្ទ្រិយ ១ អញ្ញិន្ទ្រិយ ១ អញ្ញតាវិន្ទ្រិយ ១ ទាំង ៤ នេះរួមជា ១ ព្រោះជាជាតិបញ្ញាជាមួយគ្នា ឥន្ទ្រិយមាន ២២ លើក ៩ ចេញនៅសល់ ១៣ ឥន្ទ្រិយទាំង ៩ លើកចេញនោះជាជាតិវេទនា ១ ជាតិបញ្ញា ១ គង់នៅ ១៥ ជីវិតិន្ទ្រិយ ១ នោះអាចារ្យលោកញែកចេញជា ២ គឺរូបជីវិតិន្ទ្រិយ ១ អរូបជីវិតិន្ទ្រិយ ១ ទើបជា ១៦ ។

ពលៈ ៩ នៅគង ៩ ដដែល អធិបតី ៤ នៅគង់ ៤ ដដែល អាហារ ៤ នៅគង់ ៤ ដដែល ។

មិស្សកសង្គហៈពោលដោយកុសល និងអកុសលនិងអព្យាកតៈច្រឡំគ្នា ៧ កង ។

( ចប់ មិស្សកសង្គហៈ )

ក្នុងពោធិបក្ខិយសង្គហៈនេះ លោកចាត់ពោធិបក្ខិយ ៣៧ ជា ៧ កងគឺ :

១-*សតិបដ្ឋាន* ទីជាទីតម្កល់ គឺស្មារតី ៤ គឺកាយានុបស្សនា ១ វេទនានុបស្សនា ១ ចិត្តានុបស្សនា ១ ធម្មានុបស្សនា ១ ជា ៤ ។

២-*សម្មប្បធាន* សេចក្តីព្យាយាមតាំងទុកទូទៅព្រមមាន ៤ គឺសេចក្តីព្យាយាមដើម្បីនឹងលះបាបធម៌ដែលកើតឡើងហើយ ១ សេចក្តីព្យាយាមដើម្បីញ៉ាំងបាបធម៌ដែលមិនទាន់កើតឡើង មិនឱ្យកើតឡើងបាន ១ សេចក្តីព្យាយាមដើម្បីញ៉ាំងកុសលធម៌ដែលមិនទាន់កើតឡើង ឱ្យកើតឡើង ១ សេចក្តីព្យាយាមញ៉ាំងកុសលធម៌ដែលកើតឡើងហើយឱ្យចម្រើនឡើងដោយភិយ្យោភាពក្រៃលែង ១ ជា ៤ ។

៣-*ឥទ្ធិបាទ* ៤ ប្រការគឺ ឆន្ទិទ្ធិបាទ សេចក្តីបំណងជាទីតាំងនៃឫទ្ធិ ១ វីរិយិទ្ធិបាទ សេចក្តីប្រឹងប្រែងជាទីតាំងនៃឫទ្ធិ ១ ចិត្តិទ្ធិបាទ សេចក្តីសន្សំត្រិះរិះជាទីតាំងនៃឫទ្ធិ ១ វីមំសិទ្ធិបាទ គឺចេតនាដែលដឹងគ្រប់យ៉ាងជាទីតាំងនៃឫទ្ធិ ១ ជា ៤ ។

ក្នុងវិធីដែលឱ្យសម្រេចកិច្ចអភិញ្ញាទាំង ៦ នោះមិនប្រាសចាកឥទ្ធិបាទទាំង ៤ ប្រការឡើយ តែមិនក្លៀវក្លាស្មើគ្នាទេ ជួនកាលឆន្ទៈ និងវីរិយៈក្លៀវក្លា ជួនកាលចិត្ត និងបញ្ញា-ក្លៀវក្លា បើចំណែកណាក្លៀវក្លាហើយ ចំណែកនោះ ក៏ជាទីតាំងនៃឫទ្ធិឱ្យសម្រេចកិច្ចអភិ-ញ្ញាទាំង ៦ នោះ ។

៤-*ឥន្ទ្រិយ* ៥ គឺសទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ ត្រូវជា ៥ ។

៥-*ពលៈ* ៥ គឺសទ្ធា ១ វីរិយៈ ១ សតិ ១ សមាធិ ១ បញ្ញា ១ ។

៦-*ពោជ្ឈង្គៈ* ៧ គឺ សតិ ១ ធម្មាវិចយៈ ១ វីរិយៈ ១ បីតិ ១ បស្សទ្ធិ ១ សមាធិ ១ ឧបេក្ខា ១ ជា ៧ ។

៧-*អដ្ឋង្គិកមគ្គ* ៨ គឺ សម្មាទិដ្ឋិ ១ សម្មសង្កប្បៈ ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មាសមាធិ ១ ជា ៨ ។

សម្មាសតិ ១ លោកចែកចេញជាសតិប្បដ្ឋាន ៤ សម្មាវាយាមៈ ១ លោកចែកចេញជាសម្មប្បធាន ៤ ។

*ឆន្ទោ ចិត្តមុបេក្ខា ច សទ្ធាបស្សទ្ធិបីតិយោ*
*សម្មាទិដ្ឋិ ច សង្កប្បោ វាយាមោ វិរតិត្តយំ ។*

*សម្មាសតិ សមាធីតិ ចុទ្ទតេសេ សភាវតោ*
*សត្តត្តឹសប្បភេទេន សត្តធា តត្ថ សង្គហោ ។*

ធម៌ ១៤ ប្រការគឺឆន្ទះ ១ ចិត្ត ១ តត្រមជ្ឈត្តុបេក្ខា ១ សទ្ធា ១ បស្សទ្ធិ ១ បីតិ ១ សម្មាទិដ្ឋិ ១ សម្មាសង្កប្បៈ ១ សម្មាវាយាមៈ ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាសតិ ១ សម្មាសមាធិ ១ ធម៌ទាំង ១៤ ប្រការនេះ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សម្តែងញែកចេញជា ៧ កងគឺ សតិប្បដ្ឋាន ១ សម្មប្បធាន ១ ឥទ្ធិបាទ ១ ឥន្ទ្រិយ ១ ពលៈ ១ ពោជ្ឈង្គៈ ១ អដ្ឋង្គិកមគ្គ ១ ជាធម៌ ៧ កងញែកចែកនូវធម៌ ៧ កងនោះចេញជា ៣៧ ហៅថាពោធិបក្ខិយធម៌ ។ ពោធិបក្ខិយធម៌ ជាចំណែកដែលនឹងត្រាស់ដឹង ។

*សង្កប្បបស្សទ្ធិ ច បីត្យុបេក្ខា*
*ឆន្ទោ ច ចិត្តំ វិរតិត្តយញ្ច*
*នវេកឋានា វិរិយំ នវដ្ឋ*
*សតិ សមាធិ ចតុ បញ្ច បញ្ញា*
*សទ្ធា ទុឋានុត្តម សត្តត្តឹស*
*ធម្មានមេសោ បវរោ វិភាគោ ។*

ប្រែសេចក្តីថា ធម៌ ៣៧ បើនឹងថាដោយស្ថានទីតាំងជាមួយគ្នាមាន ៩ ប្រការគឺ សម្មាសង្កប្បៈ ១ បស្សទ្ធិសម្ពោជ្ឈង្គ ១ បីតិសម្ពោជ្ឈង្គ ១ ឧបេក្ខាសម្ពោជ្ឈង្គ ១ ឆន្ទិទ្ធិបាទ ១ ចិត្តិទ្ធិបាទ ១ វិរតិត្រៃ ៣ គឺសម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ ជា ៩ ប្រការ វិរិយៈមានស្ថាន ៩ គឺសម្មប្បធាន ៤ វិរិយិទ្ធិបាទ ១ វិរិយិន្ទ្រិយ ១ វិរិយពលៈ ១ វិរិយសម្ពោជ្ឈង្គ ១ សម្មាវាយាមៈ ១ រួមជា ៩ សតិមានស្ថាន ៨ គឺសតិបដ្ឋាន ៤ សតិន្ទ្រិយ ១ សតិពលៈ ១ សតិសម្ពោជ្ឈង្គ ១ សម្មាសតិ ១ រួមជា ៨ សមាធិមានស្ថាន ៤ គឺ សមាធិន្ទ្រិយ ១ សមាធិពលៈ ១ សមាធិសម្ពោជ្ឈង្គ ១ សម្មាសមាធិ ១ រួមជា ៤ បញ្ញាមាន ៥ ស្ថានគឺ វីមំសិទ្ធិបាទ ១ បញ្ញិន្ទ្រិយ ១ បញ្ញាពលៈ ១ ធម្មវិចយសម្ពោជ្ឈង្គ ១ សម្មាទិដ្ឋិ ១ រួមជា ៥ សទ្ធាមានស្ថាន ២ គឺសទ្ធិន្ទ្រិយ ១ សទ្ធាពលៈ ១ រួមជា ២ ។

ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ចំណែកធម៌ ៣៧ ប្រការដ៏ឧត្តមប្រសើរតែងមានក្នុងលោកុត្តរៈ ។

ម្យ៉ាងទៀត សម្មាសង្កប្បៈ និងបីតិទាំងឡាយតែងមិនមានក្នុងឈានតាំងអំពីទុតិយជ្ឈានទៅ ។

សេចក្តីថា កាលលោកុត្តរចិត្តកើតក្នុងបឋមជ្ឈានហើយធម៌ ៣៧ ប្រការកើតឡើងព្រមគ្នា លុះដល់ទុតិយជ្ឈានក៏វៀរសម្មាសង្កប្បៈ លុះដល់តតិយជ្ឈាន ចតុត្ថជ្ឈាន បញ្ចមជ្ឈាន ក៏វៀរសម្មាសង្កប្បៈ និងបីតិដោយលំដាប់ ។

ព្រះយោគាវចរដែលនៅជាលោកិយជន កាលចម្រើនវិសុទ្ធិភាវនាទាំង ៦ ប្រការក្នុងខាងដើម ដោយគួរដល់សេចក្តីព្យាយាមដែលប្រកបចូលកាន់បឋមជ្ឈានហើយ ក៏វៀរសម្មាកម្មន្តៈ សម្មាអាជីវៈ ចូលកាន់ទុតិយជ្ឈានក៏វៀរសម្មាសង្កប្បៈ សម្មាកម្មន្តៈ សម្មាអាជីវៈ កាលចូលកាន់តតិយជ្ឈាន ចតុត្ថជ្ឈាន បញ្ចមជ្ឈាន ក៏វៀរសម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ និងបីតិសម្ពោជ្ឈង្គ ។

( ពោធិបក្ខិយសង្គហៈ ចប់ )

**អំពីនេះនឹងវិនិច្ឆ័យក្នុងសព្វសង្គហៈតទៅ :**

បញ្ចក្ខន្ធ ៥ គឺរូប ២៨ វេទនាកើតនៅក្នុងចិត្ត ១២១ សញ្ញាកើតទូទៅក្នុងចិត្តទាំងអស់សង្ខារ ៥០ លើកវេទនា ១ សញ្ញា ១ ចេញវិញ្ញាណ ៨៩ ។

អាចារ្យពោលថា ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ទុកថា រូបដូចភាជនៈដាក់ភោជនវេទនាដូចយាគូ និងភត្ត សញ្ញាដូចស្ងួបៈនិងព្យញ្ជនៈផ្សេងៗ សង្ខារដូចអ្នកគ្រួ វិញ្ញាណដូចបរមក្សត្រិយ៍ជាអ្នកសោយនូវព្រះស្ងោយ ។

បញ្ចុបាទានក្ខន្ធ ៥ គឺរូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ កាលឧបាទាននៅមិនទាន់កាន់ជាអារម្មណ៍ហៅថាបញ្ចក្ខន្ធ លុះឧបាទានតោងយកជាអារម្មណ៍ហើយ ហៅថាបញ្ចុបាទានក្ខន្ធ ឧបាទានគឺតណ្ហាក្តៀវក្លាឡើង ។

អាយតនៈ ១២ គឺចក្ខាយតនៈ ១ សោតាយតនៈ ១ ឃានាយតនៈ ១ ជិវ្ហាយតនៈ ១ កាយាយតនៈ ១ មនាយតនៈ ១ រូបាយតនៈ ១ សទ្ទាយតនៈ ១ គន្ធាយតនៈ ១ រសាយតនៈ ១ ផោដ្ឋព្វាយតនៈ ១, ១១ នេះជាភវង្គមនៈ ធម្មាយតនៈ ១ គឺចេតសិក ៥២ សុខុមរូប ១៦ នព្វាន ១ ។

ធាតុ ១៨ គឺចក្ខុធាតុ ១ សោតធាតុ ១ ឃានធាតុ ១ ជិវ្ហាធាតុ ១ កាយធាតុ ១ រូបធាតុ ១ សទ្ទធាតុ ១ គន្ធធាតុ ១ រសធាតុ ១ ផោដ្ឋព្វធាតុ ១ ចក្ខុវិញ្ញាណធាតុ ១ សោតវិញ្ញាណធាតុ ១ ឃានវិញ្ញាណធាតុ ១ ជិវ្ហាវិញ្ញាណធាតុ ១ កាយវិញ្ញាណធាតុ ១ មនោធាតុ ១ មនោធាតុនេះមាន ៣ រួមជា ១៨ ធម្មធាតុ ១ មាន ៦ មនោវិញ្ញាណធាតុ ១ មាន ៣0 ដូចបានពោលហើយក្នុងបរិច្ឆេទទី ៣ ខាងដើម ។

អរិយសច្ច ៤ គឺទុក្ខអរិយសច្ច ១ ទុក្ខសមុទយអរិយសច្ច ១ ទុក្ខនិរោធអរិយសច្ច ១ ទុក្ខនិរោធគាមិនីអរិយសច្ច ១ ទុក្ខសច្ចគឺ ជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ បញ្ចក្ខន្ធរង ទទួលនូវទុក្ខ ៤ សមុទយសច្ចគឺ តណ្ហា ៣ ប្រការគឺកាមតណ្ហា ភវតណ្ហា វិភវតណ្ហា និរោធសច្ចគឺ ព្រះនិព្វានជាទីរំលត់ទុក្ខ មគ្គសច្ចគឺ អដ្ឋង្គិមគ្គ ៨ ជាផ្លូវប្រតិបត្តិ និងឱ្យដល់នូវព្រះនិព្វាន ឈ្មោះថាអរិយសច្ចនោះព្រោះជាសេចក្តីពិតនៃព្រះអរិយៈជាម្ចាស់ ។

ធម៌ទាំងឡាយនេះជាធម៌មាន ៦៩ ដោយអំណាចនៃចេតសិក ៥២ សុខុមរូប ១៦ និព្វាន ១ ដល់នូវកិរិយារាប់ថាធម្មាយតនៈផង ធម្មធាតុផង ។

មនាយតនៈចំណែក ១ ចែកចេញដោយអំណាចជាវិញ្ញាណធាតុ ៧ គឺចក្ខុវិញ្ញាណ-ធាតុ ១ សោតវិញ្ញាណធាតុ ១ ឃានវិញ្ញាណធាតុ ១ ជិវ្ហាវិញ្ញាណធាតុ ១ កាយវិញ្ញាណ-ធាតុ ១ មនោធាតុ ១ មនោវិញ្ញាណធាតុ ១ ។

*រូបញ្ច វេទនា សញ្ញា　　សេសា ចេតសិកា តថា*
*វិញ្ញាណមិតិ បញ្ចេតេ　　បញ្ចក្ខន្ធាតិ ភាសិតា ។*
*បញ្ចុបាទានក្ខន្ធាតិ　　តថា តេភូមិកា មតា*
*ភេទាភាវេន និព្វានំ　　ខន្ធសង្គហនិស្សដំ ។*

ខន្ធ ៥ គឺរូប ១ វេទនា ១ សញ្ញា ១ ចេតសិកដ៏សល់ចាកវេទនា សញ្ញាគឺសង្ខារ ១ វិញ្ញាណ ១ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថាបញ្ចក្ខន្ធ ។

ម្យ៉ាងទៀតខន្ធ ៥ នោះប្រព្រឹត្តទៅក្នុងភូមិ ៣ ព្រះអង្គត្រាស់ថាបញ្ចុបាទានក្ខន្ធ ។

សេចក្តីថា ខន្ធ ៥ មានរូបជាដើម ឈ្មោះថាបញ្ចក្ខន្ធ លុះតណ្ហា ឧបាទានកាន់យកជាអារម្មណ៍ ប្រព្រឹត្តទៅក្នុងភូមិ ៣ ក៏ឈ្មោះថាឧបាទានក្ខន្ធ ។

ព្រះនិព្វានមិនផ្សេងដោយហេតុ ព្រះសម្មាសម្ពុទ្ធទ្រង់មិនសង្គ្រោះចូលក្នុងខន្ធ ។

អាយតនៈ ១២ ផ្សេងចេញដោយទ្វារ និងអារម្មណ៍ ធាតុ ១៨ ព្រះអង្គទេសនាដោយលំដាប់នៃទ្វារនិងអារម្មណ៍ អាស្រ័យទ្វារនិងអារម្មណ៍ហើយទើបកើតឡើង ចក្ខុ សោតៈ ឃានៈ ជិវ្ហា កាយ មនៈ ជាទ្វារជាទីកើតនៃវិថីចិត្ត រូប សទ្ទៈ គន្ធៈ រសៈ ផោដ្ឋព្វៈ ធម្មៈ ជាអារម្មណ៍ជាទីតោងយកនៃចិត្ត ចក្ខុវិញ្ញាណធាតុ សោតវិញ្ញាណធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាវិញ្ញាណធាតុ កាយវិញ្ញាណធាតុ មនោវិញ្ញាណធាតុ អាស្រ័យនូវទ្វារនិងអារម្មណ៍ហើយទើបកើតឡើង ទុក្ខប្រព្រឹត្តក្នុងភូមិ ៣ តណ្ហាជាសមុទយៈឱ្យកើតទុក្ខ និរោធធម៌ជាទីរំលត់ទុក្ខ ឈ្មោះថា និព្វាន មគ្គ ៨ នោះ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ពោលតែមគ្គដែលជាលោកុត្តរៈថាជាអរិយសច្ច មគ្គ ៨ ដែលកើតក្នុងលោកិយចិត្តនោះទ្រង់មិនត្រាស់ថាជាមគ្គ-សច្ចឡើយ ព្រោះព្រះអរិយបុគ្គលត្រាស់ដឹងអរិយសច្ច ៤ នោះ ត្រាស់ដឹងព្រមគ្នាក្នុងខណៈដែលអរិយមគ្គកើតឡើង ។

ម្យ៉ាងទៀត ចេតសិកទាំងឡាយ មានផស្សៈនិងវេទនាជាដើម ដែលកើតព្រមដោយមគ្គចិត្ត និងផលចិត្តនោះ មិនរាប់ចូលក្នុងអរិយសច្ចឯណាមួយ ដោយមុខន័យមែនពិត បើនឹងរាប់ចូលក្នុងទុក្ខសច្ចក៏រាប់តែអមុខន័យ យកជាប្រធានពិតមិនបាន ។

( សព្វសង្គហៈ ប្រព្រឹត្តទៅហើយដោយប្រភេទ ៥ ចប់ )

*ឥតិ អភិធម្មត្ថសង្គហេ*

*សមុច្ចយសង្គហវិភាគោ នាម សត្តមោ បរិច្ឆេទោ*

បរិច្ឆេទទី ៧ ឈ្មោះថា សមុច្ចយសង្គហវិភាគ ក្នុងអភិធម្មត្ថសង្គហៈ ចប់តែប៉ុណ្ណោះហោង ។

## បរិច្ឆេទទី ៨

បច្ចយសង្គហវិភាគ

*យេសំ សង្ខតធម្មានំ យេ ធម្មា បច្ចយា យថា*

*តំ វិភាគមិហេទានិ បវក្ខាមិ យថារហំ ។*

ធម៌ទាំងឡាយឯណាជាបច្ច័យគឺ ឧបការនឹងឱ្យកើតតាំងនៅមាំ ធម៌ទាំងឡាយឯណាជាបច្ចយុប្បន្ន កើតហើយអំពីធម៌ដែលជាបច្ច័យប្រជុំតាក់តែងទាំងឡាយឯណា ដោយបការយ៉ាងណា ខ្ញុំម្ចាស់នឹងសម្តែងនូវធម៌ទាំងឡាយនោះៗថាជាបច្ច័យដល់ធម៌នោះផង ថាជាបច្ចយុប្បន្នកើតអំពីធម៌ដែលបច្ច័យប្រជុំតាក់តែងនោះផងដោយប្រការដូច្នេះ នឹងពោលឱ្យសមគួរដល់ព្រះបរមពុទ្ធាធិប្បាយក្នុងបច្ចយាការគឺនឹងពោលនូវបច្ចយសង្គហៈក្នុងកាលឥឡូវនេះ ។

បច្ច័យសង្គហៈនេះមានន័យ ២ ប្រការគឺ បដិច្ចសមុប្បាទន័យ ១ បដ្ឋានន័យ ១ ជិនុំន័យទាំង ២ នោះ រីឯបដិច្ចសមុប្បាទន័យ ព្រះដ៏មានព្រះភាគទ្រង់កំណត់នូវមាត្រាថាអាការ គឺភាវៈនៃបច្ច័យ និងបច្ចយុប្បន្ន និងសេចក្តីកើតច្បាស់នៃបច្ច័យដែលផ្សេងគ្នា ១២ ចេញទៅដល់ ២៤ ឈ្មោះមានហេតុប្បច្ច័យជាដើម មានវិគតប្បច្ច័យជាបរិយោសាន ។

អាចារ្យទាំងឡាយញាំុងន័យទាំង២ឱ្យច្រឡំចូលគ្នាហើយក៏សម្តែងដោយពិស្តារ ។

**នឹងវិនិច្ឆ័យក្នុងបដិច្ចសមុប្បាទន័នោះថា :**

បដិច្ចសមុប្បាទន័យ គឺន័យនៃធម៌ដែលជាដែនអាស្រ័យកើតឡើងព្រមគ្នានៃផល ឬធម៌ដែលជាបច្ច័យជាដែនអាស្រ័យកើតឡើងព្រមនេះ អ្នកប្រាជ្ញគប្បីដឹងដូច្នេះ ។

សង្ខារធម៌ដែលប្រុងធ្វើ ដែលតាក់តែងគឺ ចេតនាជាកុសល និងចេតនាជាអកុសលតែងមានព្រម តែងកើតព្រមអំពីបច្ច័យគឺអវិជ្ជា ឬនិងថាព្រោះអវិជ្ជាជាបច្ច័យ សង្ខារធម៌ជាអ្នកប្រុងធ្វើ អ្នកតាក់តែង តែងមានព្រម តែងកើតព្រមយ៉ាងនេះក៏បាន រហូតដល់សេចក្តីថាព្រោះជាតិជាបច្ច័យជរា មរណៈ សេចក្តីស្ងួតក្រៀមចិត្ត សេចក្តីខ្សឹកខ្សួល សេចក្តីទោមនស្សនិងសេចក្តីចង្អៀតចង្អល់ចិត្ត តែងមានព្រមតែងកើតព្រម ។

សេចក្តីកើតឡើងព្រមនៃកងទុក្ខទាំងពួងនោះ គឺមិនច្រឡំដោយសេចក្តីសុខឡើយ តែងមានព្រម តែងកើតព្រមយ៉ាងនេះ ឬនឹងកាន់យកសេចក្តីឱ្យបានច្បាស់ប្រាកដថា អវិជ្ជា សេចក្តីមិនដឹង ឬមោហោ សេចក្តីល្ងង់វង្វេង មិនដឹងក្នុងសច្ចៈ ៤ និងវត្ថុ ៨ ជាបច្ច័យរបស់សង្ខារគឺកុសលចេតនា និងអកុសលចេតនា សង្ខារជាបច្ច័យរបស់វិញ្ញាណ ២២ វិញ្ញាណ-ជាបច្ច័យរបស់នាមរូបគឺនាម ២ រូប ២៨ នាមរូបជាបច្ច័យរបស់អាយតនៈ ៦ អាយតនៈជាបច្ច័យរបស់ផស្សៈ ៦ ផស្សៈជាបច្ច័យរបស់វេទនា ៥ វេទនាជាបច្ច័យរបស់តណ្ហា ១០៨ តណ្ហាជាបច្ច័យឧបាទាន ៤ ឧបាទានជាបច្ច័យរបស់ភព ២ គឺកម្មភព ១ ឧបបត្តិភព ១ ភពជាបច្ច័យរបស់ជាតិ គឺកិរិយាកើតក្នុងកំណើត ៤ ជាបច្ច័យរបស់ជរា គឺសេចក្តីគ្រាំគ្រា មរណៈ សេចក្តីស្លាប់ សោកៈ សេចក្តីក្រៀមក្រំ បរិទេវៈ សេចក្តីខ្សឹកខ្សួល ទោមនស្ស សេចក្តីតូចចិត្ត ឧបាយាសៈ សេចក្តីចង្អៀតចង្អល់ចិត្ត សេចក្តីកើតព្រមនៃកងទុក្ខទាំងអស់នេះតែងមាន តែងកើតឡើង ។

ដែលពោលមកនេះ ជាចំណែកសមុទយថាដោយកើតឡើងចំណែក ១ ក្នុងបដិច្ច-សមុប្បាទនោះមានអទ្ធា ៣ មានអង្គ ១២ មានអាការ ២០ មានសន្ធិ ៣ មានសង្ខេប ៤ មានវដ្តៈ ៣ មានមូល ២ ។

សួរថា ចំណែកទាំងឡាយមានអទ្ធា ៣ ជាដើមនោះ មានអធិប្បាយដូចម្តេច ?

ឆ្លើយថា អទ្ធា ៣ គឺអតីតអទ្ធា ១ អនាគតអទ្ធា ១ បច្ចុប្បន្នអទ្ធា ១ អវិជ្ជា ១ សង្ខារ ១ ទាំង ២ នេះឈ្មោះថាអតីតអទ្ធា ជរា ១ មរណៈ ១ ទាំង ២ នេះឈ្មោះអនាគតអទ្ធា វិញ្ញាណ ១ នាមរូប ១ សឡាយតនៈ ១ ផស្សៈ ១ វេទនា ១ តណ្ហា ១ ឧបាទាន ១ ភព ១ ទាំង ៨ នេះឈ្មោះបច្ចុប្បន្នអទ្ធា អង្គនៃបដិច្ចសមុប្បាទ ១២ គឺអវិជ្ជា ១ សង្ខារ ១ វិញ្ញាណ ១ នាមរូប ១ សឡាយតនៈ ១ ផស្សៈ ១ វេទនា ១ តណ្ហា ១ ឧបាទាន ១ ភព ១ ជាតិ ១ ជរាមរណៈ ១ សោក បរិទេវ ទុក្ខទោមនស្ស ឧបាយស នេះជាផលរបស់ជាតិ មិនបានរាប់ថាអង្គឡើយ ។

អាការ ២០ លោកចាត់ដូច្នេះ អវិជ្ជា និងសង្ខារ ២ នេះនៅខាងដើមសង្គ្រោះយក តណ្ហា និងឧបាទាន និងភពទាំង ៣ នេះទៀតបំពេញចូលជា ៥ ហៅថាអតីតហេតុ ជាហេតុដ៏កន្លងទៅហើយ ឱ្យកើតបច្ចុប្បន្នផលក្នុងជាតិដែលនៅឥឡូវនេះ វិញ្ញាណ ១ នាមរូប ១ សឡាយតនៈ ១ ផស្សៈ ១ វេទនា ១ ដែលមាននៅក្នុងឥឡូវនេះចាត់ជាបច្ចុប្បន្នផល ៥ ព្រោះកើតមកអំពីហេតុដែលកន្លងទៅហើយអំពីជាតិមុន ។

តណ្ហា ១ ឧបាទាន ១ ភព ១ អវិជ្ជា ១ សង្ខារ ១ ដែលមាននៅក្នុងបច្ចុប្បន្នឥឡូវនេះ ចាត់ជាបច្ចុប្បន្នហេតុ ៤ ព្រោះនឹងឱ្យកើតផលទៅក្នុងអនាគតខាងមុខ ។

វិញ្ញាណ ១ នាមរូប ១ សឡាយតនៈ ១ ផស្សៈ ១ វេទនា១ ដែលនឹងកើតមានទៅក្នុងភពខាងមុខនោះចាត់ជាអនាគតផល៥ ព្រោះនឹងកើតអំពីបច្ចុប្បន្នហេតុក្នុងជាតិនេះ អតីត-ហេតុ ៥ បច្ចុប្បន្នផល ៥ បច្ចុប្បន្នហេតុ ៥ អនាគតផល ៥ ជាអាការ ២០ ។

សេចក្តីថា ជាតិ ១ ជរា ១ មរណៈ ១ ទាំង ៣ នេះមិនផ្សេងគ្នាចាកបច្ចុប្បន្នផល ៥ ៗ នោះលុះកើតឡើងហើយ ក៏ហៅថាជាតិម្យ៉ាង ព្រោះមិនឃើញជរានិងមរណៈហៅថា ជាតិ ៗ នោះដល់ចាស់គ្រាំគ្រាហើយទើបហៅថា ជរា លុះផល ៥ បែកទម្លាយក៏ហៅថាមរណៈ ដែលពិតនោះគឺរួបរួមគ្នានៅក្នុងរបស់ ៥ ចំណែកនោះ ហេតុនោះព្រះដ៏មានព្រះភាគទើបកាន់យកផល ៥ គឺវិញ្ញាណ ១ នាមរូប ១ សឡាយតនៈ ១ ផស្សៈ ១ វេទនា ១ ទាំង ៥ នេះទ្រង់សម្តែងថា កាលដែលរបស់ ៥ ចំណែកនេះកើតឡើង ឈ្មោះថាជាតិ លុះរបស់ ៥ ចំណែកនេះទ្រុឌទ្រោមគ្រាំគ្រាទៅ ឈ្មោះថា មរណៈ ។

សន្ធិ ៣ គឺរវាងសង្ខារដែលជាអតីតហេតុ និងវិញ្ញាណជាបច្ចុប្បន្នផលតគ្នា ឈ្មោះថា ហេតុផលសម្ពន្ធ ជាសន្ធិ ១ ។

រវាងវេទនាដែលជាបច្ចុប្បន្នផល និងតណ្ហាដែលជាបច្ចុប្បន្នហេតុតគ្នា ឈ្មោះថា ហាតុផលសម្ពន្ធ ជាសន្ធិ ១ ។

រវាងភពដែលជាបច្ចុប្បន្នហេតុ និងជាតិដែលជាអនាគតផលតគ្នា ឈ្មោះថា ហេតុ-ផលសម្ពន្ធ ជាសន្ធិ ១ ត្រូវជាសន្ធិ ៣ ។

សង្ខេប ៤ គឺអតីតហេតុ ២ គឺអវិជ្ជា ១ សង្ខារ ១ ជាសង្ខេប ១ , បច្ចុប្បន្នផល ៥ គឺ វិញ្ញាណ ១ នាមរូប ១ សឡាយតនៈ ១ ផស្សៈ ១ វេទនា ១ ជាសង្ខេប ១ ។បច្ចុប្បន្នហេតុ ៣ គឺតណ្ហា ១ ឧបាទាន ១ ភវៈ ១ ជាសង្ខេប ១ ។អនាគតផល ២ គឺជាតិ ១ ជរាមរណៈ ១ ជាសង្ខេប ១ ត្រូវជាសង្ខេប ៤ ។វដ្តៈ ៣ គឺអវិជ្ជា ១ តណ្ហា ១ ឧបាទាន ១ ជា ៣ ឈ្មោះកិលេសវដ្តៈ ។កម្មភព ១ សង្ខារ ១ ជា ២ ឈ្មោះកម្មវដ្តៈ ។ឧបបត្តិភព ១ វិញ្ញាណ ១ នាមរូប ១ សឡាយតនៈ ១ ផស្សៈ ១ វេទនា ១ ជរាមរណៈ ១ ជាតិ ១ ជា ៨ ឈ្មោះវិបាកវដ្តៈ ។ មូលនៃភវចក្ក ២ គឺអវិជ្ជា ១ តណ្ហា ។

*តេសមេវ ច មូលានំ* — *និរោធេន និរុជ្ឈតិ*
*ជរាមរណមុច្ឆាយ* — *បីឡិតានមភិណ្ហសោ ។*
*អាសវានំ សមុប្បាទា* — *អវិជ្ជា ច បវត្តតិ*
*វដ្តមាវទ្ធមិច្ចេវំ* — *តេភូមិកមនាទិកំ*
*បដិច្ចសមុប្បាទោតិ* — *បដ្ឋបេសិ មហាមុនិ ។*

នាកាលមូលគឺ អវិជ្ជា និងតណ្ហាទាំង ២ មិនបានរលត់ហើយភវចក្កមានគ្រឿងវិល ៣ គឺកម្មវដ្តៈ កិលេសវដ្តៈ វិបាកវដ្តៈផ្គុំបញ្ចូលគ្នា ទើបវិលទៅមិនឈប់បាន នាកាល-កិលេសវដ្តៈដែលជាប្រធាន ព្រះអរិយមគ្គកាត់ផ្តាច់ហើយ កម្មវដ្តៈនិងវិបាកវដ្តៈក៏អស់ជុំវិញ ភវចក្កក៏រលត់ចុះមិនអាចវិលទៅបាន ព្រោះរលត់មូលទាំងឡាយនោះអស់ហើយ កាលសត្វទាំងឡាយ គឺអវិជ្ជារារាំងបិទបាំងតណ្ហាចងព័ទ្ធព័ន្ធទុក្ខ គ្រឿងសញ្ចប់ សុបសៅគឺជរា និងមរណៈ ក៏បៀតបៀននៅរឿយៗហើយក៏បង្កើតសេចក្តីសោក បរិទេវទុក្ខ ទោមនស្ស និងឧបាយាសឡើង ក៏កើតអាសវៈទាំង ៤ ឡើង អវិជ្ជាក៏ចម្រើនឡើងជាបច្ច័យរបស់សង្ខារ-ទៀត សង្ខារក៏ជាបច្ច័យរបស់ផលធម៌ទាំងឡាយ មានវិញ្ញាណជាដើមតៗទៅទៀត វដ្តៈ-គ្រឿងវិល គឺកម្មនិងកិលេស និងវិបាកវិលទៅក្នុងភូមិទាំង ៣ មិនមានខាងដើម ជាប់ព័ទ្ធព័ន្ធមិនដាច់ចុះយ៉ាងនេះ សម្តេចព្រះមហាមុនីទ្រង់ត្រាស់ហៅថា បដិច្ចសមុប្បាទធម៌ ។

( ចប់បដិច្ចសមុប្បាទន័យ )

**ពីនេះនឹងសម្តែងនូវបដ្ឋានន័យតទៅ :**

បដ្ឋាននន័យនោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដោយបច្ច័យ ២៤ ប្រការដូច្នេះគឺ :

១-*ហេតុប្បច្ចយោ* ធម៌ជាឧបការ ដោយសភាវៈជាហេតុគឺចងទុកឱ្យតាំងនៅមាំនៃកុសលាកុសលធម៌ ឈ្មោះហេតុប្បច្ច័យ បានដល់ហេតុ ៦ ប្រការ ប្រៀបបីដូចជាឫសឈើ និងទប់ទល់ទ្រ ជាឧបការតាំងមាំនៃដើមឈើ ។

២-*អារម្មណប្បច្ចយោ* អារម្មណ៍បច្ច័យបានដល់អារម្មណ៍ ៦ ជាទីទាញតោងនៃចិត្ត និងចេតសិកដែលកើតក្នុងទ្វារទាំង ៦ ប្រៀបដូចខ្សែនិងឈើស្នួរជាទីទាញតោងនៃមនុស្សទាំងពួង ។

៣-*អធិបតិប្បច្ចយោ* ធម៌ជាឧបការ ដោយសភាវៈជាធំក្នុងធម៌ដ៏ប្រព្រឹត្តដែលជាប់ដោយខ្លួន ។

៤-*អនន្តរប្បច្ចយោ* ធម៌ដែលកើតមុនរលត់ទៅហើយ ជាឧបការឱ្យឱកាសដល់ធម៌ដែលកើតខាងក្រោយ ។

៥-*សមនន្តរប្បច្ចយោ* ធម៌កើតមុនរលត់ទៅហើយ ជាឧបការឱ្យឱកាសល្អ មិនមានធម៌ដទៃមករារាំងដល់ធម៌ដែលកើតខាងក្រោយ ។

៦-*សហជាតប្បច្ចយោ* ធម៌ជាឧបការដោយសភាវធម៌ ដែលកើតព្រមគ្នាដូចអណ្តាតប្រទីប និងរស្មីភ្លឺស្វាងព្រមគ្នាឡើង ។

៧-*អញ្ញមញ្ញប្បច្ចយោ* ធម៌កើតព្រមគ្នាជាឧបការដល់គ្នានឹងគ្នា ដូចឈើ ៣ កំណាត់ដែលបុគ្គលលើបញ្ឈរឡើង ហើយដាក់ផ្អែកនូវគ្នានឹងគ្នា ឈើនោះក៏ព្រយុងនូវគ្នានឹងគ្នា ។

៨-*និស្សយប្បច្ចយោ* ធម៌ជាឧបការដោយសភាវៈជាទីអាស្រ័យ ប្រៀបដូចផែនដីជាទីអាស្រ័យនៃសត្វ និងដើមឈើជាដើម ឧបមាដូចផ្ទាំងសំពត់ជាទីអាស្រ័យនៃរូបគំនូរគូសវាសផ្សេងៗ ។

៩-*ឧបនិស្សយប្បច្ចយោ* ធម៌ជាឧបការដោយសភាវៈជាឧបនិស្ស័យជាប់តាមខ្លួនជាដើមហេតុ ។

១០-*បុរេជាតប្បច្ចយោ* ធម៌កើតមុនជាឧបការបច្ច័យដល់ចិត្តនិងចេតសិកដែលកើតខាងក្រោយ ។

១១-*បច្ឆាជាតប្បច្ចយោ* ធម៌គឺចិត្តនិងចេតសិកកើតខាងក្រោយជាឧបការបច្ច័យដល់រូបដែលកើតមុន ។

១២-*អាសេវនប្បច្ចយោ* ជវនចិត្តមានជាតិស្មើគ្នាឱ្យកម្លាំងដល់គ្នាឱ្យសម្រេចកិច្ចជាបុណ្យជាបាប ឈ្មោះអាសេវនប្បច្ច័យ ។

១៣-*កម្មប្បច្ចយោ* កុសលាកុសលជាបច្ច័យឱ្យកើតផលជាសុខជាទុក្ខ ។

១៤-*វិបាកប្បច្ចយោ* វិបាកចិត្តកើតឡើងជាបច្ច័យឱ្យសត្វបានសុខ និងទុក្ខ ដោយគួរដល់កុសលាកុសល ។

១៥-*អាហារប្បច្ចយោ* អាហារ ៤ ប្រការគឺផស្សាហារ ចេតសិកជាបច្ច័យឱ្យកើតសុខវេទនា ទុក្ខវេទនា និងឧបេក្ខាវេទនា ១ មនោសញ្ចេតនាហារបានដល់កុសលាកុសល-ចិត្តជាបច្ច័យឱ្យកើតបដិសន្ធិវិញ្ញាណ ១ វិញ្ញាណាហារ គឺបដិសន្ធិចិត្តជាបច្ច័យឱ្យកើតរូបធម៌នាមធម៌ក្នុងបវត្តិកាល ខាងមុខអំពីបដិសន្ធិចិត្តដរាបដល់ចុតិចិត្ត ១ កវឡិង្ការាហារ ឧបត្ថម្ភគាំទ្ររូបធម៌ នាមធម៌ ឱ្យតាំងនៅជាប្រក្រតី ១ ឈ្មោះអាហារប្បច្ច័យ ។

១៦-*ឥន្ទ្រិយប្បច្ចយោ* បសាទរូប ៥ ឱ្យវិញ្ញាណទាំង ៥ ប្រព្រឹត្តទៅក្នុងអំណាច ១ រូបជីវិតិន្ទ្រិយជាធំ ធ្វើឱ្យកម្មជរូបប្រព្រឹត្តទៅក្នុងអំណាច ១ ឈ្មោះ ឥន្ទ្រិយបច្ច័យ ។

១៧-*ឈានប្បច្ចយោ* អង្គឈាន ៥ មានវិតក្កៈជាដើមជាបច្ច័យឱ្យកម្លាំងដល់រូបធម៌នាមធម៌ដែលព្រមដោយព្រមខ្លួនឈ្មោះឈានបច្ច័យ ។

១៨-*មគ្គប្បច្ចយោ* អដ្ឋង្គិមគ្គ ៨ ជាចំណែកលោកិយ លោកុត្តរៈជាបច្ច័យឱ្យកម្លាំងនាម និងរូបដែលកើតនោះឈ្មោះ មគ្គបច្ច័យ ។

១៩-*សម្បយុត្តបច្ចយោ* ចិត្ត និងចេតសិកជាបច្ច័យដល់គ្នានឹងគ្នាគឺកើតព្រមគ្នា មានអារម្មណ៍ ឈ្មោះសម្បយុត្តបច្ច័យ ។

២១-*អត្ថិប្បច្ចយោ* នាមនិងរូបនៅមិនទាន់រលត់ជាបច្ច័យឱ្យកម្លាំងដល់គ្នានឹងគ្នាកាលនៅមិនរលត់ឈ្មោះអត្ថិបច្ច័យ ។

២២-*នត្ថិប្បច្ចយោ* នាមនិងរូបរលត់ហើយ នៅកើតជាបច្ច័យឱ្យកើតនាមនិងរូបត-ទៅក្នុងខាងមុខ ឈ្មោះនត្ថិប្បច្ច័យ ។

២៣-*វិគតប្បច្ចយោ* អធិប្បាយដូចនត្ថិប្បច្ច័យ ។

២៤-*អវិគតប្បច្ចយោ* អធិប្បាយដូចអត្ថិប្បច្ច័យ ។

ព្រះដ៏មានព្រះភាគ ព្រះអង្គត្រាស់ទេសនាព្យញ្ជនៈឱ្យផ្សេងគ្នា តែអត្ថជាមួយគ្នា ផ្សេងដោយព្យញ្ជនៈនោះ ព្រោះអនុលោមតាមអធ្យាស្រ័យនៃសត្វទាំងពួង បច្ច័យទាំងឡាយនោះព្រះអនុរុទ្ធាចារ្យលោករួមសម្តែងដោយពយកជា ៦ ពួកគឺ :

១-*នាមធម៌* ជាបច្ច័យដល់នាមធម៌ ៦ បច្ច័យឱ្យកើតតែនាមធម៌ម្យ៉ាង ។

២-*នាមធម៌* ជាបច្ច័យដល់នាមនិងរូបទាំងពីរ ៥ បច្ច័យឱ្យកើតបានទាំងនាមនឹងរូប។

៣-*នាមធម៌* ជាបច្ច័យដល់រូបធម៌ម្យ៉ាងឱ្យកើតរូបធម៌ម្យ៉ាង ។

៤-*រូបធម៌* ជាបច្ច័យដល់នាមធម៌ ដោយបច្ច័យចំណែក ១ ឱ្យកើតតែនាមធម៌ចំណែក១ ។

៥-*បញ្ញត្តិ និងនាមរូបទាំង ៣ ប្រការ* ជាបច្ច័យដល់នាមធម៌ ២ បច្ច័យឱ្យកើតតែនាមធម៌ចំណែក ១ ។

៦-*ប្រជុំ ២ នៃនាមនិងរូប* ជាបច្ច័យដល់នាមនិងរូប ៩ បច្ច័យចំពោះឱ្យកើតទាំងនាមធម៌ រូបធម៌ទាំង ២ ចំណែក ។

សួរថា បច្ច័យជាបឋមដែលពោលថា នាមធម៌ជាបច្ច័យ ៦ បច្ច័យឱ្យកើតតែនាមធម៌ចំណែក ១ ដូចម្តេច?

តបថា បច្ច័យ ៦ ឱ្យកើតបានតែនាមធម៌ចំណែក ១ នោះគឺអនន្តរប្បច្ច័យ ១ សមនន្ត-រប្បច្ច័យ ១ នត្ថិប្បច្ច័យ ១ វិគតប្បច្ច័យ ១ អាសេវនប្បច្ច័យ ១ សម្បយុត្តប្បច្ច័យ ១ ។

ធម៌ទាំងឡាយគឺចិត្ត ចេតសិក រលត់ចុះហើយថ្មីៗជាបច្ច័យដល់ធម៌ទាំងឡាយគឺ

ចិត្ត និងចេតសិកដែលជាបច្ចុប្បន្ន ដោយអំណាចនៃអនន្តរប្បច្ច័យ និងសមនន្តរប្បច្ច័យ និងនត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ។

ដែលហៅថា អនន្តរប្បច្ច័យនោះ ដោយសេចក្តីថា ញុំាងចិត្តដែលគួរនឹងកើតឱ្យកើត ចិត្តដែលមិនគួរនឹងកើតក៏មិនឱ្យកើត ដូចបញ្ចទ្វារាវជ្ជនចិត្តក្នុងដើមចក្ខុវិញ្ញាណក៏ជាហេតុជាបច្ច័យឱ្យចក្ខុវិញ្ញាណកើតជាលំដាប់ ចំណែកចក្ខុវិញ្ញាណក៏ជាចប្ច័យឱ្យកើតសម្បដិច្ឆន្នចិត្ត ។ ក៏ជាបច្ច័យឱ្យកើតសន្តីរណចិត្ត ។ ក៏ជាបច្ច័យឱ្យកើតវោដ្ឋវនចិត្ត។ ក៏ជាបច្ច័យឱ្យកើតជវនចិត្ត។ ក៏ជាបច្ច័យឱ្យកើតជវនចិត្តជាលំដាប់តទៅដូច្នេះ ទើបឈ្មោះថាអនន្តរប្បច្ច័យ ។

សមនន្តរប្បច្ច័យនោះ ក៏ដូចអនន្តរប្បច្ច័យដែរ ផ្សេងគ្នាតែព្យញ្ជនៈឯសេចក្តីនោះដូចគ្នា ព្រោះព្រះអង្គទេសនាអនុលោមតាមអធ្យាស្រ័យនៃសត្វ ។

នត្ថិប្បច្ច័យនោះ សេចក្តីធម៌មិនមាន ហើយក៏នៅជាបច្ច័យឱ្យកើតធម៌ដទៃឡើងទៀត ដូចចក្ខុវិញ្ញាណនឹងកើតនោះ បញ្ចទ្វារាវជ្ជនចិត្តមិនមានក្នុងចក្ខុទ្វារវិថី ក៏ជាបច្ច័យឱ្យកើតចក្ខុវិញ្ញាណឡើងបាន ។

បញ្ចទ្វារាវជ្ជន ជានត្ថិប្បច្ច័យនៃចក្ខុវិញ្ញាណ ។ ជានត្ថិប្បច្ច័យនៃសម្បដិច្ឆន្នៈ។ជានត្ថិ-បច្ច័យនៃសន្តីរណៈ។ជានត្ថិបច្ច័យនៃវោដ្ឋវនៈ។ជានត្ថិប្បច្ច័យនៃជវន ដោយលំដាប់ដូច្នេះ ។

វិគតប្បច្ច័យ ក៏អធិប្បាយដូចគ្នានឹងនត្ថិប្បច្ច័យ នត្ថិ ប្រែថា មិនមាន វិគតៈ ប្រែថាប្រាសចាក សេចក្តីដូចគ្នា ផ្សេងតែព្យញ្ជនៈ ។

ជវនចិត្តទាំងឡាយមានហើយក្នុងមុន ជាបច្ច័យដល់ជវនចិត្តមានក្នុងខាងក្រោយ-ដោយអំណាចនៃអាសេវនប្បច្ច័យ ។

សេចក្តីថា អាសេវនប្បច្ច័យនោះ ចំពោះមានក្នុងជវនចិត្តជាបច្ច័យផ្សេងបំពេញចូលមក សេចក្តីថា បឋមជាជវនជាអនន្តរប្បច្ច័យ និងសមនន្តរប្បច្ច័យ និងនត្ថិប្បច្ច័យ និងវិគត-ប្បច្ច័យនៃទុតិយជវន ហើយក៏ជាអាសេវនប្បច្ច័យផងទៀត ត។ទៅដរាបអស់ទាំង ៧ ជវន។

ដែលហៅថាអាសេវនៈនោះ ព្រោះមានជាតិស្មើគ្នាជវនទី ១ ជាកុសលឬអកុសលជាសោមនស្សឬទោមនស្ស ជាសសង្ខារិក ឬអសង្ខារិកយ៉ាងណាជវនទាំងឡាយមានទុតិយ-

ជវនជាដើមក៏យ៉ាងនោះដូចគ្នា ជវនចិត្តមានជាតិស្មើគ្នា ឱ្យកម្លាំងដល់គ្នានឹងគ្នាឱ្យសម្រេចជាបុណ្យនិងជាបាបបាន ប្រៀបដូចគោ ៧ ពឹងកម្លាំងនៃគ្នានឹងគ្នាអូសឈើធំៗទៅបាន ទើបឈ្មោះថាអាសេវនប្បច្ច័យ លើកតែលោកុត្តរជវន ៧ មិនជាអាសេវនប្បច្ច័យឡើយ ។

ធម៌ទាំងឡាយគឺចិត្ត និងចេតសិក កើតហើយព្រមគ្នា ជាបច្ច័យដល់គ្នានឹងគ្នាដោយអំណាចប្រកបព្រមដល់គ្នានឹងគ្នា ឈ្មោះថាសម្បយុត្តប្បច្ច័យ ។

សម្បយុត្តប្បច្ច័យនោះ មាននៅសម្រាប់ចិត្តគ្រប់ៗខណចិត្ត ដោយសេចក្ដីថា ចិត្តនិងចេតសិកកើតព្រមគ្នា រលត់ព្រមគ្នា ប្រកបព្រមគ្នាដូច្នេះទើបឈ្មោះថា សម្បយុត្តបច្ច័យ ។

( សម្ដែងបច្ច័យ ៦ ប្រការក្នុងទី ១ អស់សេចក្ដីតែប៉ុណ្ណេះ)

សួរថា ក្នុងពួកទី ២ សេចក្ដីថានាមធម៌ជាបច្ច័យ ៥ បច្ច័យឱ្យកើតនាមនិងរូបព្រមទាំង ២ ចំណែកនោះ នឹងមានសេចក្ដីអធិប្បាយយ៉ាងណា?

តបថា មានសេចក្ដីអធិប្បាយដូច្នេះថា :

ហេតុនិងអង្គ និងអង្គនៃមគ្គទាំងឡាយ ជាបច្ច័យដល់នាមនិងរូបទាំងឡាយ ដ៏កើតហើយដោយអំណាចនៃបច្ច័យមានហេតុប្បច្ច័យជាដើម ។

សេចក្ដីថាហេតុ ៦ គឺលោភ: ១ ទោស: ១ មោហ: ១ ជា ៣ ៗនេះជាហេតុនៃបច្ច័យចំណែកបាបឱ្យកើតនាមនឹងរូបក្នុងអបាយ ៤ ។

អលោភ: អទោស: អមោហ: ៣ នេះជាហេតុនៃបច្ច័យចំណែកបុណ្យឱ្យកើតមនុស្សសុគតិ និងឆកាមាវចរ ។

អង្គឈាន ៥ មានវិតក្ក:ជាដើម ជាអង្គនៃឈានមានបឋមជ្ឈានជាដើមជារូបាវចរ-កុសលក៏ជាបច្ច័យឱ្យកើតនាមនិងរូបក្នុងឈានភូមិទាំងឡាយ បឋមជ្ឈានភូមិជាដើម រូបាទិ-ឈានបច្ច័យនោះ មានកម្មជរូបកើតក្នុងបដិសន្ធិខណ: ចិត្តសមុដ្ឋាន រូបនោះកើតក្នុងបវត្តិ-កល ។

អង្គមគ្គ ១២ គឺសម្មាទិដ្ឋិ ១ ។ល។ សម្មាសមាធិ, ៨ នេះជាចំណែកខាងកុសល

មិច្ឆាទិដ្ឋិ ១ មិច្ឆាសង្កប្បៈ ១ មិច្ឆាវាយាមៈ១ មិច្ឆាសមាធិ ១, ៤ នេះជាចំណែកខាងអកុសល អង្គ ១២ នេះជាបច្ច័យឱ្យកើតនាម និងរូបក្នុងសុគតិភព និងទុគ្គតិភព ។

ឱ្យកើតរូបនោះគឺ កម្មជរូបក្នុងបដិសន្ធិកាល ចិត្តជរូបក្នុងបវត្តិកាល ។

អង្គ ៨ ចំណែកខាងកុសលឱ្យកើតនាម និងរូបដ៏ឧត្តមក្នុងសុគតិភព អង្គមគ្គ ៤ ដែលជាចំណែកខាងអកុសលឱ្យកើតនាម និងរូបដ៏អាក្រក់ក្នុងទុគ្គតិភព ។

ចេតនា ២ យ៉ាងគឺសហជាតចេតនា ១ នានាខណិកចេតនា ១ សហជាតចេតនាកើតព្រមដោយកុសលចិត្ត កាលធ្វើកុសល និងអកុសល ក្នុងបច្ច័យជាតិនេះ នានាខណិកចេតនានោះជាចេតនាប្រព្រឹត្តទៅក្នុងខណៈផ្សេងៗដោយកុសលចិត្តឱ្យសម្រេចជាបុណ្យ ការបាបមានមកហើយអំពីជាតិមុន ។

សេចក្តីថា កុសលាកុសលដែលសត្វធ្វើហើយអំពីជាតិមុន ភពមុននោះជាប់តាមមកទាន់តាក់តែងឱ្យកើតសុខ និងទុក្ខនោះគឺនានាខណិកចេតនា ម្យ៉ាងទៀត កុសលាកុសលដែលសត្វធ្វើក្នុងជាតិនេះក៏ឱ្យផលក្នុងជាតិនេះ ហៅថា នានាខណិកចេតនាដូចគ្នា ។

សហជាតចេតនានោះ ជាកម្មប្បច្ច័យនៃនាមនិងរូបដែលកើតព្រមដោយខ្លួន និងរួមខណចិត្តមួយអន្លើដោយខ្លួនឱ្យនៅក្នុងអំណាចនានាខណិកចេតនានោះមានអំណាចច្រើន - ដល់នាម និងរូបសត្វទាំងឡាយដែលជនកកម្មឱ្យកើតហើយ បើនានាខណិកចេតនាចូលឧបត្ថម្ភទំនុកបំរុងហើយ ក៏ចំរើនដោយអាយុ វណ្ណៈ សុខៈ ពលៈ បរិបូណ៌គ្រប់ប្រការ បើនានាខណិកចេតនាចូលបៀតបៀនហើយ ក៏កើតរោគ ភ័យ វិបត្តិផ្សេងៗ កាត់បង់នូវជីវិតិន្ទ្រិយក៏បានចំណែកដោយកម្មនោះនានាខណិកចេតនា ជាកម្ម ១១ យ៉ាងមានទិដ្ឋធម្មវេទនីយកម្មជាដើម មានឧបឃាដកម្មជាទីបំផុត ចេតនា ២ យ៉ាងដែលពោលមកនោះឈ្មោះថាកម្មប្បច្ច័យ ។

វិបាកចិត្តឱ្យសម្រេចកិច្ចជាបដិសន្ធិ និងភវង្គ រហូតដល់ចុតិ ឈ្មោះថាវិបាកខន្ធ៦នេះអាស្រ័យនូវគ្នានឹងគ្នា ជាវិបាកបច្ច័យដល់គ្នានឹងគ្នាហើយទើបកើត ។

ម្យ៉ាងទៀត វិបាកខន្ធជាវិបាកបច្ច័យឱ្យកើតកម្មជរូប តាំងអំពីបដិសន្ធិខណៈមកហើយ ឱ្យកើតចិត្តសមុដ្ឋានរូបតាំងអំពីភវង្គមុនបដិសន្ធិមក ។

វិបាកខន្ធនេះ ចាត់ជានាមធម៌ ជាបច្ច័យឱ្យកើតនាមធម៌និងរូបធម៌ទាំង២ ចំណែក ។

សម្តែងបច្ច័យ ៥ គឺហេតុប្បច្ច័យ ១ ឈានប្បច្ច័យ ១ មគ្គប្បច្ច័យ ១ កម្មប្បច្ច័យ ១ វិបាកប្បច្ច័យ ១ ជានាមធម៌តែ ១ ជាបច្ច័យ ៥ ឱ្យកើតនាមធម៌ និងរូបធម៌ទាំង ២ ចំណែក ក៏ចប់តែប៉ុណ្ណេះ ។

សួរថា ក្នុងពួកទី ៣ សេចក្តីថានាមធម៌ជាបច្ច័យចំណែក ១ ឱ្យកើតរូបធម៌ចំណែក ១ នោះដូចម្តេច ?

ឆ្លើយថា ធម៌ទាំងឡាយគឺចិត្ត និងចេតសិក នឹងកើតក្នុងខាងក្រោយជាបច្ច័យនៃកាយនេះ ដែលកើតហើយមុន ឈ្មោះថា បច្ឆាជាតប្បច្ច័យ ។

ចិត្ត ៨៩ លើកយកទ្វិបញ្ចវិញ្ញាណ ១០ និងអរូបវិបាក ៤ ចេញនៅសល់ ៧៥ ចិត្តជាបច្ច័យឱ្យកើតចិត្តសមុដ្ឋានរូបបានទាំងអស់ រូបធម៌ដែលគួរនឹងកើតមុននោះ មិនកើតឡើងបានដោយទំនើងខ្លួនឯងចំណែក ១ ត្រូវអាស្រ័យចិត្តនិងចេតសិកដែលនឹងកើតក្នុងក្រោយជាបច្ច័យឧបត្ថម្ភគាំទ្រឱ្យកម្លាំងទើបកើតឡើងបាន ឧបមាដូចខ្សែទឹកដែលហូរជន់លិចទៅក្នុងទីទាំងពួងបាន ព្រោះហេតុនេះហើយទើបថាចិត្តនិងចេតសិកដែលកើតខាងក្រោយនោះ បានឈ្មោះថា បច្ឆាជាតបច្ច័យ ។

សួរថា ក្នុងពួកទាំង ៤ សេចក្តីថា រូបធម៌ម្យ៉ាងឱ្យកើតនាមធម៌ចំណែក ១ នោះដូចម្តេច ?

ឆ្លើយថា រូបធម៌ម្យ៉ាងជាបច្ច័យនៃនាមធម៌នោះ អធិប្បាយថា រូបកើតប្រាកដមុន ចិត្តនិងចេតសិកនោះទើបកើតឡើងបាន ហេតុនោះ រូបទើបឈ្មោះថាបុរេជាតប្បច្ច័យ ។ នេះមាន ២ យ៉ាងគឺ វត្ថុបុរេជាតប្បច្ច័យ ១ អារម្មណបុរេជាតប្បច្ច័យ ១ ។

វត្ថុ ៦ មានចក្ខុជាដើមផង អារម្មណ៍ ៦ មានរូបជាដើមមកប្រាកដក្នុងបញ្ចទ្វារវិថីផង ជាបច្ច័យនៃវិញ្ញាណធាតុ ៧ ដោយអំណាចបុរេជាតប្បច្ច័យកើតហើយមុនក្នុងបវត្តិកាល ។

សេចក្តីថា មានវត្ថុរូបគឺចក្ខុ សោតៈ ឃានៈ ជីវ្ហា កាយ ទាំង ៥ នេះតាំងនៅជាទីមួយ អារម្មណបុរេជាតប្បច្ច័យគឺរូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ទាំង ៥ នេះទើបបានឱកាសមកកើតក្នុងចក្ខុទ្វារវិថី សោតទ្វារវិថី ឃានវិថី ជីវ្ហាទ្វារវិថី កាយទ្វារវិថី នោះចាត់ជាទី ២ ខាងវិញ្ញាណធាតុ ៧ គឺបញ្ចទ្វារាវជ្ជនៈ ១ បញ្ចវិញ្ញាណ ១ សម្បដិច្ឆន្នៈ ១ សន្តីរណៈ ១ វោដ្ឋវនៈ ១ ជវនៈ ១ តទាលម្ពណៈ ១ ទើបអាចកើតឡើងបាន ។

ក្នុងមនោទ្វារនោះមានហទយវត្ថុចាប់ជាទី ១ ធម្មារម្មណ៍ទើបបានឱកាសមកប្រាកដក្នុងមនោទ្វារវិថីនេះចាត់ជាទី ២ ខាងក្រោយមនោទ្វារាវជ្ជនៈ ១ ជវនៈ ១ តទាលម្ពណៈ ១ ទើបបានមកកើតក្នុងកាលខាងក្រោយ ហទយវត្ថុជាបុរេជាតប្បច្ច័យទី ១ ធម្មារម្មណ៍ជាបុរេជាតប្បច្ច័យទី ២ រូបធម៌ ១ ជាបច្ច័យដល់នាមធម៌ ដូចពោលមកនោះ ។

( អស់សេចក្តីក្នុងពួកទី ៤ តែប៉ុណ្ណោះ )

ក្នុងពួកទី ៥ សេចក្តីថាធម៌ ៣ យ៉ាងគឺបញ្ញត្តិ ១ នាម ១ រូប ១ ជាបច្ច័យនៃនាមធម៌ជាបច្ច័យ ២ យ៉ាងគឺ អារម្មណប្បច្ច័យ ១ ឧបនិស្សយប្បច្ច័យ ១ និងលើកបញ្ញត្តិ និងនាម និងរូបទាំង ៣ នេះឡើងសម្តែងមុន ។

ឈ្មោះសត្វ ឈ្មោះមនុស្ស ឈ្មោះវត្ថាភរណៈឈ្មោះគ្រឿងឧបភោគ និងគ្រឿងបរិ-ភោគ ឈ្មោះវិញ្ញាណកទ្រព្យ និងអវិញ្ញាណកទ្រព្យ ឈ្មោះដែលលោកតែងមានហៅផ្សេង ៗ គេតែងតាំងឡើងជាចំណែកឱ្យហៅថា ដូច្នេះ ដូច្នោះ ឈ្មោះនេះ ឈ្មោះនោះ របស់ដូចន័យដែលបានពោលមកនេះហៅថាបញ្ញត្តិធម៌ ជាធម៌គឺលោកតែងតាំងឡើង ។

ចិត្ត ១ ចេតសិក ១ ហៅថា នាមធម៌ ។

រូប ១ សំឡេង ១ ក្លិន ១ រស ១ ផោដ្ឋព្វៈ ១ ហៅថា រូបធម៌ ។

រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ជា ៥ ចិត្ត ១ ចេតសិក ១ បញ្ញត្តិ ១ បើចំណែកនេះរួមជា ១ ផ្សំគ្នាជាអារម្មណ៍ ៦ ៗ នេះមកប្រាកដដល់ទ្វារទាំង ៦ កាលណាក៏ជាអារម្មណ-ប្បច្ច័យនៃវិថីចិត្តទាំង ៧ កើតឡើងក្នុងកាលនោះ ។

ធម៌ ៣ យ៉ាងគឺបញ្ញត្តិ ១ នាម ១ រូប ១ កាលជាឧបនិស្សយប្បច្ច័យនោះចាត់ជា ៣ យ៉ាងគឺ អារម្មណូបនិស្ស័យ ១ អនន្តរូបនិស្ស័យ ១ បកតូបនិស្ស័យ ។

អារម្មណូបនិស្ស័យនោះ សេចក្តីថា ពុទ្ធាទិរូបដែលជនគេគោរពរាប់អានក្តី សីល ៥ សីល ៨ សីល ១0 និងសមាធិភាវនា និងវិបស្សនាភាវនាក្តីនិងមគ្គផលជាទីស្រឡាញ់គោរពរាប់អានក្តី ហៅថាអារម្មណូបនិស្ស័យ ។

អនន្តរូបនិស្ស័យនោះ សេចក្តីថា ចិត្តនិងចេតសិកដែលរលត់ចុះថ្មី ៗ ជិតគ្នានឹងចិត្តចេតសិកបច្ចុប្បន្នប្បច្ច័យឱ្យកើតចិត្តនិងចេតសិកបច្ចុប្បន្ន បានកើតរៀងជិតខណៈគ្នាហៅថាអនន្តរូបនិស្ស័យ ។

អនន្តរប្បច្ច័យនិងអនន្តរូបនិស្ស័យទាំង២ នេះក៏ដូចគ្នាប្លែកតែមានកម្លាំងច្រើននិងតិច កាលជាអនន្តរប្បច្ច័យនោះមានកម្លាំងតិច កាលជាអនន្តរូបនិស្ស័យនោះមានកម្លាំងច្រើន ។

បកតូបនិស្ស័យនោះសេចក្តីថា រាគ ទោសៈ មោហៈ មានទិដ្ឋិជាឧបនិស្ស័យជាចំណែកអកុសល សទ្ធា សីលៈ សុតៈ ចាគៈ សមាធិ បញ្ញាជាឧបនិស្ស័យចំណែកខាងកុសល។

សេចក្តីសុខកាយ សុខចិត្ត កល្យាណមិត្ត គ្រូអាចារ្យនិងភោជនជាទីសប្បាយ និងរដូវជាទីសប្បាយ និងសេនាសនៈជាទីសប្បាយ ជាឧបនិស្ស័យចំណែកល្អ សេចក្តីទុក្ខ ទុក្ខចិត្តនិងបាបមិត្ត និងមនុស្សទ្រុស្តសីល និងភោជនជាទីធុញទ្រាន់ ឬជាទីខ្ពើមឆ្អើមមិនជាទីសប្បាយក៏ជាឧបនិស្ស័យចំណែកខាងអាក្រក់ ។

វត្ថុខាងក្នុងផង វត្ថុខាងក្រៅផងសមគួរនឹងញ៉ាំងកុសលាទិធម៌និងកម្មវិបាកឱ្យកើតឡើងបានឈ្មោះថាបកតូបនិស្ស័យទាំងអស់ ។

( សម្តែងសេចក្តីក្នុងពួកទី ៥ អស់សេចក្តីតែប៉ុណ្ណេះ )

ក្នុងពួកទី ៦ សេចក្តីថា នាមនិងរូបជាបច្ច័យឱ្យកើតនាម និងរូបតែងមានដោយគួរដោយប្រការ ៩ នោះគឺ អធិបតិប្បច្ច័យ ១ សហជាតប្បច្ច័យ ១ អញ្ញមញ្ញប្បច្ច័យ ១ និស្សយ-ប្បច្ច័យ ១ អាហារប្បច្ច័យ ១ ឥន្ទ្រិយប្បច្ច័យ ១ វិប្បយុត្តប្បច្ច័យ ១ អត្ថិប្បច្ច័យ ១ អវិគតប្បច្ច័យ ១ ។

អារម្មណាធិបតិប្បច្ច័យនោះ សេចក្តីថាអារម្មណ៍ដែលបុគ្គលគប្បីធ្វើគោរពមានពុទ្ធាទិរូបជាដើមជាបច្ច័យនៃនាមធម៌គឺចិត្ត ៨៤ ក្នុងចិត្ត ៨៩ លើកយកចិត្ត ៥ ចេញគឺបដិឃចិត្ត២ មោហចិត្ត ២ ទុក្ខសហគតកាយវិញ្ញាណ ១ ជា ៥ នៅសល់ចិត្ត ៨៤ មានអារម្មណាធិបតិ-ប្បច្ច័យ ។

រូប ២៨ ក៏ឈ្មោះថា អារម្មណាធិបតិ ព្រះនិព្វានក៏ឈ្មោះថាអារម្មណាធិបតិ ហេតុព្រះនិព្វានជាអារម្មណ៍នៃគោត្រភូចិត្ត និងមគ្គចិត្ត ។

សហជាតាធិបតិប្បច្ច័យនោះ បានដល់អធិបតិ ៤ គឺឆន្ទាធិបតិ ១ វីរិយាធិបតិ ១ ចិត្តាធិបតិ ១ វីមំសាធិបតិ ១ តែថាមិនជាបច្ច័យព្រមគ្នាទេ បើអធិបតិឯណាជាបច្ច័យហើយ អធិបតិ ៣ ដែលសល់នៅនោះ ក៏ជួយឧបត្ថម្ភទំនុកបំរុងគ្នា ។

ឆន្ទៈ ១ វីរិយៈ ១ ចិត្តៈ ១ អធិបតិ ៣ នេះមានក្នុងទុហេតុកចិត្ត ក្នុងចិត្តដ៏មិនមានវិមំសាធិបតិ មានក្នុងចិត្តជាត្រៃហេតុ ក្នុងចិត្តដទៃមិនមាន ។

*សហជាតប្បច្ច័យមាន ៣ ប្រការគឺៈ

១-ចិត្តនិងចេតសិកកើតព្រមគ្នា ទំនុកបំរុងនូវគ្នានឹងគ្នា ជាសហជាតប្បច្ច័យឱ្យកើតកម្មជរូប ចិត្តសមុដ្ឋានរូប ។

២-មហាភូតរូប ៤ កើតព្រមគ្នាជាសហាជាតប្បច្ច័យឱ្យកើតឧបាទាយរូប ២៤ ព្រមគ្នា ។

៣-កម្មជរូបនិងវិបាកខន្ធកើតព្រមគ្នាជាសហជាតប្បច្ច័យក្នុងកាលដែលសត្វបដិសន្ធិ។

*អញ្ញមញ្ញប្បច្ច័យមាន ៣ ប្រការគឺៈ

១-ចិត្តនិងចេតសិកជាបច្ច័យដល់គ្នានឹងគ្នា ។

២-មហាភូតរូបនឹងឧបាទាយរូបជាបច្ច័យដល់គ្នានឹងគ្នា ។

៣-កម្មជរូប និងវិបាកខន្ធជាបច្ច័យដល់គ្នានឹងគ្នាក្នុងបដិសន្ធិខណៈ ។

*និស្សយប្បច្ច័យមាន ៣ ប្រការគឺ:

១-ចិត្ត និងចេតសិកអាស្រ័យនូវគ្នានឹងគ្នា ជានិស្សយប្បច្ច័យនៃកម្មជរូប និងចិត្ត—សមុដ្ឋានរូប ។

២-មហាភូតរូបអាស្រ័យគ្នានឹងគ្នា ជានិស្សយប្បច្ច័យនៃឧបាទាយរូប ២៤ ។

៣-វត្ថុ ៦ មានចក្ខុជាដើមមានហទយវត្ថុដែលប្រាកដនូវក្នុងទីករក្សាហទយៈជាទីកើតនៃមនោធាតុ និងមនោវិញ្ញាណធាតុជាទីបំផុត វត្ថុរូប ៦ ប្រការនេះជានិស្សយប្បច្ច័យនៃវិញ្ញាណធាតុ ៧ ។

និស្សយប្បច្ច័យ ២ ខាងដើមនេះគួរនឹងហៅថា សហជាតនិស្សយប្បច្ច័យដោយសេចក្ដីថាចិត្តនិងចេតសិក និងមហាភូតរូបកើតព្រមគ្នាអាស្រ័យនូវគ្នានឹងគ្នាសុទ្ធជាទីអាស្រ័យនៃកម្មជរូបនិងចិត្តសមុដ្ឋានរូប និងឧបាទាយរូប ។

និស្សយប្បច្ច័យទី ៣ នោះគួរនឹងហៅថា បុរេជាតនិស្សយប្បច្ច័យៈ ដាយសេចក្ដីថា វត្ថុ ៦ ប្រការកើតមុនហើយចិត្ត និងចេតសិកទើបមកកើតក្នុងខាងក្រោយ ។

*អាហារប្បច្ច័យមាន ២ ប្រការគឺ:

១-អាហារមានឱជៈ ដែលបុគ្គលធ្វើឱ្យជាពំនូតហើយបរិភោគ ឱជៈជ្រួតជ្រាបទៅឱ្យកើតជាអាហារជរូប ឧបត្ថម្ភ កម្មជរូប និងចិត្តជរូប និងឧតុជរូបដោយសមគួរដល់កម្លាំង ។

២-អាហារមិនមានរូប ៣ ប្រការគឺផស្សាហារ បានដល់ផស្សៈ ៦ ប្រការ មនោ-សញ្ចេតនាហារ បានដល់កុសលចេតនា និងអកុសលចេតនា ១ វិញ្ញាណាហារ បានដល់បដិសន្ធិចិត្ត ១ អាហារមិនមានរូប ៣ ប្រការនេះជាបច្ច័យឱ្យកើតចិត្ត និងចេតសិក និងឱ្យកើតកម្មជរូប និងចិត្តសមុដ្ឋានរូបដែលនឹងកើតនឹងរលត់ព្រមដោយខ្លួន ។

*ឥន្ទ្រិយប្បច្ច័យមាន ៣ ប្រការគឺ:

១-បសាទរូប ៥ ហៅថាបុរេជាតិន្ទ្រិយ សេចក្ដីថាចក្ខុបសាទនោះបើជ្រះថ្លាល្អហើយក៏ជាបច្ច័យឱ្យកើតចក្ខុវិញ្ញាណឱ្យឃើញរូបដែលល្អិតរូបដែលនៅក្នុងទីឆ្ងាយឱ្យឃើញជាក់-

បាន ឯបសាទរូប ៤ មានសោតបសាទជាដើមនោះក៏ជាបច្ច័យរបស់វិញ្ញាណ ៤ មានសោតវិញ្ញាណជាដើមអធិប្បាយដូចចក្ខុបសាទដែរ ។

២-ជីវិតិន្ទ្រិយ ដែលជ្រាបនៅក្នុងឧបាទិន្នករូបគឺកម្មជរូប ១៨ ប្រការ នោះក៏ជាបច្ច័យរបស់ឧបាទិន្នករូប ។

៣-សហជាតិន្ទ្រិយនោះបានដល់ឥន្ទ្រិយ ១៤ មានមនិន្ទ្រិយជាដើមមានអញ្ញតាវិន្ទ្រិយជាឥន្ទ្រិយមិនមានរូបជាបច្ច័យជាធំឱ្យនាមធម៌ រូបធម៌ដែលកើតព្រមដោយខ្លួនប្រព្រឹត្តទៅក្នុងអំណាចបាន ។

*វិប្បយុត្តប្បច្ច័យមាន ៣ ប្រការគឺ សហជាតវិប្បយុត្តប្បច្ច័យ ១ បច្ឆាជាតវិប្បយុត្ត-ប្បច្ច័យ ១ បុរេជាតវិប្បយុត្តប្បច្ច័យ ។

សហជាតវិប្បយុត្តប្បច្ច័យទី ១ នោះគឺ ចិត្ត និងចេតសិកជាបច្ច័យដល់កម្មជរូប និងសមុដ្ឋានរូបនិងវិបាកខន្ធ ដោយអំណាចកើតព្រមគ្នាក្តី ចិត្តនិងចេតសិកជាបច្ច័យដល់រូបកើតព្រមគ្រប់ ៧ ខណចិត្ត ដោយអំណាចកើតព្រមគ្នាក្តី កើតព្រមគ្នាក្នុងបដិសន្ធិខណៈក្តីក្នុងភវង្គខណៈក្តីតាំងអំពីបឋមភវង្គ រហូតដល់ចុតិចិត្តកើតក្តី ការកើតនោះកើតព្រមគ្នាកាលនឹងរលត់នោះ វិបាកខន្ធជាអ្នកឱ្យសម្រេចកិច្ចជាបដិសន្ធិ ភវង្គនោះរលត់ទៅមុន រូបដែលកើតព្រមដោយចិត្តគ្រប់ ៧ ខណចិត្តនោះមិនទាន់រលត់ឡើយ តាំងនៅរហូតគ្រប់ ១៧ ខណចិត្តទើបរលត់ព្រោះហេតុនេះទើបឈ្មោះថាសហជាតវិប្បយុត្តប្បច្ច័យ ព្រោះជាបច្ច័យកើតព្រមគ្នានឹងការរលត់ព្រាត់ប្រាសចាកគ្នា ។

បច្ឆាជាតវិប្បយុត្តប្បច្ច័យទី ២ នោះគឺចិត្តនិងចេតសិកដែលកើតខាងក្រោយជាបច្ច័យឱ្យរូបកើតមុន កើតមិនរួមខណៈគ្នា តែចិត្ត និងចេតសិកដែលកើតខាងក្រោយនោះឱ្យកម្លាំងដល់រូបដែលកើតមុន ព្រោះហេតុនេះទើបឈ្មោះថាបច្ឆាជាតវិប្បយុត្តប្បច្ច័យ ។

បុរេជាតវិប្បយុត្តប្បច្ច័យទី ៣ នោះសេចក្តីថា បសាទរូប ៥ ហទយវត្ថុ ១ ជា ៦ កើតមុន កើតមិនរួមខណៈគ្នា តែជាបច្ច័យឱ្យកម្លាំងដល់វិញ្ញាណធាតុ ៧ ក្នុងបវត្តិកាលខាងមុខអំពីបដិសន្ធិកាលដោយអំណាចវត្ថុជាអ្នកកើតមុនឱ្យកម្លាំងដល់ចិត្ត និងចេតសិកដែលកើត-

ខាងក្រោយ ព្រោះហេតុនេះទើបឈ្មោះថា បុរេជាតវិប្បយុត្តប្បច្ច័យ ។

អត្ថិប្បច្ច័យមាន ៥ ប្រការគឺសហជាតអត្ថិ ១ បុរេជាតអត្ថិ ១ បច្ឆាជាតអត្ថិ ១ កវឡិង្ការាហារអត្ថិ ១ រូបជីវិតិន្ទ្រិយអត្ថិ ១ ត្រូវជា ៥ ប្រការ ។

សហជាតអត្ថិនោះ អធិប្បាយដូចសហជាតប្បច្ច័យ ។

បុរេជាតអត្ថិនោះ អធិប្បាយដូចបុរេជាតប្បច្ច័យ ។

បច្ឆាជាតអត្ថិនោះ អធិប្បាយដូចបច្ឆាជាតប្បច្ច័យ ។

ផ្សេងគ្នាតែកវឡិង្ការាហារអត្ថិ និងរូបជីវិតិន្ទ្រិយអត្ថិ ។

អាហារអត្ថិនោះ មានតែកវឡិង្ការាហារម៉្យាង ផស្សាហារនិងមនោសញ្ចេតនាហារនិងវិញ្ញាណាហារមិនរាប់បញ្ចូលក្នុងអាហារអត្ថិប្បច្ច័យ ។

រូបជីវិតិន្ទ្រិយអត្ថិនោះ យកតែរូបជីវិតិន្ទ្រិយម៉្យាង ឥន្ទ្រិយដទៃ ៧ មិនរាប់ចូលក្នុងរូបជីវិតិន្ទ្រិយអត្ថិ ។

សួរថា សហជាតប្បច្ច័យ បុរេជាតប្បច្ច័យ បច្ឆាជាតប្បច័យ អាហារប្បច្ច័យ និងរូបជីវិតិន្ទ្រិយប្បច្ច័យ ក៏ចាត់ជាបច្ច័យម៉្យាង ៗ ហើយហេតុដូចម្តេចទើបយកមកចាត់អត្ថិប្បច្ច័យទៀតដើម្បីនឹងប្រាថ្នាផលដូចម្តេច ?

តបថា ព្រះដ៏មានព្រះភាគជាម្ចាស់មានប្រាថ្នានឹងឱ្យសត្វឃើញសេចក្តីច្បាស់ដូច្នេះថា សហជាតប្បច្ច័យនោះ អាស្រ័យកើតព្រមគ្នាក្នុងឧប្បាទខណៈ មាននៅដដែល ។

បុរេជាតប្បច្ច័យនោះកើតមុនក៏មាននៅដដែល ។

បច្ឆាជាតប្បច្ច័យនោះ កើតខាងក្រោយក៏មាននៅដដែល ។

កវឡិង្ការាហារនោះ ដើមចាត់ជាអាហារប្បច្ច័យហើយក៏យកមកចាត់ជាអត្ថិប្បច្ច័យទៀតនោះដោយមានពុទ្ធអធ្យាស្រ័យប្រាថ្នានឹងឱ្យឃើញថា អាហារដែលបុគ្គលបរិភោគនោះក៏នៅមានដដែល ទើបមិនទាន់បានបរិភោគ ក៏មានទាន់ជាបច្ច័យនៅឡើយគ្រាន់តែហៅថាអាហារ លុះបរិភោគកន្លងបំពង់កទៅហើយទើបនឹងកើតជាបច្ច័យព្រោះហេតុនោះទើបចាត់យកកវឡិង្ការាហារជាអត្ថិប្បច្ច័យទៀត ។

រូបជីវិតិន្ទ្រិយនោះ ដើមក៏ចាត់ជាបច្ច័យ ហើយក៏មកចាត់ជាអត្ថិប្បច្ច័យទៀតដោយមានព្រះពុទ្ធអធ្យាស្រ័យប្រាថ្នានឹងឃើញសេចក្ដីថា រូបជីវិតិន្ទ្រិយដែលមាននៅក្នុងរូបកលាបៈនោះក៏នៅមានដដែល ទើបចាត់យកមកជាអត្ថិប្បច្ច័យទៀត ។

( អត្ថិប្បច្ច័យ ចប់ )

អវិគតប្បច្ច័យក៏មាន ៥ ប្រការដូចនឹងអត្ថិប្បច្ច័យ ផ្សេងតែព្យញ្ជនៈ ព្រោះព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ទេសនាតាមពុទ្ធអធ្យាស្រ័យនៃសត្វ ។

ប្រមូលរូបរួមបច្ច័យជា ៩ ប្រការគឺអធិបតិប្បច្ច័យ ១ សហជាតប្បច្ច័យ ១ អញ្ញមញ្ញប្បច្ច័យ ១ និស្សយប្បច្ច័យ ១ អាហារប្បច្ច័យ ១ ឥន្ទ្រិយប្បច្ច័យ ១ វិប្បយុត្តប្បច្ច័យ ១ អត្ថិប្បច្ច័យ ១ អវិគតប្បច្ច័យ ១ ។

បច្ច័យទាំងពួងតែងប្រជុំចុះក្នុងបច្ច័យ ៤ ប្រការគឺអារម្មណប្បច្ច័យ ១ ឧបនិស្សយប្បច្ច័យ ១ កម្មប្បច្ច័យ ១ អត្ថិប្បច្ច័យ ១ ជា ៤។

បណ្ដារូបទាំងនោះ សហជាតរូបមាន ២ យ៉ាងគឺចិត្តសមុដ្ឋានក្នុងបវត្តិកាល ១ កម្មជរូបក្នុងបដិសន្ធិកាល ១ ។

*ឥតិ តេកាលិកា ធម្មា កាលមុត្តា ច សម្ភវា*
*អជ្ឈត្តញ្ច ពហិទ្ធា ច សង្ខតាសង្ខតា តថា ។*
*បញ្ញត្តិនាមរូបានំ វសេន តិវិធា ឋិតា*
*បច្ចយា នាម បដ្ឋានេ ចតុវីសតិ សព្វថា ។*

បច្ច័យ ២៤ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ហើយក្នុងគម្ពីរមហាបដ្ឋានដោយប្រការទាំងពួង តាំងនៅយ៉ាងណា ក៏ជាយ៉ាងនោះ ចាត់ដោយធម៌មាន ៣ ប្រការគឺបញ្ញត្តិធម៌ ១ នាមធម៌ ១ រូបធម៌ ១ ឯធម៌ប៉ុណ្ណោះនោះបច្ច័យប្រជុំតាក់តែងខ្លះមិនប្រជុំតាក់តែងខ្លះ ប្រកបក្នុងកាល ៣ គឺអតីតកាល អនាគតកាល បច្ចុប្បន្នកាលខ្លះ ផុតចាកកាលទាំង ៣ កើតព្រមហើយក្នុងខាងក្នុងខ្លះ ក្នុងខាងក្រៅខ្លះ ។

បញ្ញត្តិធម៌នោះ បើផុតចាកកាល ៣ ហើយ បច្ច័យក៏មិនប្រជុំតាក់តែងឡើយ ។

កងរូប ២៨ ឈ្មោះថា រូបធម៌ អរូបខន្ធ ៤ ដែលព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ហៅថាចិត្ត និងចេតសិក ជា ៥ ទាំងព្រះនិព្វាន បណ្ឌិតលោកហៅថាអរូបធម៌ផង នាមធម៌ផង ។

របស់ក្រៅចាករូបធម៌ នាមធម៌ឈ្មោះថា បញ្ញត្តិធម៌ ។ នេះមាន ២ យ៉ាងគឺ បញ្ញាបិយត្តាបញ្ញត្តិ ១ បញ្ញាបនតោបញ្ញត្តិ ១ ។

សួថា បញ្ញត្តិ ២ ប្រការនេះដូចម្ដេច ?

តបថា វត្ថុទាំងឡាយមានផែនដី និងភ្នំជាដើម លោកបញ្ញត្តហៅ ឈ្មោះនោះឈ្មោះនេះព្រោះអាស្រ័យអាការដែលប្រែប្រួលទៅនៃភូតរូបនោះ ៗ គ្រឿងប្រើអូសទាញហៅថារថ រទេះជាដើម ព្រោះអាស្រ័យអាការប្រជុំដោយគ្រឿងឈើដែលគេតាក់តែង ។

សត្វទាំងឡាយ គេហៅថាស្រីប្រុស និងបុគ្គលជាដើម ព្រោះអាស្រ័យខន្ធ ៥ ។

វោហារស្ថានទាំងឡាយ ហៅថា ទិសឯត្បូង ទិសឯជើង ទិសទាំង ៨ វេលាព្រឹក វេលាល្ងាច វេលាថ្ងៃជាដើម ព្រោះអាស្រ័យចន្ទគតិ-សុរិយគតិ មានកាលវិលមកនៃព្រះ-ចន្ទ និងព្រះអាទិត្យជាដើម ។

បថវីធាតុ ហៅថាអណ្ដូង ថាស្រះ ថារណ្ដៅ ថាប្រហោង ថាជ្រោះថាគុហាជាដើម ព្រោះអាស្រ័យអាការដែលមនុស្សមិនបានពាល់ត្រូវ គឺមិនបានធ្វើមិនបានជីកជារបស់កើតឡើងឯង ។

ម្យ៉ាងទៀត ប្រភេទដែលហៅថា កសិណនិមិត្ត និងឧគ្គហនិមិត្តជាដើមនោះ ព្រោះអាស្រ័យភូតនិមិត្តនោះ១ និងភាវនាវិសេសកើតជាអារម្មណ៍របស់ចេតសិក ដោយអាការជាស្រមោលរបស់សេចក្ដី មិនមានប្រាកដដោយបរមត្ថសច្ច អាចារ្យលោកកំណត់ប្រៀបធៀបហៅយកយកយ៉ាងនោះឯង ធ្វើហេតុផលប្រៀបធៀបកាន់យកចំណែកនោះ១ តាំងឈ្មោះសត្វ និងសង្ខារដែលមានវិញ្ញាណឱ្យដឹងព្រមៗគ្នា ឱ្យហៅនិងញ៉ាំងគ្នានឹងគ្នាឱ្យដឹងថាចំណែកនេះ ឈ្មោះនោះ ចំណែកនោះឈ្មោះនេះ ដូច្នេះឈ្មោះថា បញ្ញាបិយត្តាបញ្ញត្តិ ថាបញ្ញត្តិជាហេតុញ៉ាំងគ្នានឹងគ្នាឱ្យដឹងទូទៅ ។

ឯបញ្ញាបនតោបញ្ញត្តិនោះ  បុគ្គលចេញឈ្មោះហៅក្នុងកាលដែលត្រូវការនឹងប្រើប្រាស់ក្នុងកាលខាងក្រោយ តាមឈ្មោះដែលតាំងទុកអំពីមុននោះ ។

បញ្ញាបនតោបញ្ញត្តិនោះ មាន ៦ ប្រការគឺ វិជ្ជមានបញ្ញត្តិ ១ អវិជ្ជមានបញ្ញត្តិ ១ វិជ្ជមានេនអវិជ្ជមានបញ្ញត្តិ ១ អវិជ្ជមានេនវិជ្ជមានបញ្ញត្តិ ១ វិជ្ជមានេនវិជ្ជមានបញ្ញត្តិ ១ អវិជ្ជមានេនអវិជ្ជមានបញ្ញត្តិ ១ ។

អាចារ្យទាំងឡាយ លោកហៅខន្ធបញ្ចកៈថារូប ថាវេទនាជាដើម កាលមានដោយបរមត្ថដោយបញ្ញត្តិនោះកាលណាបញ្ញត្តិនេះឯង លោកហៅថា វិជ្ជមានបញ្ញត្តិកាលនោះ។

ជនទាំងឡាយបញ្ញត្តិវត្ថុមានផែនដី និងភ្នំជាដើម ដែលមិនមានដោយបរមត្ថ ដោយបញ្ញត្តិនេះកាលណា បញ្ញត្តិនេះបណ្ឌិតក៏ហៅថា អវិជ្ជមានបញ្ញត្តិកាលនោះ ។

បញ្ញត្តិដ៏សល់នោះ  បណ្ឌិតគប្បីដឹងដោយលំដាប់  ដោយអំណាចដែលច្រឡំគ្នានឹងបញ្ញត្តិទាំង ២ នោះ ។

ពាក្យដែលយកបរមត្ថទុកខាងចុង យកវោហារទុកខាងដើមដូចពាក្យថា (ឆឡភិ-ញ្ញា) ៦ អភិញ្ញា, (បញ្ចពលោ) ៥ ពលៈ, (សត្តពោជ្ឈង្គោ) ៧ ពោជ្ឈង្គ ។

ពាក្យថា អភិញ្ញា និពលៈ និងពោជ្ឈង្គ ៣ ពាក្យនេះ ជាបរមត្ថ ពាក្យថា ៦.៥.៧.បីពាក្យនេះជាលោកវោហារបញ្ញត្តិហៅដូច្នេះ ឈ្មោះថា វិជ្ជមានេនអវិជ្ជមានបញ្ញត្តិ ។

ពាក្យដែលយកលោកវោហារទុកខាងដើម យកបរមត្ថទុកខាងចុងនោះដូចពាក្យថា ស្រីមានសំឡេង ប្រុសមានសំឡេង បុគ្គលមានសំឡេង ក៏ពាក្យថាស្រីប្រុស បុគ្គលនោះ ជាលោកវោហារ  ពាក្យសំឡេងនោះជាបរមត្ថបញ្ញត្តិហៅដូច្នេះឈ្មោះថា  អវិជ្ជមានេនវិជ្ជ-មានបញ្ញត្តិ ។

ពាក្យដែលយកបរមត្ថសច្ចៈទុកទាំងខាងដើម ខាងចុងនោះដូចស័ព្ទថា ចក្ខុវិញ្ញាណ ពាក្យថាចក្ខុនោះជាបរមត្ថ  ពាក្យថាវិញ្ញាណក៏ជាបរមត្ថ  សោតវិញ្ញាណជាដើមក៏ដូចគ្នាបញ្ញត្តិយ៉ាងនេះ ឈ្មោះថា វិជ្ជមានេនវិជ្ជមានបញ្ញត្តិ ។

ពាក្យដែលជាលោកវោហារទាំងខាងដើម ទាំងខាងចុង ដូចពាក្យថា រាជបុត្ត អមច្ចបុត្ត ព្រាហ្មណបុត្ត គហបតិបុត្តជាដើម ពាក្យថារាជ ជាដើមក៏ជាលោកវោហារ ពាក្យថាបុត្តក៏ជាលោកវោហារបញ្ញត្តិ យ៉ាងនេះជាដើមឈ្មោះថា អវិជ្ជមានេនអវិជ្ជមានបញ្ញត្តិ លោកវោហារគឺហៅដោយគេតាក់តែងតាំងទុកហើយ ចេញឈ្មោះហៅក្នុងកាលដែលត្រូវការនឹងប្រើប្រាស់មាន ៦ ប្រការដូចសម្តែងមកនេះ ។

*វចីឃោសានុសារេន សោតវិញ្ញាណវីថិយា*
*បវត្តានន្តរុប្បន្ន- មនោទ្វារស្ស គោចរា ។*
*អត្ថា យស្សានុសារេន វិញ្ញាយន្តិ តតោ បរំ*
*សាយំ បញ្ញត្តិ វិញ្ញេយ្យា លោកសង្កេតនិម្មិតាតិ ។*

កាលបើសោតវិញ្ញាណវិថីមានក៏ឱ្យបានឮនាមបញ្ញត្តិនោះៗ ប្រព្រឹត្តទៅតាមសំឡេងនិយាយ សទ្ទារម្មណ៍មកផ្ទប់សោតបសាទ ញ៉ាំងសោតវិញ្ញាណឱ្យកើតឡើង សំឡេងនោះជាអារម្មណ៍របស់មនោទ្វារាវជ្ជនចិត្តៗ កើតខាងដើមនៃមនោទ្វារវិថីៗ កើតជាលំដាប់គ្នាកាលសទ្ទារម្មណ៍មកផ្ទប់សោតបសាទបញ្ចទ្វារាវជ្ជនចិត្តក៏កាត់ខ្សែភវង្គកើតឡើងខណៈ ១ ហើយក៏រលត់ទៅ សោតវិញ្ញាណកើតឡើងខណៈ ១ ហើយក៏រលត់ទៅដូចគ្នា លំដាប់នោះសម្បដិច្ឆន្នចិត្តកើតឡើងខណៈ១ ហើយក៏រលត់ទៅ សន្តីរណចិត្តកើតឡើងខណៈ១ ហើយក៏រលត់ទៅ វោដ្ឋវនចិត្តកើតឡើងខណៈ១ហើយក៏រលត់ទៅ លំដាប់នោះជវនចិត្តកើតឡើងដល់ ៧ ខណៈហើយក៏រលត់ទៅ គ្រានោះតទាលម្ពណចិត្តកើតឡើង ២ ខណៈហើយក៏រលត់ទៅ ។

ចិត្តក៏ធ្លាក់ចុះកាន់ខ្សែភវង្គដូចមុន ពោលដូច្នេះ ពោលដោយអារម្មណ៍ដែលបានឮនោះ ជាអតិមហន្តារម្មណ៍ ។

សោតវិញ្ញាណវិថី និងមនោទ្វារវិថីនោះ ស្ទុះបណ្តើរទៅជាមួយគ្នាមិនដាច់ ជនទាំងឡាយទើបបានដឹងហេតុផល អត្ថ ព្យញ្ជនៈ ទីឃៈរស្សៈ សិថិល គរុ លហុ ដោយគួរដល់សទ្ទារម្មណ៍ដែលមកផ្ទប់សោតបសាទនោះ ។

បុគ្គលតែងដឹងអត្ថ ព្យញ្ជនៈជាដើមនោះ ដឹងខាងមុខសទ្ទារម្មណ៍មកផ្ទប់សោតបសាទ ដឹងដោយរលឹកតាមឈ្មោះនោះ ដោយសេចក្តីតាមលោកសង្កេតនិមិត្ត ។

លោកសង្កេតនិមិត្តនោះគឺសភាវៈទាំងពួងកំណត់ហៅ កំណត់និយាយ អ្នកប្រាជ្ញគប្បី ដឹងថាជាឈ្មោះបញ្ញត្តិធម៌ ក្នុងបច្ចយសង្គហៈនេះ ។

អនុដីកាវិសជ្ជនាថា បុគ្គលនឹងដឹងសេចក្តីដោយកំណត់យ៉ាងតិចបំផុតត្រឹម ២ អក្សរ នោះសោតវិញ្ញាណវិថី និងមនោវិញ្ញាណវិថីកើតជាមួយគ្នា ក្នុងម្តង ២ វិថី កើត ៣ ដង ៦ វិថី បុគ្គលទើបដឹងច្បាស់ដូចយ៉ាង (ឃដ)ស័ព្ទប្រែថាក្អម ឬឆ្នាំង ជាអក្សរ ២ តួកាលបុគ្គល ស្តាប់អ្នកដទៃពោល ហើយបានដឹងថា (ឃ)នោះវិថីចិត្តលឿនទៅ ២ វិថី បឋមវិថីនោះ ឈ្មោះថាសោតវិញ្ញាណវិថី ទុតិយវិថីនោះឈ្មោះមនោទ្វារវិថី ហើយបានឮទៀតថា (ដ) ចិត្តក៏លឿនទៅទៀត ២ វិថីដូចគ្នាដូច្នេះជា ៤ វិថី ហើយយក (ឃ)ស័ព្ទនិង(ដ)ស័ព្ទមកត គ្នាវិថីចិត្តក៏លឿនទៅទៀត ២ វិថីជា ៣ ដងត្រូវជា ៦ វិថីទើបដឹងសេចក្តីច្បាស់ថា (ឃ) ស័ព្ទនេះ ពោលដោយចំណែកយ៉ាងតិចបំផុតត្រឹម ២ អក្សរ បើអក្សរច្រើនជាងនេះទៅ ក៏ គប្បីរាប់វិថីចិត្តឱ្យច្រើនឡើងទៅ ដូចន័យដែលពោលមកនេះចុះ ។

*ឥតិ អភិធម្មត្ថសង្គហេ*

*បច្ចយសង្គហវិភាគោ នាម អដ្ឋមោ បរិច្ឆេទោ*

បរិច្ឆេទទី ៨ ឈ្មោះបច្ចយសង្គហវិភាគ ក្នុងអភិធម្មត្ថសង្គហៈចប់តែប៉ុណ្ណោះហោង ។

# បរិច្ឆេទទី ៩

កម្មដ្ឋានសង្គហវិភាគ

*សមថវិបស្សនានំ ភាវនានមិតោ បរំ*
*កម្មដ្ឋានំ បវក្ខាមិ ទុវិធម្បិ យថាក្កមំ ។*

ខ្ញុំម្ចាស់ឈ្មោះអនុរុទ្ធាចារ្យ នឹងពោលនូវកម្មដ្ឋាន ២ យ៉ាងដោយលំដាប់ខាងមុខនៃសមថភាវនា នឹងវិបស្សនាភាវនានេះតទៅ ។

នឹងវិនិច្ឆ័យក្នុងសមថសង្គហៈជាមុន សមថសង្គហៈនោះចាត់នូវ កម្មដ្ឋាន ៤០ ជា ៧ ពួក គឺ កសិណ ១០ ពួក ១ អសុភ ១០ ពួក ១ អនុស្សតិ ១០ ពួក ១ អប្បញ្ញា ៤ ពួក ១ អាហារបដិកុលសញ្ញា ១ ពួក ១ ធាតុវវត្ថាន ១ ពួក ១ អរូប ៤ ពួក ១ ជា ៧ ពួក ។

ក្នុងចរិតសង្គហៈនោះចាត់កម្មដ្ឋានតាមចរិតជា ៦ យ៉ាង គឺ រាគចរិត ១ ទោសចរិត ១ មោហចរិត ១ សទ្ធាចរិត ១ ពុទ្ធិចរិត ឬ បញ្ញាចរិត ១ វិតក្កចរិត ១ ជា ៦ ពួក ។

*ចាត់តាមភាវនាជា ៣ គឺ បរិកម្មដ្ឋានា ១ ឧបចារភាវនា ១ អប្បនាភាវនា ១ ជា ៣ ។

*ចាត់តាមនិមិត្តជា ៣ គឺ បរិកម្មនិមិត្ត ១ ឧគ្គហនិមិត្ត ១ បដិភាគនិមិត្ត ១ ជា ៣ ។ សួរថា ក្នុងសមថកម្មដ្ឋាន ៤០ នោះគឺអ្វីខ្លះ ? ឆ្លើយថា សមថកម្មដ្ឋាន ៤០ នោះដូច្នេះ ។ កសិណ ១០ គឺ :

១-បឋវីកសិណ ព្រះយោគាវចរធ្វើកសិណដោយដីមានពណ៌ក្រហមដូចរស្មីព្រះអាទិត្យដែលទើបរះឡើង ជាវង់មូលមានទំហំ ១ ចំអាម ៤ ធ្នាប់ ដុះខាត់ឱ្យរាបស្មើដូចមុខស្គរហើយយកមកតាំងទុកចំពោះមុខ ចម្ងាយ ១ ហត្ថ ១ ចំអាមទើបបរិកម្មថា ( បឋវី១ ដី១ ) ។

២-អាបោកសិណ យកទឹកដែលថ្លាដាក់ចុះក្នុងភាជនៈមានបាត្រជាដើមឱ្យពេញដល់កណ្តាប់ បរិ- កម្មថា ( អាបោ ១ ទឹក១) ។

៣-តេជោកសិណ ធ្វើដោយពន្លឺភ្លើង យកវត្ថុមានកន្ទេលជាដើម មកវះចោះ ជាប្រហោងឱ្យមាន រង្វង់មូល មានទំហំ ១ ចំអាម ៤ ធ្នាប់ ហើយដាក់បាំងពីខាងមុខ សម្លឹងមើលពន្លឺភ្លើង តាមប្រហោងនោះ ពិចារណាថាភ្លើង ហើយបរិកម្មថា ( តេជោ១ ភ្លើង១ ) ។

៤-*វាយោកសិណ* ឱ្យមើលសក់មនុស្ស កាលខ្យល់បក់មកត្រូវក៏បានឬស្លឹកឈើ នឹងចុងស្មៅ ក៏បាន បរិកម្មថា (វាយោ។ ខ្យល់។) ។

៥-*នីលកសិណ* ធ្វើដោយសំពត់មានពណ៌ខៀវ ដែលពាសលើមាត់ភាជនៈក៏បាន ឬផ្កាឈើមាន ពណ៌ខៀវក៏បាន ដែលប្រដាប់ដាក់ចុះក្នុងភាជនៈ លាក់ទងនឹងកេសឱ្យបាត់កុំឱ្យឃើញ ឱ្យឃើញតែត្របក ឬស្រទាប់ បរិកម្មថា ( នីលំ។ ខៀវ។ ) ។

៦-*បីតកសិណ* ធ្វើដោយសំពត់មានពណ៌លឿងក៏បាន ឬផ្កាឈើមានពណ៌លឿងក៏បាន ធ្វើដូច គ្នា ហើយបរិកម្មថា ( បីតកំ។ លឿង។ ) ។

៧-*លោហិតកសិណ* ធ្វើដោយសំពត់មានពណ៌ក្រហមក៏បាន ឬផ្កាឈើមានពណ៌ក្រហមក៏បាន ហើយ បរិកម្មថា ( លោហិតកំ។ ក្រហម។ ) ។

៨-*ឱទាតកសិណ* ធ្វើដោយសំពត់មានពណ៌សក៏បាន ឬផ្កាឈើមានពណ៌ស ហើយបរិកម្មថា( ឱទាតោ។ ស។ ) ។

៩-*អាកាសកសិណ* ឱ្យមើលចន្លោះប្រហោងដែលមូល មានទំហំ ១ ចំអាម ៤ ធ្នាប់ យកអាកាសជា អារម្មណ៍ បើពុំនោះសោត បានកសិណទាំង ៩ ហើយបើកកសិណទាំង ៩ ចោលចេញ ហើយយកអាកាសទទេ មកជាអារម្មណ៍ បរិកម្មថា ( អាកាសោ។ ទទេ។) ។

១០-*អាលោកកសិណ* ឱ្យមើលពន្លឺភ្លើងដែលភ្លឺចេញចាកប្រហោងឯណា ១ ក៏បាន ឬមើលពន្លឺរស្មីនៃ ព្រះអាទិត្យ នឹងព្រះចន្ទក៏បាន ហើយបរិកម្មថា ( អាលោកោ។ ពន្លឺ។ ) ។

(កសិណ ១០ ចប់ដោយសង្ខេប )

*អសុភ ១០ គឺ :

១-*ឧទ្ធុមាតកំ* អសុភហើមពោរពងហើយ

២-*វិនីលកំ* អសុភហើមមានពណ៌ខៀវដូចសំពត់ខៀវ

៣-*វិបុព្វកំ* អសុភហើមមានទឹកខ្ទុះហូរទៅក្នុងខាងលើខាងក្រោម

៤-*វិច្ឆិទ្ទកំ* អសុភដែលគេកាត់ដាច់ពាក់កណ្ដាលខ្លួន

៥-*វិក្ខាយិតកំ* អសុភដែលសត្វខាំ កកេរ មានដំបៅរលុះរលួយគគ្រុះគគ្រុលផ្សេង ៗ

៦-*វិក្ខិត្តកំ* អសុភមានដៃ នឹងជើងដាច់ចេញជាកំណាត់ ៗ

៧-*ហតវិក្ខិត្តកំ* អសុភដែលគេកាប់សាប់មានស្នាមសាំរវាម

៨-*លោហិតកំ* អសុភត្រូវប្រហារមានលោហិតហូរស្រោចទៅ

៩-*បុឡុវកំ* អសុភមានដង្កូវវារហូរចេញចាកទ្វារទាំង ៩

១០-*អដ្ឋិកំ* អសុភមានតែរាងឆ្អឹងរាត់រាយខ្ទាត់ខ្ទាយផ្សេង ៗ

(អសុភ ១០ ចប់ដោយសង្ខេប )

* អនុស្សតិ ១០ គឺ :

១-*ពុទ្ធានុស្សតិ* រលឹកដល់ព្រះពុទ្ធគុណ តាំងអំពីពាក្យថា ( *បណិធានតោ បដ្ឋាយ*) ជាដើម ។

២-*ធម្មានុស្សតិ* រលឹកដល់គុណព្រះធម៌មាន ពាក្យថា *( និយ្យានិកោ ស្វាក្ខាតោ ភគវតា ធម្មោ )* ជាដើម ។

៣-*សង្ឃានុស្សតិ* រលឹកដល់គុណព្រះអរិយសង្ឃ មានពាក្យថា *( សុបដិបន្នោ ភគវតោ-សាវកសង្ឃោ )* ជាដើម ។

៤-*សីលានុស្សតិ* រលឹកដល់សីល ៥ សីល ៨ សីល ១០ ដែលខ្លួនរក្សាមានពាក្យថា *( អខណ្ឌានិ សីលានិ សុរក្ខិតានិ )* ជាដើម ។

៥-*ចាគានុស្សតិ* រលឹកដល់ទានដែលខ្លួនបានបរិច្ចាគ មានពាក្យថា *( មុត្តចាគោ )* ជាដើម ។

៦-*ទេវតានុស្សតិ* រលឹកដល់ទេវតាដែលមានសីលាទិគុណ យកមកជាតម្រាប់ មានពាក្យ ថា *( សន្តិទេវា ចាតុមហារាជិកា )* ជាដើម ។

៧-*ឧបសមានុស្សតិ* រលឹកដល់ព្រះនិព្វានដែលជាទីរលត់ទុក្ខថា *( ឯតំ សន្តំ និព្វានំ )* ជាដើម ។

៨-*មរណានុស្សតិ* រលឹកដល់សេចក្ដីស្លាប់ទូទៅក្នុងលោកទាំងអស់ដរាបមកដល់ខ្លួនថា *( មរណំ មេ ភវិស្សតិ )* ជាដើម ។

៩-*កាយគតាសតិ* រលឹកទៅក្នុងកាយគឺចំរើនអាហារ ៣២ តាមរបៀបដែល លោក ចងទុកជាលំដាប់ ។

១០-*អានាបានុស្សតិ* រលឹកដល់ខ្យល់ចេញខ្យល់ចូល យកសតិចងចិត្តទុកនឹងសសរបង្គោល គឺខ្យល់ចេញចូលនោះ ។

(អនុស្សតិ ១០ ចប់ដោយសង្ខេប )

អប្បមញ្ញា ៤ ជួនកាលលោកហៅថាព្រហ្មវិហារ ដែលហៅថា អប្បមញ្ញានោះ ព្រោះផ្សាយទៅដល់ សត្វទាំងឡាយច្រើននឹងប្រមាណមិនបាន ដែលហៅថាព្រហ្មវិហារធមិនេះ ព្រោះធមិ ៤ យ៉ាងនេះជាទីសម្រា-ន្តនៅរបស់ពួកព្រហ្ម ។

*អប្បមញ្ញា ៤ គឺ :

១-*មេត្តា* ផ្សាយមេត្តាព្រហ្មវិហារថា សត្វទាំងពួងដែលាមានខ្យល់ចេញចូលកើតហើយរាប់ថាមានអត្តភាពរាងកាយជាអរិយៈក្តី មិនមែនជាអរិយៈក្តី ជាទេវតា មនុស្ស គ្រុឌ នាគ វិនិបាត នឹងអសុរកាយក្តី មានចិត្តក្តី មិនមានចិត្តក្តី បណ្តាមានជីវិតដែលនៅក្នុងទិសខាងលើដល់អកនិដ្ឋកាព្រហ្ម ខាងក្រោមដល់អវិចីមហានរក ក្នុងខាងៗទិសទាំង ៨ រហូតទៅក្នុងអនេកកោដិចក្រវាឡចូរកុំមានពៀរដល់គ្នានឹងគ្នាឡើយ ចូរកុំ ព្យាបាទអាឃាដគ្នាឡើយ ចូរកុំឱ្យមានទុក្ខ មានសោកឡើយ ចូរកុំឱ្យមានរោគ មានភ័យឡើយ ចូរមានអាយុ យឺនយូរវែងឆ្ងាយទៅចុះ ចូរសម្រេចនូវ សម្បត្តិទាំងពួងចុះ ចូររក្សាខ្លួនឱ្យជាសុខរួចចាកទុក្ខទាំងពួងចុះ ។

២-*ករុណា* ផ្សាយករុណាព្រហ្មវិហារថា សត្វទាំងពួង ។ល។ រហូតទៅក្នុងអនេកកោដិចក្រ-វាឡចូរផុតចាកចំណែកដែលមិនមែនជាលាភចុះ ចូរផុតចាកចំណែកដែលមិនមែនជាយសចុះ ចូរផុតចាកសេចក្តីនិន្ទាចុះ ចូរផុតចាកសេចក្តីទុក្ខភ័យចុះ ចូរផុតចាកសេចក្តីខ្វះខាត ទញ់ទាល់ ចង្អៀតចង្អល់ចិត្តចុះ ។

៣-*មុទិតា* ផ្សាយមុទិតាព្រហ្មវិហារថា សត្វទាំងពួង ។ល។ រហូតទៅក្នុងអនេកកោដិចក្រ-វាឡកុំប្រាសចាកលាភដែលបានហើយ កុំប្រាសចាកយសដែលបានហើយ កុំប្រាសចាកសេចក្តីសរសើរដែលបានហើយ កុំប្រាសចាកសេចក្តីសុខដែលបានហើយកុំប្រាសចាកសម្បត្តិដែលបានហើយ សូមឱ្យមានលាភមានយស មានសេចក្តីសរសើរ នឹងសេចក្តីសុខ នឹងមានសម្បត្តិចំរើនឡើងៗទៅសព្វថ្ងៃ សព្វវេលាចុះ ។

៤-*ឧបេក្ខា* ផ្សាយឧបេក្ខាព្រហ្មវិហារថា សត្វទាំងពួង ។ ល ។ រហូតទៅក្នុងអនេកកោដិចក្រ-វាឡ មានកម្ម គឺបុណ្យនឹងបាបជារបស់ខ្លួន ។ ជាអ្នកទទួលមតិក គឺផលនៃកម្ម គឺបុណ្យនឹងបាប មានកម្មគឺបុណ្យ នឹងបាបជាកំណើត មានកម្មគឺ បុណ្យនឹងបាបជាផៅពង្សឬជាមិត្រសំឡាញ់ មានកម្មគឺបុណ្យ នឹងបាបជាទីរលឹក នឹកឃើញនឹងធ្វើកម្មឯណាជាបុណ្យក្តី ជាបាបក្តី នឹងជាអ្នកទទួលមតិក គឺផលនៃកម្មនោះ ។

(ព្រហ្មវិហារ ៤ ចប់ដោយសង្ខេប )

អាហារបដិកុលសញ្ញានោះ ព្រះយោគាវចរពិចារណាអាហារដោយបដិកូល ចាត់ជាកម្មដ្ឋាន ឈ្មោះថា សញ្ញា ១ ។

( បដិកុលសញ្ញា ចប់ )

ធាតុវវត្ថាននោះ ព្រះយោគាវចរពិចារណាធាតុទាំង ៤ មានបថវិធាតុជាដើមក្នុងករជកាយ ដោយអាការថាមិនមែនសត្វ មិនមែនជីវិត ជាកម្មដ្ឋាន ហៅថា ធាតុវវត្ថានប្រការ ១ ។

(ធាតុវវត្ថានចប់ )

អរូប ៤ គឺ អាកាសានញ្ចាយតនៈ ១ វិញ្ញាណញ្ចាយតនៈ ១ អាកិញ្ចញ្ញាយតនៈ ១ នេវសញ្ញានាសញ្ញាយតនៈ ១ ការចំរើនអរូបកម្មដ្ឋាន ៤ នោះ បានពោលមកក្នុងបរិច្ឆេទទី ១ ហើយ ។

(កម្មដ្ឋាន ៤០ ចប់ដោយសង្ខេប )

ក្នុងសមថសង្គហៈនេះ មានប្រភេទ ៣ សប្បាយបភេទ ១ ភាវនាបភេទ ១ គោចរបភេទ ១ ។

អសុភ ១០ នឹងកាយគតាសតិ ១ ជាទីសប្បាយនៃបុគ្គលជារាគចរិត ។

អប្បមញ្ញា ៤ នីលកសិណ ១ បីតកសិណ ១ លោហិតកសិណ ១ ឱទាតកសិណ ១ ជាទីសប្បាយនៃ បុគ្គលជាទោសចរិត ។

អានាបានសតិ ជាទីសប្បាយនៃបុគ្គលជាមោហចរិត នឹងវិតក្កចរិត ។

ពុទ្ធានុស្សតិ ១ ធម្មានុស្សតិ ១ សង្ឃានុស្សតិ ១ សីលានុស្សតិ ១ ចាគានុស្សតិ ១ ទេវតានុស្សតិ ១ ជាទីសប្បាយនៃបុគ្គលជាសទ្ធាចរិត ។

មរណានុស្សតិ ១ ឧបសមានុស្សតិ ១ បដិកូលសញ្ញា ១ ធាតុវវត្ថាន ១ ជាទីសប្បាយនៃបុគ្គលជាពុទ្ធិ ចរិត ។

កម្មដ្ឋាន ១០ ទៀតគឺ បថវីកសិណ ១ អាបោកសិណ ១ តេជោកសិណ ១ វាយោកសិណ ១ អាលោកកសិណ ១ អាកាសកសិណ ១ អរូបកម្មដ្ឋាន ៤ ត្រូវជា ១០ កម្មដ្ឋាននេះ ជាទីសប្បាយនៃបុគ្គលប្រកបដោយ ចរិតទាំងពួង ។

បើព្រះយោគាវចរជាមោហចរិត ធ្វើវង់កសិណឱ្យធំល្អ ទើបជាទីសប្បាយ ។

បើព្រះយោគាវចរជាវិតក្កចរិត ធ្វើវង់កសិណឱ្យតូចទើបជាទីសប្បាយ ។

(សប្បាយបភេទ ចប់ )

**អំពីនេះនឹងសំដែងនូវភាវនាបភេទតទៅ :**

ភាវនាមាន ៣ ប្រការគឺ បរិកម្មភាវនា ១ ឧបចារភាវនា ១ អប្បនាភាវនា ១ ។

បរិកម្មភាវនានោះ គឺបណ្ឌិតទាំងឡាយលោកតែងបានក្នុងកម្មដ្ឋានទាំងពួង គឺ កម្មដ្ឋាន ៤០ ។

ឯឧបចារភាវនា នឹង អប្បនាភាវនានោះ មានតែក្នុងកម្មដ្ឋានដោយកន្លែងៗ មិនបាន សាធារណ៍ទៅក្នុងកម្មដ្ឋានទាំងពួងឡើយ ។

កម្មដ្ឋាន ១០ គឺ ពុទ្ធានុស្សតិ ១ ធម្មានុស្សតិ ១ សង្ឃានុស្សតិ ១ សីលានុស្សតិ ១ ចាគានុស្សតិ ១ ទេ-វតានុស្សតិ ១ ឧបសមានុស្សតិ ១ មរណានុស្សតិ ១ បដិកូលសញ្ញា ១ ធាតុវវត្ថាន ១ មានតែឧបចារភាវនា អប្បនាភាវនាមិនមាន ព្រោះកម្មដ្ឋានទាំង ១០ នេះ ជាកម្មដ្ឋានសុខុមល្អិតជ្រាលជ្រៅក្រៃពេកណាស់ កម្រ-ព្រះយោគាវចរនឹងពិចារណាឱ្យរហូតសព្វគ្រប់ទាំងអស់ទៅបាន បើនឹងដឹងសោត ក៏ដឹងតែត្រឹមបន្តិចបន្តួច ។

កម្មដ្ឋានដែលសល់នោះ ៣០ គឺ កសិណ ១០ អសុភ ១០ អានាបានសតិ ១ កាយគតាសតិ ១ ព្រហ្មវិហារ ៤ អរូប ៤ កម្មដ្ឋាន ៣០ នេះមានទាំងឧបចារភាវនានឹងអប្បនាភាវនា ។

ក៏ក្នុងកម្មដ្ឋាន ៣០ នោះ កសិណ ១០ អានាបានសតិ ១ ទាំង ១១ នេះមានអានុភាពច្រើន ឱ្យសម្រេច រូបឈានតាំងអំពីបឋមជ្ឈាន រហូតដល់បញ្ចមជ្ឈាន ។

អសុភ ១០ កាយគតាសតិ ១ ទាំង ១១ នេះឱ្យសម្រេចបានតែត្រឹមបឋមជ្ឈាន ។

ព្រហ្មវិហារ ៣ គឺ មេត្តា ១ ករុណា ១ មុទិតា ១ ឱ្យសម្រេចបានតែត្រឹមចតុត្ថជ្ឈាន ។

ឧបេក្ខាព្រហ្មវិហារនោះ ឱ្យសម្រេចរូបាវចរបញ្ចមជ្ឈាន ។

អរូបឈាន ៤ ឱ្យសម្រេចអរូបឈានតែម្យ៉ាង រាប់ចូលក្នុងអង្គបញ្ចមជ្ឈាន ជាកម្មដ្ឋាន ៣០ ឱ្យ-សម្រេចអប្បនាឈាន ។

(ភាវនាបភេទ ចប់ )

**អំពីនេះនឹងសំដែងនូវអារម្មណ៍បភេទតទៅ :**

និមិត្តមាន ៣ ប្រការគឺ បរិកម្មនិមិត្ត ១ ឧគ្គហនិមិត្ត ១ បដិភាគនិមិត្ត ១

និមិត្ត ២ ខាងដើមគឺ បរិកម្មនិមិត្ត នឹងឧគ្គហនិមិត្ត នោះព្រះយោគាវចរតែងបានក្នុងកម្មដ្ឋាន ទាំងពួង ដោយបរិយាយតាមសមគួរ ។

ឯបដិភាគនិមិត្តនោះ មិនមានទូទៅក្នុងកម្មដ្ឋានទាំងពួងទេ មានតែក្នុងកម្មដ្ឋាន ២២ គឺ កសិណ ១០ អសុភ ១០ កាយគតាសតិ ១ អានាបានសតិ ១ ។

ព្រះយោគាវចរនឹងបាននូវឧបចារសមាធិ នឹងអប្បនាសមាធិ និមិត្តទាំងឡាយនោះ អាស្រ័យ ឈោងតោងយកបដិភាគនិមិត្តជាអារម្មណ៍ ។

សួរថា បរិកម្មនិមិត្ត ឧគ្គហនិមិត្ត នឹងបដិភាគនិមិត្តនោះ ដូចម្តេច ?

ឆ្លើយថា អាទិកម្មិកកុលបុត្រមិនបានបំពេញនូវកម្មដ្ឋានទុកអំពីជាតិមុនទើបនឹងតាំងផ្តើមរៀវ ក្នុងជាតិ នេះ ធ្វើកសិណមានបថវីកសិណជាដើមហើយ តាំងទុកខាងមុខចម្ងាយ ២ ហត្ថ ១ ចំអាម ហើយទាញចិត្តឱ្យ មើលកសិណ ហើយបរិកម្មថា ( បថវីៗ ) ដូច្នេះ ភាវនានោះ ឈ្មោះថាបរិកម្មភាវនា វង់កសិណនោះ ឈ្មោះថា បរិកម្មនិមិត្ត ចិត្តទាញយកនិមិត្តនោះ និមិត្តនោះក៏មក ប្រាកដដល់ មនោទ្វារ របស់យោគាវចរ ដូចបើកភ្នែកក្រឡេកមើលឃើញក្នុងកាលណា អារម្មណ៍ដែលទាញយក និមិត្ត ឃើញ និមិត្តនោះ ឈ្មោះថាឧគ្គហនិមិត្តក្នុងកាលនោះ ភាវនានោះឈ្មោះសមាធិភាវនា កាលយោគាវចរតាំង សមាធិចិត្តទុកយ៉ាងនោះ ខាង មុខអំពីឧគ្គហនិមិត្តកើតហើយ ក៏ប្រកបតាមនៅបរិកម្មភាវនា នឹង សមាធិភាវនា ក្នុងឧគ្គហនិមិត្តនោះ ។

អារម្មណ៍ដ៏ហើយទៅដោយភាវនា ព្រះដ៏មានព្រះភាគលើកឡើងបញ្ញត្តិត្រាស់ហៅថា ឧគ្គហ- និមិត្តប្រាកដដូចកសិណនោះកន្លងផុតចាកវត្ថុធម៌ គឺ ពណ៌នៃកសិណហើយ ក៏ប្រាកដល្អដូច ពណ៌កែវ ដ៏ជ្រះថ្លាបរិសុទ្ធ ស្ងប់ឆ្អែតនៅស្មើមានក្នុងចិត្តយោគាវចរនឹងគិតឱ្យធំក៏ធំបាន នឹងឱ្យតូចក៏តូចបាន នឹងឱ្យ ល្អិតក៏ល្អិតបាន ដូចចិត្ត ប្រាថ្នាតែងមានក្នុងកាលណា ឈ្មោះថាបដិភាគនិមិត្តកើតហើយក្នុងកាលនោះ ។

ចាប់ដើមអំពីនោះមក ឧបចារភាវនា ពោលគឺ កាមាវចរសមាធិ នឹងលះបង់នូវអន្តរាយគឺ នីវរណៈ ៥ បានជាតទង្គបហាន ក៏សម្រេចបរិបូណ៌ក្នុងសន្តានលំដាប់អំពីនោះទៅ ព្រះយោគាវចរ សេព នូវបដិភាគនិមិត្ត ដោយឧបចារសមាធិសម្រេចរូបាវចរបឋមជ្ឈានមានអង្គ ៥ មានវិតក្កៈជាដើម ។

**លំដាប់អំពីនោះ យោគាវចរក៏ធ្វើបឋមជ្ឈានឱ្យស្ទាត់ជំនាញដោយវសី ៥ ប្រការគឺ :**

១- *អាវជ្ជនៈ* ស្ទាត់ជំនាញក្នុងការនឹកប្រាថ្នាក្នុងកាលនឹងចូលកាន់ឈាន ។

២- *សមាបជ្ជនៈ* ថ្មិកជំនាញក្នុងការចូលកាន់ឈាន ។

៣- *អធិដ្ឋានៈ* ស្ទាត់ជំនាញក្នុងការដែលនឹងតាំងឈានទុកឱ្យមាំមិនឱ្យឃ្លៀងឃ្លាតចាក វេលា ដែលកំណត់ ។

៤- *វុដ្ឋានៈ* ស្ទាត់ជំនាញក្នុងការដែលនឹងចេញចាកឈាន ។

៥- *បច្ចវេក្ខណៈ* ស្ទាត់ជំនាញក្នុងការពិចារណាអង្គឈានក្នុងកាលដែលនឹងចេញចាកឈាន ។

លុះធ្វើបឋមជ្ឈានឱ្យស្ទាត់ហើយ ក៏ធ្វើព្យាយាមលះបង់នូវអង្គដ៏គ្រោតគ្រាតមានវិតក្កៈជាដើម តាំង ទុកនូវសេចក្តីព្យាយាម ដើម្បីនឹងឱ្យកើតអង្គដ៏សុខុមមានវិចារៈជាដើម ទើបចូលកាន់ឈានទាំង-ឡាយមានទុតិយជ្ឈានជាដើម ដោយលំដាប់តាមសមគួរ ។

បដិភាគនិមិត្តនោះ យោគាវចរបានក្នុងការចំរើនកម្មដ្ឋាន ២២ ប្រការគឺកសិណ ១០ អសុភ ១០ កាយ គតាសតិ ១ អានាបានសតិ ១ ដូចសំដែងមកហើយដោយប្រការដូច្នេះ ។

ជំនុំកម្មដ្ឋានដ៏សល់ចាកកម្មដ្ឋានដែលពោលមកហើយ រឹងអប្បមញ្ញា ៤ នោះ ឈោងតោងយក សត្តបញ្ញត្តិជាអារម្មណ៍ ក៏ក្នុងកសិណទាំងឡាយ ៩ លើកយកអាកាសកសិណចេញ កសិណណាមួយ ដែលព្រះយោ គាវចរបានហើយ ព្រោះបើកកសិណចោលចេញកាលធ្វើអាកាសទទេជាអារម្មណ៍ ធ្វើបរិកម្មថា ( អាកាលមិន មានទីបំផុត ៗ ) យោគាវចរក៏អាចនឹងចូលកាន់អរូបឈានជាបឋមបាន កាលយោគាវចរកំណត់បឋមារូបចិត្ត ជាអារម្មណ៍ ហើយធ្វើបរិកម្មថា ( វិញ្ញាណមិនមានទីបំផុត ៗ ) ក៏អាចនឹងចូលកាន់ទុតិយារូបឈានបាន កាលយោគាវចរប្រាថ្នាចូលកាន់តតិយរូបឈាន ធ្វើសេចក្តី កំណត់ចិត្តជាបឋមារូបវិញ្ញាណមិនមានហើយជាអារម្មណ៍ ធ្វើបរិកម្មថា ( អ្វី ៗ ក៏មិនមាន ) ក៏អាច នឹងចូលកាន់អរូបទី ៣ បានយោគាវចរប្រាថ្នានឹងចូលកាន់អរូបទី ៤ ហើយធ្វើបរិកម្មថា ( អរូបទី ៣ នេះល្អិតក្រៃពេកណាស់ ៗ ) ក៏អាចនឹងចូលកាន់អរូបទី ៤ បាន ។

កម្មដ្ឋានដ៏សល់អំពីនេះ ១០ ឱ្យបានឧបចារសមាធិ កាលបើនិមិត្តនោះយោគាវចរទាញ យក អារម្មណ៍ មានពុទ្ធគុណជាដើមធ្វើបរិកម្មកាន់យកដ៏ល្អ ហើយបរិកម្មក្នុងនិមិត្តនោះជាបរិកម្មសមាធិ លំដាប់អំពីនោះ ក៏ នឹងបានសម្រេចឧបចារសមាធិបរិបូណ៌ ។

( ន័យក្នុងកម្មដ្ឋាន ៤០ ចប់ )

**អំពីនេះនឹងសំដែងនូវអភិញ្ញា ៥ ប្រការតទៅ :**

សេចក្តីថា យោគាវចរបានសម្រេចរូបាវចរបញ្ចមជ្ឈានហើយ រូបាវចរបញ្ចមជ្ឈានប្រព្រឹត្តទៅឱ្យ សម្រេចកិច្ចដោយអំណាចអភិញ្ញា យោគាវចរប្រាថ្នានឹងធ្វើឥទ្ធិឫទ្ធិ ចូលកាន់បញ្ចមជ្ឈានមាន អភិញ្ញា ជាទីតាំង ចេញចាកបញ្ចមជ្ឈាន ហើយពិចារណានូវរូបដែលគួរខ្លួននឹងគប្បីអធិដ្ឋាន ធ្វើបរិកម្មត្រឡប់ ចូលកាន់បញ្ចមជ្ឈានទៀតខណចិត្ត ១ អាចារ្យពោលថា បញ្ចមជ្ឈានខណចិត្ត ១ ដែលឱ្យសម្រេច

កិច្ចជាអភិញ្ញានោះ ជួន កាលយកសំឡេង ក្លិន រស ផោដ្ឋព្វៈ បញ្ញត្តិ ចិត្ត បសាទរូប នឹង សុខុមរូបជាអារម្មណ៍ ដោយសមគួរដល់បាដិ-ហារដែលនឹងសំដែងនោះ ។

អភិញ្ញាមាន ៥ គឺ ឥទ្ធិវិធី ១ ទិព្វសោត ១ បរចិត្តវិជ្ជា ១ បុព្វេនិវាសានុស្សតិ ១ ទិព្វចក្ខុ ១ ជា ៥ ។

( សំដែងក្នុងអារម្មណបភេទ ក្នុងសមថកម្មដ្ឋាន ចប់ )

**អំពីនេះនឹងសំដែងនូវវិបស្សនាកម្មដ្ឋានតទៅ :**

ក្នុងវិបស្សនាកម្មដ្ឋាននោះប្រកបដោយប្រភេទ ៤ គឺវិសុទ្ធិ១ វិមោក្ខ១ បុគ្គល១ សមាបត្តិ១ ។

ក្នុងវិសុទ្ធិបភេទនោះ សំដែងវិសុទ្ធិ ៧ ប្រការគឺ សីលវិសុទ្ធិ ១ ចិត្តវិសុទ្ធិ ១ កង្ខាវិតរណវិសុទ្ធិ ១ មគ្គាមគ្គញាណទស្សនវិសុទ្ធិ ១ បដិបទាញាណទស្សនវិសុទ្ធិ ១ ញាណទស្សនវិសុទ្ធិ ១ ។

លក្ខណៈ ៣ គឺ អនិច្ចលក្ខណៈ ១ ទុក្ខលក្ខណៈ ១ អនត្តលក្ខណៈ ១ ។

អនុបស្សនាមាន ៣ គឺ អនិច្ចានុបស្សនា ១ ទុក្ខានុបស្សនា ១ អនត្តានុបស្សនា ១ ។

*វិបស្សនាញាណ មាន ១០ ប្រការគឺ :

១-*សម្មសនញាណ* បញ្ញាពិចារណាសង្ខារដោយអនិច្ចាទិលក្ខណៈ ។

២-*ឧទយព្វយញាណ* បញ្ញាពិចារណានូវកិរិយាកើត នឹងកិរិយារលត់នៃសង្ខារ ។

៣-*ភង្គញាណ* បញ្ញាពិចារណានូវកិរិយាបែកធ្លាយនៃសង្ខារ ។

៤-*ភយញាណ* បញ្ញាពិចារណាឃើញសង្ខារថាជាទីគួរខ្លាចដូចបុរសខ្លាចសត្វកាចមាន រាជសីហ៍ជាដើម ។

៥-*អាទីនវញាណ* បញ្ញាឃើញទោសនៃសង្ខារ ដូចបុរសឃើញផ្ទះដែលភ្លើងឆេះហើយ គិតរត់ចេញចាកផ្ទះ ។

៦-*និព្វិទាញាណ* បញ្ញានឿយណាយឃើញទោសក្នុងបញ្ចខន្ធ ។

៧-*មុញ្ចិតុកាម្យតាញាណ* បញ្ញាប្រាថ្នានឹងចង់រួចចាកបញ្ចខន្ធ ប្រៀបដូចត្រី ប្រាថ្នានឹងចង់ឱ្យរួចចាកទីគោកទីទួល នឹងមនុស្សដែលប្រាថ្នាចង់ឱ្យរួចចាកគុកច្រវាក់ ខ្នោះឃ្នាង ។

៨-*បដិសង្ខាញាណ* បញ្ញាពិចារណារកឧបាយ ដែលនឹងដោះខ្លួនឱ្យរួចចាកខន្ធ ។

៩-*សង្ខារុបេក្ខាញាណ* បញ្ញាតាំងឧបេក្ខាក្នុងសង្ខារគឺមិនសោមនស្សមិនទោមនស្ស ដូចបុរសដែលព្រងើយកន្តើយក្នុងភរិយា ដែលលះលែងគ្នាស្រឡះហើយ ។

១០-*អនុលោមញាណ* បញ្ញាដែលអនុលោមតាមព្រះអរិយមគ្គទាំងពួងក្នុងខាងក្រោយ ។

វិមោក្ខ មាន ៣ គឺ សុញ្ញតវិមោក្ខ ១ អនិមិត្តវិមោក្ខ ១ អប្បណិហិតវិមោក្ខ ១ ទាំង ៣ នេះជាឈ្មោះ នៃព្រះនិព្វាន ។

វិមោក្ខមុខ មាន ៣ គឺ សុញ្ញតានុបស្សនា ១ អនិមិត្តានុបស្សនា ១ អប្បណិហិតានុបស្សនា ១ ទាំង ៣នេះជាឧបាយ ជាប្រធាន នឹងឱ្យដល់ព្រះនិព្វាន ។

សួរថា វិសុទ្ធិ ៧ ប្រការនោះ តើមានសេចក្តីអធិប្បាយដូចម្តេច ?

ឆ្លើយថា វិសុទ្ធិ ៧ ប្រការនោះគឺ :

១-*សីលវិសុទ្ធិ* គឺបរិសុទ្ធិដោយសីល គឺរក្សានូវបារិសុទ្ធសីលទាំង ៤ គឺ

(ក) បាដិមោក្ខសំវរសីល សីលគឺកិរិយាប្រតិបត្តិសង្រួមតាមព្រះបាដិមោក្ខ គឺមិនកន្លងសិក្ខាបទទាំង ២២៧ ដែលពុទ្ធានុញ្ញាតទុកមក ។

(ខ) ឥន្ទ្រិយសំវរសីល សីលគឺកិរិយាសង្រួមរក្សាឥន្ទ្រិយទាំង ៦ មិនមានធ្វេសស្មារតី ។

(គ) អាជីវបារិសុទ្ធសីល សីលគឺសេចក្តីចិញ្ចឹមជីវិតដោយធម៌មិនធ្វើអនេសនៈ ២១ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ហាម ។

(ឃ) បច្ចយសន្និស្សិតសីល សីលដ៏អាស្រ័យនូវបច្ច័យហើយមានបច្ចវេក្ខណសតិពិចារណាមុនទើបបរិ ភោគនូវបច្ច័យ ៤ ជាក្រោយ ។

២-*ចិត្តវិសុទ្ធិ* សេចក្ដីបរិសុទ្ធិដោយចិត្ត គឺ សមាធិ ២ យ៉ាងគឺ ឧបចារសមាធិ ដែលជាកាមាវចរជិតនឹង បានឈាន ១ អប្បនាសមាធិជារូបាវចរ នឹងអរូបាវចរ ១ ។

៣-*ទិដ្ឋិវិសុទ្ធិ* បរិសុទ្ធិដោយបញ្ញាជាគ្រឿងឃើញ គឺ បញ្ញាពិចារណាឃើញលក្ខណៈ នឹងកិច្ច នឹងបច្ចុប្បដ្ឋាន គឺផល នឹងបទដ្ឋានគឺ ហេតុជិតនៃនាមធម៌រូបធម៌ ដ៏មានសភាវៈកើត នឹងរលត់ ។

៤-*កង្ខាវិតរណវិសុទ្ធិ* បរិសុទ្ធិដោយបញ្ញាជាហេតុឆ្លងផុតនូវសេចក្ដីសង្ស័យ គឺបញ្ញាពិចារណា ឃើញ បច្ច័យនៃនាមធម៌ថាអវិជ្ជាគឺ មោហៈ ១ តណ្ហា គឺ សេចក្ដីប្រាថ្នាចង់បាន ១ កម្មគឺ កុសល នឹង អកុសលជាលោកិយ ១ ធម្មជាតិ ៣ យ៉ាងនេះ ជាបច្ច័យឱ្យកើតរូប វេទនា សញ្ញា ។

កវឡិង្ការាហារជាបច្ច័យឱ្យកើតអាហារជរូប នឹងឧបត្ថម្ភកកម្មជរូប ១ ចិត្តជរូប ១ ឧតុជរូប ១ ។

ផស្សាហារ ជាបច្ច័យឱ្យកើតវេទនាខន្ធ ១ សញ្ញាខន្ធ ១ សង្ខារខន្ធ ១ ។

សង្ខារជាបច្ច័យឱ្យកើតវិញ្ញាណខន្ធ វិញ្ញាណជាបច្ច័យឱ្យកើតនាម នឹងរូបបញ្ញាកំណត់បច្ច័យនៃ នាម នឹងរូប ឱ្យផុតចាកសេចក្ដីសង្ស័យ ឈ្មោះថាកង្ខាវិតរណវិសុទ្ធិ ។

៥-*មគ្គាមគ្គញាណទស្សនវិសុទ្ធិ* បរិសុទ្ធិដោយបញ្ញាជាហេតុពិចារណាដឹងថាមគ្គ នឹងមិនមែនមគ្គ សេចក្ដីថា នាកាលសង្ខារប្រព្រឹត្តទៅក្នុងភូមិ ៣ គឺកាមភូមិ រូបភូមិ និងអរូបភូមិផ្សេងដោយ ប្រភេទ ជាអតីត អនាគត បច្ចុប្បន្ន ប្រព្រឹត្តទៅដោយបច្ច័យគឺ អវិជ្ជា ១ តណ្ហា ១ កម្ម ១ អាហារ ១ ដែលយោគាវចរកំណត់ កាន់យកហើយមែនក្នុងខាងមុខ អំពីកង្ខាវិតរណវិសុទ្ធិនោះ ។

យោគាវចរប្រារព្ធនូវទេសនាន័យមានខន្ធជាដើម ដែលព្រះអង្គទ្រង់ត្រាស់ទុកជាប្រធាន បំប្រួញ សង្ខារចូលក្នុងភូមិ ៣ នៃលក្ខណៈដោយបញ្ញាជាគ្រឿងពិចារណាថា នាមរូបមិនទៀង ដោយសេចក្ដី ថា អស់ទៅ មិនតាំងនៅជាថាវរកម្មមាំមួនយឺនយូរឡើយនាមរូបនាំមកនូវសេចក្ដីទុក្ខ ដោយសេចក្ដីថា អកុសលឱ្យផលជាភ័យ គឺបុគ្គលគប្បីខ្លាច នឹងប្រកបដោយទុក្ខ ៤ មានជាតិទុក្ខជាដើម ជាគ្រឿង បៀតបៀន នាមរូបមិនមែនខ្លួន ប្រាណ មិនមែនជារបស់ផងខ្លួន ដោយសេចក្ដីថា មិនមានខ្លឹមសារ មិនប្រព្រឹត្តតាមអំណាចអ្នកណា១ នឹង-បង្គាប់បញ្ជាក៏មិនបាន មិនមានអ្នកណាជា ឥស្សរៈសង្កត់សង្កិន បាន ។

កាលតាំងផ្ដើមពិចារណាអនិច្ចលក្ខណៈ ទុក្ខលក្ខណៈ អនត្តលក្ខណៈ នោះពិចារណាដោយអំណាចអទ្ធានបច្ចុប្បន្នគឺ កំណត់យកកាលជាតិ ១ ភព ១ ជាទីកើតជាទីរលត់នៃសង្ខារ ។

កាលបញ្ញាក្លៀវក្លាឡើងហើយ ក៏ពិចារណាដោយអំណាចនៃសន្តតិបច្ចុប្បន្ន គឺកំណត់នូវទីតគឺអាយុ ឱ្យតិចចុះ ឱ្យខ្លីចុះជាជាន់ ៗ ។

កាលបញ្ញាក្លៀវក្លាឡើងហើយ ក៏ពិចារណាដោយអំណាចនៃខណចិត្ត គឺចិត្តដែលរលត់ចុះក្នុងភង្គខណៈ នោះឱ្យឃើញថាស្លាប់ម្ដងៗ កំណត់ឱ្យឃើញសេចក្ដីស្លាប់គ្រប់ៗខណៈចិត្ត ដូចពោលមកហើយនេះ ។

លុះរួចហើយពិចារណានូវឧទ័យ នឹងវ័យ គឺទីកើតនឹងរលត់នៃសង្ខារនោះដោយឧទយព្វយញាណ គឺបញ្ញាជាគ្រឿងឃើញទីកើត នឹងរលត់ ដោយអំណាចនៃបច្ច័យផង ដោយអំណាចនៃខណចិត្តផង ថាសង្ខារដែលកើត នឹងរលត់ក្នុងអទ្ធានបច្ចុប្បន្នក្ដី ក្នុងសន្តតិបច្ចុប្បន្នក្ដី ក្នុងភង្គខណៈក្ដី មិនប្រាសចាកបច្ច័យ គឺអវិជ្ជា នឹងតណ្ហា នឹងកម្ម នឹងអាហារបច្ច័យនៅដរាបណា សង្ខារក៏វិលកើត វិលស្លាប់ទៅដរាបនោះ បើបច្ច័យរលត់ ហើយ សង្ខារទើបនឹងរលត់ នឹងអស់ទៅមិនកើតទៀត ប្រាកដកាលឧទយព្វយញាណកើតក្លាឡើងៗ ខណៈ ណា វិបស្សនូបកិលេស ១០ វិបស្សនូបកិលេសឯណាមួយរមែងតែងកើតឡើងក្នុងខណៈនោះ ។ វិបស្សនូបកិលេស ១០ នោះគឺ :

១-ឱភាសោ រស្មីភ្លឺស្វាង កើតអំពីវិបស្សនាចិត្តភ្លឺស្វាងជាងអំពីកាលមុន ។

២-បីតិ សេចក្ដីឆ្អែតកាយឆ្អែតចិត្តកើតក្លៀវក្លាជាងដែលធ្លាប់ប្រទះធ្លាប់ឃើញមក ។

៣-បស្សទ្ធិ សេចក្ដីងាប់កាយរំងាប់ចិត្ត កើតក្លៀវក្លាជាងអំពីមុន ។

៤-អធិមោក្ខោ សទ្ធិន្ទ្រិយយ៉ាងចុះមានកម្លាំងក្លៀវក្លា ។

៥-បគ្គហោ ព្យាយាមក្លៀវក្លាអាចឱ្យសម្រេចសម្មប្បធាន ។

៦-សុខំ សេចក្ដីសុខកើតឧត្ដមក្រៃពេក ។

៧-ញាណំ បញ្ញាក្នុងគ្រានោះកើតក្លៀវក្លា ដូចព្រះខ័នកែវវជិរ របស់សម្ដេចអម្រិន្ទ្រាធិរាជ ។

៨-ឧបដ្ឋានំ សតិចូលទៅតាំងមាំមួនក្លៀវក្លាកើតជាសតិបដ្ឋាន

៩-ឧបេក្ខា ឧបេក្ខាកើតក្លៀវក្លាជាឧបេក្ខាសម្ពោជ្ឈង្គ

១០-និកន្តិ សេចក្តីប្រាថ្នាគឺសុខុមតណ្ហា ឱ្យយោគាវចរមានសេចក្តីត្រេកអរក្នុងរូបនិមិត្ត ។

កាលវិបស្សនូបកិលេសឯណាមួយកើតឡើងហើយ បើយោគាវចរមិនដឹងទៅសំគាល់ថា អរិយ-មគ្គហើយឈប់លះបង់សេចក្តីព្យាយាមចោលមិនចំរើនវិបស្សនាតទៅក៏មិនបាននូវអរិយមគ្គ សមដូចសេចក្តីប្រាថ្នា ។

កាលសតិកើតក្លៀវក្លាឡើងជាសតិបដ្ឋាន ឧបេក្ខាកើតក្លៀវក្លាជាឧបេក្ខាសម្ពោជ្ឈង្គ យោគាវចរវង្វេង ភាន់ភាំងថាជាអរិយមគ្គ មិនចំរើនវិបស្សនាតទៅ ក៏ដាច់ចាកអរិយមគ្គញាណ ។

បើបញ្ញាកើតក្លៀវក្លាពិចារណាថា សភាវៈទាំងឡាយមានឱភាសជាដើមនេះជាវិបស្សនូប-កិលេសមិនមែនព្រះអរិយមគ្គឡើយ វិបស្សនាចិត្តដែលប្រព្រឹត្តទៅក្នុងវិបស្សនាវិថី គង់នឹងកើតឡើងជាអរិយមគ្គ កាលដឹងច្បាស់ដូច្នេះហើយយោគាវចរ ក៏មិនត្រេកអរដោយវិបស្សនូបកិលេស មានឱភាសជាដើមក៏ឧស្សាហ៍ចំរើនវិបស្សនាតទៅបញ្ញាពិចារណាដឹងថា មគ្គនឹងមិនមែនមគ្គដូច្នេះ ឈ្មោះថាមគ្គា-មគ្គញាណទស្សនវិសុទ្ធិ។

៦-បដិបទាញាណទស្សនវិសុទ្ធិ បរិសុទ្ធិដោយប្រាជ្ញាជាហេតុពិចារណាដឹងនូវសេចក្តីប្រតិបត្តិ គឺបានដល់ វិបស្សនាញាណ ៩ មានឧទយព្វយញាណជាដើមមានអនុលោមញាណ ជាទីបំផុត ។

កាលយោគាវចររួចផុតហើយចាកសេចក្តីអន្តរាយគឺ វិបស្សនូបកិលេស ១០ នោះ ឧស្សាហ៍ប្រតិបត្តិ ទៅដោយលំដាប់នៃបស្សនាដោយលក្ខណៈ ៣ មានអនិច្ចលក្ខណៈជាដើម ចាប់ដើមអំពីឧទយព្វយញាណ មក រហូតដល់អនុលោមញាណជាទីបំផុត ឈ្មោះថា បដិបទាញាណទស្សនវិសុទ្ធិ ។

៧-ញាណទស្សនវិសុទ្ធិ បរិសុទ្ធិដោយញាណទស្សនៈ គឺកាលយោគាវចរកំពុងប្រតិបត្តិ អាស្រ័យនូវសេចក្តីចាស់ជ្រុំវិញគឺសេចក្តីចាស់ក្លៀវក្លានៃវិបស្សនាដ៏គួរនឹងពោលថាអប្បនាគឺព្រះអរិយមគ្គ នឹងកើតឡើង ក្នុងកាលឥឡូវនេះ ដូច្នេះមនោទ្វារាវជ្ជនចិត្តកាត់ខ្សែនៃភវង្គហើយ ក៏កើតឡើងក្នុងដើមនៃ

មគ្គវិថីញាណសម្ប យុត្តកាមាវចរជវនជាវិបស្សនាចិត្តទាំងឡាយ ជួនកាលឃោងតោងយក អនិច្ច-លក្ខណៈខ្លះ ទុក្ខលក្ខណៈខ្លះ អនត្តលក្ខណៈខ្លះ មកជាអារម្មណ៍ឱ្យសម្រេចកិច្ចកំចាត់កិលេសយ៉ាង គ្រោតគ្រាត យ៉ាងកណ្តាល យ៉ាងល្អិត ហើយកើតឡើង ២ ខណៈខ្លះ ៣ ខណៈខ្លះ ដោយឈ្មោះថាបរិកម្ម ឧបចារ អនុលោមសមគួរដល់អរិយបុគ្គល ដែលជាទន្ធាភិញ្ញា នឹងខិប្បាភិញ្ញា ។

ដែលជាទន្ធាភិញ្ញានោះកើត ៣ ខណៈគឺបរិកម្មខណៈ ១ ឧបចារខណៈ ១ អនុលោមខណៈ ១ ។

ដែលជាខិប្បាភិញ្ញានោះ កើត ២ ខណៈគឺ ឧបចារខណៈ ១ អនុលោមខណៈ ១ ។

វិបស្សនាចិត្តឯណាមានកម្លាំងក្លាដល់ហើយនូវភារៈជាកំពូលនៃវិបស្សនាវិបស្សនាចិត្តនោះព្រះអាចារ្យលោកហៅថាអនុលោមញាណខ្លះសង្ខារុបេក្ខាញាណខ្លះវុដ្ឋានគាមិនីវិបស្សនាខ្លះខាងមុខអំពីអនុលោមកើតហើយនោះគោត្រភូចិត្តទើបទាញយកនិព្វានជាអារម្មណ៍គ្របសង្កត់បង់នូវបុថុជ្ជនគោត្រ ញ៉ាំងចិត្តឱ្យប្រព្រឹត្តទៅកាន់អរិយគោត្រផង កាន់សេចក្តីត្រាស់ដឹងផង មគ្គចិត្តដែលកើតជាលោកុត្តរៈ មាននិព្វានជាអារម្មណ៍ ទើបកើតក្នុងលំដាប់នៃ គោត្រភូចិត្តនោះកំណត់ដឹងនូវទុក្ខសច្ចលះ បង់នូវ សមុទយ-សច្ច ធ្វើនិរោធសច្ចឱ្យជាក់ច្បាស់យាងចុះកាន់អប្បនាវិថី ដោយអំណាចចំរើនមគ្គសច្ចខាង មុខអំពីមគ្គ-ចិត្តកើតហើយនោះ ផលចិត្តមាននិព្វានជាអារម្មណ៍កើតឡើង ២ ខណៈ ខ្លះ ៣ ខណៈខ្លះ ហើយធ្លាក់ចុះកាន់ភវង្គហើយទើបរលត់ទៅ បើជាទន្ធាភិញ្ញាបុគ្គល ផលចិត្តកើត ២ ខណៈហើយ ទើបធ្លាក់ចុះ កាន់ភវង្គបើជាខិប្បាភិញ្ញាបុគ្គល ផលចិត្តកើត ៣ ខណៈហើយ ទើបធ្លាក់ចុះកាន់ភវង្គ លំដាប់នោះ មនោ-ទ្វារាវជ្ជនចិត្តទើបកាត់ខ្សែភវង្គកើតឡើងក្នុងខាងដើមនៃបច្ចវេក្ខណញាណគឺសម្បយុត្តកាមាវចរជវនកើតឡើងក្នុងលំដាប់នៃមនោទ្វារាវជ្ជនពិចារណានូវមគ្គធម៌ផលធម៌ នឹងនិព្វានធម៌ ដែលខ្លួនបាន ។

*មគ្គំ ផលញ្ច និព្វានំ* *បច្ចវេក្ខតិ បណ្ឌិតោ*
*បហីនេ ក្លេសេ សេសេ ច* *បច្ចវេក្ខតិ វា នវា ។*
*ឆព្វិសុទ្ធិក្កមេនេវំ* *ភាវេតព្វោ ចតុព្វិធោ*
*ញាណទស្សនវិសុទ្ធិ* *នាម មគ្គោ បវុច្ចតិ ។*

អរិយបណ្ឌិតលោកពិចារណាមគ្គធម៌ ផលធម៌ នឹងនិព្វានធម៌ មានទូទៅក្នុងសន្តានគ្រប់អង្គ ។

កាលដែលពិចារណាកិលេសដែលខ្លួនលះបង់ហើយ នឹងសល់នៅនោះអង្គខ្លះក៏ពិចារណា អង្គខ្លះមិនពិចារណា ។

អរិយមគ្គ ៤ យ៉ាង ព្រះអរិយៈជាម្ចាស់លោកចំរើនតាមលំដាប់នៃវិសុទ្ធិ ៦ ប្រការ មានសីលវិសុទ្ធិជាដើមមានបដិបទាញ្ញាណទស្សនវិសុទ្ធិជាទីបំផុតលោកហៅថាមគ្គ ឈ្មោះថាញ្ញាណទស្សនវិសុទ្ធិ ។

( សំដែងប្រភេទនៃវិសុទ្ធិ ៧ ប្រការចប់ )

អំពីនេះនឹងសំដែងនូវវិមោក្ខមុខតទៅ :

*វិមោក្ខមុខមាន ៣ ប្រការគឺ :

១-*អនត្តានុបស្សនា* ព្រះយោគាវចរលោកចំរើនអនត្តលក្ខណៈ បញ្ជូនប្រាជ្ញាពិចារណាឃើញថាសង្ខារមិនមែនខ្លួនប្រាណ មិនមែនថាជារបស់ៗខ្លួន លះបង់នូវអត្តាភិនិវេស គឺ ទិដ្ឋិកាន់យកថា ជាខ្លួនប្រាណ ថាជារបស់ៗ ខ្លួនជាវិមោក្ខមុខ គឺ ជាឧបាយនៃធម៌ជាគ្រឿងផុតវិសេស គឺ មគ្គផលវិមោក្ខមុខនោះឈ្មោះថា សុញ្ញតាវិបស្សនា ។

២-*អនិច្ចានុបស្សនា* ព្រះយោគាវចរលោកចំរើនអនិច្ចលក្ខណៈបញ្ជូនប្រាជ្ញាពិចារណាឃើញថាសង្ខារ មិនទៀង លះបង់នូវវិបល្លាសនិមិត្ត គឺហេតុដែលវង្វេងថាទៀង ថាល្អ ជាឧបាយជាគ្រឿងផុតវិសេសគឺមគ្គផល ឈ្មោះអនិមិត្តានុបស្សនា ។

៣-*ទុក្ខានុបស្សនា* ព្រះយោគាវចរលោកចំរើននូវទុក្ខលក្ខណៈ បញ្ជូនប្រាជ្ញាពិចារណាឃើញថាសង្ខារអាកូលដោយទុក្ខភ័យលះបង់នូវតណ្ហាបណិធិ គឺសេចក្តីដឹកលំទុកទូទៅនៃតណ្ហា គឺសេចក្តីលោភស្រឡាញ់ក្នុងមនុស្សសម្បត្តិ នឹងសគ្គសម្បត្តិ ក៏ជាឧបាយជាគ្រឿងផុតវិសេសគឺមគ្គផល ឈ្មោះថាអប្បណិហិតានុបស្សនា ព្រោះហេតុនោះ វុដ្ឋានគាមិនីវិបស្សនាគឺ អនុលោមញ្ញាណ បើតោងយកអនត្តលក្ខណៈជាអារម្មណ៍ជាមគ្គឈ្មោះថាសុញ្ញតវិមោក្ខ បើតោងយកអនិច្ចលក្ខណៈជាអារម្មណ៍ ជា មគ្គឈ្មោះថា អប្បណិហិតវិមោក្ខ មគ្គបានឈ្មោះ ៣ យ៉ាងដោយអំណាច នៃកិរិយាមក នៃវិបស្សនាដូច្នេះ ។

( សំដែងចំណែកខាងមគ្គ ចប់ )

**នឹងសំដែងចំណែកខាងផលតទៅ :**

អរិយផលកើតឡើងក្នុងមគ្គវិថី ២ ខណៈខ្លះ ៣ ខណៈខ្លះ ដូចយ៉ាងដែលពោលមកហើយ ព្រះដ៏មានព្រះភាគជាម្ចាស់ក៏ទ្រង់ត្រាស់ហៅឈ្មោះនៃអរិយផលដោយអំណាចនៃកិរិយាមកនៃមគ្គ បើមគ្គឈ្មោះថាសុញ្ញតវិមោក្ខផលដែលកើតរៀងខណៈនៃមគ្គនោះក៏ឈ្មោះថាសុញ្ញតវិមោក្ខដូចគ្នា បើមគ្គឈ្មោះថាអនិមិត្តវិមោក្ខ អប្បណិហិតវិមោក្ខ ផលក៏ឈ្មោះថាអនិមិត្តវិមោក្ខ អប្បណិហិត-វិមោក្ខដូចគ្នា ។

កាលព្រះអរិយៈជាម្ចាស់ចូលកាន់ផលសមាបត្តិ ព្រះអរិយផលកាលកើតឡើងបាននាមតាមឈ្មោះនៃវិបស្សនាចិត្ត ដោយន័យដែលពោលថាកើតឡើងជាបរិកម្មជវន ឧបចារជវន នឹងអនុលោម-ជវនក្នុងដើមនៃផលសមាបត្តិនោះ ។

ចិត្តក្នុងដើមនៃផលសមាបត្តិ ពិចារណានូវអនត្តលក្ខណៈជាអារម្មណ៍ផលសមាបត្តិនោះ ក៏ឈ្មោះថាសុញ្ញតវិមោក្ខ បើវិបស្សនាចិត្តក្នុងដើមនៃផលសមាបត្តិ ពិចារណានូវអនិច្ចលក្ខណៈ នឹងទុក្ខលក្ខណៈជាអារម្មណ៍ ផលសមា បត្តិនោះក៏ឈ្មោះថាអនិមិត្តវិមោក្ខ អប្បណិហិតវិមោក្ខ ដោយអំណាច នៃកិរិយាមកនៃវិបស្សនាដូច្នេះ ។

ប្រជុំ ៣ នៃនាមគឺ វិមោក្ខ ៣ ប្រការ មានស្មើគ្នាទូទៅដល់មគ្គចិត្ត ដល់ចិត្តទាំងពួងខ្លះ ដល់ផលចិត្តក្នុងមគ្គ វិថី ក្នុងសមាបត្តិវិថីទាំងពួងខ្លះ ដោយអំណាចនៃអារម្មណ៍ខ្លះ ដោយអំណាចនៃកិច្ចរបស់ខ្លួនខ្លះ ។

( សំដែងក្នុងវិមោក្ខបភេទ ចប់ )

**អំពីនេះនឹងសំដែងនូវបុគ្គលបភេទតទៅ :**

ព្រះយោគាវចរ លោកព្យាយាមបំពេញសមថៈ នឹងវិបស្សនាកម្មដ្ឋាន បានលុះសោតាបត្តិ-មគ្គញាណ ឈ្មោះ សោតាបន្នបុគ្គល ព្រោះលះបង់នូវអកុសលចិត្តដាច់ស្រឡះ ៣ ចិត្ត គឺលោភមូល-សោមនស្សទិដ្ឋិសម្បយុត្ត ២ វិចិកិច្ឆាសម្បយុត្ត ១ ជា ៣ ។

សោមនស្សទិដ្ឋិវិប្បយុត្ត ២ នឹងឧបេក្ខាទិដ្ឋិសម្បយុត្ត ២ ឧបេក្ខាទិដ្ឋិវិប្បយុត្ត ២ នឹងទោសមូល ២ នេះលះ បង់បានតែដែលគ្រោតគ្រាត ដែលជាយ៉ាងកណ្តាល នឹងយ៉ាងល្អិតនោះនៅកំចាត់មិនទាន់បាន មោហៈ ឧទ្ធច្ចៈក៏កំចាត់មិនបានតែមិនអាចនឹងនាំឱ្យបដិសន្ធិបានព្រោះហេតុនោះហើយ ព្រះសោតាបន្នៈ ទើបមិនទៅកាន់អបាយភូមិ ៤ ឡើយ នៅកើតក្នុងមនុស្ស នឹងទេវតា ៧ ជាតិទៀតជាធម្មតា ។

ព្រះសោតាបន្នៈព្យាយាមចំរើនវិបស្សនាបានលុះដល់សកទាគាមិមគ្គឈ្មោះសកទាគាមិបុគ្គល ព្រោះមាន រាគៈ ទោសៈ មោហៈ ដ៏ស្រាលស្តើងតិចចុះ នឹងមកបដិសន្ធិក្នុងកាមលោក ១ ជាតិទៀត ។

កាលចំរើនវិបស្សនាបានអនាគាមិមគ្គ ឈ្មោះអនាគាមិបុគ្គល ព្រោះលះបង់នូវកាមរាគ នឹងព្យាបាទដាច់អស់ មិនមានសេសសល់ នឹងលះបង់នូវទោសចិត្ត ២ ដែលជាគ្រោតគ្រាត បានរលត់ខន្ធអស់ជីវិតហើយ ទៅកើតក្នុងជាន់ សុទ្ធាវាសព្រហ្មមិនត្រឡប់មកកាន់កាមលោកនេះទៀតឡើយ ។

កាលព្រះយោគាវចរ ចំរើនវិបស្សនាដល់ព្រះអរហត្តមគ្គហើយ ឈ្មោះថា អរហន្ត ព្រោះលះបង់នូវកិលេសធម៌ មិនមានសេសសល់ លោភមូលដែលជាទិដ្ឋិវិប្បយុត្ត ៤ នឹងទោសមូល ២ ដែលល្អិត នឹងឧទ្ធច្ចៈព្រះអរហន្តកាត់ដាច់អស់ចាកសន្តានប្រសើរដោយអរហន្តផលវិមុត្តិជាខីណាសវ ទក្ខិណេយ្យ-បុគ្គលដ៏លើសក្នុងលោក ។

( បុគ្គលបភេទ ចប់ )

**អំពីនេះនឹងសំដែងនូវសមាបត្តិបភេទតទៅ :**

ផលសមាបត្តិក្នុងកម្មដ្ឋាននេះ ជាសាធារណៈទូទៅមែនដល់ព្រះអរិយបុគ្គលទាំងពួងដោយអំណាច នៃផលជារបស់នៃខ្លួនយ៉ាងណា គឺមិនលាយច្រឡំគ្នាដែលជាសោតាបន្នៈ ក៏ចំពោះទូទៅ ក្នុងសោតាបន្នៈ សកទាគាមិ អរហន្ត ។

បុគ្គលដែលចូលកាន់និរោធសមាបត្តិបាននោះ មាន ២ ពួកគឺ ព្រះអនាគាមិពួក ១ ព្រះអរហន្តពួក ១ ក្រៅពីនោះចូលកាន់និរោធសមាបត្តិមិនបានឡើយ ។

តែថា ព្រះអនាគាមី ព្រះអរហន្តសុក្ខវិបស្សក បានតែបថមជ្ឈាន ម្យ៉ាងមិនបាន សមាបត្តិព្រមទាំង ៨ ក៏ចូលនិរោធមិនបាន ព្រោះនិរោធសមាបត្តិ នោះជា នវានុបុព្វវិហារសមាបត្តិ ត្រូវចូលរូបឈាន ៤ អរូបឈាន ៤ ទើបនឹងចូលកាន់និរោធសមាបត្តិ បាន លោកដែលនឹងចូល កាន់និរោធ-សមាបត្តិនោះ ត្រូវចូលកាន់ មហគ្គតឈាន តាំងអំពី បថម-ជ្ឈានឡើងទៅ រហូតដល់នេវសញ្ញានា-សញ្ញាយតនៈ កាលចេញចាកបថមជ្ឈានហើយ ក៏ពិចារណានូវអង្គឈានទាំង ៥ ហើយនោះ ៗ លុះចេញចាកបថមជ្ឈានហើយ ក៏ចូលកាន់ ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ហើយក៏ពិចារណាអង្គឈានគ្រប់ ៗ ឈានដូចគ្នា ហើយពិចារណាសង្ខារ ដែលប្រព្រឹត្តទៅក្នុងទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ដោយ អនិច្ចំ ទុក្ខំ អនត្តា ដូចគ្នាគ្រប់ៗឈាន លុះចេញចាករូបសមាបត្តិហើយ ក៏ចូលអរូបសមាបត្តិគឺ អាកាសានញ្ចាយតនៈ វិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ ចំរើនវិបស្សនាបន្តគ្នា ជាលំដាប់ទៅគ្រប់ៗឈាន ។

ហើយចេញចាកអាកិញ្ចញ្ញាយតនៈខាងមុខអំពីចេញចាកអរូបទី ៣ ហើយនោះក៏ធ្វើបុព្វកិច្ចមានធ្វើ អធិដ្ឋាន កុដិ វិហារ នឹងគ្រឿងបរិក្ខារដែលជាប់នៅនឹងខ្លួនឱ្យ ប្រាសចាកភ័យជាដើម ជាបុព្វកិច្ច ហើយ ក៏ចូល អរូបសមាបត្តិទី ៤ គឺ នេវសញ្ញានាសញ្ញាយតនៈ ២ ខណចិត្ត ខាងមុខអំពីអប្បនាជវនទាំង ២ តំណនៃចិត្ត របស់ព្រះយោគាវចរនោះ ក៏អាចចុះរំងាប់នៅមិនបានកើតទៅ ខាងមុខអំពីចិត្តរំងាប់រលត់ចុះហើយនោះ ក៏ឈ្មោះថាចូលកាន់និរោធសមាបត្តិក្នុងនោះ ។

បើព្រះអនាគាមិចូលនិរោធសមាបត្តិ កាលចេញចាកនិរោធនោះ អនាគាមិផលចិត្តកើត ឡើងខណចិត្ត ១ ចិត្តទើបធ្លាក់ចុះកាន់ភវង្គ ។

បើព្រះអរហន្តចូលកាន់និរោធសមាបត្តិ កាលចេញចាកនិរោធសមាបត្តិនោះ អរហត្តផលចិត្តកើតឡើងខណចិត្ត ១ ចិត្តទើបធ្លាប់ចុះកាន់ភវង្គខាងមុខអំពីនោះ បច្ចវេក្ខណញ្ញាណជាគ្រឿង ពិចារណានិរោធសមាបត្តិនោះ ទើបប្រព្រឹត្តទៅក្នុងសន្តាននៃព្រះអនាគាមិ ព្រះអរហន្តលោក ចេញចាកនិរោធសមាបត្តិ ។

( សំដែងប្រភេទនៃសមាបត្តិក្នុងវិបស្សនាកម្មដ្ឋាន ចប់ )

*ភាវេតព្វំ បនិច្ចេវំ ភាវនាទ្វយមុត្តមំ*

*បដិបត្តិរសស្សាទំ បត្ថយន្តេន សាសនេ ។*

ប្រជុំ ២ នៃវិបស្សនា មានន័យដូចពោលហើយយ៉ាងនេះជារបស់ប្រសើរដែលនឹងលើកខ្លួនឱ្យផុតចាក សំសារវដ្ត កុលបុត្រអ្នកប្រាថ្នានូវសេចក្តីត្រេកអរក្នុងរសនៃសេចក្តីប្រតិបត្តិក្នុងព្រះពុទ្ធសាសនាគប្បីឧស្សាហ៍ចំរើនភាវនា កុំខ្ជិលច្រអូស កុំខ្ជិលច្រអូសឡើយ បើបារមីចាស់ក្លៀវក្លា ក៏បានលុះធម្មាភិសម័យ បើបារមីនៅទន់ ក៏គង់បានជាឧបនិស្ស័យឱ្យសម្រេចផលក្នុងភពខាងមុខ ។

*ឥតិ អភិធម្មត្ថសង្គហេ*

*កម្មដ្ឋានសង្គហវិភាគោ នាម នវមោ បរិច្ឆេទោ*

បរិច្ឆេទទី ៩ ឈ្មោះកម្មដ្ឋានសង្គហវិភាគ ក្នុងអភិធម្មត្ថសង្គហៈ

ចប់តែប៉ុណ្ណោះហោង

*ចារិត្តសោភិតវិសាលកុលោទយេន*

*សទ្ធាភិវុឌ្ឍបរិសុទ្ធគុណោទយេន*

*នម្ពវ្ហយេន បណិធាយ បរានុកម្បំ*

*យំ បត្ថិតំ បករណំ បរិនិដ្ឋិតន្តំ ។*

គម្ពីរសត្តបករណៈឯណា ដែលឧបាសកឈ្មោះថានម្ពៈជាអ្នកកើតហើយក្នុងត្រកូលដ៏ធំ ដ៏ល្អដោយចារិត្តសីលមានគុណបរិសុទ្ធដ៏ចំរើនក្រៃពេកគឺសេចក្តីជឿកើតឡើងក្នុងសន្តាន ទើបបានមក អារាធនាខ្ញុំម្ចាស់ឈ្មោះថាអនុរុទ្ធាចារ្យ ឱ្យរចនាតាក់តែងឡើង ដោយតាំងទុកទូទៅនូវសេចក្តីអាណិត ដល់អ្នកដែលនឹងកើតមកក្នុងខាងក្រោយ គម្ពីរសត្តបករណៈនោះ ក៏សម្រេចស្រេចហើយ ដូចសេចក្តីប្រាថ្នា ។

*បុញ្ញេន តេន វិបុលេន តុ មូលសោមំ*

*ធញ្ញាធិវាសមុទិតោទិតមាយុគន្តំ*

*បញ្ញាវទាតគុណសោភិតលជ្ជិភិក*

*មញ្ញន្តុ បុញ្ញវិភវោទយមង្គលាយ ។*

ភិក្ខុទាំងឡាយជាអ្នកមានប្រាជ្ញា និងល្អដោយគុណមានពណិស គឺសីលនឹងជាអ្នកមានសេចក្តី-ខ្មាស់បាប កាលរៀនព្រះគម្ពីរសង្គហៈនេះដឹងបាលីនឹងសេចក្តីតាមបំណងសម្រេចដូចសេចក្តីប្រាថ្នា របស់ខ្លួនហើយ បើមានសេចក្តីប្រាថ្នានឹងគោរពបូជាសក្ការៈនូវអាចារ្យជាអ្នកតែងនូវព្រះគម្ពីរនេះ ចូរសំគាល់យកនូវតុមូលសោមវិហារជាទីគោរពជួសអង្គព្រះអាចារ្យជាអ្នកតែងព្រះគម្ពីរព្រោះ ព្រះអាចារ្យអ្នកតែងព្រះគម្ពីរសង្គហៈនោះលោកនៅក្នុងវិហារ នេះ១ ជាទីនៅអាស្រ័យនៃព្រះសមណៈ ដែលមានបុណ្យមានគុណគឺបុណ្យដ៏បរិបូណ៌នោះឱ្យកើតឡើង ហើយចូរ គោរពនូវតុមូលសោមវិហារ ដរាបដល់អស់ជីវិតនៃខ្លួន ដើម្បីមង្គលចំរើនជាទីកើតឡើងនៃសម្បត្តិ គឺគំនរបុណ្យ ។

*ឥតិ អនុរុទ្ធាចរិយេន រចិតំ អភិធម្មត្ថសង្គហំ នាម បករណំ*

គម្ពីរឈ្មោះអភិធម្មត្ថសង្គហៈ

ព្រះអនុរុទ្ធាចារ្យលោកតែងទុកដោយវិសេស ដោយសេចក្តីព្យាយាម

ចប់បរិបូណ៌ហើយ ។

*គន្ថតោ បញ្ញាសាធិកានិ អដ្ឋសតានិ សមត្តានិ*

គន្ថៈទាំងឡាយ ៨ រយ ៥០ លោកប្រមូលនាំមករួបរួមទុកក្នុងគម្ពីរនេះ

ឱ្យបរិបូណ៌គ្រប់ប្រការ ។

*ឥតិ អភិធម្មត្ថសង្គហោ និដ្ឋិតោ*

គម្ពីរព្រះអភិធម្មត្ថសង្គហៈ ៩ បរិច្ឆេទ ចប់បរិបូណ៌ហើយ ដោយបការដូច្នេះហោង ។

**ប្រែចាកបាលិភាសាដោយព្រះឧត្តមមុនីអ៊ុម ស៊ូរធម្មវិនយរក្ខិតោ**